ទស្សនាវដ្តីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរករការពិត

លេខ៥៧ ខែកញ្ញា ឆ្នាំ២០០៤

## មាតិកា


- សំបុត្រ៖ ការនាំយកខ្មែរក្រហមទៅរកយុត្តិធម៌........................ ១

**ផ្នែកឯកសារ**

- ពួយ គ្មាន.........................................................................៣
- សូមរាយការណ៍ជូនបក្សកុម្មុយនិស្តកម្ពុជា..............................៦
- បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១..........១០
- ការជួបសន្ទនាជាមួយអគ្គរដ្ឋទូតយូហ្គោស្លាវី .........................១២
- ការដកស្រង់សម្ដីរបស់បក្សពលករវៀតណាម.......................១៤

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

- នៅតែចងចាំ.............................................................១៥
- គ្មានអ្វីឈឺចាប់ជាងការព្រាត់ប្រាសទេ ..............................១៨
- កូនខ្ញុំនឹងដើររកខ្ញុំនៅថ្ងៃបុណ្យភ្ជុំបិណ្ឌ ..................................១៩
- រំឭកអនុស្សាវរីយ៍បដិវត្តន៍...................................................២១
- ឡូវ ថា ៖បើកុំតែមានរបបខ្មែរក្រហម ...............................២៣
- ការបោសសម្អាតខ្មាំងនៅភូមិភាគបូព៌ា...............................២៥
- មិនចង់សងសឹក ប៉ុន្តែចង់បានតុលាការ...................................២៨

**ផ្នែកច្បាប់**

- តុលាការអន្តរជាតិលាតត្រដាងអំពីការកាត់ទោស....................៣១

**វេទិកាពិភាក្សាសាធារណៈ**

- យោបល់ទៅលើសៀវភៅ"ការផ្សះផ្សានៅកម្ពុជា"..................៤៦
- ឱកាសដ៏កម្រដើម្បីកាត់ទោសស្ថាបនិកនៃអំពើឃោរឃៅ............៥៣

**ទំព័រស្រាវជ្រាវរកគ្រួសារ**

- អ្នកទោសអង្គការ...........................................................៥៥





## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



**ស្នេរលេខនេះ៖** យិន នាន, អឿ រតនា, ប៉ាង ពីរីន, សំ ប៊ន, ញាណ សុជាតិ, អែម សុខឃីម, យិន ហ៊ន, សម គា, ស៊ូហ្សាណា លីនគុន, ដេវីដ ស៊ីហ៊ុរ, អេនឌ្រូ វីដប៊ី **អ្នកនិពន្ធនិងស្រាវជ្រាវ៖** លី សុផល, សូហ្សារីណា **ជំនួយការនិពន្ធនាយក៖** សាន់ កល្យាណ **និពន្ធនាយករង៖** សួ ប៊ុនស៊ូ **អ្នកបកប្រែ៖** អេង កុកថាយ **និពន្ធនាយកទូទៅ៖** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រ៖** ស៊ឹម សុភ័ក្រ្ត **គ្រប់គ្រងការចែកផ្សាយ៖** មាស ប៊ុនថាន

*សំបុត្រៈ*

# ការនាំខ្មែរក្រហមទៅរកយុត្តិធម៌

## (សេចក្តីដកស្រង់ពីរបាយការណ៍ច្បាប់របស់វិទ្យុអូស្ត្រាលី ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៤)

*ខាងក្រោមនេះជាការដកស្រង់សម្តីរបស់អ្នកជំនាញការច្បាប់និងប្រវត្តិសាស្ត្រខ្មែរក្រហមចេញពីកម្មវិធី «អូស្ត្រាលី ថក ប៉ែក» វិទ្យុអូស្ត្រាលី រៀបចំដោយ ដេមៀន ឃែរីក ផ្សាយថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៤ វេលាម៉ោង៨និង៣០នាទីព្រឹក ។ អ្នកជំនាញការដែលយើងដកស្រង់សម្តីនៅពេលនេះ មានលោក នីនាន ស៊ីហ៊ិន អតីតប្រធានក្រុមចរចាបញ្ហាតុលាការខ្មែរក្រហម, លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា, ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា, និង សេដា ខ្ញូក្លាស អ្នកនិយាយវិទ្យុអូស្ត្រាលីជាភាសាខ្មែរ ។*

**នីនាន ស៊ីហ៊ិនៈ** *យើងបានរកឃើញភ័ស្តុតាងដ៏ច្បាស់បំផុតនៃការរំលោភច្បាប់ដ៏ធ្ងន់ធ្ងររបស់ខ្មែរក្រហម ហើយគ្រប់ទិដ្ឋភាពនៃច្បាប់អន្តរជាតិនឹងយោងទៅតាមតុលាការក្នុងស្រុកប្រភេទណាមួយ ។ អនុសាសន៍ដែលយើងមាន គឺការបង្កើតឡើងនូវតុលាការឧក្រិដ្ឋកម្មពិសេសរបស់អង្គការសហប្រជាជាតិ ដើម្បីជំនុំជម្រះទោសមេដឹកនាំខ្មែរក្រហម ។ មតិណែនាំគឺថាមានតែតាមរយៈការជំនុំជំម្រះនៅក្នុងតុលាការអន្តរជាតិទេទើបយុត្តិធម៌អាចត្រូវបានស្វែងរកប្រកបដោយប្រសិទ្ធភាព ។*

*សេចក្តីរាយការណ៍របស់ក្រុមអ្នកជំនាញការនេះបានរកឃើញថា ប្រព័ន្ធតុលាការកម្ពុជាខ្វះលក្ខណៈវិនិច្ឆ័យសំខាន់បីគឺៈ ចៅក្រម មេធាវី និងចៅក្រមស៊ើបអង្កេតដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវនូវហេដ្ឋារចនាសម្ពន្ធ័សមរម្យ និងការគោរពដំណើរការត្រឹមត្រូវ ។*

*ជាជំនួសចំពោះគោលគំនិតនៃការរួមបញ្ចូលគ្នានៃក្រុមចៅក្រមដែលត្រួតត្រាដោយតំណាងក្នុងស្រុក រដ្ឋាភិបាលបានជំរុញយើងនូវអ្វីដែលយើងទាំងបីនាក់បានទាត់ចោលដោយសារតែកង្វះឯករាជ្យភាពឯករាជ្យ ។*

*ជម្លោះផ្នែកអារម្មណ៍ដែលទំនងអាចនឹងកើតឡើងរវាងចៅក្រមខ្មែរ ដែលភាគច្រើនទទួលរងគ្រោះ ដោយផ្ទាល់ឬយ៉ាងហោចណាស់ប៉ះទង្គិចខាងអារម្មណ៍ជាមួយនឹងចៅក្រមឯករាជ្យដែលខ្វល់ខ្វាយតែអំពីការស៊ើបអង្កេត និងបើមានការចាំបាច់កាត់ទោសទៅលើជនទាំងឡាយណាដែលគាត់យល់ឃើញថាគួរនឹងស៊ើបអង្កេត ។*

*លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ ក៏មានការព្រួយបារម្ភអំពីឥទ្ធិពលរបស់រដ្ឋាភិបាលកម្ពុជាទៅលើដំណើរការសាលាក្តីនេះដែរ ។ គាត់មានការព្រួយបារម្ភយ៉ាងខ្លាំងទៅលើទម្រង់រួមបញ្ចូលគ្នាដែលត្រូវគ្រោងឡើងនៅក្នុងសេចក្តីព្រាងកិច្ចព្រមព្រៀងដែលគាត់បានផ្តល់ជាអនុសាសន៍នៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ ។*

**ឯកឧត្តម សុខ អានៈ** *ខ្ញុំមានទស្សនៈផ្សេង ពីព្រោះយើងជឿជាក់ថាចៅក្រមខ្មែរនិងចៅក្រមអន្តរជាតិនឹងគោរពបទដ្ឋានជាតិ ហើយដំណើរការនៃការកាត់ក្តីនឹងប្រព្រឹត្តទៅដោយយុត្តិធម៌និងអនុលោមទៅតាមនីតិវិធីនៃច្បាប់ ។*

*ខ្ញុំគិតថា អ្នកខ្លះកំពុងតែគិតអំពីអតីតកាល ហើយមិនបានពិនិត្យពិចារណាឲ្យបានត្រឹមត្រូវទៅលើដំណើរការរីកចម្រើននៃប្រព័ន្ធយុត្តិធម៌របស់កម្ពុជាទេ ។*

**សេដា ខ្ញូក្លាសៈ** *ពេលវេលាមិនមែនស្ថិតនៅលើយើងទេ ដូច្នេះយើងចាំបាច់ត្រូវដំណើរការឲ្យបានឆាប់រហ័សនៅពេលដែលមេដឹកនាំខ្មែរក្រហមនៅរស់ ។ យើងបានបាត់បង់ ប៉ុល ពត ម្នាក់ហើយនៅឆ្នាំ១៩៩៨ ហើយនៅសល់តែប៉ុន្មាននាក់ទៀតតែប៉ុណ្ណោះ ដែលមានជំងឺធ្ងន់ធ្ងរនិងចាស់ជរា ។ ខ្ញុំគិតថា ការកាត់ក្តីប្រហែលជាមានគុណវិបត្តិខ្លះ ពីព្រោះចៅក្រមក្នុងស្រុកប្រហែលជាមានអំណាចច្រើនជាងក្នុងការកោះហៅជនដែលត្រូវទទួលការ*

កាត់ទោសនិងជនដែលត្រូវផ្ដន្ទាទោស ។ និយាយឲ្យស្មោះត្រង់ទៅ ទោះជាយ៉ាងណាក៏ដោយ ក៏ប្រសើរជាងមិនបានកាត់ក្ដីដែរ ។

**ឆាំង យុះ** ក្នុងនាមជាជនរងគ្រោះម្នាក់ ខ្ញុំមានសិទ្ធិទទួលបានចម្លើយពីចម្ងល់ទាំងឡាយ ។

ការនិយាយអំពីទម្រង់នៃសាលាក្ដី ការនិយាយអំពីដំណើរការអ្វីក៏ដោយដែលអ្នកអាចគិតដល់ និងមិនអាចនាំយកជីវិតមនុស្សជាងពីរលាននាក់ ហើយក៏មិនអាចនាំមកវិញនូវអ្វីដែលយើងបានបាត់បង់នោះដែរ ។ ដូច្នេះ ដំណើរការណាមួយដែលមានការចូលរួមពីអន្តរជាតិនិងរដ្ឋាភិបាលកម្ពុជាគឺជាដំណើរការដែលមានតម្លាភាពនិងមានការចូលរួមយ៉ាងពេញលេញពីសំណាក់ប្រជាជន ។ ដំណើរការប្រភេទនេះនឹងផ្ដល់ឲ្យប្រជាជននូវមូលដ្ឋានក្នុងការបន្ដពិភាក្សាការផ្សះផ្សានិងបញ្ចប់ភាពមន្ទិលសង្ស័យ ។ ខ្ញុំជឿថា គំរូនៃតុលាការនេះអាចនឹងធ្វើដូច្នេះបាន ។

សារទូរលេខរបស់ខ្មែរក្រហមមានពត៌មានដែលផ្ញើមកពីភូមិតំបន់ និងភូមិភាគ ទៅកាន់មេដឹកនាំ ។ នៅពេលដែលអ្នកអានផ្នែកខ្លះនៃពត៌មានក្នុងសារទូរលេខនីមួយៗ វាស្ទើរតែមិនបានបង្ហាញអ្វីទាំងអស់ ។ សារទូរលេខទាំងនេះនិយាយអំពីការលួចមាន់ អ្នកដែលទៅធ្វើការមិនទាន់ពេលវេលាការចាប់ខ្លួនជនជាតិវៀតណាមពីរនាក់ ឬឃាតកម្មនៅតាមព្រំដែន ។ ប៉ុន្ដែប្រសិនបើអ្នកយកសារទូរលេខទាំងនោះមកផ្គុំគ្នានោះ វានឹងបង្ហាញថារាល់ដំណើរការនៃការធ្វើបដិវត្តន៍នៅថ្នាក់ក្រោមត្រូវបានរាយការណ៍មកថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ ។

អ្នកដឹងទេ ជនរងគ្រោះមួយចំនួនបានប្រាប់ខ្ញុំថាយើងគួរតែព្យួរកមេដឹកនាំទាំងនោះ កាត់មេដឹកនាំទាំងនោះនឹងកាំបិតចិញ្ច្រាំអ្នកទាំងនោះឲ្យទៅជាចំណិតៗ ។ សូមកាត់ អៀង សារី និង ខៀវ សំផន ឲ្យទៅជា១,៧លានចំណិត ធ្វើដូច្នេះយើងម្នាក់ៗនឹងទទួលបានមួយចំណិតម្នាក់ ។ ប៉ុន្ដែសួរថាតើវាគ្រប់គ្រាន់ទេ? មិនគ្រប់គ្រាន់ទេ!មានទោសឬគ្មានទោស ត្រូវចោទប្រកាន់ឬអត់ អ្វីដែលសំខាន់គឺការយល់ដឹងថាតើត្រូវធ្វើដូចម្ដេចហើយត្រូវធ្វើដោយរបៀបណា ។



*(អត្ថបទសង្ខេបចេញពីឯកសារចម្លើយសារភាព)*

# ពួយ ត្វាង

ពួយ ត្វាង ហៅ សំ ជាជនជាតិទំពួន មានស្រុកកំណើតនៅភូមិរការតែ ឃុំម៉ាលិស ស្រុកបរកែវ ខេត្តរតនគិរី ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពួយ ត្វាង គឺជាប្រជាជននៅក្នុងសហករណ៍លេខ៣ ស្រុកបរកែវ តំបន់១០៧ ភូមិភាគឦសាន ហើយត្រូវអង្គការចាប់ខ្លួននៅចុងឆ្នាំ១៩៧៨ ។

នៅឆ្នាំ១៩៦៨ ពួយ ត្វាង បានធ្វើជាកងឈ្លបនៅឃុំម៉ាលិស ខេត្តរតនគិរី ។ ឆ្នាំ១៩៧០ ជាឆ្នាំដែល លន់ ណុល ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ អង្គភាពរបស់ ត្វាង ត្រូវបានរៀបចំទៅជាកងអនុសេនាធំលេខ៥១៣របស់ខ្មែរក្រហមប្រចាំភូមិភាគឦសាន ដែលឋិតនៅក្រោមការគ្រប់គ្រងរបស់សមមិត្ត ខាន់ ប្រធានកងអនុសេនាតូច និង ប៊ុនមី ជាអ្នកទទួលខុសត្រូវមន្ទីរភូមិភាគឦសានដែលមានទីតាំងនៅក្នុងស្រុកវ៉ឺនសៃ ខេត្តរតនគិរី ។ ក្រោយមក ត្វាង និងមិត្តរបស់គាត់បួននាក់បានធ្វើការឲ្យសេ.អ៊ី.អាតាមការបញ្ចុះបញ្ចូលរបស់ឈ្មោះ ខាន់, ប៊ុនមី និង ប៊ុត ។ អ្នកទាំងប្រាំបានទទួលផែនការបួនគឺ ទីមួយ បំផុសកម្លាំងប្រជាជនកុំឲ្យជឿលើបដិវត្តកម្ពុជា ទីពីរ ធ្វើសកម្មភាពប្រឆាំងនឹងមាគ៌ារបស់បក្សនិងបំផ្លិចបំផ្លាញសម្ភារគ្រប់កន្លែងដូចជាសម្ភារយោធា និងគ្រឿងម៉ាស៊ីនដែលរឹបអូសបានពីខ្មាំង ទីបី បំផុសទំនាស់តាមកន្លែងឲ្យបែកបាក់ និងទីបួន អូសទាញកម្លាំងសេ.អ៊ី.អា តាមកន្លែងនីមួយៗជាពិសេសក្នុងជួរយោធា ។ បន្ទាប់ពីនោះ ខាន់ និង ប៊ុនមី បានណែនាំគាត់ឲ្យស្គាល់កម្លាំងមួយចំនួនដែលមាន យ៉ា លេខាភូមិភាគឦសាន, វី៎ង អនុលេខាភូមិភាគ, ខាត់ លេខាតំបន់១០២ អុន អតីតប្រធានពាណិជ្ជកម្មភូមិភាគឦសាន និង ស្រេង ប្រធានយោធាភូមិភាគឧត្តរ និងសមាជិកជាច្រើនទៀត ។ ក្រោយពីបានស្គាល់ខ្សែបណ្តាញហើយ ត្វាង ចាប់ផ្តើមធ្វើសកម្មភាពនិងកសាងកម្លាំងបាន២នាក់ឈ្មោះ ចក ប្រធានកងចល័តស្រុកបរកែវ និង បាឡូន ជនជាតិចារាយ ។

ឆ្នាំ១៩៧១ អង្គភាពរបស់ ត្វាង ត្រូវដកពីវ៉ឺនសៃទៅនៅស៊ឹងត្រែងរួមទាំង ខាន់ និង ប៊ុនមី ផង ។ ខាន់ ជាអ្នកក្តាប់សភាពការណ៍នៅស៊ឹងត្រែង ចំណែក ប៊ុនមី ទទួលខុសត្រូវក្តាប់សភាពការណ៍នៅស្រុកវ៉ឺនសៃ ។ ត្វាង, ដែង និង ថុង ធ្វើការនៅក្នុងគណៈកងវរសេនាធំលេខ៥១៣ ហើយកសាងបានកម្លាំងបីនាក់ឈ្មោះ ឡាត់, ខុន និង ម៉ង់ ។ អ្នកទាំងបីនេះបានទទួលភារកិច្ចដើរបំផុសយុទ្ធជនប្រជាជនឲ្យស្អប់ខ្មែរក្រហម រត់ចោលជួរនិងរត់ទៅប្រទេសឡាវ ។ ឡាក់, ខុន និងម៉ង់ បានធ្វើឲ្យយុទ្ធជនមួយចំនួនធំដែលកំពុងធ្វើស្រែជាមួយប្រជាជនរត់ទៅផ្ទះ មួយចំនួនទៀតបំផ្លាញស្រូវនិងសម្ភារធ្វើស្រែរបស់ខ្មែរក្រហម ។

ដើមឆ្នាំ១៩៧២ ត្វាង និងកម្មាភិបាលយោធាភូមិភាគឦសានចំនួន៣០នាក់ត្រូវអង្គការចាត់តាំងឲ្យទៅរៀនវគ្គនយោបាយនិងបច្ចេកទេសនៅខេត្តកំពង់ធំរយៈពេល៧ខែ ។ ក្នុងអំឡុងពេលនោះ ត្វាងបានទាក់ទងមនុស្សមួយចំនួនដែលមកពីភូមិភាគផ្សេងៗ គឺ ហាន, ឡី, ឈឺន, សឿន និង បៀន ដើម្បីស្វែងយល់អំពីសភាពការណ៍នៅតាមភូមិភាគនិងធ្វើការជាមួយគ្នា ។ បន្ទាប់ពីចប់វគ្គសិក្សា ត្វាង បានត្រឡប់មកភូមិភាគវិញ ។ ត្វាង, បៀន, ខាំវៀង និង សេង បានទទួលបញ្ជាពី ប៊ុត ទៅចាប់ ប៉ូលិស ទាហាន និងប្រជាជនចំនួន២០នាក់យកទៅដាក់មន្ទីរសន្តិសុខស៊ឹងត្រែង ។ បន្ទាប់មក ត្វាង និងបក្សពួកបាននាំគ្នាបន្តសកម្មភាពនៅតាមមូលដ្ឋានតទៅទៀត ។ ត្វាង បានធ្វើសកម្មភាពយ៉ាងផុសផុលនៅឃុំហាង សាវ៉ាត ខេត្តស៊ឹងត្រែង ចលនាប្រជាជនចំនួន៣០នាក់រត់ទៅប្រទេសឡាវ ។

ឆ្នាំ១៩៧៣ ត្វាង និង ថុង បានដឹកនាំកម្លាំងពីរនាក់ដែលទើបនឹងកសាងបាន ឲ្យធ្វើសកម្មភាពបង្កទំនាស់នៅក្នុងអង្គភាពនិងជួយពង្រីកកម្លាំងបន្ថែម ។ នៅខែកុម្ភៈ ត្វាង បានធ្វើដំណើរទៅខេត្តស៊ឹងត្រែង ដើម្បីរាយការណ៍អំពីលទ្ធផលការងារនិងទទួលការណែនាំឲ្យស្គាល់សមាជិកថ្មីៗពី បៀន និង ខាន់ ។ នៅក្នុងខែមីនា ត្វាង និងសមាជិកមួយចំនួន បានរៀបចំទ័ពទៅធ្វើការជាមួយ

ស្រេង (ធ្វើការនៅសេនាធិការភូមិភាគឧត្តរ) នៅសមរភូមិខេត្តកំពង់ចាម ។ ស្រេង បានដាក់ផែនការឲ្យ តាង អនុវត្តដូចតទៅ ១) ពេលវាយខ្មាំងសមមិត្តបំផុសយុទ្ធជនឲ្យរត់ចោលសមរភូមិ ២) ពេលវាយខ្មាំងត្រូវឲ្យពត៌មានទៅខ្មាំងមុន ដើម្បីឲ្យខ្មាំងដឹងខ្លួន បំផ្លាញកម្លាំងបដិវត្តន៍ឲ្យបានច្រើន ៣) បើកផ្លូវឲ្យប្រជាជនយកសម្ភារទៅលក់នៅតំបន់ខ្មាំង និង៤) បំផ្លាញគ្រាប់កាំភ្លើងរបស់អង្គការ ។ ចាប់តាំងពីពេលទទួលផែនការ តាង កសាងបានកម្លាំង៣នាក់ទៀតឈ្មោះ កាញូង, ចាម៉ាយ និង ណាល់ ។ រហូតដល់ខែមិថុនា អង្គភាពរបស់ តាង បានសហការជាមួយកងទ័ពភូមិភាគឧត្តរ បើកសមរភូមិប្រយុទ្ធមួយ ធ្វើឲ្យកងអនុសេនាតូចទី១ត្រូវស្លាប់ទាំងអស់ ក្នុងនោះក៏មាន កាញូង ចាម៉ាយ និង ណាល់ដែរ ។ តាង ត្រូវរបួសបញ្ជូនមកព្យាបាលនៅមន្ទីរពេទ្យស្រុកចម្ការលើ ។ ប៉ុន្មានខែក្រោយមក អង្គភាពរបស់ តាង បានត្រឡប់មកភូមិភាគឦសានវិញ ប៉ុន្តែរបួសរបស់ តាង មិនទាន់ជានៅឡើយទេ គាត់បានបន្តសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តស្ទឹងត្រែងរហូតដល់ឆ្នាំ១៩៧៤ ។

នៅខែមករា ឆ្នាំ១៩៧៤ តាង ត្រូវបានចាត់តាំងឲ្យទៅធ្វើការជាមួយ ឡៅ លេខាតំបន់ដ-១ ហៅតំបន់១០៧ ។ សកម្មភាពការងារនៅក្នុងតំបន់ដ-១ គឺអនុវត្តនៅតាមមូលដ្ឋាន និងផ្នែកយោធា ១) បំផុសប្រជាជនឲ្យរត់ទៅស្រុកយួន ២) ឲ្យប្រជាជនប្រឆាំងនឹងមាគ៌ារបស់បក្សក្នុងការធ្វើស្រែ និង៣) កសាងកម្លាំងសេ.អ៊ី.អាឲ្យបានច្រើន ។ តាង និងមិត្តរបស់គាត់ពីរនាក់ទៀតឈ្មោះ តឿន និង ហ្សឺយ បានទៅទាក់ទង វ៉ាន់ គណៈស្រុកបរកែវ, ណុ គណៈស្រុកលំផាត់លើ ដើម្បីសម្រេចកិច្ចការនេះ ។ តាង បានស្គាល់មនុស្សម្នាក់ឈ្មោះ ឡយ ជាមេឃុំនៅស្រុកបរកែវខាងត្បូង តាមរយៈ វ៉ាន់ ។ តាង និង ឡយ បានធ្វើសកម្មភាពរួមគ្នា និងបានបំផុសឲ្យប្រជាជនចំនួន៦០នាក់រត់ទៅប្រទេសវៀតណាម ។ បន្ទាប់ពីសម្រេចកិច្ចការនេះ តាង បានត្រឡប់មកធ្វើការជាមួយ ហ្សឺយ, ណុ និង តឿន វិញ ដោយបំផុសប្រជាជននៅតាមសហករណ៍មិនឲ្យធ្វើស្រែ មិនឲ្យលើកទំនប់ ហើយបំផុសយុទ្ធជន និងយុទ្ធនារីមិនឲ្យចូលធ្វើជាយោធា ។ បន្ទាប់ពីនោះ តាង ត្រូវបានចាត់តាំងឲ្យដើរល្បាតមើលភូមិសាស្ត្រព្រៃនៅតាមព្រំប្រទល់កម្ពុជា-វៀតណាមរយៈពេលពីរខែ ។ ដោយសារ តាង ចេះនិយាយភាសាវៀតណាម ។ គោលបំណងនៃការដើរល្បាតគឺរកផ្លូវទាក់ទងការងារជាមួយវៀតណាម ប៉ុន្តែពុំទាន់ទទួលលទ្ធផលអ្វីផង តាង ត្រូវបានផ្លាស់មកនៅមន្ទីរថ្មីវិញ ។ រយៈពេល៦ថ្ងៃនៅមន្ទីរថ្មី តាង កសាងកម្លាំងបានពីរនាក់ឈ្មោះ ដៅ និង ធឿង ។ តាង បានត្រូវអង្គការអនុញ្ញាតឲ្យទៅលេងផ្ទះរយៈពេលកន្លះខែ ។ ក្រោយពេលត្រឡប់មកវិញ បឿន បានចាត់តាំងគាត់ឲ្យធ្វើជាគ្រូបច្ចេកទេសយោធា ។ តាង បានចាប់ផ្តើមបង្រៀនមុខវិជ្ជានេះដល់កងទ័ពរយៈពេលពីរខែ ហើយឆ្លៀតពេលនោះ តាង បានបំផុសយុទ្ធជនឲ្យរត់ទៅផ្ទះអស់ចំនួន៣០នាក់ ។

នៅខែមករា ឆ្នាំ១៩៧៥ តាង សម្រេចបានកិច្ចការថ្មីមួយទៀតគឺទៅមើលបង្គោលស្លាកនៅព្រំដែនឡាវម្តុំភ្នំ១២០ និងបានបើកផ្លូវឲ្យប្រជាជនរត់ទៅប្រទេសឡាវដោយសុវត្ថិភាព ។ ដោយសារ តាង បំពេញកិច្ចការនេះបានល្អ បឿន ក៏ចាត់តាំងឲ្យគាត់នាំកម្លាំងទៅកាន់ព្រំដែនម្តងទៀត ដើម្បីបំផុសប្រជាជនឲ្យរត់ចូលប្រទេសឡាវកាន់តែច្រើនឡើង ។ នៅខែឧសភា តាង ក៏ផ្លាស់មកនៅមន្ទីររបស់ បឿន ។ នៅពេលនោះរបួសរបស់គាត់បានរើឡើងវិញ ។ គាត់ត្រូវអង្គការបញ្ជូនទៅដេកពេទ្យព-១៧ នៅភ្នំពេញអស់រយៈពេលមួយខែ ។ គ្រាន់តែត្រឡប់មកដល់អង្គភាពភ្លាម តាង ត្រូវ យ៉ា ហៅឲ្យទៅចូលរួមប្រជុំការងារភ្លាមជាមួយសមាជិកសេ.អ៊ី.អាទាំងអស់នៅទន្លេសេសាន ។ តាង បានទទួលភារកិច្ចការពារព្រំដែនភូមិអញ្ជែងឡាចនិងទាក់ទងវៀតណាមដើម្បីសុំកម្លាំងជំនួយ ។

ក្រោយពីទទួលផែនការនេះប្រាំថ្ងៃ ផែន, បឿន និង គី បាននាំ តាង ទៅជួបពិភាក្សាការងារជាមួយវៀតណាមបីនាក់ឈ្មោះ ដុង, វ៉ាន់ និង ផៀស ។ ខាងកម្ពុជាបានយល់ព្រមឲ្យវៀតណាមបោះទីតាំងនៅអូរវ៉ាយ ចំណែកវៀតណាមវិញបានយល់ព្រមតាមសំណើរបស់ យ៉ា ដែលសុំកម្លាំងទ័ពជំនួយវាយបដិវត្តន៍កម្ពុជាត្រង់តំបន់កន្ទុយនាគ ។ បឿន និងកងទ័ពមួយចំនួនត្រូវទៅប្រចាំការនៅទល់ដែនវៀតណាម ។ តាង និងអង្គភាពបានទៅបោះជំរំនៅអញ្ជែងឡាច ហើយ ខាំហៀង និង ស៊ីឡៃ ក៏នៅប្រចាំការទីនោះដែរ ។

នៅខែវិច្ឆិកា អង្គការបានបញ្ជូន គុាង ឲ្យគ្រប់គ្រងប្រជាជនដែលធ្វើផ្លូវពីស្វាយរៀងទៅដល់វ៉ុនសៃ ។ គុាង បានដឹកនាំការងារនេះនៅខែមករា និងបញ្ចប់នៅខែឧសភា ។ សកម្មភាពរបស់ គុាង នៅទីនោះ គឺអូសបន្លាយពេលវេលានិងធ្វើផ្លូវខ្ជីខ្ជាមិនឲ្យល្អ ។

ក្រោយពីបញ្ចប់ការងារធ្វើផ្លូវ គុាង បានទទួលការងារថ្មីមួយទៀតពីសមមិត្ត ឡៅ ដែលឲ្យទៅបំផុសប្រជាជនតាមសហករណ៍ ។ ដើម្បីសម្រេចកិច្ចការនេះ គុាង ត្រូវទាក់ទងការងារជាមួយប្រធានសហករណ៍មួយចំនួនដូចជា ឡឹន, រុន និង សេក ។ គុាង ដើរបំផុសបងប្អូនជនជាតិកុំឲ្យធ្វើស្រែ ហើយឲ្យបំផ្លាញសំណាបចោលនិងបំផុសឲ្យមានការស៊ីផឹកនៅតាមសហករណ៍នានា ។ បន្ទាប់ពីចបការងារនេះ គុាង បានទទួលផែនការមួយទៀតពីឡាម និង ហ៊ុម ។ គុាង និងខ្សែបណ្តាញថ្មីមួយចំនួនមាន ឈ្មោះ យឺន, កុំ, មិន, ង៉ឹប, ដើង, លី និង ឡេន បានចុះទៅសហករណ៍ក្របាប់ធ្វើសកម្មភាពបំផ្លាញដំណាំបំផ្លាញសេដ្ឋកិច្ចរបស់ប្រជាជននិងមិនឲ្យប្រជាជនសម្រេចការងារទៅតាមទិសរបស់អង្គការ ។

នៅឆ្នាំ១៩៧៧ បក្ខពួករបស់ គុាង មួយចំនួនត្រូវអង្គការដកសិទ្ធិ ហើយខ្លះទៀតត្រូវបញ្ជូនទៅតាមសហករណ៍ផ្សេងៗ ។ គុាង និង បាញ ត្រូវអង្គការដកមកឲ្យធ្វើសួន ។ ទោះបីជាត្រូវអង្គការបញ្ជូនទៅដល់ទីណា ក៏ គុាង នៅតែបន្តការងាររបស់ខ្លួនដដែល ។ គុាង កសាងបាននារីពេទ្យបីនាក់ឈ្មោះ ព្រេង, ព្រឹង និង ហ៊ា ហើយនារីទាំងបីក៏បានណែនាំកម្លាំងមួយចំនួនឲ្យ គុាង ស្គាល់ដែរ ។ នៅចុងខែកញ្ញា គុាង បានជួប ហ៊ុម និង ឡេន នៅអូរសាងី ។ អ្នកទាំងពីរបានប្រាប់អំពីសភាពការណ៍នៅតំបន់១០៧ ថា៖ «ផែន បានត្រៀមឲ្យវៀត-ណាមចូលពិនិត្យតំបន់១០៧ ដើម្បីឲ្យវៀតណាមចូលវាយតំបន់ នេះនៅដើមឆ្នាំ១៩៧៨» ។ ដូច្នេះ គុាង ត្រូវត្រៀមប្រមូលកម្លាំងប្រជាជនឲ្យបានច្រើនដើម្បីរួមកម្លាំងជាមួយវៀតណាមវាយបដិវត្តន៍កម្ពុជា ។

នៅដើមឆ្នាំ១៩៧៨ គុាង បានត្រឡប់ទៅសហករណ៍វិញដោយគ្មានតួនាទីអ្វីឡើយ ។ ដប់ថ្ងៃក្រោយមក គុាង ត្រូវប្រធានសហករណ៍ចាត់តាំងឲ្យទៅធ្វើទំនប់តំបន់នៅអូរសាងីមួយរយៈ ទើបអង្គការបញ្ជូនមកធ្វើចម្ការនៅតំបន់១០៧វិញ ។ នៅខែកក្កដា គុាង បានត្រឡប់ទៅសហករណ៍ ។ នៅខែសីហា ណុ បានហៅគណៈសហករណ៍ទាំងអស់ មកប្រជុំគ្នានៅសហករណ៍រុន ដើម្បីពង្រឹងគោលជំហរគណៈសហករណ៍ទាំងអស់ឲ្យខិតខំបំពេញការងារឲ្យបានល្អនិងប្រមូលកម្លាំងឲ្យបានកាន់តែច្រើន ។ នៅខែកញ្ញា ឆ្នាំ១៩៧៨ គុាង បានត្រូវចាត់តាំងឲ្យទៅធ្វើផ្លូវលេខ១៩នៅស្រុកបរកែវ ។ នៅទីនោះ គុាង មិនអាចទាក់ទងការងារជាមួយខ្សែបណ្តាញរបស់គាត់ទេ គឺគាត់ត្រូវធ្វើសកម្មភាពតែម្នាក់ឯង ។ គាត់ដើរឃោសនាប្រជាជនថា «នៅតាមសហករណ៍ស្រុកលើមានរបបហូបចុក៣-៤ កំប៉ុងក្នុងមួយថ្ងៃ ក្រៅពីនោះមានបន្ថែមដំឡូង ចេក សាច់ជ្រូក មាន់ ហូបតាមចិត្ត» ។ ធ្វើឲ្យប្រជាជននាំគ្នាទាមទារអង្គការគ្រប់បែបយ៉ាងបង្កឲ្យមានភាពស្មុគស្មាញជាច្រើន ដែលធ្វើឲ្យការសាងសង់ផ្លូវមិនសម្រេចបានតាមផែនការ ។ មកដល់ចុងខែវិច្ឆិកា ឆ្នាំ១៩៧៨ អង្គការបានហៅ គុាង ទៅមន្ទីរភាគនៅស្ទឹងត្រែង ហើយក៏ចាប់បញ្ជូនគាត់មកភ្នំពេញ ។

គុាង ត្រូវសួរចម្លើយដោយឈ្មោះ សេង នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៨ ។ ភ្ជាប់ជាមួយនឹងចម្លើយសារភាពរបស់ គុាង មានបញ្ជីឈ្មោះអ្នកជាប់ពាក់ព័ន្ធចំនួន១៧២នាក់ទៀត ដែលមានចម្រុះជនជាតិ ។ ចម្លើយសារភាពរបស់គាត់មានតម្កល់ទុកនៅមន្ទីរគុកទួលស្លែង ។

**លី សុផល**

## ពាក្យស្លោកខ្មែរក្រហម

◆ សព្វថ្ងៃនេះ នៅគ្រប់ប្រទេសនៃសកលលោកគេនាំគ្នាជជែកអំពីការដែលសង្គ្រាមលោកលើកទី៣ផ្ទុះឡើង ចំពោះបញ្ហានេះ យើងត្រូវតែរៀបចំផ្លូវចិត្តនិងពិនិត្យស្ថានការណ៍ ដោយប្រើវិធីវែកញែកលម្អិតបែងភាគ យើងសម្រេចជាច់ណាត់ សន្តិភាព ហើយប្រឆាំងនឹងសង្គ្រាម ប៉ុន្តែបើចក្រពត្តិនិយម វានៅតែក្បាលរឹងចចេសធ្វើឱ្យផ្ទុះសង្គ្រាមមួយថ្មីទៀត យើងមិនត្រូវភ័យខ្លាចទេ។

(ដកស្រង់ចេញពីសៀវភៅញុក)

◆ កងទ័ពស្រួចប្រមូលផ្តុំវាយកម្ទេចខ្មាំង កម្ទេចកម្លាំងរបស់ខ្មាំង ទើបយើងឆាប់រហ័សបានទទួលជ័យជម្នះ និងអាចការពារពង្រីកកម្លាំងយើង។ (ដកស្រង់ពីសៀវភៅកំណត់ហេតុលេខ១៩៤)

# សូមរាយការណ៍ជូនបក្សកុម្មុយនិស្តកម្ពុជា

ខ្ញុំឈ្មោះ ង្វៀន វ៉ាន់សឺន អាយុ២២ឆ្នាំ ជាយុទ្ធជនពលទោ កងកាំភ្លើងធំនៃអនុសេនាធំវរសេនាធំ១៦៥កងពលលេខ៧ ។ ខ្ញុំត្រូវចាប់ខ្លួននៅបាវិត ខេត្តស្វាយរៀង ប្រទេសកម្ពុជា នៅថ្ងៃទី៩ ខែសីហា ឆ្នាំ១៩៧៨ ។

ខ្ញុំកើតនៅភូមិទី៤ ឃុំអាន់គី ស្រុកវិញបាវ ខេត្តហាយហុង ភាគខាងជើងនៃប្រទេសវៀតណាម ។ ទឹកដីខ្ញុំបានរួចផុតពីកណ្តាប់ដៃរបស់អាណានិគមបារាំងមុនពេលខ្ញុំកើត ហើយដោយសារបក្សកុម្មុយនិស្តដឹកនាំ ដូច្នេះទើបប្រជាជនត្រូវទទួលរងគ្រោះមហន្តរាយនិងឈឺចាប់ ។ ពន្ធកសិកម្មរបស់បក្សនិងរដ្ឋាភិបាលវៀតណាមបានធ្វើឲ្យកសិករកាន់តែក្រីក្រ ដូចជាឪពុកម្តាយខ្ញុំដែលមានដីស្រែតិចតួចទទួលផលស្រូវបានតិចខ្លះខាតរាល់ឆ្នាំ ។ តាមច្បាប់របស់ពួកវា ពន្ធកសិកម្មនេះមានតម្លៃតែ៥០ភាគរយប៉ុណ្ណោះ ប៉ុន្តែជាក់ស្តែងគឺឡើងទៅដល់៧៥ ទៅ៨០ភាគរយនៃផលិតផលដែលប្រមូលបានឯណោះ ។

ចំពោះស្រូវ ពួករដ្ឋអំណាចឃុំនិងសហករណ៍បាននាំគ្នាទៅជ្រើសរើសកន្លែងណាដែលមានស្រូវផ្លែល្អបំផុត ក្នុង១០ម៉ែត្រការ៉េ វាប្រូតយកទៅថ្លឹងទាំងស្រូវដែលមិនទាន់ទុំស្ងួត គឺនៅពណ៌បៃតងនៅឡើយ ដែលវាគិតពន្ធនៅក្នុងសហករណ៍ទាំងមូលដោយឲ្យលទ្ធផលថា ក្នុង១០ម៉ែត្រការ៉េស្មើនឹងរង្វាស់ដូ ។ ដំឡូង ពោត សណ្តែក...ក៏វាឆក់ប្លន់យ៉ាងសាហាវព្រៃផ្សៃដូចស្រូវអង្ករដែរ ។ ក្រៅពីនេះ នៅមានការចូលរួមវិភាគទានជាច្រើនផ្នែកទៀតដូចជាការចាប់ដាក់ពិន័យមានច្រើនផ្នែក ឧទាហរណ៍ដូចជាជ្រូក ប្រជាជនគ្មានសិទ្ធិធ្វើជ្រូកហូបទេ ហើយក៏គ្មានសិទ្ធិទិញសាច់ជ្រូកខ្លាញ់ជ្រូកនិងសំណាកខ្លាញ់ហូបដែរ ។ ផ្ទុយទៅវិញ ប្រសិនបើប្រជាជនណាគ្មានជ្រូកលក់ឲ្យរដ្ឋត្រូវរដ្ឋដាក់ពិន័យជាស្រូវ ។

សព្វថ្ងៃនេះ អំបិលបានឡើងថ្លៃ៧-៨ដង ហើយក៏ខ្វះអំបិលលក់ឲ្យប្រជាជនទៀត ។ ចំពោះក្រណាត់ ទោះជារដ្ឋបានដំឡើងថ្លៃយ៉ាងណាក៏គ្មានក្រណាត់លក់ដែរ ។

តា១យាយ១នៅក្នុងភូមិខ្ញុំបាននិយាយថា៖ ភូមិឃុំយើងប្រសើរជាងភូមិឃុំខ្លះ កន្លែងផ្សេងស្លាប់ដោយអត់ឃ្លានក្នុងមួយឆ្នាំតិចបំផុតក៏៥ភាគរយដែរ ។ នេះគឺជាឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនិស្តវៀតណាម ។ ពួកវាសម្លាប់ប្រជាជនក្រីក្រលំបាកវេទនារបស់យើងតាមចិត្តនិងដោយលាក់មុខ ។ ពួកវាសម្លាប់ប្រជាជនតាំងពីជំនាន់ ហូជីមិញ មកដល់ជំនាន់ ឡេយន់ ។ ប្រជាជនយើងត្រូវតែកម្ទេចបក្សកុម្មុយនិស្តវៀតណាមនេះឲ្យរលំរលាយ ។ ប្រសិនបើទុកបក្សកុម្មុយនិស្តនេះឲ្យនៅមានអត្ថិភាពនោះប្រជាជនក្រីក្ររបស់យើងនឹងត្រូវពួកវាសម្លាប់ ។

តាំងពីខ្ញុំធំដឹងក្តីមក ខ្ញុំបានឃើញប្រជាជនលាក់ស្រូវលាក់ពោត សណ្តែក ដំឡូង... ។ ទោះបីជាពួកវាបានចេញច្បាប់ដាក់ពិន័យធ្ងន់ជាបួន បានចូលរុករកស្វែងរើកន្លែងលាក់ទុកក៏ដោយ ក៏រាល់ឆ្នាំប្រជាជននៅតែលាក់ស្រូវ ពោត សណ្តែក ដំឡូង បានមួយចំនួន ហើយក៏មានការតស៊ូទាមទារបន្ថយពន្ធអាករ បន្ថយការដាក់ពិន័យ បន្ថយការចូលរួមវិភាគទានជាបន្តបន្ទាប់ឥតដាច់ដែរ ។

នៅឆ្នាំ១៩៧៦ បក្សនិងរដ្ឋាភិបាលវៀតណាមបានចាប់ផ្តើមចាប់យុវជនឲ្យចូលធ្វើទាហាន ។ ប្រជាជនតែងតែឲ្យកូនចៅរត់គេចពីពួកដៃជើង ឡេយន់ និង ផាម វ៉ាន់ដុង ។ ពេលដែលពួកដៃជើងរបស់ ផាម វ៉ាន់ដុង ចាប់បានយុវជន វាតែងតែចងដៃចងជើង ហើយវាគំរាមកំហែងឪពុកម្តាយយុវជនយ៉ាងព្រៃផ្សៃ ។ ដល់ក្រោយមក នៅខែមេសា ឆ្នាំ១៩៧៨ វាបានប្រើកលល្បិចបោកប្រាស់យ៉ាងថោកទាប ដោយមានឈ្មោះ ផាម វ៉ាន់បា ប្រធានឃុំអានគី ស្រុកវិញបាវ ខេត្តហាយហុង ដែលជាមនុស្សវៀចវេរកាចសាហាវ ធ្វើពើជាមនុស្សទៀងត្រង់ ថ្ងៃថ្នូរ រាបសា បានទៅជួបកសិករមួយចំនួននៅឃុំអានគី ដើម្បីពាំនាំពត៌មានពីកូនចៅរបស់ពួកគាត់ដែលបានស្លាប់នៅលើទឹកដីកម្ពុជា ក្នុងខែធ្នូ ឆ្នាំ១៩៧៧

និងដើមខែមករា ឆ្នាំ១៩៧៨ ។ ផាម វ៉ាន់បា បានផ្តល់លុយឲ្យឪពុកម្តាយយុទ្ធជនពលី ប៉ុន្តែអ៊ីចាស់ៗមួយចំនួនបានហែកលុយចោល ហើយចង្អុលមុខថា "ម្ចាស់ហ្វែងថ្មើមធំណាស់ ចង់លេបទឹកដីកម្ពុជា ចាប់បង្ខំឲ្យកូនចៅអញទៅស្លាប់យ៉ាងថោកទាបដោយសារការឈ្លានពានទឹកដីកម្ពុជា ។ អញក្រមែន ប៉ុន្តែអញទ្រាំស្លាប់ដោយការអត់ឃ្លាន អញខ្ពើមរអើមលុយរបស់ពួកហ្វាស៊ីសឯងណាស់" ។ កសិករមួយចំនួនទៀតបានបិទទ្វារផ្ទះដេញអ្នកទាំងនោះមិនឲ្យចូលផ្ទះឡើយ ។

អ្នកដែលមានកូនស្លាប់នៅកម្ពុជា និងអ្នកដែលមានកូនទៅធ្វើទាហានហើយបាត់ដំណឹង បានជួបជុំគ្នាដើរទៅដើរមកបង្ហាញទឹកមុខចង់គំនុំ និងស្ដោយសម្ដីថា "នេះគឺជាហ៊ីត្លែរថ្មីៗ ឡេ យន់ និង ផាម វ៉ាន់ដុង បានខំប្រឹងអនុវត្តផែនការសហព័ន្ធឥណ្ឌូចិនរបស់ហូជីមិញពិតប្រាកដ ដោយធ្វើឲ្យកូនចៅប្រជាជនវៀតណាម និងអ្នកក្រីក្រយើងត្រូវវេទនាមហន្តរាយ ដូចប្រជាជនអាល្លឺម៉ង់ក្នុងជំនាន់ហ៊ីត្លែរអ៊ីចឹង ។ បញ្ហានេះយើងជាប្រជាជនត្រូវតែក្រោកឈរឡើងតស៊ូប្រឆាំងនឹងសង្គ្រាមឈ្លានពានកម្ពុជារបស់បក្ស





កុម្មុយនិស្តវៀតណាមជាដាច់ខាត" ។

ក្នុងនោះមានយោបល់ថា "ត្រូវតែផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មរបស់ ឡេ យន់ និង ផាម វ៉ាន់ដុង ដែលបានលក់ឯករាជ្យទៅឲ្យសូវៀតយ៉ាងថោក" ។ អ្នកខ្លះបញ្ចេញយោបល់ថា "មិនគ្រាន់តែឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនិស្តវៀតណាមប៉ុណ្ណឹងទេ ជាងនេះទៅទៀត វាបានបំផ្លាញចលនារំដោះជាតិរបស់ប្រជាជនវៀតណាមយើងទៀត ។ ក្នុងដំណាក់កាលតស៊ូរំដោះភូមិភាគខាងត្បូងវៀតណាម វាបានបំផ្លាញអាយុជីវិតរបស់យុវជនយើងយ៉ាងខ្លះខ្លាយបំផុត ដោយលាក់កំបាំងនិងដោយស្របច្បាប់" ។ យើងមើលឡើងវិញយើងនឹងឃើញ ហូជីមិញ និង ឡេ យន់ ប្រមូលផ្តុំយុវជននៅភូមិភាគខាងជើងយកទៅធ្វើសង្គ្រាមនៅភូមិភាគខាងត្បូង ។ ចំណែកយុវជននិងប្រជាជនភូមិភាគខាងត្បូងពួកអាមេរិកប្រមូលផ្តុំចូលក្នុងភូមិយុទ្ធសាស្ត្រស្ទើរតែទាំងអស់ ធ្វើឲ្យពួកចក្រពត្តិអាមេរិកមានកម្លាំងកាន់តែច្រើន ។

មិនតែប៉ុណ្ណោះ ហូជីមិញ និង ឡេ យន់ បានបំផ្លាញចលនារំដោះជាតិភូមិភាគខាងត្បូងឲ្យបាក់ស្រុតនៅឆ្នាំ១៩៦៨ បន្ទាប់មក ទើបបោះជំហានចូលសារភាពជាមួយចក្រពត្តិអាមេរិកនិងពួកបរិវារ ។ ការដែលបក្សកុម្មុយនិស្តវៀតណាមភ្លាប់បានរដ្ឋអំណាចនៅភូមិភាគខាងត្បូងនេះ គឺដោយហេតុផលផ្ទាល់របស់បដិវត្តន៍កម្ពុជា ដែលមានបក្សកុម្មុយនិស្តកម្ពុជាដឹកនាំ ។ ជ័យជម្នះថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៣ លើសង្គ្រាមអាកាសរបស់ចក្រពត្តិអាមេរិកបានធ្វើឲ្យចលនានៅគ្រប់តំបន់មានពន្លឺថ្មី មានកម្លាំងថ្មី ដ៏ខ្លាំងក្លា ហើយចលនាបដិវត្តន៍រំដោះភូមិភាគខាងត្បូងក៏បានឈានមុខឡើង ហើយបានអូសទាញទាំងបក្សកុម្មុយនិស្តវៀតណាមដែលមានដាប់សាច់ឈាមគ្នាមកចុះចូលដែរ ។ ជាចុងក្រោយជ័យជម្នះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ របស់បក្សកុម្មុយនិស្តកម្ពុជា បានផ្តល់ឥទ្ធិពលយ៉ាងខ្លាំងក្លានិងយ៉ាងជ្រាលជ្រៅ ហើយបានបង្កដោយផ្ទាល់ដល់ចលនារំដោះជាតិនៅភាគខាងត្បូងវៀតណាមឲ្យឈានឡើងដើម្បីសម្រេចបានគោលបំណងខ្លួន ប៉ុន្តែគួរឲ្យសោកស្តាយ ចលនានេះបាននាំសាច់មួយចំណែកពាក់ព័ន្ធទៅដល់គ្រោះមហន្តរាយនោះគឺ ការនាំមកជាមួយនូវបក្សកុម្មុយនិស្តវៀតណាម ។ បងម្នាក់បានឆ្លើយថា "មូលហេតុនេះ ទើបបក្សកុម្មុយនិស្តវៀតណាមបានលក់ឯករាជ្យលក់ទឹកដីឲ្យពួកវាតទីនិយមសូវៀត ដែលបានក្បត់ចំពោះការពលីជីវិតរបស់ប្រជាជនវៀតណាមយើងយ៉ាងថោកទាបបំផុត" ។ ពូមីងមួយចំនួនបានឆ្លើយថា "ខ្ញុំស្តាយកូនរបស់ខ្ញុំណាស់ ស្លាប់ដោយមានឈ្មោះស្អុយនៅក្នុងប្រវត្តិសាស្ត្រ គឺជាទាហានទៅឈ្លានពានលេបទឹកដីរបស់គេ" ។ ចុងក្រោយលោកតាចំណាស់ជាងគេបាននិយាយថា "យើងត្រូវតែវាយបក្សកុម្មុយនិស្តវៀតណាមនេះឲ្យដួលរលំខ្ទេចខ្ទីឲ្យបានឆាប់ ពីព្រោះជាប្រភពនៃឧក្រិដ្ឋកម្មគ្រប់

ប្រភេទ ទុកឲ្យវារស់តទៅទៀតមិនបានទេ” ការដែលបកស្រាយរបៀបនេះមានយ៉ាងច្រើននៅក្នុងស្រទាប់ប្រជាជន ។

ចំណែករដ្ឋអំណាចរបស់បក្សកុម្មុយនិស្តវៀតណាម ពួកវារវល់តែឆក់ប្លន់ ហុតឈាម អង្កៀមឆ្អឹងប្រជាជន ហើយផ្ដេកផ្ដួលទៅលើរដ្ឋាភិបាលសូវៀត ។ ពួកវាកំពុងតែខ្វល់ចិត្តចំពោះការដែលប្រជាជនតស៊ូ ហើយពួកវាកំពុងរត់ទាំងញញើញញ័រស្វែងរកចាប់យុវជនឲ្យធ្វើទាហាន ។

ក្រោយពីបានរត់គេចខ្លួនរួចចំនួន២៥លើក ខ្ញុំត្រូវបានចាប់ឲ្យចូលធ្វើទាហាននៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៨ ។ ច្បាប់របស់ពួកនេះគឺចាប់បុរសដែលមានអាយុចាប់ពី១៥ឆ្នាំដល់៤៥ឆ្នាំឲ្យចូលធ្វើទាហាន ។ ខ្ញុំត្រូវបញ្ជូនឲ្យទៅហាត់រៀននៅហាបាក់នៅអង្គភាពកងពល៣២៥អា ។

ក្នុងរយៈកាល៦-៧ឆ្នាំមុននេះ សូវៀតបានចងសម្ព័ន្ធភាពជាមួយវៀតណាម ។ ពេលនេះបានផ្ទុះបញ្ចាំងឲ្យឃើញមុខមាត់ពិតរបស់សូវៀត គឺធ្វើជាម្ចាស់លើវៀតណាម ។ សូម្បីតែសាលារៀនរបស់ខ្ញុំនៅហាបាក់ក៏មានសូវៀតម្នាក់ឈ្មោះថាអ៊ីវ៉ាន់នូវិច នៅត្រួតពិនិត្យការងារដែរ ។

វៀតណាម-សូវៀតគឺដូចតែគ្នា ពួកវាទប់ស្កាត់មិនឲ្យមានស្ថានភាពទាហានរត់ចោលជួរឡើយ ។

ខ្ញុំហាត់រៀនមិនទាន់ចប់កម្មវិធីផង ត្រូវបានចាប់បង្ខំឲ្យមកភូមិភាគខាងត្បូងវៀតណាមទាំងទទឹងទទែង ។

ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៧៨ វរសេនាធំ២២៨របស់កងពល៣២៥អា ត្រូវបានបញ្ចូលជាមួយនឹងវរសេនាធំ១៦៥របស់កងពលលេខ៧ ដែលទើបតែត្រូវបានកម្ទេចឲ្យខ្ទេចខ្ទាំទាំងស្រុង កាលពីប៉ុន្មានថ្ងៃមុននេះ ។ ចំពោះវរសេនាធំ២២២ត្រូវបានបញ្ចូលជាមួយកងពលលេខ១ ចំពោះវរសេនាធំ២២៦ត្រូវបញ្ចូលជាមួយកងពលលេខ៩ ។

ថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៧៨ កងពលលេខ៧បានទទួលបញ្ជាឲ្យចូលមកវាយនៅទឹកដីកម្ពុជាតាមផ្លូវជាតិលេខ១ ។ ថ្ងៃទី៩ ខែសីហា ឆ្នាំ១៩៧៨ កងទ័ពកម្ពុជាបានវាយផ្ដាច់និងវាយកម្ទេចកងពលលេខ៧របស់ខ្ញុំនៅបាវិត ។ កងវរសេនាធំ១៦៥របស់កងពលលេខ៧ដែលខ្ញុំទើបតែមកពីភូមិភាគខាងជើងមិនទាន់បានមួយសប្ដាហ៍ផង ត្រូវបានកម្ទេចទាំងស្រុង ហើយខ្ញុំត្រូវចាប់ខ្លួនជាមួយមិត្តភក្តិរបស់ខ្ញុំ៣នាក់ទៀត ។

ប្រជាជនវៀតណាមជាឪពុកម្ដាយ!

យុវជនវៀតណាមជាទីរាប់អាន!

កងទ័ពវៀតណាមទាំងអស់ជាមិត្ត!

កងទ័ពវៀតណាមយើងត្រូវបានពួក ឡេ យន់ និង ផាមវ៉ាន់ដុង រុញក្បាលឲ្យមកឈ្លានពានកម្ពុជា គឺត្រូវស្លាប់យ៉ាងវេទនាដូចសត្វមេភ្លៀងហើរចូលភ្លើងអីចឹង ។

ក្នុងស្ថានភាពបែបនេះ នាំឲ្យយើងត្រូវតែដោះស្រាយជាបន្ទាន់កុំឲ្យ ឡេ យន់ និង ផាមវ៉ាន់ដុង ដែលជាហ៊ីត្លែរសម័យថ្មីបំផ្លិចបំផ្លាញប្រជាជនវៀតណាម និងបន្តបំផ្លិចបំផ្លាញតទៅទៀត ។

សូមពុកម៉ែកាត់ផ្ដាច់ស្បៀងអាហារ ការពារកុំឲ្យពួកវាឆក់




គូ យ៉ាំង ង៉ូវ

ប្លន់បាន កាត់ផ្ដាច់កម្លាំងកុំឲ្យកូនចៅទៅធ្វើទាហាន រៀបចំចាត់តាំងជាពួក ជាក្រុម ចូលព្រៃកាន់អាវុធតស៊ូវាយរំលំបក្សកុម្មុយនិស្តវៀតណាមដែលសាហាវឃោរឃៅនេះទៅតាមទិសដៅដែលពុកម៉ែនិងបងប្អូនបានសម្រេច ។

ទាហានទាំងអស់ដែលស្ថិតក្នុងកណ្ដាប់ដៃរបស់បក្សកុម្មុយនិស្តវៀតណាម សូមភ្ញាក់រឭកឡើង រួបរួមគ្នាវាយឲ្យខ្ទេចខ្ទី រត់ត្រឡប់ទៅស្រុកកំណើត ភូមិស្រុក កុំត្រឡប់ទៅផ្ទះ សូមមិត្តរត់ចូលព្រៃ ការពារខ្លួនកុំឲ្យពួកវាចាប់បានទៀត ។

ធ្វើនៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៧៨

**ឡៀន វ៉ាន់សឺន**

***អត្ថបទចម្លើយសារភាពរបស់អ្នកទោសជនជាតិវៀតណាមដែលត្រូវកងទ័ពខ្មែរក្រហមចាប់ខ្លួន ។ ប្រែសម្រួលដោយ ឡុង ដានី***


អ្នកទោសនៅមន្ទីរស-២១
71

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ (គុកទួលស្លែង)

**រៀបចំនិងចងក្រងដោយៈ យិន នាន**

**(តពីលេខមុន)**

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ១៦០៨ | នូ ផ្លួន | គ្រូបង្រៀន | ស្រុកបារាំង | ១-១-៧៧ | ២៨-១-៧៧ |
| ១៦០៩ | ជា វើងសៀន | សក្តិ៤កន្ទះ | ស្រុកបារាំង | ២៦-១២-៧៦ | ២៨-១-៧៧ |
| ១៦១០ | ទូច សារ៉ែង | កម្មករថ្មី | រទេះភ្លើង | ២២-១០-៧៦ | ២៨-១-៧៧ |
| ១៦១១ | វ៉ា ចាន់សំអន ហៅ អឿន | កម្មករចាស់ | រទេះភ្លើង | ១៥-១០-៧៦ | ២៨-១-៧៧ |
| ១៦១២ | ហួន ថេត | កម្មករថ្មី | រទេះភ្លើង | ១១-១២-៧៦ | ២៨-១-៧៧ |
| ១៦១៣ | ឡាយ រ៉ូសេ | និស្សិតអគ្គិសនី | ស្រុកបារាំង | ២៣-១០-៧៦ | ២៨-១-៧៧ |
| ១៦១៤ | ស្វាយ សុខន | កម្មករថ្មី | ដែកំពង់សោម | ៨-១១-៧៦ | ២៨-១-៧៧ |
| ១៦១៥ | គី គីមស្រ៊ី | និស្សិតពេទ្យ | ស្រុកបារាំង | ២៣-១០-៧៦ | ២៨-១-៧៧ |
| ១៦១៦ | អ៊ីវ សេណានី | និស្សិតតម្បាញ | ស្រុកបារាំង | ២៣-១០-៧៦ | ២៨-១-៧៧ |
| ១៦១៧ | នេត ញ៉ៅ ហៅ ខុន | មេក្រុម | រោងចក្រអ-២ | ២២-៩-៧៦ | ២៨-១-៧៧ |
| ១៦១៨ | ប៉ិច វឿន | កម្មករថ្មី | រទេះភ្លើង | ??-៩-៧៦ | ២៨-១-៧៧ |
| ១៦១៩ | ឆាំ ខន | កម្មករចាស់ | រទេះភ្លើង | ២៨-១២-៧៦ | ២៨-១-៧៧ |
| ១៦២០ | រស់ សំអឿន ហៅ ឡាត់ | យុទ្ធជន | ពាណិជ្ជកម្មក្រុង | ១៣-៩-៧៦ | ២៨-១-៧៧ |
| ១៦២១ | ដួង បូផា | គយ | បាត់ដំបង | ២៧-១១-៧៦ | ២៨-១-៧៧ |
| ១៦២២ | ស៊ិន អួន | កម្មករចាស់ | បាត់ដំបង | ៤-១-៧៦ | ២៨-១-៧៧ |
| ១៦២៣ | វីរ យិន ហៅ ចារ | យុទ្ធជន | កងពល៣១០ | ២២-១-៧៧ | ២៨-១-៧៧ |
| ១៦២៤ | ថៅង ឌី | កម្មករ | រទេះភ្លើង | ២០-១១-៧៦ | ២៨-១-៧៧ |
| ១៦២៥ | ពាង ឈាង ហៅ រិត | យុទ្ធជន | កងពល៣១០ | ៤-១២-៧៦ | ២៨-១-៧៧ |
| ១៦២៦ | ប៊ិន សឿន | យុទ្ធជន | កងពល២៩០ | ១៨-១០-៧៦ | ២៨-១-៧៧ |
| ១៦២៧ | វង់ សឿន (ស្រី) | ប្រជាជន | កំពង់ធំ | ១៧-១០-៧៦ | ២៨-១-៧៧ |
| ១៦២៨ | កែប ថាច (ស្រី) | គ្រូបង្រៀន | ស្រុកបារាំង | ២៣-១០-៧៦ | ២៨-១-៧៧ |
| ១៦២៩ | ជា ដាវី (ស្រី) | ប្រពន្ធ ហួត សុវណ្ណា | ស្រុកបារាំង | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៦៣០ | សេង កេកហៀង (ស្រី) | ប្រពន្ធ សេង សុងហ៊ី | ស្រុកបារាំង | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៦៣១ | សំ អួន (ស្រី) | មេក្រុម | រោងចក្រក-២ | ២០-៩-៧៦ | ២៨-១-៧៧ |
| ១៦៣២ | ជា វណ្ណា (ស្រី) | កម្មករថ្មី | រោងចក្រប-៤ | ២៤-១០-៧៦ | ២៨-១-៧៧ |
| ១៦៣៣ | ដុន ផល (ស្រី) | កូនស័ក្តិ៤ | បាត់ដំបង | ??-១២-៧៦ | ២៨-១-៧៧ |
| ១៦៣៤ | កែវ សុដារ៉ា (ស្រី) | ប្រពន្ធ គង់ ប៊ុន សិរី | ស្រុកបារាំង | ២៨-១០-៧៦ | ២៨-១-៧៧ |

| | | | | | |
|---|---|---|---|---|---|
| ១៦៣៥ | អ៊ុំង ចាន់ថុល (ស្រី) | ប្រពន្ធ ទូច ថុង | ស្រុកបារាំង | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៦៣៦ | ស៊ុយ តូយ៉ាណា (ស្រី) | ប្រពន្ធ ម៉ុក សុវណ្ណា | ស្រុកបារាំង | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៦៣៧ | តាំង ស៊ីវឆេង (ស្រី) | ប្រពន្ធ តាន់ សំប៊ុន | ស្រុកបារាំង | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៦៣៨ | សៀវ សុថន (ស្រី) | ប្រពន្ធ ទៀវ កាសេម | ស្រុកបារាំង | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៦៣៩ | ហ៊ុយ សូថា (ស្រី) | មេផ្ទះ | ស្រុកបារាំង | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៦៤០ | រស់ វ៉ៃ (ស្រី) | ប្រជាជន | សៀមរាប | ១៨-១០-៧៦ | ២៨-១-៧៧ |
| ១៦៤១ | ឈួន ឈន (ស្រី) | ប្រជាជន | សៀមរាប | ១៨-១០-៧៦ | ២៨-១-៧៧ |
| ១៦៤២ | សេង ស៊ីធឿន (ស្រី) | ប្រពន្ធ នា គីមស្រ៊ាង | ស្រុកបារាំង | ២៣-១០-៧៦ | ២៨-១-៧៧ |
| ១៦៤៣ | ហែម ម៉ាលី (ស្រី) | ប្រពន្ធ ប៊ុន ប៉េងលី | ស្រុកបារាំង | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៦៤៤ | សាំង ស៊ុនណារ៉ាក់ (ស្រី) | ប្រពន្ធ មាស សារ៉េត | ស្រុកបារាំង | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៦៤៥ | ប៉ែន ទួន ហៅ ទន (ស្រី) | ប្រពន្ធ មាស សាមី | កងពល៣១០ | ២៩-១២-៧៦ | ២៨-១-៧៧ |
| ១៦៤៦ | ផាន់ អេវ ហៅ ចាន់ (ស្រី) | យុទ្ធនារី ប្រពន្ធ ភាគ | កងពល៣១០ | ៣១-១២-៧៦ | ២៨-១-៧៧ |
| ១៦៤៧ | នាគ យឿន ហៅ ឃីម (ស្រី) | ប្រពន្ធ ឈូក ផល | កងពល៣១០ | ៣១-១២-៧៦ | ២៨-១-៧៧ |
| ១៦៤៨ | ទា គីមស្រ៊ុន (ស្រី) | ប្រពន្ធ ជាម វ៉េងសៀន | ស្រុកបារាំង | ១-១-៧៧ | ២៨-១-៧៧ |
| ១៦៤៩ | អ៊ុក សាហៀង (ស្រី) | ប្រពន្ធ ស ថៃហេង | ស្រុកបារាំង | ១-១-៧៧ | ២៨-១-៧៧ |
| ១៦៥០ | ឆាយ ង្វួនឆេង ហៅ ធីន (ស្រី) | ប្រពន្ធ អ៊ុម ថន | កងពល៣១០ | ៣១-១-៧៦ | ២៨-១-៧៧ |
| ១៦៥១ | ដួង ប៊ុនធឿន | កុមារចោរព្រៃ | បាត់ដំបង | ៣០-១០-៧៦ | ២៨-១-៧៧ |
| ១៦៥២ | សុក ដិច | កុមារចោរព្រៃ | បាត់ដំបង | ៣០-១០-៧៦ | ២៨-១-៧៧ |
| ១៦៥៣ | សាប់ រ៉ា | កូន ហុក សាប់ | សៀម | ២៧-១១-៧៦ | ២៨-១-៧៧ |
| ១៦៥៤ | អៀម ខុន ហៅ ខែម | វរសេនាតូច | កងពល៣១០ | ២២-៩-៧៦ | ៣១-១-៧៧ |
| ១៦៥៥ | ម៉ក់ សូមិត្ត ហៅ ហួន | កងរយ | កសិដ្ឋានអគ្គរជ័យ | ១០-១-៧៧ | ១៨-២-៧៧ |
| ១៦៥៦ | ឃឹម សាន | មេក្រុម | ស្រែអំបិល | ១៨-១១-៧៦ | ១៨-២-៧៧ |
| ១៦៥៧ | ថៃ សុផល | កម្មករចាស់ | ឡានទឹក | ២៨-១០-៧៦ | ១៨-២-៧៧ |
| ១៦៥៨ | ពត ឈាន់ ហៅ ឈឿន | យុទ្ធជន | ព.រ ដឹកជើងទឹក | ១៨-១០-៧៦ | ១៨-២-៧៧ |
| ១៦៥៩ | នុន ប៊ុនលឹម | កម្មករ | រទេះភ្លើង | ២០-១១-៧៦ | ១៨-២-៧៧ |
| ១៦៦០ | អ៊ុម សំណាង | កម្មករ | រទេះភ្លើង | ២១-១១-៧៦ | ១៨-២-៧៧ |
| ១៦៦១ | ជា ហឿង | សាស្ត្រាចារ្យ | បារាយណ៍ | ១២-១១-៧៦ | ១៨-២-៧៧ |
| ១៦៦២ | មៀច សួន | វិស្វករ | ស្រុកបារាំង | ១២-១០-៧៦ | ១៨-២-៧៧ |
| ១៦៦៣ | ណោត គុន ហៅ ចិត | យុទ្ធជនបើកឡាន | កងពល៣១០ | ១១-១២-៧៦ | ១៨-២-៧៧ |
| ១៦៦៤ | មិុល សុវណ្ណ ហៅ នប់ | យុទ្ធជនទទួលភ្ញៀវ | សូវៀត | ៤-១-៧៧ | ១៨-២-៧៧ |
| ១៦៦៥ | អេង រាត្រី | កម្មករថ្មី | រទេះភ្លើង | ៨-១១-៧៦ | ១៨-២-៧៧ |

(នៅមានត)

*(ឯកសារខ្មែរក្រហម)*

# ជូនចំពោះ បងហែម ជាទីគោរពស្នេហា
# សូមរាយការណ៍ជូនបងស្តីពីការជួបសន្ទនាជាមួយអគ្គរដ្ឋទូតយូហ្គោស្លាវី
## ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៧៧ វេលាម៉ោង៣រសៀលដល់ម៉ោង៤ នៅក្រសួងពាណិជ្ជកម្ម

**ខាងកម្ពុជាមាន៖** *ស.ម រិត, ឆេង និង លុត (អ្នកបកប្រែ)*

**ខាងយូហ្គោស្លាវីមាន៖** *ឯកឧត្តមអគ្គរដ្ឋទូត*

**មតិយើង៖**

*យើងខ្ញុំស្នើជួបឯកឧត្តមថ្ងៃនេះដើម្បីលើកបញ្ហាពីរជូនឯកឧត្តម ។*

*ទី១) ខ្ញុំសូមជម្រាបឯកឧត្តមថា តំណាងក្រុមហ៊ុននាវាចរណ៍* JUGOLINIJA *នៅប៉េកាំងបានឲ្យដំណឹងតាមទូរលេខមកយើងខ្ញុំថា កប៉ាល់ឈ្មោះ«រ៉ាប់»ដឹកសម្ភារមកឲ្យយើងខ្ញុំនឹងមកដល់កំពង់សោមប្រហែលនៅថ្ងៃទី១ ធ្នូ ខាងមុខនេះ ។ យើងខ្ញុំសូមអញ្ជើញឯកឧត្តមទៅកំពង់សោមនៅថ្ងៃកប៉ាល់នេះមកដល់ដើម្បីពិនិត្យសម្ភារដែលដឹកមក ។*

*ទី២) យើងចង់បានព័ត៌មានពីឯកឧត្តម តើមានក្រុមហ៊ុនយូហ្គោស្លាវីចង់ទិញអនុផលដែលយើងខ្ញុំស្នើមកលក់ឬទេ? តើក្រុមហ៊ុននេះឈ្មោះអ្វី? ដូចយើងខ្ញុំបានជម្រាបឯកឧត្តមពីពេលមុនហើយ អនុផលទាំងនោះតែទុកយូរពេកវាខូចគុណភាពជាពិសេសសណ្តែកដីដែលយើងខ្ញុំបានបកសំបករួចហើយ ។ ឆ្លៀតឱកាសនេះ យើងខ្ញុំសូមជម្រាបឯកឧត្តមជាដំណឹងថា អង្ករ៥.០០០តោនដែលយើងខ្ញុំត្រៀមទុកលក់ជូនប្រទេសយូហ្គោស្លាវីកន្លងមកនោះ ដោយទុកយូរពេកបានចុះគុណភាពអស់ជាច្រើន ហើយយើងខ្ញុំក៏បានចាត់ចែងតាមសភាពការណ៍នោះទៅ ។*

**មតិអគ្គរដ្ឋទូតយូហ្គោស្លាវី៖**

*១) ចំពោះកប៉ាល់ដែលត្រូវមកដល់កំពង់សោមនៅដើមខែធ្នូនេះបើតាមយើងខ្ញុំដឹងត្រូវមានកប៉ាល់មួយទៀតមកជាប់គ្នានឹងកប៉ាល់រ៉ាប់ ។ ឆ្លៀតឱកាសនេះ យើងខ្ញុំសូមជូនលិខិតមួយច្បាប់របស់ក្រុមហ៊ុនរុដណាប់ចុះថ្ងៃ៨ វិច្ឆិកា ១៩៧៧ ដែលបញ្ជាក់ពីការអនុវត្តកិច្ចសន្យាថ្ងៃទី៤ កុម្ភៈ ១៩៧៧ និងការផ្ញើសម្ភារ ។ល ។ លិខិតជាភាសាបារាំង (ផ្ញើជូនមកជាមួយនេះ) ។*

*យើងខ្ញុំសូមថ្លែងអំណរគុណចំពោះអនុប្រធានគណៈកម្មាធិការពាណិជ្ជកម្មដែលបានអញ្ជើញយើងខ្ញុំឲ្យទៅកំពង់សោមនៅឱកាសកប៉ាល់មកដល់ យើងខ្ញុំរីករាយនឹងទៅកំពង់សោមនៅពេលអនាគតជិតនេះ ។*

*២) ចំពោះបញ្ហាកម្ពុជាស្នើលក់ផលិតផលកសិកម្មទៅប្រទេសយើងខ្ញុំនោះ យើងខ្ញុំសូមអនុប្រធានគណៈកម្មាធិការពាណិជ្ជកម្មអធ្យាស្រ័យដោយយើងខ្ញុំមិនទាន់បានបំពេញសំណូមពរកម្ពុជាមកដល់ថ្ងៃនេះ ។ ការយឺតយ៉ាវនេះបណ្តាលមកពីទាក់ទងរវាងមន្ទីរចាត់ការស្បៀងបម្រុងនៃប្រទេសយើងខ្ញុំនិងសហគ្រាសនាំចូលទាំងឡាយដែលមានសិទ្ធិនាំផលិផលពីបរទេសមិនទាន់បានដោះស្រាយទៅតាមក្រឹត្យក្រមរបស់គេ ។ ម្យ៉ាងទៀតក្រុមហ៊ុននាំចូលចង់បានឈុតគំរូផលិតផលពិនិត្យជាមុនសិន ។ នៅថ្ងៃមុខក្នុងគោលបំណងចាត់ចែងដំណើរការក្នុងវិស័យនេះឲ្យមានប្រសិទ្ធភាព យើងខ្ញុំនឹងស្នើឲ្យមានគណៈប្រតិភូមួយមកកាន់ប្រទេសកម្ពុជាដើម្បីពិនិត្យនិងសម្រេចការទិញផលិតផលកម្ពុជា ។*

*៣) យើងខ្ញុំសូមជូនឈ្មោះអ្នកបច្ចេកទេសបីនាក់ដែលត្រូវមកកម្ពុជា ដើម្បីហ្វឹកហ្វឺនអ្នកបច្ចេកទេសកម្ពុជាក្នុងការប្រើប្រាស់និងថែទាំសម្ភារដែលកម្ពុជាទិញពីប្រទេសយើងខ្ញុំ ។ យើងខ្ញុំចង់ដឹងថាតើឲ្យយើងខ្ញុំស្នើការអនុញ្ញាតឆ្លងដែនតាមរយៈទូតចិននៅបែលក្រាត ឬតាមរយៈទូតកម្ពុជានៅប៉េកាំង ។ បើផ្ញើតាមរយៈទូតកម្ពុជានៅប៉េកាំងយើងខ្ញុំបារម្ភក្រែងពេលខ្លីពេកផ្ញើមិនទាន់ ព្រោះអ្នកបច្ចេកទេសត្រូវមកដល់ប៉េកាំងថ្ងៃសុក្រ ហើយត្រូវចេញដំណើរពីប៉េកាំងថ្ងៃសៅរ៍ព្រឹក ។ ចំពោះបញ្ហានេះស្រេចខាងភាគីកម្ពុជាសម្រេចទេ យើងខ្ញុំនឹងគោរពតាមការ*

សម្រេចនេះ ។

៤) យើងខ្ញុំសូមជូនលិខិតនិងឯកសារទាក់ទងដល់ការស្នើលក់សម្ភារនិងឧបករណ៍ផ្សេងៗ ដោយ យោងតាមលិខិតក្រសួងពាណិជ្ជកម្មកម្ពុជាលេខ០០២-យូ-៧៧ និង០០៤-យូ-៧៧ (លិខិតនិងតារាងសម្ភារភ្ជាប់មកជាមួយនេះ) ។ ក្នុងលិខិតនេះ គេបានស្នើបញ្ជូនគណៈប្រតិភូពាណិជ្ជកម្មមួយមកកម្ពុជាមានតំណាងក្រុមហ៊ុនរុជណាប់ តំណាងយូហ្គោបង់កា និងតំណាងក្រុមហ៊ុននាំចូលឈ្មោះ សង់ត្រូព្រំ ទាំងអស់មានសមាជិក៤នាក់ នៅថ្ងៃ១០ ធ្នូ ១៩៧៧ ខាងមុខនេះ ដូច្នេះស្នើភាគីកម្ពុជាមានមតិ ។

៥) ធនាគារយូហ្គោបង់កាបានសួរមកយើងខ្ញុំអំពីការចុះហត្ថលេខាលើប័ណ្ណសងប្រាក់ ។ គេណែនាំយើងខ្ញុំថា ឲ្យប្រគល់ឯកសារដឹកជញ្ជូនសម្ភារប្តូរនឹងប័ណ្ណសងប្រាក់ដែលក្រសួងពាណិជ្ជកម្មកម្ពុជានិងធនាគារកម្ពុជាបានចុះហត្ថលេខារួចហើយ ។ ពេលណាយើងខ្ញុំបានទទួលប័ណ្ណសងប្រាក់ទាំងនេះ យើងខ្ញុំត្រូវវាយទូរលេខទៅប្រាប់ក្រសួងការបរទេសយើងខ្ញុំ ក្រសួងការបរទេសយើងខ្ញុំនឹងចេញលិខិតបញ្ជាក់ទៅធនាគារយូហ្គោបង់កាថា យើងខ្ញុំបានទទួលប័ណ្ណសងប្រាក់ដែលភាគីកម្ពុជាបានចុះហត្ថលេខាហើយ ។ ស្នើភាគីកម្ពុជាពិនិត្យបញ្ហានេះ ហើយឲ្យយើងខ្ញុំដឹងមតិផង ។ ឯកសារដឹកជញ្ជូនទាំងឡាយ យើងខ្ញុំអាចជូនភាគីកម្ពុជាពិនិត្យបាននៅស្ថានទូតយើងខ្ញុំ បើសិនជាភាគីកម្ពុជាចង់ពិនិត្យមុន ។

៦) ឆ្លៀតឱកាសនេះ យើងខ្ញុំសូមផ្ញើជូនធនាគារកម្ពុជាសម្រាប់ពាណិជ្ជកម្មក្រៅប្រទេសនូវសៀវភៅគំរូហត្ថលេខាបន្ថែមរបស់ធនាគារយូហ្គោបង់កា ។

**មតិយើង:**

យើងខ្ញុំអរគុណឯកឧត្តមដែលបានយកចិត្តទុកដាក់ដល់ការងារពាណិជ្ជកម្មរវាងប្រទេសយើងទាំងពីរ ហើយដែលបានប្រគល់លិខិតនិងឯកសារផ្សេងៗមកឲ្យយើងខ្ញុំថ្ងៃនេះ ។ យើងខ្ញុំរីករាយដោយឃើញក្រុមហ៊ុនរុជណាប់បានខិតខំអនុវត្តកិច្ចសន្យាថ្ងៃទី៤ កុម្ភៈ ១៩៧៧ ហើយព្រមជាមួយនោះ ក៏យើងខ្ញុំចង់ឃើញប្រទេសយូហ្គោស្លាវីទិញផលិតផលខ្លះពីប្រទេសយើងខ្ញុំដែរ ។ ចំពោះបញ្ហាដែលឯកឧត្តមបានលើកឡើងត្រង់ចំណុចទី៣ និងទី៤ យើងខ្ញុំនឹងជូនរដ្ឋាភិបាលយើងខ្ញុំពិនិត្យ ហើយជូនមតិឯកឧត្តមនៅថ្ងៃក្រោយ ។

អំពីការចុះហត្ថលេខាលើប័ណ្ណសងប្រាក់យើងខ្ញុំចង់បានព័ត៌មានខ្លះជាមុនសិន ដូចជាតម្លៃសម្ភារដែលចុះកប៉ាល់និងកម្មវិធីសងប្រាក់ ដែលក្រុមហ៊ុនរុជណាប់បានគ្រោង ។ ស្នើឯកឧត្តមផ្តល់ឲ្យយើងខ្ញុំផង ។

**មតិអគ្គរដ្ឋទូតយូហ្គោស្លាវី:**

យើងខ្ញុំអាចផ្តល់ព័ត៌មានខ្លះអំពីឯកសារទាក់ទងនឹងប័ណ្ណសងប្រាក់តាមសំណូមពររបស់ភាគីកម្ពុជា ។ ប៉ុន្តែ យើងខ្ញុំបានទទួលអនុញ្ញាតឲ្យប្រគល់ឯកសារដឹកជញ្ជូនមកភាគីកម្ពុជាដែលនៅពេលណាភាគីកម្ពុជាប្រគល់ប័ណ្ណសងប្រាក់ឲ្យយើងខ្ញុំ ។

ការជួបសន្ទនាថ្ងៃនេះស្ថិតក្នុងបរិយាកាសជាមិត្តភាពរីករាយនិងយោគយល់គ្នាទៅវិញទៅមក ។

សូមបងជ្រាបជាព័ត៌មាននិងមានមតិណែនាំ ។

សូមគោរពដោយភាតរភាពបដិវត្ត ។

ផ្ញើនៅថ្ងៃទី១៤ វិច្ឆិកា ១៩៧៧

គណៈកម្មាធិការពាណិជ្ជកម្ម

**ផ្ញើជូន:** បងហែម១ច្បាប់, បងវ៉ន១ច្បាប់, ក៥១ មួយច្បាប់ និងឯកសារ២ច្បាប់ ។

**(ឯកសារលេខ D២២៩០៥)**

## ពន្យល់ពាក្យខ្មែរក្រហម

◆ **សុភមង្គល:** សប្បាយមិនខ្វល់ខ្វាយលំបាកដោយហេតុការណ៍អ្វីមួយ ។ ដូចសង្គមយើងសព្វថ្ងៃនេះហៅសង្គមមានសុភមង្គល ។

◆ **ប្រតិសកម្ម:** សកម្មភាពដែលមានដំណើរទៅមុខ និងដំណើរកំពុងអនុវត្ត ។

◆ **ធាតុភាព:** អំពើកើតឡើងដោយចេតនាក្តី ដោយអចេតនាក្តី ។

◆ **ភាវគតិ:** គំនិតដែលមានមកក្នុងខ្លួនតាំងពីក្មេងរហូតដល់ពេញវ័យ ។

◆ **ពលិកម្ម:** លះបង់ទ្រព្យសម្បត្តិនិងអាយុជីវិតខ្លួន ។

(ដកស្រង់ពីសៀវភៅកំណត់ហេតុអ៊ីវ)

*(ឯកសារខ្មែរក្រហម)*

# ការដកស្រង់សម្ដីធូរទៅរបស់បក្សពលករវៀតណាមដែលទាក់ទងដល់ការឈ្លានពានទឹកដីកម្ពុជា

## បញ្ហាជំនួយ

១) ក្នុងឱកាសបុណ្យជប់លៀងចូលឆ្នាំខ្មែរឆ្នាំ៦៨ឬ៦៩ ឡេយន់ អគ្គលេខាធិការបក្សពលករវៀតណាមនិយាយថា ទៅព្រួយអីរឿងកម្ពុជា ឲ្យតែវៀតណាមខាងត្បូងរំដោះហើយគឺទុកដូចជាបានរំដោះកម្ពុជាហើយ៩០ភាគរយដូច្នោះ ។

២) ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ពេលដែលបក្សយើងស្នើឲ្យអ្នកទៅរៀនត្រឡប់ចូលមកក្នុងប្រទេសវិញ មានពាក្យថាភារកិច្ចរបស់បក្សពលករវៀតណាមត្រូវតែបន្តជួយបក្សកុម្មុយនិស្តកម្ពុជាតទៅទៀត ទាំងខាងកម្លាំងមនុស្ស ទាំងខាងបច្ចេកទេសខ្វះទៀតដែលកម្ពុជាខ្វះ ។

## ការជ្រៀតជ្រែកលើផ្នែកចាត់តាំងៈ

១) ម៉ី ផូ ហៅ សាត តែងនិយាយថា បក្សកុម្មុយនិស្តកម្ពុជាគឺត្រូវដូចគល់ ថៃ ហៅ វង ពាក្យវៀតណាមគេថាអនុធនគឺមានជំហរអនុធន ។

២) បណ្ដាំរបស់បក្សពលករវៀតណាមៈ

◆ បក្សពលករវៀតណាម ប្រជាជនវៀតណាម ក៏ដូចជាកងទ័ពវៀតណាម ឋិតនៅជិតបង្កើយជាមួយបណ្ដាមិត្តនិងបដិវត្តកម្ពុជាជានិច្ច ។ ដូចនេះ សូមជឿជាក់លើបក្សពលករវៀតណាមប្រជាជនវៀតណាមនិងកងទ័ពវៀតណាមចុះ ។

◆ ត្រឡប់មកប្រទេសវិញគឺសហការរួមជាមួយវៀត-ណាមដូចសម័យរួមគ្នាវាយបារាំង ។

◆ ក្ដាប់ទ័ព ក្ដាប់ប្រជាជនទាំងមូលឲ្យបាននៅក្នុងដៃ ដោយរួមជាមួយកងទ័ពវៀតណាមនៅកម្ពុជា ។

◆ កុំភ្លេចបក្សនៅក្រៅប្រទេសគឺបក្សប្រជាជនបដិវត្តកម្ពុជាខ្មែរ ។

◆ ស្វះស្វែងទាក់ទងអ្នកបដិវត្តចាស់ៗមាន បងសុវណ្ណ បងជូ ជេត, បងប្រសិទ្ធ និង បងសម្បត្តិ តែត្រូវចាំបាច់ជួបបងនាយសារ៉ាន ជាដំបូង ។

ទាំងអស់នេះគឺជាឈ្មោះដែលវៀតណាមតែងរំពឹកមកនិយាយជារឿយៗមកហើយ ។

◆ យោធាក្ដី រដ្ឋអំណាចក្ដី អាចចាត់តាំងចម្រុះខ្មែរផងវៀតណាមផង ដូចសម័យវាយបារាំង ។ ថ្ងៃ១៣ ខែ៥ ឆ្នាំ៧៦ ប៉ុន

**(ឯកសារលេខ D១៣៨៩៧)**

## សេចក្ដីជូនដំណឹងស្ដីអំពីការបើកឱ្យប្រើប្រាស់
# ការិយាល័យពត៌មានសាធារណៈ
## របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

ការិយាល័យពត៌មានសាធារណៈរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានឹងចាប់បើកទ្វារបម្រើសាធារណជនពីថ្ងៃនេះតទៅ ។ ការិយាល័យពត៌មានសាធារណៈគឺជាទីតាំងសម្រាប់អានឯកសារដែលទាក់ទងនឹងរបបខ្មែរក្រហម ទស្សនាខ្សែភាពយន្តឯកសារខ្មែរក្រហម និងចូលរួមកម្មវិធីពិភាក្សាជាមួយអ្នកច្បាប់និងអ្នកសិក្សាស្រាវជ្រាវអំពីប្រធានបទខ្មែរក្រហមយុត្តិធម៌និងការផ្សះផ្សាបង្រួបបង្រួមជាតិ និងប្រធានបទដទៃទៀត ។ ទិសដៅសំខាន់ពីររបស់ការិយាល័យពត៌មានសាធារណៈគឺ ១)ផ្ដល់ពត៌មាននិងអប់រំប្រជាជនខ្មែរអំពីរបបខ្មែរក្រហម ២) ផ្សព្វផ្សាយពត៌មានអំពីដំណើរការអង្គជំនុំជម្រះក្ដីអតីតមេដឹកនាំខ្មែរក្រហមជូនសាធារណជនឲ្យបានទូលំទូលាយ ។

ការិយាល័យពត៌មានសាធារណៈរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមានទីតាំងនៅផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ។ ពត៌មានបន្ថែមស្ដីអំពីការិយាល័យពត៌មានសាធារណៈ សូមទាក់ទង **សុភ្វា អ៊ីរ៉ែន** ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# នៅតែចងចាំ

តាំងពីខែធ្នូ ឆ្នាំ២០០២ ក្រុមស្រាវជ្រាវ“ដាក់ឲ្យមានការទទួលខុសត្រូវ”របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះស្រាវជ្រាវរកអតីតកម្មាភិបាលខ្មែរក្រហមនៅខេត្តចំនួន៥គឺខេត្តកណ្តាល កំពង់ចាម កំពង់ធំ តាកែវ និងកំពត។ ក្រៅពីការសម្ភាសន៍និងសាកសួរតាមទម្លាប់ក្រុមស្រាវជ្រាវតែងតែចែកទស្សនាវដ្តី “ស្វែងរកការពិត” ដល់ប្រជាជននៅគ្រប់ទីកន្លែងដែលខ្លួនបានទៅដល់។ នៅខេត្តកណ្តាល ក្រុមអ្នកស្រាវជ្រាវបានជួបស្ត្រីវ័យកណ្តាលម្នាក់ឈ្មោះ ប៊ុត បឿន ហៅ ណា ដែលជាអតីតយុទ្ធនារីខ្មែរក្រហម។ បឿន បានទទួលទស្សនាវដ្តីលេខ៣៤ ចេញខែតុលា ឆ្នាំ២០០២ ចៃដន្យ គាត់បានឃើញរូបរបស់គាត់នៅលើក្របទស្សនាវដ្តីនោះ។ បឿន ចង្អុលរូបនារីម្នាក់ដែលនៅលំដាប់ទីប្រាំក្នុងជួរ ហើយលាន់មាត់ទាំងភ្ញាក់ផ្អើលថា “នេះគឺជារូបខ្ញុំទេតើ!”។ គាត់បន្ថែមថា “រូបថតនេះជាក្រុមរបស់ខ្ញុំនៅក្នុងកងវរសេនាតូច២២៩ ដែលថតនៅឆ្នាំ១៩៧៤ ពេលចូលប្រយុទ្ធនៅសមរភូមិម្តុំវាលកប់ស្រូវ”។ បឿន បានរៀបរាប់ពីឈ្មោះយុទ្ធនារីដែលគាត់ស្គាល់នៅក្នុងរូបថតនោះ។

បឿន បានស្ម័គ្រចិត្តចូលបម្រើបដិវត្តខ្មែរក្រហមនៅឆ្នាំ១៩៧១ ក្នុងវ័យ២១ឆ្នាំ តាមការឃោសនារបស់អាជ្ញាធរភូមិឃុំដែលនិយាយថា ធ្វើបដិវត្តន៍ដើម្បីរំដោះប្រទេសជាតិឲ្យរួចផុតពីការជិះជាន់របស់របបសក្តិភូមិនិងអំពើពុករលួយ។ បឿន បានធ្វើដំណើរដោយថ្មើរជើងអស់រយៈពេល៣យប់៣ថ្ងៃទៅដល់ស្រុកកំពង់ត្រឡាចខេត្តកំពង់ឆ្នាំង។


បឿន

នៅទីនោះ បឿនធ្វើការនៅក្នុងក្រុមផលិតឱសថ។ ជារៀងរាល់ថ្ងៃ បឿន ស្វែងរកឫសឈើនិងដើមឈើនៅក្នុងព្រៃដើម្បីយកមកផលិតជាថ្នាំ។ ដើមឈើដែលគាត់ស្វែងរកគឺប្រភេទឈើណាដែលមានរសជាតិល្វីង។ ឈើដែលរកបានត្រូវយកមកចិញ្ច្រាំហើយដាក់ហាលឲ្យស្ងួតនិងកិនឲ្យម៉ដ្តសម្រាប់សូនជាគ្រាប់តូចៗ។ តារ៉េត ពេទ្យមកពីប្រទេសវៀតណាម ជាអ្នកស្លថ្នាំដោយផ្ទាល់។ ថ្នាំដែលផលិតបានអាចព្យាបាលជំងឺដូចជាគ្រុនចាញ់ រាកមួល និងជំងឺទូទៅជាច្រើនមុខទៀត។ ថ្នាំដែលផលិតបានត្រូវបែងចែកទុកព្យាបាលនៅមន្ទីរនិងចែកទៅតាមមន្ទីរពេទ្យភូមិភាគ។

ក្រៅពីធ្វើថ្នាំ បឿន ត្រូវធ្វើស្រែថែមទៀត។ ការហូបចុករបស់គាត់មិនមានការខ្វះខាតឡើយ។ បឿន បានចូលរួមប្រជុំនៅពេលយប់ជាមួយយុទ្ធនារី ជារឿយៗ ដែលកិច្ចប្រជុំនោះ អូនជាអ្នកអប់រំពីការក្រោកឡើងតស៊ូប្រយុទ្ធប្រឆាំងនឹងការជិះជាន់និងបំបាត់អំពើពុករលួយ បំបាត់របបនាយទុនសក្តិភូមិ។

នៅឆ្នាំ១៩៧៣ បឿន ត្រូវបានអង្គការចាត់តាំងឲ្យធ្វើជាប្រធានក្រុមនៅក្នុងកងវរសេនាតូច២២៩។ អង្គភាពរបស់គាត់ឡើងច្បាំងនៅម្តុំត្រពាំងព្រាយភ្នំប្រសិទ្ធិនិងទំនប់កប់ស្រូវ។

បឿន វាយប្រយុទ្ធរហូតដល់ខ្មែរក្រហមដណ្តើមបានទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥។ ក្រោយពីទទួលបានជ័យជម្នះ បឿន សប្បាយចិត្តណាស់ ពីព្រោះសង្ឃឹមថានឹងបានវិលត្រឡប់ទៅភូមិកំណើតវិញ ផ្ទុយទៅវិញប្រធានកងមិនអនុញ្ញាតឡើយ។ ប្រធានកងបាននិយាយថា “កាលពីមុនយើងប្រយុទ្ធដើម្បីរំដោះប្រទេសជាតិ ក្រោយពេលយើងទទួលបានជ័យជម្នះហើយ យើងមានតួនាទីកសាងនិងការពារប្រទេសជាតិ”។ បឿន នឹកអាល័យផ្ទះនិងក្រុមគ្រួសាររបស់គាត់ខ្លាំងណាស់។ ពេលមកដល់ទីក្រុងភ្នំពេញ បឿន ឃើញតែកងទ័ពបដិវត្តន៍ខ្មែរក្រហម ហើយទីក្រុងទាំងមូលមានសភាពស្ងាត់ជ្រងំ។ បឿន ត្រូវអង្គការចាត់តាំងឲ្យទៅនៅស្តាតចាស់ក្បែរស្ពានជ្រោយចង្វារ។ ការងាររបស់ បឿន គឺបោសសម្អាតនិងធ្វើស្រែនៅម្តុំវត្តសំរោងអណ្តែត គឺផ្លាស់ប្តូរវេនមួយសប្តាហ៍ធ្វើស្រែមួយសប្តាហ៍ធ្វើការងារនៅក្នុងស្តាត។

បឿន ពុំអាចដើរទៅណាមកណាក្រៅវង្វង់ដែលគាត់រស់នៅឡើយ ។ ដោយសាររបបហូបចុកមិនគ្រប់គ្រាន់ ពេលខ្លះ បឿន សុំរបបបន្ថែម ប៉ុន្តែគណៈកងមិនអនុញ្ញាត ។ ក្រោយមកទៀត អង្គការផ្លាស់ប្តូរគាត់ឲ្យទៅធ្វើការជាច្រើនកន្លែងដូចជា ទៅកាត់ដេរនៅម្ពុស្ទឹងមានជ័យ ស្ថានទូតចិន និងបញ្ជូនឲ្យទៅធ្វើស្រែនៅម្តុំបឹងជើងឯក ដោយផ្លាស់ប្តូរមួយអាទិត្យឬមួយខែម្តង ។

នៅឆ្នាំ១៩៧៦ បឿន ត្រូវអង្គការចាត់តាំងឲ្យទៅទទួលសម្តេចព្រះ នរោត្តម សីហនុ នៅព្រលានយន្តហោះពោធិចិនតុង ។ នៅក្នុងឱកាសនោះ គាត់បានឃើញសម្តេច ប៉ែន នុត និងប្រពន្ធរបស់គាត់ ព្រមទាំងគណៈកងពលផ្សេងៗទៀត ។ អ្នកទាំងអស់គ្នាបានស្រែកអបអរសាទរថា "ជយោ!ការបង្រួបបង្រួមជាតិ!" ។ ក្នុងឆ្នាំនោះ បឿន ត្រូវអង្គការផ្លាស់ឲ្យមកកាត់ដេរសម្លៀកបំពាក់កងទ័ពនៅក្បែរស្ថានីយប្រេងឥន្ធនៈគីឡូម៉ែត្រលេខ៧ ។

នៅឆ្នាំ១៩៧៧ បឿន ត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅក្រសួងពាណិជ្ជកម្មដែលមានសមមិត្ត ហុង និងសមមិត្ត វ៉ាន់ រិតជាប្រធាន ។ បឿន មានតួនាទីជាអ្នកសម្រាំងផលិតផលសម្រាប់នាំចេញទៅប្រទេសក្រៅ ។ ផលិតផលទាំងនោះមានដូចជាសណ្តែកដីសណ្តែកសៀង និង កាហ្វេ ។ គាត់បានចូលរួមប្រជុំជាមួយ វ៉ាន់



រិត ជាញឹកញាប់ ។ នៅក្នុងកិច្ចប្រជុំ រិត បានអប់រំឲ្យយកចិត្តទុកដាក់ប្រុងប្រយត្ន័ចំពោះសម្ភារដែលត្រូវដឹកចេញដឹកចូល ។ (តាមរយៈឯកសារពាណិជ្ជកម្មជាច្រើនដែលតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាបានបញ្ជាក់ឲ្យឃើញថា នៅក្នុងចន្លោះឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៨ ហុង បានធ្វើវិក្កយបត្រនាំទំនិញទៅប្រទេសចិន ប្រទេសកូរ៉េ និងមានការពិនិត្យទទួលខុសត្រូវលើគុណភាពទំនិញ ដោយ វ៉ាន់ រិត) ។

នៅក្រសួងពាណិជ្ជកម្ម បឿន ត្រូវអង្គការចាត់តាំងឲ្យរៀបការជាមួយ ប៊ុន ថូង ដែលជានិរសាររបស់ ហុង ។ អ្នកទាំងពីរធ្លាប់បានស្គាល់គ្នាពីមុន ប៉ុន្តែមិនសូវបាននិយាយរកគ្នាទេ ព្រោះអ្នកទាំងពីរធ្វើការនៅផ្នែកផ្សេងពីគ្នា ។ ក្រោយមក ហុង ត្រូវអង្គការចាប់ខ្លួន ចំណែក ប៊ុនថូង អង្គការហៅឲ្យទៅរៀនសូត្រ ហើយក៏ត្រូវចាប់ខ្លួនដែរ ។ ពេលដែល ថូង ត្រូវចាប់ខ្លួន បឿន មានផ្ទៃពោះរយៈពេល១ខែ ។ ពេលនោះសមមិត្ត នារីថា បានបញ្ជាឲ្យពេទ្យចាក់ថ្នាំទម្លាក់កូនរបស់ បឿន ប៉ុន្តែមិនបានសម្រេច ។ ពេទ្យ បានឲ្យគាត់លោតចុះលោតឡើង ប៉ុន្តែកូនក្នុងផ្ទៃរបស់គាត់នៅតែមិនព្រមធ្លាក់ ។ មួយខែក្រោយមក បឿន មានជំងឺគ្រុនក្តៅយ៉ាងខ្លាំង ហើយនៅពេលដែលគាត់លេបថ្នាំ កូនរបស់គាត់ក៏ស្លាប់នៅក្នុងផ្ទៃ ។ បន្ទាប់មកអង្គការបានចាត់តាំងឲ្យ សុវណ្ណ នាំ បឿន មកភូមិរយៈពេលមួយថ្ងៃ ដើម្បីសាកសួរពីក្រុមគ្រួសាររបស់គាត់ ពីព្រោះអង្គការសង្ស័យថាគាត់លាក់លៀមប្រវត្តិរូប ។ ពេលមកដល់ផ្ទះ បឿន មិនបានឃើញឪពុកឡើយ ដោយសារគាត់ត្រូវគ្រាប់ផ្លោងស្លាប់បាត់បង់ជីវិតតាំងពីឆ្នាំ១៩៧៤ម្ល៉េះ ។




ក្រោយពីការបាត់បង់ប្តីនិងកូននៅក្នុងផ្ទៃ បឿន ត្រូវបញ្ជូនឲ្យទៅធ្វើស្រែនៅវត្តគោកខ្សាច់ដែលស្ថិតនៅជិតផ្ទះរបស់គាត់ ប៉ុន្តែគាត់នៅតែមិនអាចទៅលេងផ្ទះបានដដែល ។ បឿន រស់នៅវត្តកោះខ្សាច់មួយរយៈខ្លីក៏ត្រូវអង្គការបញ្ជូនទៅធ្វើស្រែនៅផ្សារក្រោម ខេត្តកំពង់ឆ្នាំង ។ នៅដើមឆ្នាំ១៩៧៩ អង្គការបានបញ្ជូនយុទ្ធជនមួយចំនួនយកទៅសម្លាប់នៅម្តុំអន្លង់គូប ហើយមានគម្រោងបញ្ជូនយុទ្ធនារីទៅសម្លាប់នៅពេលក្រោយទៀត ប៉ុន្តែត្រូវអាក់ខានដោយសារកងទ័ពវៀតណាមផ្តួលរំលំរបបខ្មែរក្រហមនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។

បឿន បានវិលត្រឡប់មកផ្ទះវិញ ហើយនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ គាត់បានរៀបការម្តងទៀត ប៉ុន្តែបានលែងលះទៅវិញ ។ សព្វថ្ងៃ បឿន រស់នៅជាមួយម្តាយនៅក្នុងស្រុកកណ្តាលស្ទឹងខេត្តកណ្តាល ។ បឿន តែងតែនិយាយថាធ្វើបដិវត្តន៍គ្មានបានលទ្ធផលអ្វីឡើយ ។ រូបថតរបស់គាត់នៅលើក្របទស្សនាវដ្តីស្វែងរកការពិតធ្វើឲ្យគាត់នឹកឃើញហេតុការណ៍ដែលគាត់បានចូលប្រយុទ្ធនៅក្នុងសមរភូមិជាច្រើន ហើយព្រឹត្តិការណ៍ទាំងនោះហាក់បីដូចជានៅថ្មីៗនៅឡើយ ។

**ប៉ាង ពីន័រ**

# គ្មានអ្វីឈឺចាប់ជាងការព្រាត់ប្រាសទេ

នេះជាការរៀបរាប់ដោយសង្ខេបនូវដំណើរជីវិតរបស់អតីតទាហានខ្មែរក្រហមម្នាក់ឈ្មោះ អ៊ឹង វ៉ាន់ ដែលបានលះបង់កម្លាំងកាយដើម្បីបុព្វហេតុបដិវត្តន៍ខ្មែរក្រហម ។ ជីវិតរបស់អតីតកងទ័ពមួយរូបនេះក៏មិនខុសពីជីវិតរបស់កងទ័ពខ្មែរក្រហមដទៃទៀតដែលបានបម្រើបដិវត្តន៍ខ្មែរក្រហមហើយទទួលនូវការខកចិត្តយ៉ាងខ្លាំង នៅពេលដែលដឹងថាឪពុកម្តាយសាច់ញាតិរបស់ខ្លួនត្រូវអង្គការបង្ខំឲ្យធ្វើការហួសកម្លាំងនិងបង្អត់អាហារក្នុងខណៈដែលខ្លួនកំពុងតែតស៊ូបម្រើអង្គការ ។


អ៊ឹង វ៉ាន់

វ៉ាន់ បានបម្រើខ្មែរក្រហមអស់រយៈពេល២០ឆ្នាំ គឺចាប់ពីឆ្នាំ១៩៧៦ដល់ឆ្នាំ១៩៩៦ ។ វ៉ាន់ មានស្រុកកំណើតនៅភូមិខ្នាយ ឃុំទទុង ស្រុកទូកមាស ខេត្តកំពត ។ វ៉ាន់ ជាកូនទីពីរក្នុងចំណោមបងប្អូនចំនួន៦នាក់ ។ មុនខ្មែរក្រហមកាន់កាប់អំណាចក្នុងឆ្នាំ១៩៧៥ វ៉ាន់ គឺជាសិស្សសាលា ហើយនៅពេលដែលខ្មែរក្រហមកាន់កាប់អំណាចទាំងស្រុង គ្រួសាររបស់ វ៉ាន់ មិនត្រូវបានជម្លៀសទៅណាទេ ។ កាលនោះ វ៉ាន់ បានឃើញសកម្មភាពរុះរើផ្ទះសម្បែងប្រជាជន វត្តអារាមដើម្បីយកទៅធ្វើរោងសហករណ៍ រោងបាយ ឬក្រោលគោ ។ ក្រោយមកទៀត វ៉ាន់ ត្រូវខ្មែរក្រហមចាត់តាំងឲ្យទៅនៅក្នុងកងចល័ត លើកទំនប់មួយហៅថាទំនប់រំលេច ។ វ៉ាន់ និយាយថា ការងារលើកទំនប់នេះលំបាកណាស់ ។ គាត់ត្រូវធ្វើការសឹងតែពេញមួយថ្ងៃ ហើយគ្មានអាហារហូបចុកគ្រប់គ្រាន់ ។ អំឡុងពេលនោះ វ៉ាន់ បានឃើញមនុស្សស្លាប់ជាបន្តបន្ទាប់រៀងរាល់ថ្ងៃដោយសារជំងឺគ្មានថ្នាំព្យាបាល និងដោយសារកង្វះចំណីអាហារ ។ ជាងនេះទៅទៀត បើនរណាម្នាក់ធ្វើការមិនសូវសកម្មនឹងត្រូវខ្មែរក្រហមយកទៅភូមិថ្មី ។ អ្នកដែលត្រូវយកទៅភូមិថ្មីមិនដែលមានឱកាសត្រឡប់មកវិញទេ ។

វ៉ាន់ បានចូលធ្វើកងទ័ពខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៦ បន្ទាប់ពីលើកទំនប់រំលេចបានប្រហែលមួយខែ ។ វ៉ាន់ មិនដែលមានបំណងចង់ធ្វើទ័ពទេ ព្រោះនឹងត្រូវឃ្លាតពីឪពុកម្តាយ បងប្អូន ប៉ុន្តែគាត់មិនហ៊ានជំទាស់នឹងបទបញ្ជារបស់អង្គការឡើយ បើមិនដូច្នោះ គាត់នឹងត្រូវចាត់ទុកថាចូលដៃជាមួយខ្មាំង ហើយនិងត្រូវសម្លាប់ចោលជាមិនខាន ។ ក្នុងចំណោមបងប្អូនរបស់ វ៉ាន់ មានតែ វ៉ាន់ ម្នាក់ប៉ុណ្ណោះដែលចូលធ្វើបដិវត្តន៍ ។ កាលពីដំបូង វ៉ាន់ ត្រូវបានចាត់តាំងជាទ័ពស្រុក ក្រោយមកត្រូវផ្លាស់ទៅព្រំដែនវៀតណាមខាងភូមិភាគបូព៌ាចំណុចជ្រៃធំ ។ អំឡុងពេលដែល វ៉ាន់ ធ្វើកងទ័ពខ្មែរក្រហម វ៉ាន់ បានជួបប្រទះនូវភាពលំបាកវេទនាគ្រប់បែបយ៉ាងដូចជាគ្មានជម្រកត្រឹមត្រូវ ខ្វះថ្នាំព្យាបាលជំងឺ ហើយជាពិសេសទៅទៀតនោះគឺ ចាប់តាំងពី វ៉ាន់ ចូលធ្វើកងទ័ពខ្មែរក្រហមក្នុងឆ្នាំ១៩៧៦មក គាត់មិនដែលមានពេលមកលេងឪពុកម្តាយ សូម្បីតែដំណឹងបន្តិចក៏មិនដែលបានទទួលដែរ ។ យូរៗម្តង វ៉ាន់ បានសុំមេបញ្ជាការរបស់គាត់មកលេងផ្ទះដែរ ប៉ុន្តែមិនដែលបានទទួលការអនុញ្ញាតទេ ។ ដោយក្តីនឹករឭកឪពុកម្តាយបងប្អូនខ្លាំងពេក វ៉ាន់ ស្មុគស្មាញក្នុងអារម្មណ៍ជាខ្លាំង ប៉ុន្តែគាត់នៅតែខំប្រឹងធ្វើការបំពេញចិត្តអង្គការដដែល ។

បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមក្នុងឆ្នាំ១៩៧៩ វ៉ាន់ មានបំណងស្រុកកំណើតវិញដើម្បីជួបជុំឪពុកម្តាយ ប៉ុន្តែមិនហ៊ានមកព្រោះមេបញ្ជាការបានប្រាប់ថា បើត្រឡប់ទៅវិញនឹងត្រូវកងទ័ពវៀតណាមដំដែកគោលលើក្បាលនិងចោះស្លឹកត្រចៀក ។ វ៉ាន់ ទ្រាំរស់នៅជាមួយខ្មែរក្រហមតទៅទៀតរហូតដល់ឆ្នាំ១៩៩៦ ពេលកងកម្លាំងខ្មែរក្រហមធ្វើសមាហរណកម្មជាមួយរដ្ឋាភិបាលកម្ពុជា ទើប វ៉ាន់ បានត្រឡប់មកស្រុកកំណើតវិញ ក្នុងចិត្តរំពឹងថានឹងបានជួបឪពុកម្តាយបងប្អូនមិនខាន ។ វ៉ាន់ ខកចិត្តជាខ្លាំងនៅពេលដែលមកដល់ភូមិកំណើតហើយបានដឹងថាឪពុកម្តាយរបស់គាត់បានស្លាប់បាត់បង់ជីវិតទៅហើយ នៅក្នុងអំឡុងពេលដែល វ៉ាន់ កំពុងតស៊ូនៅក្នុងព្រៃជាមួយខ្មែរ

ក្រហម ។ បងប្អូនជីដូនមួយរបស់ វ៉ាន់ ជាច្រើននាក់ក៏ស្លាប់ក្នុងរបបខ្មែរក្រហមដែលកាន់កាប់អំណាចពីឆ្នាំ១៩៧៥-១៩៧៩ដែរ ។

វ៉ាន់ មានការសោកស្តាយខ្លាំងណាស់ដែលខ្លួនខំធ្វើការបម្រើអង្គការ ប៉ុន្តែអង្គការបែរជាសម្លាប់បងប្អូនរបស់ខ្លួនទៅវិញ ។

សព្វថ្ងៃ វ៉ាន់ មានអាយុ៤០ឆ្នាំ និងជាប្រជាពលរដ្ឋម្នាក់ដែលមានទីលំនៅៗភូមិកោះស្លា ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត ។ គាត់ក៏ជានាយទាហានមួយរូបរបស់រាជរដ្ឋាភិបាលកម្ពុជាដែរ ។

ស្លាកស្នាមបន្សល់ពីរបបខ្មែរក្រហមមិនទាន់ជ្រះស្រឡះពីផ្លូវចិត្តរបស់ វ៉ាន់ នៅឡើយទេ ។ គាត់សន្លប់បាត់ស្មារតីជាញឹកញាប់ ហើយគាត់តែងយល់សប្តិឃើញរូបគាត់ត្រូវខ្មែរក្រហមយកទៅសម្លាប់ជារឿយៗ ។ វ៉ាន់ បានទៅពិគ្រោះយោបល់ជាមួយគ្រូពេទ្យផ្នែកចិត្តសាស្ត្រនៅស្រុកឈូកជាច្រើនដងឥឡូវនេះគាត់មាន មានអារម្មណ៍ធូរស្បើយជាងមុនច្រើន ។

វ៉ាន់ បាននិយាយអំពីបទពិសោធន៍របស់ខ្លួនកាលពីរបបខ្មែរក្រហមប្រាប់កូនចៅនិងផ្តាំកុំឲ្យយកគំរូតាមគាត់ព្រោះគ្មានប្រយោជន៍អ្វីក្រៅពីលំបាកវេទនានិងព្រាត់ប្រាសក្រុមគ្រួសារឡើយ ។ គាត់ចង់ឲ្យក្មេងជំនាន់ក្រោយរៀនសូត្រអំពីប្រវត្តិសាស្ត្រខ្មែរក្រហមដើម្បីឲ្យដឹងអំពីទំហំនៃការឈឺចាប់របស់ប្រជាជនខ្មែរកាលពីសម័យនោះ ។

**ញាណ សុជាតិ**

# កូនខ្ញុំនឹងដើររកខ្ញុំនៅថ្ងៃបុណ្យភ្ជុំបិណ្ឌ

នៅខែកញ្ញា ឆ្នាំ២០០៤ ក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះសម្ភាសន៍ប្រជាជនមួយចំនួននៅស្រុកត្រាំកក់ ខេត្តតាកែវ ។ ស្ទើរតែគ្រប់ភូមិដែលយើងទៅដល់ប្រជាជនបានមកចោមរោមស្តាប់ការសម្ភាសន៍សាកសួរអំពីការងារ និងស្តាប់ការពន្យល់របស់យើង ។ ប្រជាជនម្នាក់ៗសម្តែងនូវការចាប់អារម្មណ៍យ៉ាងខ្លាំងនិងចង់ចែករំលែករឿងរ៉ាវរបស់ខ្លួនដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម ។ លោកយាយ អ៊ុក យ៉េន អាយុ៧៣ឆ្នាំ រស់នៅភូមិស្រែខ្វាវ ឃុំជាងទង បានមកអង្គុយស្តាប់ការសម្ភាសន៍អ្នកភូមិរបស់គាត់ដោយក្តីរំជួលចិត្ត ហើយដោយមិនអាចទ្រាំលាក់ទុកនៅក្នុងចិត្តតទៅទៀត បន្ទាប់ពីបានស្តាប់រឿងរ៉ាវរបស់អ្នកភូមិក្បែរផ្ទះ យាយក៏រៀបរាប់រឿងរ៉ាវរបស់គាត់ដែលបានបាត់បង់កូនប្រុសច្បងម្នាក់នៅក្នុងរបបខ្មែរក្រហម ។


អ៊ុក យ៉េន

យាយ អ៊ុក យ៉េន មានស្រុកកំណើតនៅភូមិចក ឃុំរការក្នុងស្រុកដូនកែវ ខេត្តតាកែវ ។ លោកយាយមានប្តី និងមានកូនប្រុសបីនាក់រស់នៅទីនោះ ។ នៅឆ្នាំ១៩៦៦ ពេលដែលសម្តេចឪចែកដីឲ្យប្រជាជនទៅរស់នៅឃុំអមលាំងក្នុងខេត្តកំពង់ស្ពឺ យាយនិងប្តីរបស់គាត់បានផ្លាស់ទៅរស់អមលាំងវិញដោយទុកកូនប្រុសទាំង៣នាក់ដែលកំពុងរៀនឲ្យរស់នៅជាមួយបងប្រុសរបស់គាត់នៅក្នុងភូមិចក ។ នៅអមលាំងយាយសម្រាលបានកូនពីរនាក់ទៀត គឺស្រីមួយ ប្រុសមួយ ។ គាត់តែងតែធ្វើដំណើរមកលេងកូនទាំងបីដែលរស់នៅខេត្តតាកែវជាញឹកញាប់ ប៉ុន្តែគាត់មិនអនុញ្ញាតឲ្យកូនទៅលេងនៅអមលាំងទេ ព្រោះនៅទីនោះជាតំបន់មានជំងឺគ្រុនចាញ់ ។ ទឹម សុវណ្ណ ជាកូនច្បងបានប្រឡងជាប់ឌីប្លូមក្នុងឆ្នាំ១៩៧០ ដែលធ្វើឲ្យយាយសប្បាយចិត្តយ៉ាងខ្លាំង ។ ក្រោយមកមិនយូរប៉ុន្មាន សុវណ្ណ បានចូលធ្វើជាទាហានខាងក្រុមភ្លេងប្រចាំការនៅវត្តជើងចាបខាងត្បូងខេត្តតាកែវ ។ ចាប់ពីនោះមក យាយយ៉េន ក៏លែងបានមកលេងកូនទៀតព្រោះការធ្វើដំណើរចេញចូលតំបន់រំដោះមានការលំបាក ។ ដោយក្តីនឹករឭកនិងបារម្ភពីកូន យាយតែងតែស៊ើបសួរដំណឹងកូនពីប្រជាជនដែលធ្វើដំណើរមកពីខេត្តតាកែវជានិច្ច ប៉ុន្តែដំណឹង

ដែលគាត់ទទួលបានគឺតិចតួចបំផុត ។

រហូតមកដល់ឆ្នាំ១៩៧៥ ពត៌មាននិងទំនាក់ទំនងផ្សេងៗត្រូវកាត់ផ្តាច់ទាំងស្រុង ។ យាយមិនដែលបានដឹងដំណឹងអំពីកូននិងបងប្អូនរបស់គាត់ដែលរស់នៅខេត្តតាកែវសោះឡើយ ។ ក្នុងអំឡុងពេលខ្មែរក្រហមកាន់កាប់ ខ្មែរក្រហមមិនបានជម្លៀសក្រុមគ្រួសារយាយទៅណាទេ គឺឲ្យរស់នៅក្នុងភូមិឃុំដដែល ព្រោះទីនោះជាតំបន់ព្រៃស្រាប់ ។ មួយឆ្នាំក្រោយពីការដួលរលំរបស់របបខ្មែរក្រហម ពោលគឺនៅឆ្នាំ១៩៨០ យាយបានវិលត្រឡប់មករស់នៅស្រុកកំណើតរបស់គាត់វិញ ។ យាយបានជួបនឹងកូនប្រសាគាត់ឈ្មោះ ប៊ុន ឡាង (ជាប្រពន្ធរបស់ ទឹម សុវណ្ណ ដែលរៀបការបានបីខែមុនពេលខ្មែរក្រហមជម្លៀសចេញពីភូមិនៅឆ្នាំ១៩៧៥) ។ ឡាង បានរៀបរាប់ប្រាប់លោកយាយថា គាត់បែកពី សុវណ្ណ តាំងពីថ្ងៃខ្មែរក្រហមជម្លៀសចេញពីភូមិម្ល៉េះ ហើយមិនដែលបានជួបមុខគ្នាជារៀងរហូត ។

សព្វថ្ងៃនេះ យាយ អ៊ុក យ៉េន ជឿជាក់ក្នុងចិត្តថាកូនរបស់គាត់ត្រូវខ្មែរក្រហមសម្លាប់ចោលទៅហើយ ព្រោះសម័យនោះ ទាហាន លន់ ណុល ជាមុខសញ្ញាដែលត្រូវសម្លាប់មុនគេ ។ យាយបាននិយាយថា «កូនហ្នឹងពិតជាស្លាប់ហើយ អត់មានបែកទៅនៅឯណាទេ ព្រោះវាយូរឆ្នាំណាស់ហើយ មិនមែនទើបតែពីរបីឆ្នាំឯណា ប្រសិនបើរស់ ទោះបីជាទៅនៅដល់ណាក៏ត្រូវតែមករកម៉ែឪបងប្អូនដែរ» ។ ទោះបីជាមិនបានឃើញដោយផ្ទាល់ភ្នែកនូវការស្លាប់របស់កូនក៏ដោយ ប៉ុន្តែដោយសារក្តីស្រឡាញ់និងការនឹករឭកកូន យាយចេះតែស្រមើស្រមៃឃើញសកម្មភាពខ្មែរក្រហមកំពុងតែសម្លាប់កូនរបស់គាត់នៅនឹងមុខ ។ រូបភាពកូនប្រុសរបស់គាត់ដែលលុតជង្គង់ទាំងដៃជាប់ចំណងនៅមុខឃាតករអាវខ្មៅដែលកំពុងតែលើកដំបងសំពងទៅលើកញ្ចឹងកបានលេចឡើងនៅក្នុងចិត្តរបស់គាត់ ព្រមទាំងសំឡេងស្រែកហៅឲ្យម៉ែឪជួយ នៅលាន់ឮក្នុងត្រចៀករបស់គាត់ហាក់ដូចជាហេតុការណ៍នេះទើបតែកើតឡើងថ្មីៗ ។

យាយហូរទឹកភ្នែកស្ទើរតែរាល់ពេលដែលនឹកឃើញដល់កូនម្តងៗ ។ យាយនៅតែចងចាំពីអត្តចរិតរបស់កូនកាលពីនៅរស់ជានិច្ច ។ គាត់និយាយថា «កូនរបស់ខ្ញុំស្លូត វាចិត្តបានណាស់ បានជាខ្ញុំនឹកឃើញពេលណាចង់ស្រក់ទឹកភ្នែកហ្នឹងណា៎ ។ ខ្ញុំខំរកនឹកថាតើខ្ញុំធ្លាប់ខឹងនឹងកូនហ្នឹងឬកូនហ្នឹងបានធ្វើអ្វីមួយឲ្យខ្ញុំខាស់ចិត្តដើម្បីឲ្យខ្ញុំបានរសាយចិត្តខ្លះ តែខ្ញុំរកនឹកមិនឃើញសោះ ។ កូនមួយហ្នឹងដូចមនុស្សស្រីអីចឹង និយាយពីចានឆ្នាំង ភ្ញាក់ឡើង វាលាងអស់ហើយ ខោអាវក៏មិនដែលឲ្យខ្ញុំបោកដែរ ធ្វើស្អាតហើយបានទៅសាលារៀន» ។ យាយបានខិតខំរកវិធីដើម្បីកាត់បន្ថយការនឹកគិតពីកូនរបស់គាត់ដោយខ្លួនឯង «ជួនកាលខ្ញុំខំបន្ទប់ខ្លួនឯងដោយគិតថា ណ្ហើយ! កុំគិតកូនយើងក៏ស្លាប់ កូនគេក៏ស្លាប់អារម្មណ៍ហ្នឹងក៏បានរសាយបន្តិចទៅ ។ តែបើកាលណាយើងនឹកឃើញភ្លាមហ្នឹងដូចនៅថ្មីៗអីចឹង» ។ រហូតមកដល់ពេលនេះអ្វីដែលយាយអាចធ្វើបានគឺមានតែការធ្វើបុណ្យបញ្ជូនកុសលដល់កូនរបស់គាត់ប៉ុណ្ណោះ ព្រោះយាយគិតថា បុណ្យកុសលទាំងនោះអាចជួយដល់ខ្លួនគាត់ផ្ទាល់ផងនិងជួយដល់កូនរបស់គាត់ផង ។

ការប្រតិបត្តិខ្លួនតាមព្រះពុទ្ធសាសនាដូចជារៀនធម៌ស្តាប់ធម៌ ការកសាងអំពើល្អតាមពុទ្ធឱវាទ និងការទៅវត្តយកចង្ហាន់ទៅប្រគេនព្រះសង្ឃ ភាវនាធម៌ ធ្វើឲ្យយាយមានអារម្មណ៍ស្ងប់ ភ្លេចគិតទៅដល់រឿងអតីតកាល ។ ឥឡូវនេះយាយកាន់សីល៨ហើយ ជារៀងរាល់ថ្ងៃសីល យាយតែងតែទៅសុំសីលនៅវត្តអង្គរការដែលស្ថិតនៅក្បែរផ្ទះរបស់គាត់ជានិច្ច ។ យាយបានប្រាប់ថា «ការទៅវត្តស្តាប់ធម៌ធ្វើឲ្យខ្ញុំបានរសាយចិត្តច្រើន វាមិនធ្វើឲ្យអារម្មណ៍របស់ខ្ញុំមូលតែទៅលើរឿងហ្នឹងដូចមុនទេ ហើយពេលដែលខ្ញុំទន្ទេញធម៌ក៏ខ្ញុំមិនសូវនឹកឃើញវាញឹកញាប់ទៀតដែរ ព្រោះឥឡូវអារម្មណ៍របស់ខ្ញុំនឹកគិតដល់រឿងធម៌ច្រើនជាង» ។

យាយបានត្រៀមរៀបចំគ្រឿងទេយ្យទានបម្រុងទុកសម្រាប់យកទៅប្រគេនព្រះសង្ឃនៅរដូវបុណ្យភ្ជុំបិណ្ឌដែលនឹងមកដល់នៅពេលឆាប់ៗខាងមុខនេះ ។ យាយមានប្រសាសន៍ថា «ឲ្យតែដល់ថ្ងៃបុណ្យភ្ជុំបិណ្ឌ បុណ្យចូលឆ្នាំ ខ្ញុំតែងតែនឹកឃើញដល់កូន ដល់បងប្អូនដែលស្លាប់ទៅ ដូច្នេះហើយទើបខ្ញុំទៅធ្វើបុណ្យនៅវត្តជារៀងរាល់ឆ្នាំមិនដែលខាន ។ ខ្ញុំអុជធូបនៅមុខព្រះខ្ទិសបន់ស្រន់ហៅកូន ម៉ែឪ បងប្អូនជីដូនជីតាឲ្យមកទទួលភោគផលដែលខ្ញុំបញ្ជូនឲ្យ ព្រោះខ្ញុំមិនចង់ឲ្យកូនរបស់ខ្ញុំដែលស្លាប់ទៅនោះអត់ឃ្លាន

ដើរមើលមាត់គេ ។ ខ្ញុំដឹងថានៅថ្ងៃនោះកូនខ្ញុំនឹងដើររកខ្ញុំហើយ» ។ លោកយាយបន្តទៀតថា «ខ្ញុំជឿថាកុសលទាំងអស់នោះនឹងបានទៅដល់កូនរបស់ខ្ញុំនិងញាតិមិត្តដែលបានស្លាប់ទៅ ពួកគេនឹងបានហូបឆ្អែត ។ ពេលមានមានបុណ្យ មានទាននៅឯណាប្អូគេធ្វើពិធីអភិសេកអីក៏ខ្ញុំទៅចូលរួមធ្វើបុណ្យបញ្ជូនឲ្យកូនខ្ញុំដែរ» ។

យាយមិនបានដឹងពីកន្លែងដែលកូនរបស់គាត់ស្លាប់ទេ ប៉ុន្តែដោយសារនៅខេត្តតាកែវមានគុកខ្មែរក្រហមធំមួយឈ្មោះក្រាំងតាចាន់ ដែលមានមនុស្សជាច្រើននាក់ត្រូវបានសម្លាប់នៅទីនោះ ដូច្នេះយាយបានសន្និតថាកូនរបស់គាត់ក៏ត្រូវខ្មែរក្រហមយកទៅសម្លាប់នៅទីនោះដែរ ។ ជារៀងរាល់ឆ្នាំ នៅថ្ងៃទី២០ ខែឧសភា យាយតែងតែទៅចូលរួមពិធីគោរពវិញ្ញាណក្ខន្ធជនរងគ្រោះនៅគុកក្រាំងតាចាន់ជានិច្ច ។ យាយមានប្រសាសន៍ថា «ខ្ញុំទៅចូលរួមមិនដែលខានមួយឆ្នាំណាទេ ព្រោះខ្ញុំគិតថាកូនខ្ញុំប្រហែលជាត្រូវខ្មែរក្រហមយកទៅសម្លាប់កន្លែងហ្នឹងហើយ ។ ឲ្យតែដល់ថ្ងៃនោះ ខ្ញុំធ្វើបាយសម្លនិងបង្អែមដែលកូនខ្ញុំចូលចិត្តយកទៅប្រគេនលោក» ។

យាយ យ៉េន ជាពុទ្ធសាសនិកម្នាក់ដែលមានជំនឿយ៉ាងមុតមាំទៅលើកម្មផល ប៉ុន្តែចំពោះការស្លាប់របស់កូនគាត់និងប្រជាជនខ្មែររាប់លាននាក់នៅក្នុងរបបខ្មែរក្រហម យាយបែរជាគិតថាមិនមែនជាបញ្ហាកម្មផលទៅវិញ ។ យាយបានបញ្ជាក់ប្រាប់ថា «របបនោះជារបបទមិឡអត់សាសនា គឺជារបបដែលយកមនុស្សទៅសម្លាប់ចោលតែម្តងមិនមែនដោយសារកម្មផលរបស់អ្នកទាំងនោះទេ» ។ ហើយចំពោះអំពើដែលខ្មែរក្រហមបានធ្វើមកលើប្រជាជនខ្មែរយាយចង់ឲ្យអ្នកទាំងនោះទទួលនូវផលដែលខ្លួនបានសាងវិញ ។ យាយបានមានប្រសាសន៍ថា «បើពេលកើតឡើងភ្លាមៗគឺកំហឹងទល់កំហល់ដូចគ្នា បើខ្មែរក្រហមសម្លាប់កូនខ្ញុំ ខ្ញុំចង់សម្លាប់ខ្មែរក្រហមវិញ បើខ្មែរក្រហមវាយកូនខ្ញុំ ខ្ញុំចង់វាយខ្មែរក្រហមវិញ ។ តែមកដល់ជំនាន់នេះហើយយើងធ្វើមិនកើតទេ ព្រោះរបបនេះមិនដូចជារបបខ្មែរក្រហមទេ យើងមិនអាចធ្វើដូច្នេះបានទៀតទេ» ។ តាមគំនិតរបស់យាយផ្ទាល់ យាយយល់ថា អតីតខ្មែរក្រហមនឹងទទួលផលដែលខ្លួនបានធ្វើ ។ យាយបន្ថែមទៀតថា «ខ្ញុំដឹងកាលជំនាន់អាពតគេមិនយកអ្នកចេះឲ្យធ្វើការទេ គេយកតែអ្នកល្ងង់ៗឲ្យទៅធ្វើការដើម្បីងាយស្រួលគេបញ្ជាឲ្យទៅធ្វើអ៊ីក៏ធ្វើដែរ ដូច្នេះត្រូវតែឲ្យអ្នកបញ្ជាហ្នឹងទទួលផលអ៊ីមួយដូចជាឲ្យតុលាការកាត់ទោសតែម្តងទៅ» ។

**អឿ រតនា**

# រំឭកអនុស្សាវរីយ៍បដិវត្តន៍

ស្រុកឈូក ស្ថិតនៅក្នុងខេត្តកំពត បានធ្លាក់ទៅក្នុងការគ្រប់គ្រងរបស់ខ្មែរក្រហមកាន់កាប់តាំងពីមុនឆ្នាំ១៩៧៥ ។ យុវជនក្មេងៗទាំងប្រុសទាំងស្រីតម្រូវឲ្យចូលបម្រើកងទ័ព ឬធ្វើការក្នុងកងចល័តស្ទើរតែទាំងអស់ ។ ស៊ុំ ស៊ី បានត្រូវប្រធានភូមិជ្រើសរើសឲ្យចូលកងចល័តជាមួយកុមារីក្នុងភូមិដែលមានអាយុស្របាលៗគ្នា ។ ក្រោយមក ស៊ី បានចូលធ្វើជាពេទ្យនៅមន្ទីរពេទ្យ ៦មករា នាទីក្រុងភ្នំពេញរហូតដល់របបខ្មែរក្រហមត្រូវដួលរលំ ។



ស៊ុំ ស៊ី

ស៊ី ជាកូនទី២ ក្នុងគ្រួសារកសិករមួយនៅក្នុងស្រុកឈូក ។ ដោយស្រុកទេសមានសង្គ្រាមម្តាយរបស់គាត់បានឲ្យគាត់ឈប់រៀនត្រឹមថ្នាក់ទី១០ ។ ស៊ី បានត្រឹមតែចេះអានអក្សរបន្តិចបន្តួចប៉ុណ្ណោះ ។ នៅពេលមានអាយុ១៥ឆ្នាំ ស៊ី និងកុមារដែលមានអាយុស្របគ្នាជាច្រើននាក់ត្រូវប្រធានភូមិបញ្ជូនឲ្យចូលកងចល័ត ហើយឲ្យទៅលើកទំនប់ភូមិត្រពាំងបឹងនិងទំនប់រំលេចនៅស្រុកឈូកអស់រយៈពេលជិតមួយឆ្នាំជាមួយនឹងរបបអាហារយ៉ាងអត្តខាត់ ។ ក្រោយមកទើបអង្គការបានជ្រើសរើសគាត់ឲ្យធ្វើជាពេទ្យ ។ ស៊ី បានប្រាប់ថាក្នុងចំណោមកុមារីនៅក្នុងភូមិ គឺគាត់ជា

មនុស្សតែម្នាក់គត់ដែលបានធ្វើពេទ្យ ។ មុនពេលជ្រើសរើសអង្គការបានបញ្ជូនមនុស្សឲ្យទៅស៊ើបប្រវត្តិរូបនិងតាមដានក្រុមគ្រួសាររបស់គាត់ដល់ស្រុកកំណើត ។ ក្រោយពីដឹងថា គាត់មានប្អូនពីរនាក់ធ្វើទ័ពនិងធ្វើនិរសារ គួបផ្សំនឹងការងារល្អរបស់ ស៊ី ផង ទើបអង្គការសម្រេចជ្រើសរើសគាត់ឲ្យធ្វើពេទ្យនៅឃុំក្រាំងស្បូវ ។ ប្រធានពេទ្យនិងអនុប្រធានពេទ្យរបស់គាត់ឈ្មោះនារីស៊ីន និងនារីរឿន ។ ស៊ី មាននាទីព្យាបាលនិងចែកថ្នាំឲ្យអ្នកជំងឺ ។ ស៊ី ធ្វើការបណ្ដើរហាត់រៀនចាក់ថ្នាំបណ្ដើរ ។ ពេលហាត់រៀនគឺចាក់ដើមចេក ដល់ពេលចេះស្ទាត់ហើយទើបទៅចាក់អ្នកជំងឺផ្ទាល់ ។ អ្នកជំងឺដែលចូលមកដេកនៅក្នុងមន្ទីរពេទ្យឃុំនេះភាគច្រើនជាកងចល័តលើកទំនប់ ហើយមានច្បាប់សម្រាកតែមួយសប្ដាហ៍ប៉ុណ្ណោះត្រូវត្រឡប់ទៅសហករណ៍វិញ ព្រោះត្រូវទុកកន្លែងឲ្យអ្នកជំងឺថ្មីសម្រាក ។ ស៊ី ធ្វើការនៅពេទ្យឃុំបានតែមួយរយៈពេលខ្លីទើបត្រូវបញ្ជូនមកមន្ទីរពេទ្យ៦មករា ភ្នំពេញ ។ អ្នកជំងឺនៅក្នុងមន្ទីរពេទ្យនេះសុទ្ធតែជាកងទ័ពដែលបញ្ជូនមកពីខេត្តព្រៃវែង ។ ស៊ី បានរៀបរាប់ថា អ្នកជំងឺខ្លះស្គូត ខ្លះទៀតកាច ពេលលាងរបួសម្ដងៗ អ្នកជំងឺស្រែកជេរប្រទេចពេទ្យ ជួនកាលរហូតដល់ទាត់ពេទ្យលាងរបួសទៀតផង ។ ថ្នាំដែលប្រើប្រាស់នៅមន្ទីរពេទ្យនេះសុទ្ធសឹងនាំមកពីប្រទេសចិន ។ ចាប់តាំងពីមកធ្វើការនៅពេទ្យ៦មករារហូតដល់ឆ្នាំ១៩៧៨ ស៊ី មិនដែលបានមកលេងផ្ទះទាល់តែសោះបានត្រឹមតែផ្ញើសំបុត្រប៉ុណ្ណោះ ។ ស៊ី បានទទួលការបង្ហាត់បង្រៀនបន្ថែមទៀតអំពីរបៀបព្យាបាលអ្នកជំងឺគ្រុនចាញ់ ។ បន្ថែមពីលើនោះ គាត់បានទៅរៀនអំពីរបៀបវះកាត់នៅមន្ទីរពេទ្យព–១៧ចំនួន៥–៦ដង និងបានទទួលការបង្ហាត់បង្រៀនពីគ្រូពេទ្យចិនម្នាក់ទៀត ប៉ុន្តែមិនទាន់បានអនុវត្តផ្ទាល់នៅឡើយទេ ។

យូៗម្ដង ស៊ី ឃើញ ប៉ុល ពត និង អៀង សារី ចុះទៅពិនិត្យនៅមន្ទីរពេទ្យ ។ ក្រៅពីនោះ ស៊ី ធ្លាប់បានចូលរួមទទួលភ្ញៀវបរទេសចំនួនពីរដងនិងចូលរួមមីទ្ទីងនៅស្តាតចំនួនពីរដង ។

ពេលដែលកងទ័ពវៀតណាមវាយសម្រុកចូលមកទីក្រុងភ្នំពេញនៅខែមករា ឆ្នាំ១៩៧៩ ខ្មែរក្រហមបានចាកចេញទាំងប្រញាប់ប្រញាល់ ដោយកៀរទាំងអ្នកជំងឺទៅជាមួយផង ។ ស៊ី និយាយថា «គេឲ្យសែងអ្នកជំងឺដាក់រថភ្លើងដឹកទៅពោធិ៍សាត់ បាត់ដំបង ។ សែងជិតងាប់មួយយប់អត់បានដេកទេ ដល់ព្រលឹមឡើងមកយកទៀត ហើយឃើញខ្លះរត់ពីវត្តភ្នំ មានម៉ូតូ ឡានគេថាយួនចូលពេញទីក្រុងហើយ ស្រាប់តែផ្ទុះអាវុធពេញហ្នឹងទៅ» ។ ស៊ី មិនបានធ្វើដំណើរតាមរថភ្លើងទៅជាមួយអ្នកជំងឺទេគាត់ជិះរថយន្តដឹកស្បៀងតាមពីក្រោយ ។ គ្រាប់ផ្លោងរបស់កងទ័ពវៀតណាមធ្លាក់ចំរថយន្តដែលគាត់ជិះបណ្ដាលឲ្យស្បៀងឆេះអស់ ចំណែកមនុស្សនាំគ្នាហក់ចេញពីឡាន រត់បែកខ្ញែកគ្នាក្រោយមកទើបជួបជុំគ្នានៅស្រុកមោងខេត្តបាត់ដំបង ។ ស៊ី និយាយថា «ជិះឡានតាមប្រផុតប្រផើយ ស្ទើរស្លាប់ស្ទើររស់ដល់ហើយបែកគ្នាអស់រលីងមិនដឹងស្អីៗឯណាខ្លះទេ អាអ្នកជំងឺហ្នឹងគេដឹកទៅមុនទៅដល់ហើយទើបជួបអ្នកជំងឺនៅមោង» ។ នៅតាមផ្លូវអ្នកជំងឺខ្លះស្លាប់ដោយទ្រាំមិនបាន ខ្លះទៀតត្រឡប់ក្រោយវិញ ។ ស៊ី បានឲ្យដឹងថា «ពេលទៅដល់មោងខ្ញុំទ្រាំស៊ុំអត់ស៊ីឃ្លានដោយសារខ្វះស្បៀង ។ ដល់ពេលលំបាកពេកខ្ញុំត្រឡប់មកក្រោយវិញ ដើរសុំអង្ករប្រជាជនបន្តិចបន្តួចគ្រាន់ហូប ៗ» នៅពេល ស៊ី ធ្វើដំណើរត្រឡប់មកវិញ កងទ័ពវៀតណាមបានហៅគាត់ឲ្យឡើងជិះរថយន្តមកភ្នំពេញជាមួយ ។ មកដល់ភ្នំពេញកងទ័ពវៀតណាមបានផ្ដល់អង្ករឲ្យគាត់ខ្លះដើម្បីបន្តដំណើរទៅស្រុកកំណើត ។

ស៊ី បានរស់នៅជាមួយឪពុកម្ដាយអស់រយៈពេលបីឆ្នាំទើបគាត់រៀបការជាមួយបុរសម្នាក់នៅក្នុងភូមិនិងដែលជាស្វាមីគាត់សព្វថ្ងៃនេះ ។

ទោះជា ស៊ី បានរស់សុខស្រួលនិងមានរបបហូបចុកគ្រាន់នៅក្នុងរបបនោះក៏ដោយ ក៏គាត់ហ៊ានអះអាងថា«របបខ្មែរក្រហមជារបបសម្លាប់មនុស្ស ៗ» ប្អូនប្រុសរបស់គាត់ពីរនាក់ឈ្មោះយ៉ាវ និង ហ៊ាច ដែលធ្វើជាទ័ពបានបាត់ខ្លួនរហូតដល់សព្វថ្ងៃនេះហើយគាត់នៅតែទន្ទឹងមើលផ្លូវប្អូនប្រុសទាំងពីររបស់គាត់ត្រឡប់មកវិញជានិច្ច ។ នៅពេលទំនេរ ស៊ី តែងនិយាយរឿងរ៉ាវរបស់គាត់ប្រាប់កូនៗជារឿយៗ ដើម្បីឲ្យកូនៗបានដឹងពីអំពីការលំបាករបស់មនុស្សនៅក្នុងរបបនោះ ។

បច្ចុប្បន្ន ស៊ី មានអាយុ៤៥ឆ្នាំ រស់នៅស្រុកឈូក ខេត្តកំពតជាមួយប្ដីឈ្មោះ លាង ដែន និងកូនប្រាំមួយនាក់ ដោយប្រកបរបរធ្វើស្រែចិញ្ចឹមជីវិត ។

**លី សុផល**

# ឡូវ ថា៖ បើកុំតែមានរបបខ្មែរក្រហមម្ល៉េះសមកម្ពុជារីកចម្រើន


ឡូវ ថា

ឡូវ ថា មានឈ្មោះបដិវត្តន៍ ឡូវ ណយ មានស្រុកកំណើតនៅភូមិក្រាំងថ្កូវ ឃុំប្រភ្នំ ស្រុកអង្គរជ័យ ខេត្តកំពត ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យខ្មែរក្រហមបានឲ្យឈ្មោះស្រុកអង្គរជ័យថាស្រុក១០៦ ។ បើតាមការរៀបរាប់របស់ ណយ ស្រុកនេះជាតំបន់ប្រទាញប្រទង់រវាងទាហានលន់ណុលនិងកងទ័ពរំដោះខ្មែរក្រហមដែលធ្វើឲ្យប្រជាជនរស់នៅក្នុងតំបន់នោះមានការលំបាកនិងភិតភ័យជាប្រចាំ ។ អ្នកដែលធ្វើការឲ្យខ្មែរក្រហមត្រូវខាងលន់ណុលចាប់ដាក់គុក ហើយអ្នកដែលធ្វើការខាងលន់ណុលត្រូវខាងខ្មែរក្រហមចាប់ធ្វើទារុណកម្ម ។ ហេតុដូច្នេះហើយបានជាប្រជាជនមួយចំនួនធំបាននាំគ្នារត់ចេញពីភូមិដើម្បីគេចពីគំរាមកំហែងនិងការប្រយុទ្ធគ្នានេះ ។

ដោយសាររវល់តែរត់គេចពីសង្គ្រាម ណយ ឈប់រៀនត្រឹមថ្នាក់ទី១១(ស្មើនឹងថ្នាក់ទី២បច្ចុប្បន្ន) ហើយទៅរស់នៅឃុំដានគោម រហូតដល់ឆ្នាំ១៩៧២ ។ នៅពេលដែលស្រុកអង្គរជ័យធ្លាក់ក្នុងការគ្រប់គ្រងរបស់ខ្មែរក្រហម ទើបក្រុមគ្រួសាររបស់គាត់វិលត្រឡប់មករស់នៅស្រុកកំណើតវិញ ។

ពីដំបូង ទ័ពខ្មែរក្រហមចូលមកភូមិស្រុកហើយសុំផ្ទះរបស់អ្នកភូមិស្នាក់នៅ និងមិនឃើញមានការប្រព្រឹត្តអំពើឃោរឃៅមកលើប្រជាជនទេ គឺតែងតែជួយសម្រាលការងារស្រែចម្ការរបស់ប្រជាជនជានិច្ច ។ លុះដល់ឆ្នាំ១៩៧២ ប្រធានភូមិក្រាំងថ្កូវបានចាត់ប្រជាជនជាក្រុមដើម្បីធ្វើស្រែប្រវាស់ដៃ ។ ក្រុមប្រវាស់ដៃនេះគឺប្រមូលប្រជាជនជាក្រុម ហើយសមាជិកនៅក្នុងក្រុមត្រូវជួយធ្វើស្រែគ្នាទៅវិញទៅមក ។ នៅពេលទទួលផលគឺទទួលតាមទំហំស្រែរបស់គ្រួសារនីមួយៗដែលមាន ។ នៅឆ្នាំ១៩៧៣ ខ្មែរក្រហមបានផ្លាស់ប្តូរគោលនយោបាយដោយចាត់តាំងសហករណ៍វិញ ។ សហករណ៍នៅភូមិរបស់ ណយ មាន៥ក្រុម ក្នុងមួយក្រុមមានប្រហែល១៥គ្រួសារ ។ ក្រុមគ្រួសាររបស់ ណយ ស្ថិតនៅក្នុងក្រុមទី២ ។

នៅឆ្នាំ១៩៧៤ ប្រធានភូមិឈ្មោះ ព្រួច បានជ្រើសរើសកុមារ៥នាក់ក្នុងមួយភូមិឲ្យទៅបម្រើការងារនៅតាមអង្គភាព ។ ណយ មានអាយុប្រហែល១៥ឆ្នាំ ត្រូវប្រធានភូមិចុចឈ្មោះឲ្យធ្វើជានិរសារឃុំ ។ ប្រធាននារីឃុំឈ្មោះ លន ។ ការងារជានិរសារគឺនាំសំបុត្រពីឃុំប្រភ្នំទៅភូមិនានានៅក្នុងឃុំ ។សំបុត្រទាំងនោះជាសំបុត្រសុំស្បៀងដើម្បីផ្តល់ឲ្យកងទ័ពនៅសមរភូមិមុខ ឬសុំកម្លាំងពីភូមិឲ្យមកជួយស្ទូង ។ អង្គការបណ្តុះបណ្តាលនិរសារកុមារចំនួន១២នាក់ដែលប្រមូលមកពីភូមិនានា យកមកបង្រៀនចាប់ពីម៉ោង១ថ្ងៃត្រង់រហូតដល់ម៉ោង៤ល្ងាច ។ ក្រៅពីការងារជានិរសារ ណយ ត្រូវដើររកខុសទុកសម្រាប់ដាំបាយទៀត ។

ធ្វើជានិរសារឃុំបានប្រហែល៦ខែ នៅឆ្នាំ១៩៧៥ ណយ និងក្រុមកុមារនិរសារ ត្រូវអង្គការបញ្ជូនឲ្យទៅភូមិត្រពាំងគល់ដើម្បីហាត់រៀនពីរបៀបរបបធ្វើការងារ ត្រៀមខ្លួនចេញដំណើរទៅធ្វើការនៅអង្គភាពស្រែអំបិល ។ នៅទីនោះមានកុមារជាច្រើនដែលប្រមូលផ្តុំមកពីស្រុកផ្សេងៗទៀត ។ កន្លះខែក្រោយមក ណយ និងកុមារនិរសារទាំងអស់ ត្រូវអង្គការដឹកតាមរថយន្តឆ្ពោះទៅស្រែអំបិល ។ គ្រាន់តែទៅដល់ភ្លាមអង្គការបែងចែកកុមារទាំងអស់ទៅតាមអង្គភាពនានាភ្លាម ។ ណយ ត្រូវអង្គការបញ្ជូនឲ្យទៅធ្វើការនៅអង្គភាពផលិតអំបិល ។ ការងារដំបូងរបស់គាត់គឺលើកភ្លឺស្រែអំបិល បញ្ចូលទឹក និងកើបអំបិលទុកក្នុងឃ្លាំង ។ ណយ ធ្វើការពីម៉ោង៧ព្រឹករហូតដល់ម៉ោង១១ថ្ងៃ និងបន្តពីម៉ោង១រហូតដល់ម៉ោង៥ល្ងាច ។ ជួនកាលពេលដែលអំបិលដុះច្រើនហើយខ្លាចត្រូវភ្លៀងខូច ក្រុមកម្មករត្រូវធ្វើការនៅពេលយប់ទៀត ក្រៅពីការងារនេះ អង្គការចាត់តាំងឲ្យដាំបន្លែបង្ការផ្សេងៗសម្រាប់ផ្គត់ផ្គង់ការហូបចុក ។ ណយ ធ្វើការនៅស្រែអំបិលបានមួយឆ្នាំ អង្គការក៏ផ្លាស់ឲ្យទៅនៅឃុំត្រើយកោះខេត្តកំពតវិញ ។ ការងារនៅទីនេះមិនខុសគ្នាប៉ុន្មានពីការងារនៅស្រែ

អំបិលទេ ។ នៅរដូវភ្លៀង អង្គការបានផ្អាកការផលិតអំបិល ហើយឲ្យកម្មករដាំដំឡូង ។ នៅឆ្នាំ១៩៧៧ ណយ ត្រូវអង្គការជ្រើសរើសឲ្យទៅរៀនវិជ្ជាពេទ្យនៅស្ពាតអូឡាំពិករយៈពេលមួយសប្ដាហ៍ ។ គ្រូបង្រៀនគឺ អៀង ធីរិទ្ធ, ជួន ជឿន និងអ្នកបច្ចេកទេសពេទ្យខ្មែរនិងចិន ។ ការសិក្សាចាប់ផ្ដើមពីម៉ោង៧ រសៀលរហូតដល់ម៉ោង៥ល្ងាច ។ នៅពេលចប់វគ្គសិក្សាអង្គការបានជ្រើសរើសសិក្ខាកាមមួយចំនួនឲ្យចូលធ្វើការនៅតាមមន្ទីរពេទ្យនានានៅទីក្រុងភ្នំពេញ ។ ណយ ត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅមន្ទីរពេទ្យ៦មករា(មន្ទីរពេទ្យព្រះកេតុមាលា) នៅជិតវត្តភ្នំដែលមាន ពឿន (កូនប្រសា អៀង សារី) ជាប្រធានពេទ្យ, នី ជាអនុប្រធាន និង ហួន ជាប្រធានអគារ-១៥ ដែល ណយ ធ្វើការ ។ ណយ មាននាទីបោសសំរាម លាងបន្ទប់មន្ទីរពេទ្យ ប្រមូលកំប្រេះដែលរុំរបួសរួចយកទៅបោកគក់ និងសម្អាតកន្ត្រៃកាត់និងដាក់ចំហុយឡើងវិញ ។ ក្រោយមក ប្រធានក្រុមអនុញ្ញាតឲ្យគាត់លាងរបួស និងចាក់ថ្នាំឲ្យអ្នកជំងឺ ។ ណយ ខិតខំធ្វើការជារៀងរាល់ថ្ងៃដោយមិនដែលត្អូញត្អែរឡើយ ។

អៀង ធីរិទ្ធ ឧស្សាហ៍មកប្រជុំណែនាំបុគ្គលិកពេទ្យអំពីនយោបាយនិងគោលមាគ៌ារបស់អង្គការជាញឹកញាប់ ។ បុគ្គលិកពេទ្យទាំងអស់មិនអនុញ្ញាតឲ្យស្រឡាញ់គ្នាដោយលួចលាក់ទេ ។ ក្រោយពីស្ដាប់ការណែនាំនេះហើយ នារីពេទ្យទាំងអស់មិនហ៊ានប្រព្រឹត្តល្មើសវិន័យអង្គការឡើយ ។ តាមការណែនាំរបស់ ពឿន អ្នកជំងឺទាំងអស់ដែលសម្រាកនៅក្នុងមន្ទីរពេទ្យសុទ្ធតែត្រូវកត់ប្រវត្តិរូបទុក ។

ក្រៅពីការងារព្យាបាល ណយ ត្រូវអង្គការជ្រើសរើសឲ្យទៅទទួលភ្ញៀវបរទេសផ្សេងៗដូចជា យូហ្គោស្លាវី កូរ៉េ គុយបា និងចិន ពីព្រលានយន្តហោះពោធិចិនតុង ។ ពេលបានទៅម្ដងៗ ណយ សប្បាយចិត្តខ្លាំងណាស់ ព្រោះបានស្លៀកពាក់ស្អាតបាត ហើយបានហូបឆ្អែត ។ ក្រោយពីទទួលភ្ញៀវរួច អង្គការបានដឹកក្រុមកុមារដើរកម្សាន្តតាមទីក្រុងភ្នំពេញដើម្បីកុំឲ្យកុមារនឹកផ្ទះឲ្យភ្លេចឪពុកម្ដាយ ហើយបែរមកដើរតាមនយោបាយថ្មីរបស់អង្គការវិញ ។ ណយ និយាយថា គាត់បានផ្ញើសំបុត្រទៅឪពុកម្ដាយជារៀងរាល់ខែ ប៉ុន្ដែមិនដែលឃើញឆ្លើយតបមកវិញសោះ ។ ក្រោយមកទើបគាត់ដឹងថា រាល់សំបុត្រដែលឪពុកម្ដាយគាត់ទទួលបានត្រូវប្រធានភូមិយកទៅដុតចោលបន្ទាប់ពីអានរួច ។

នៅដើមឆ្នាំ១៩៧៩ វេលាម៉ោង៥ល្ងាច ពេលដែល ណយ កំពុងព្យាបាលអ្នកជំងឺ ពឿន បានទូរស័ព្ទមកគ្រប់ប្រធានអគារឲ្យឆាប់រៀបអីវ៉ាន់និងនាំអ្នកជំងឺចាកចេញជាបន្ទាន់ ព្រោះកងទ័ពវៀតណាមបានវាយបុកមកខ្លាំងណាស់ ។ ក្នុងរយៈពេលតែ២ ម៉ោងប៉ុណ្ណោះ អ្នកជំងឺនិងបុគ្គលិកពេទ្យទាំងអស់បានចាកចេញពីមន្ទីរពេទ្យឆ្ពោះទៅខេត្តបាត់ដំបង និងទៅកាន់ព្រំដែនកម្ពុជា-ថៃ ។

ណយ រស់នៅក្នុងជំរំសាយអេចនៅតាមព្រំដែនមិនហ៊ានត្រឡប់មកស្រុកកំណើតវិញទេ ព្រោះខ្លាចកងទ័ពវៀតណាមបាញ់សម្លាប់ ។ គាត់នៅតែយកវិជ្ជាពេទ្យដែលគាត់ចេះបន្តិចបន្តួចជួយព្យាបាលជំងឺជូនប្រជាជនដដែល ។ នៅខែ១២ ឆ្នាំ១៩៨២ គាត់បានរៀបការជាមួយ ពុធ ទុំ ។ ក្រោយមក ណយ ក៏ឈប់ធ្វើពេទ្យ ហើយងាកមកលក់ដូរបន្តិចបន្តួចនិងថែទាំកូនៗរបស់គាត់ ។ ដោយក្ដីនឹករឭកឪពុកម្ដាយខ្លាំងពេក ណយ និងប្ដីក៏សម្រេចចិត្តធ្វើមាតុភូមិនិវត្តន៍មកស្រុកកំណើតវិញនៅឆ្នាំ១៩៩១ ។

ក្រោយពីបានស្ដាប់រឿងរ៉ាវដែលខ្មែរក្រហមធ្វើមកលើឪពុកម្ដាយរបស់ខ្លួន ណយ មានការសោកស្ដាយយ៉ាងខ្លាំង ។ ណយ នឹកស្មានថា ក្រុមគ្រួសាររបស់ខ្លួនមានរបបហូបចុកគ្រប់គ្រាន់ ។ ជាងនេះទៅទៀត ណយ មិនដឹងថាខ្មែរក្រហមសម្លាប់មនុស្សទាល់តែសោះ ។ គាត់បញ្ជាក់បន្ថែមថា បើកុំតែមានរបបខ្មែរក្រហម ម្ល៉េះសមប្រទេសកម្ពុជាមានការរីកចម្រើនជាងនេះមិនខាន ។

**សូ ហ្សារីណា**

## ពាក្យស្លោកខ្មែរក្រហម

- ◆ ប្ដេជ្ញាគោរពនិងអនុវត្តការដឹកនាំនិងធ្វើការងារដោយស្មារតីទទួលខុសត្រូវខ្ពស់និងចាត់ចែងការងារដោយស្វាហាប់ ច្នៃប្រឌិតកសាងរស់រវើកដើម្បីបម្រើចលនាឱ្យបានឆាប់និងល្អបំផុត។
- ◆ ប្ដេជ្ញាខាយសម្រុក ប្រែក្លាយកម្ពុជាកសិកម្មឱ្យទៅជាកម្ពុជាឧស្សាហកម្មឱ្យបានឆាប់រហ័សបំផុត។

*(ដកស្រង់ចេញពីសៀវភៅ យស សុ)*

# ការបោសសម្អាតខ្មាំងនៅភូមិភាគបូព៌ា

រដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យមាត្រាទី១០ បានចែងថា "ចំពោះប្រភេទសកម្មភាពប្រឆាំងនិងបំផ្លិចបំផ្លាញដែលមានលក្ខណៈជាខ្សែសង្វាក់ ហើយគ្រោះថ្នាក់ដល់រដ្ឋ ប្រជាជនត្រូវផ្តន្ទាទោសកម្រិតខ្ពស់បំផុត" ។ រដ្ឋធម្មនុញ្ញនេះត្រូវបានផ្សព្វផ្សាយនិងអនុវត្តទូទាំងផ្ទៃប្រទេសដែលធ្វើឲ្យប្រជាជនរាប់លាននាក់ត្រូវស្លាប់ក្រោមរូបភាពជាខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងបដិវត្តន៍ ។ ក្នុងចំណោមភូមិភាគទាំងអស់នៅទូទាំងប្រទេសកម្ពុជា បូព៌ាជាភូមិភាគមួយដែលមានកម្មាភិបាលខ្មែរក្រហមស្លាប់ច្រើនបំផុតដោយសារខេត្តនេះមានព្រំប្រទល់ជាប់ប្រទេសវៀតណាមដែលធ្វើឲ្យមេដឹកនាំខ្មែរក្រហមគិតថាមានភ្នាក់ងារវៀតណាមច្រើននាក់បង្កប់នៅទីនោះ ។

ការកម្ទេចកម្មាភិបាលនៅភូមិភាគបូព៌ាបានចាប់ផ្តើមតាំងពីចុងឆ្នាំ១៩៧៦ ។ កម្មាភិបាលខ្មែរក្រហមចាប់ពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់តំបន់បានត្រូវកម្ទេចនិងបញ្ជូនទៅមន្ទីរស-២១ ដើម្បីសួរចម្លើយរកខ្សែរយៈក្បត់ ។ មិនត្រឹមតែប៉ុណ្ណោះ សូម្បីតែបងប្អូនសាច់ញាតិក្រុមគ្រួសារមិត្តភក្តិ ឬយុទ្ធជនដែលនៅក្រោមបង្គាប់របស់កម្មាភិបាលទាំងនោះក៏ត្រូវចោទថាខ្មាំង រួចបញ្ជូនទៅសម្លាប់ ឬបញ្ជូនទៅលត់ដំនៅកន្លែងផ្សេងៗដូចជាធ្វើព្រលានយន្តហោះនៅខេត្តកំពង់ឆ្នាំងជាដើម ។

ហ៊ូ នឹម ជារដ្ឋមន្ត្រីក្រសួងឃោសនាការមកពីភូមិភាគបូព៌ាត្រូវបានអង្គការចាប់នៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៧ ហើយកម្ទេចនៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៧៧ ។ រ៉ា ឡាន ជាប្រពន្ធរបស់គាត់ ត្រូវអង្គការចាប់នៅថ្ងៃទី១៤ ខែមេសាឆ្នាំ១៩៧៧ ហើយត្រូវសម្លាប់នៅថ្ងៃទី១២ ខែឧសភា ឆ្នាំដដែល ។ សហការីរបស់គាត់ជាច្រើនរយនាក់ទៀតក៏ត្រូវអង្គការចាប់ដាក់មន្ទីរស-២១ ហើយក៏មានវាសនាមិនខុសពីគាត់ដែរ ។

ចំណែកប្រជាជនដែលរស់នៅតាមមូលដ្ឋានក្នុងភូមិភាគបូព៌ាបានទទួលការគាបសង្កត់យ៉ាងខ្លាំងពីកម្មាភិបាលមកពីភូមិភាគនិរតីហើយបានក្លាយទៅជាប្រជាជនដែលអង្គការត្រៀមសម្លាប់ ។

ចាប ពុធ ជាអតីតប្រជាជនរស់នៅភូមិភាគបូព៌ាបាននិយាយថា អង្គការបានតែងតាំងកម្មាភិបាលនារីនិរតីចំនួន២នាក់ឈ្មោះ យឹម និង យ៉ាម ជាលេខាស្រុក២២ ។ ការសម្លាប់រង្គាលបានចាប់ផ្តើមតាំងពីនោះរហូតមកដល់ឆ្នាំ១៩៧៩ ។

កម្មាភិបាលនារីម្នាក់ឈ្មោះ ធី មកពីភូមិភាគនិរតីត្រូវបានអង្គការយកមកជំនួសកម្មាភិបាលស្រុកកងមាសនៅឆ្នាំ១៩៧៨ ។

កម្មាភិបាលភូមិភាគនិរតីរាប់ពាន់នាក់បានទៅកម្ចាត់ខ្មាំងផ្ទៃក្នុងនៅភូមិភាគបូព៌ា ហើយប្រព័ន្ធគ្រប់គ្រងថ្មីត្រូវមជ្ឈិមបង្កើតឡើងដើម្បីកម្ទេច"ខ្មាំងបង្កប់" ។ កងទ័ពនិងប្រជាជនដែលជាប់សង្ស័យត្រូវបញ្ជូនទៅដាក់នៅមន្ទីរលត់ដំក្រោមការឃ្លាំមើលយ៉ាងហ្មត់ចត់ពីអង្គការ ។ អង្គការបានផ្សព្វផ្សាយយុទ្ធនាការបោសសម្អាតខ្មាំងបង្កប់ តាមរយៈទស្សនាវដ្តី វិទ្យុ និងកម្មាភិបាលគ្រប់ជាន់ថ្នាក់ដើម្បីឲ្យកម្ទេច"តាំងពីថ្នាក់លើរហូតដល់ថ្នាក់សហករណ៍មូលដ្ឋាន" ។ ក្រោយពីបានទទួលអំណាចពេញដៃហើយ កម្មាភិបាលភូមិភាគនិរតីទាំងអស់បានចាប់ផ្តើមអនុវត្តគោលនយោបាយរបស់បក្សដោយចាប់ប្រជាជននិងកម្មាភិបាលគ្រប់ជាន់ថ្នាក់នៅភូមិភាគបូព៌ាសម្លាប់ចោលនិងដាក់ទណ្ឌកម្មទាំងខ្សែៗ ពិសេសគឺកងទ័ព ។

នៅក្នុងជួរកងទ័ព ក្រោយពីចាប់ប្រធានកងពល៣១០ ឈ្មោះ អឿន និងអនុប្រធានកងពលតាមលំដាប់ថ្នាក់យកទៅធ្វើទារុណកម្មនិងសម្លាប់រួចហើយ កងទ័ពមួយចំនួនទៀតត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅកន្លែងលត់ដំផ្សេងៗដូចជានៅព្រលានយន្តហោះកំពង់ឆ្នាំងដែលមានសមមិត្ត ម៉េត ប្រធានកងពល៥០២ទ័ពអាកាសជាអ្នកគ្រប់គ្រង ។ ចំនួនទ័ពដែលធ្វើព្រលានយន្តហោះនៅកំពង់ឆ្នាំងមាន២៧០០នាក់ ហើយត្រូវអ្នកមើលការខុសត្រូវនៅទីនោះដកហូតអាវុធនិងមិនអនុញ្ញាតឲ្យដើរហើរ

ទៅណាឆ្ងាយ ក្រៅពីទីតាំងកំណត់ឡើយ ។ ក្នុងរយៈពេលលត់ដំខ្លួន យុទ្ធជនជាច្រើននាក់បានស្លាប់ដោយថ្មភ្នំធ្លាក់សង្កត់លើនិងមួយចំនួនទៀតស្លាប់ដោយការចាប់យកទៅសម្លាប់ ។ អង្គការបានប្រគល់សិទ្ធិឲ្យកម្មាភិបាលភូមិភាគនិរតីសម្លាប់កម្មាភិបាលនិងប្រជាជនភូមិភាគបូព៌ាតាមអំពើចិត្ត ។


ឈា ស្រ៊ុន

ឈា ស្រ៊ុន អតីតយុទ្ធជននៅកងពល៣០៤បានឲ្យដឹងថា គាត់បានចូលបម្រើក្នុងទ័ពខ្មែរក្រហមតាំងពីចុងឆ្នាំ១៩៧០ ក្នុងវរសេនា៣០៩ ។ គាត់បានចូលប្រយុទ្ធក្នុងសមរភូមិជាច្រើន ដូចជាសមរភូមិចម្ការលើប្រយុទ្ធជាមួយពួកធីវគី, សមរភូមិផ្លូវជាតិលេខ៦ វាយកម្ទេចប្រតិបត្តិការចេនឡាទី១ សមរភូមិខេត្តសៀមរាបនិងកំពង់ធំរហូតក្លាយខ្លួនជាជនពិការនៅចុងឆ្នាំ១៩៧៤ ។ ក្រោយពី ស្រ៊ុន ត្រូវរបួសពិការ អង្គការក៏បញ្ជូនគាត់ទៅមន្ទីរយ-២របស់ កែពក បន្ទាប់មកទៅដាំដំណាំនៅមន្ទីរ កុយ ធួន នៅស្រុកស្ទឹងត្រង់ ។ ក្រោយរំដោះឆ្នាំ១៩៧៥ បានប៉ុន្មានខែ ស្រ៊ុន បានសុំ អឿន មកធ្វើការនៅមន្ទីរភ័ស្តុភារកងវរសេនាធំលេខ៣ ក្នុងកងពល៣១០ នៅព្រែកក្តាម ក្នុងនាទីជាអ្នកធ្វើប្រហុកផ្អក ។ នៅដើមឆ្នាំ១៩៧៧ អង្គការបានចាប់ កុយ ធួន ដែលជាលេខាបក្សភូមិភាគឧត្តរ និងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និង តាអឿន ប្រធានកងពល៣១០ព្រមទាំងប្រធានវរសេនាធំវរសេនាតូចផ្សេងទៀតយកទៅដាក់នៅមន្ទីរស-២១ ហើយសម្លាប់ចោលទាំងអស់ដោយចោទថាក្បត់ចូលដៃចូលជើងជាមួយវៀតណាម ។ ចំណែកកម្មាភិបាលដែលនៅក្រោមការដឹកនាំរបស់អ្នកទាំងនោះក៏ត្រូវអង្គការបញ្ជាឲ្យកងទ័ពនិរតីចាប់ដាក់ឡានយ៉ូបធំៗជាច្រើនគ្រឿងដឹកចេញពីទីក្រុងភ្នំពេញយកទៅសម្លាប់ដែរ ។ ស្រ៊ុន បន្ថែមថា សូម្បីតែប្រជាជនដែលរស់នៅភូមិភាគបូព៌ាក៏ត្រូវទទួលការគាបសង្កត់និងការដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរពីកងទ័ពនិរតីដូចគ្នា ។

ស្រ៊ុន ត្រូវអង្គការចោទថាជាសមាសភាពខ្សាំងមាននិន្នាការក្បត់ ហើយត្រូវបញ្ជូនទៅកង១៧ ដែលជាកងលត់ដំខ្លួនធ្វើការគ្មានពេលសម្រាកនិងគ្មានចំណីអាហារគ្រប់គ្រាន់ ។ ជួនកាលការងារត្រូវធ្វើរហូតដល់ម៉ោង១យប់ ហើយងើបធ្វើបន្តទៀតនៅម៉ោង៤ព្រឹក ។ ស្រ៊ុន បានធ្លាក់ខ្លួនឈឺជាទម្ងន់ ហើយត្រូវបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យក្នុងក្រុងភ្នំពេញ ។ នៅពេលជាសះស្បើយ ស្រ៊ុន ត្រូវអង្គការបញ្ជូនទៅធ្វើព្រលានយន្តហោះនៅខេត្តកំពង់ឆ្នាំងទៀត ។

នៅចុងឆ្នាំ១៩៧៨ ស្រ៊ុន និងយុទ្ធជនមួយចំនួនត្រូវអង្គការចាប់បញ្ជូនឲ្យទៅសមរភូមិមុខដើម្បីទប់ទល់ជាមួយវៀតណាម ។ ដោយសារមានកំហឹងឈឺចាប់នឹងអំពើរបស់ខ្មែរក្រហម ស្រ៊ុន បានរត់ចោលសមរភូមិហើយគេចត្រឡប់មកស្រុកកំណើតវិញ ។

សំ សុខ ត្រូវអង្គការបញ្ជូនទៅការដ្ឋានធ្វើព្រលានយន្តហោះខេត្តកំពង់ឆ្នាំងនៅឆ្នាំ១៩៧៧ ។ គាត់តក់ស្លុតណាស់នៅពេលឃើញយុទ្ធជនដុតឆ្អិនរំសេវផ្ទុះដាច់ខ្លួនជាបំណែកៗ ។ សុខ មានប្រសាសន៍ថា ជាលើកដំបូងហើយក្នុងជីវិតរបស់គាត់ដែលបានជួបប្រទះទិដ្ឋភាពបែបនេះ ។ គាត់មិនអាចពិពណ៌នាសព្វគ្រប់អំពីទំហំនៃការភ័យរន្ធត់របស់គាត់បានឡើយ ។ គាត់នៅតែនឹកឃើញមរណភាពគួរឲ្យសង្វេគរបស់យុទ្ធជនអ្នកដុតឆ្អិនដែលត្រូវថ្មភ្នំធ្លាក់សង្កត់ដាច់ក្បាលនិងដាច់ដៃដាច់ជើងដូចជាអង្កត់ខស ។

ឡេង គីម និយាយថា គាត់ជាមួយយុទ្ធជនជាច្រើននាក់ទៀតដែលធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំងត្រូវអង្គការដឹកយកទៅអមលាំងនៅនៅចុងឆ្នាំ១៩៧៨ ដោយបញ្ឆោតថាទៅសមរភូមិមុខ ។ ពេលទៅដល់អមលាំង គីម និងយុទ្ធជនទាំងអស់ត្រូវប្រធានកងបញ្ជាឲ្យតម្រង់ជួរនៅប្រឡោះកណ្តាលយុទ្ធជនភូមិភាគនិរតីជាច្រើនទៀតដែលឈរតម្រង់ជាជួរហើយស្រេច ។ នៅពេលដែលយុទ្ធជនបូព៌ាក្មេងខ្លួនកងទ័ពភូមិភាគនិរតីដែលឈរនៅអមសងខាងបានបាញ់ទៅលើយុទ្ធជនដែលមកពីព្រលានយន្តហោះកំពង់ឆ្នាំងសម្លាប់តែម្តង ។ ឡេង គីម ត្រូវបានប្រធានកងឈ្មោះ ចាន់ ចាប់ដៃអូសចេញពីជួរ ។


ឡេង គីម

ចាន់ ជាកម្មាភិបាលមកពីភូមិភាគនិរតី ដែលស្គាល់ ឡេង គីម នៅសមរភូមិតែនិញប្រទេសវៀតណាម កាលពីឆ្នាំ១៩៧៧ ។ គីម បានអះអាងថា ក្រៅពីគាត់គ្មានយុទ្ធជនណាម្នាក់អាចគេចខ្លួនរួចឡើយ ពីព្រោះនៅជុំវិញកន្លែងនោះមានកងប្រដាប់អាវុធជាច្រើនក្រុមឈរព័ទ្ធជារង្វង់ពីក្រៅជាស្រេចដើម្បីចាំបាញ់យុទ្ធជនណាដែលរត់រួចចេញពីទីនោះ ។ បន្ទាប់ពីសម្លាប់រួច ខ្មែរក្រហមយកត្រាក់ទ័រមកចូកសាកសពទាំងអស់ទម្លាក់នៅក្នុងរណ្ដៅធំមួយ ។

ប៉ុល សេប មាននាទីជាអ្នកការពារអ្នកបច្ចេកទេសចិននៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំង បានឲ្យដឹងថា“អង្គការមានចេតនាកេងយកផលប្រយោជន៍ពីយុទ្ធជនបូព៌ាសិនមុននឹងសម្លាប់អ្នកទាំងនោះ ។ អង្គការមិនដែលទទួលស្គាល់គុណបំណាច់របស់យុទ្ធជនទាំងនោះឡើយ ប៉ុន្តែបែរជាចោទអ្នកទាំងនោះថាជាជនក្បត់បក្សនិងក្បត់ប្រជាជនទៅវិញ ។ មានយុទ្ធជនស្លាប់ជាច្រើនដោយសារការដាក់ឆ្នូនរំសេវនៅក្នុងរូងភ្នំស្ទើរតែរាល់ថ្ងៃ ។ ប៉ុល សេប បានបញ្ជាក់ថា “អង្គការបញ្ជាឲ្យចងខ្សែឆ្នូនខ្លីៗពេលដុតហើយរត់ចេញមិនទាន់រំសេវផ្ទុះខ្ទាតត្រូវខ្លួនអ្នកដាក់ ។ អង្គការមានចេតនាសម្លាប់យុទ្ធជនបូព៌ាតាមវិធីនេះដោយមិនបាច់ចំណាយគ្រាប់កាំភ្លើងសូម្បីតែមួយគ្រាប់” ។

ហេង ដែលជាអតីតយុទ្ធជនធ្វើព្រលានយន្តហោះនៅកំពង់ឆ្នាំង បានប្រាប់ឲ្យដឹងថា បន្ទាប់ពីធ្វើព្រលានយន្តហោះរួចរាល់ អង្គការបានចាប់គាត់និងយុទ្ធជនធ្វើព្រលានយន្តហោះជាច្រើននាក់យកទៅសម្លាប់នៅម្តុំស្ថានីយរថភ្លើងរមាស ។ មុននឹងសម្លាប់ អង្គការបានចងដៃយុទ្ធជនទាំងអស់ទៅក្រោយនិងបញ្ជាឲ្យឈរជាជួរ បន្ទាប់មកទើបបាញ់រះ ។ ហេង នៅមានជីវិតដោយសារគាត់បានផ្តួលខ្លួនមុនពេលបាញ់បន្តិច ហើយត្រូវសាកសពដទៃទៀតសង្កត់ពីលើ ។ នៅពេលអ្នកបាញ់ត្រឡប់ទៅវិញអស់គាត់បានខំស្រាយចំណងចេញហើយលាក់ខ្លួននៅក្នុងព្រៃ ។

ឡាង ខុន បានឲ្យដឹងថា ក្រុមរបស់គាត់ជាអ្នកសម្លាប់យុទ្ធជនធ្វើព្រលានយន្តហោះនៅកំពង់ឆ្នាំងដោយផ្ទាល់ដោយប្រើពូថៅនិងដែកគ្នៀរទេះជាឧបករណ៍ ។ គាត់បានឲ្យដឹងទៀតថា អង្គការមិនប្រើមនុស្សដដែលៗទៅចាប់អ្នកទោសទេ គឺតែងតែផ្លាស់ប្តូរមនុស្សជានិច្ចដើម្បីកុំឲ្យយុទ្ធជនទាំងនោះកត់សម្គាល់បាន ។ យុទ្ធជនមួយកងពលធំត្រូវពួកគាត់សម្លាប់ទម្លាក់រណ្ដៅក្នុងព្រៃខេត្តកំពង់ឆ្នាំងដោយប្រើរយៈពេលពីរសប្តាហ៍ ។

ការមិនទុកចិត្តនិងការភ័យខ្លាចបានធ្វើឲ្យខ្មែរក្រហមបំផ្លាញខ្លួនឯង តាមរយៈការធ្វើវិសុទ្ធកម្មទៅលើកម្មាភិបាល កងទ័ពនិងប្រជាជនដើម្បី“បោសសម្អាតខ្មាំងបង្កប់” ។ ទីបំផុត ខ្មែរក្រហមទទួលបានត្រឹមតែបរាជ័យក្នុងការធ្វើវិសុទ្ធកម្មនេះប៉ុណ្ណោះ ។ ទង្វើរបស់អ្នកទាំងនោះគឺផ្ទុយស្រឡះនឹងទ្រឹស្តីរបស់មេដឹកនាំខ្មែរក្រហមដែលថា “ខ្លួនធ្វើបដិវត្តន៍ដើម្បីជាតិនិងការពារទឹកដី” ។ មេដឹកនាំកម្ពុជាប្រជាធិតេយ្យគួរតែត្រូវនាំឡើងតុលាការ ដែលបង្កើតនៅពេលខាងមុខដើម្បីឲ្យជនរងគ្រោះដែលស្លាប់ទៅដោយអយុត្តិធម៌និងអ្នកដែលនៅរស់បានស្ងប់ក្នុងចិត្ត ។

**វ៉ែម សុខឃីម**

# ស្ដាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្ដីស្វែងរកការពិតដែលចាក់ផ្សាយរៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៣:៣០-៣:៤៥នាទី តាមរយៈវិទ្យុ FM១០២ MHz របស់មណ្ឌលពត៌មានស្ត្រីកម្ពុជា ។

មជ្ឈមណ្ឌលក៏បានបង្កើតកម្មវិធីដូចគ្នានេះផ្សាយតាមស្ថានីយ៍វិទ្យុ FM៩៣.២៥MHz ខេត្តកំពតជារៀងរាល់ថ្ងៃនៅម៉ោង៧-៧:៣០នាទីព្រឹក និងម៉ោង៧-៧:៣០នាទីល្ងាចនិងស្ថានីយ៍វិទ្យុ FM៩៩MHz ខេត្តព្រះវិហារ នៅម៉ោង៧-៧:៣០នាទីព្រឹក និងម៉ោង៦:៣០-៧នាទីល្ងាច ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងផ្សាយកម្មវិធីដូចគ្នានេះនៅគ្រប់បណ្ដាស្ថានីយ៍វិទ្យុខេត្តនៃព្រះរាជាណាចក្រកម្ពុជា ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។

**សូ ហ្វារីណា**

# មិនចង់សងសឹក ប៉ុន្តែចង់បានតុលាការ




យាយ ហង់ ស៊ីន កើតឆ្នាំជូត នៅភូមិត្រពាំងឈូក ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ ។ ឪពុករបស់គាត់ឈ្មោះ គង់ ជាគ្រូព្យាបាលជំងឺដោយឱសថបុរាណ ។ ម្តាយរបស់គាត់ឈ្មោះ ផង់ ។ កាល យាយស៊ីន នៅពីក្មេង ផ្ទះរបស់គាត់តែងតែមានភ្ញៀវជាប់ជាប្រចាំ គឺជាភ្ញៀវដែលមកព្យាបាលជំងឺនិងកូនសិស្សដែលមករៀនវិជ្ជានេះ ។ យាយស៊ីន បានរៀបការនៅអាយុ១៩ឆ្នាំ និងមានកូន៩នាក់ ។ កូនពីរនាក់បានស្លាប់តាំងពីនៅតូច ។ ប្តីរបស់គាត់ឈ្មោះ ជិល ទង ។

នៅឆ្នាំ១៩៦៩ យាយស៊ីន និងប្តី បានទៅទិញដីនៅក្រុងព្រះសីហនុចំនួន១២ហិកតាកន្លះ ហើយសមាជិកគ្រួសារមួយចំនួនបានទៅរស់នៅទីនោះ ។ យាយនិយាយថា «ទឹកឃើញថាដីខាងណោះវាសម្បូរ អនាគតកុំឲ្យកូនវាអត់ ក្រែងលោវាចង្អៀតទៅកូនបានអីស៊ី ។» ដីរបស់យាយនៅខាងកើតរោងចក្រប្រេងកាត ។ ក្រុមគ្រួសារយាយរស់នៅទីនោះប្រកបរបរដាំដំណាំនិងនេសាទ ។ ឆ្នាំ១៩៧០ ចរាចរណ៍រវាងខេត្តតាកែវនិងក្រុងកំពង់សោមត្រូវកាត់ផ្តាច់ ។ កូនស្រីទី៥ដែលមកលេងនឹងបងប្រុសទី១និងទី២នៅខេត្តតាកែវក៏ជាប់នៅទីនោះ ហើយក៏ដាច់ទំនាក់ទំនងពីក្រុមគ្រួសារនៅកំពង់សោម ។ នៅឆ្នាំ១៩៧១ ប្តីរបស់យាយត្រូវពស់ចឹកស្លាប់ក្នុងពេលដែលចូលព្រៃរកកាប់កូនឈើយកមកធ្វើលបក្តាម ។

នៅឆ្នាំ១៩៧៣ ដោយសារការប្រយុទ្ធរវាងខ្មែរក្រហមនិងលន់ ណុល មានសភាពកាន់តែខ្លាំងឡើងៗ ក្រុមគ្រួសាររបស់យាយបានភៀសខ្លួនចេញពីខាងកើតរោងចក្រប្រេងកាត មកនៅស្ពានលេខ៨វិញ ។ ពេលខ្មែរក្រហមដេញពីស្ពានលេខ៨រត់មកនៅរោងចក្រ ប៉េសេ បន្ទាប់មកនៅទំនប់រលក កាំពេញ ចុងក្រោយគឺទៅរស់នៅកោះពស់បានជាង១ឆ្នាំទើបត្រូវខ្មែរក្រហមជម្លៀសពីកោះពស់ទៅនៅភូមិទួល ឃុំទឹកល្អក់ ខេត្តកំពត ។ ក្រុមគ្រួសាររបស់យាយចាកចេញពីផ្ទះដោយមិនបានយកអីវ៉ាន់តាមខ្លួនច្រើនឡើយនិងចោលដំណាំគ្រប់ប្រភេទតាំងពី អំពៅ ដូងស្វាយ ក្រូច ត្របែក ចេក ទៀប និងបន្លែបង្ការគ្រប់មុខដែលកំពុងតែហុចផល ។ យាយស៊ីន រំឭកថា «ប្រាប់ថាបីថ្ងៃឲ្យចូលវិញ ដល់ហើយទៅរហូតចោលអីវ៉ាន់ពេញផ្ទះ គេប្រាប់ថាទុកនៅហ្នឹងហើយចាំគេមើលឲ្យ ។ ដល់ពាក់កណ្តាលផ្លូវគេអត់ឲ្យទៅ គេថាអង្គការអត់ឲ្យទៅនៅឯហ្នឹងគេថាថ្ងៃនេះថ្ងៃនោះ គេថាចាំធ្វើស្រែមួយវស្សាហើយគេឲ្យទៅ» ។

កូនដែលនៅជាមួយយាយនៅខេត្តកំពតមានតែកូនស្រីទី៣ព្រមទាំងប្តីនិងកូនកូនប្រុសទី៤ព្រមទាំងប្រពន្ធនិងកូន កូនប្រុសទី៦ដែលត្រូវបញ្ជូនទៅកងចល័តនិងកូនស្រីពៅដែលនៅកងកុមារ ។ យាយស៊ីន ត្រូវអង្គការចាត់តាំងឲ្យត្បាញក្រមានិងកន្ទេលរំចេក ។ សមាជិកគ្រួសារយាយទាំងអស់គ្នាធ្វើការងារនៅតាមកងផ្សេងៗគ្នា ប៉ុន្តែរស់នៅក្នុងភូមិជាមួយនិងហូបបាយនៅក្នុងរោងបាយតែមួយ លើកលែងតែកូនប្រុសទី៦ដែលត្រូវបញ្ជូនទៅធ្វើការឆ្ងាយមិនបានវិលត្រឡប់មកផ្ទះវិញ ។ អំពីការហូបចុក យាយស៊ីន បានឲ្យដឹងថា «ហូបឯកជនបានមួយឆ្នាំរកអីស៊ីគ្មាន ។ គេចែកអង្ករឲ្យម្នាក់ពីរកំប៉ុង យូរៗទៅចែកបានតែមួយកំប៉ុង អស់ពីមួយកំប៉ុងទៅកន្លះកំប៉ុង ។ ហូបរួមឆ្នាំ១៩៧៧ ខែ១ ថ្ងៃ១ ស៊ីទាល់តែងាប់អស់ទៅ ។ ជួនកាលវាឲ្យស៊ីផ្អែតទៅជួនកាលក៏អត់ផ្អែតទៅខែប្រាំងទៅបានហូបផ្អែត ខែវស្សាបានកន្លះចានម្នាក់អ៊ីចឹងទៅ ។»

នៅរដូវដកស្ទូងក្នុងឆ្នាំ១៩៧៧ កូនទី៣និងប្តីដែលជាអតីតវេជ្ជបណ្ឌិត ព្រមទាំងកូនតូចៗពីរនាក់ទៀត ត្រូវខ្មែរក្រហមយកទៅសម្លាប់ទាំងអស់ ដោយប្រាប់ថាស្នើឲ្យទៅរស់នៅភូមិថ្មី ។

យាយស៊ីន រៀបរាប់ថា «គេថាហក់ទៅ ចៅខ្ញុំអាតូចជាងគេអាយុជាង១ខួប ពុថាទៅរត់ទៅមុនម្ដាយ រត់ទៅលិច ទៅផ្ទះវិញ ។ ខ្ញុំតាមហៅថាកូនកុំទៅអីមកវិញ ។ ឲ្យស៊ីបាយស៊ីអីហើយវាយកទៅបាត់ ។» បូរ៉ា កូនស្រីពៅរបស់ យាយស៊ីន ដែលកាលណោះនៅកុមារនៅឡើយហើយជាអ្នកមើលក្មួយៗទាំងពីរនាក់ បានរំឭកថា «ខ្ញុំមើលវាពីរនាក់ហ្នឹង ម៉ែវាទៅធ្វើការ ។ ខ្ញុំនាំមីងក្មួយចងសន្ទូចដាក់បង្កៃក្បែរៗផ្ទះបានត្រីពីរ ។ ដល់ទៅហូបបាយហើយមកវិញដាក់ត្រាំសារាយប្រុងស្ងោរធ្វើញាំឲ្យក្មួយហូប ។ គេ(ខ្មែរក្រហម) មកប្រាប់ថាឥឡូវហ្នឹងគេសុំយើងយកទៅដូរភូមិ ដូរកន្លែង អ្នកធ្វើការគេយកទៅដាក់មួយកន្លែង ។ គេយកទាំងម៉ែឪកូនទៅទាំងអស់» ។

បូរ៉ា រៀបរាប់ទៀតថា «ដល់គេយកបងទីបីទៅបានប្រហែលមួយអាទិត្យគេមកយកបងប្រុសទីបួន ប៉ុន្តែគេអត់ថាយកទៅវៃចោលទេ គេថាយកទៅលើកទំនប់ទឹកប្រែហើយទៅបាត់រហូត» ។ យាយស៊ីន បន្តថា «គេយកទៅសម្លាប់អត់ដឹងខុសអី ។ មុនដំបូងខ្ញុំស្មានតែគេយកទៅធ្វើការមែន ដល់តែបាត់មួយយប់ ធ្លាប់តែទៅព្រឹកមកល្ងាច ដល់ល្ងាចក៏អត់មកពេលបាយថ្ងៃត្រង់ក៏អត់មក ពេលបាយល្ងាចក៏អត់មក ដល់យប់ក៏អត់មកទៀត បីបួនយប់ ដល់យូរៗទៅអត់ ឃើញមកខ្ញុំសួរគេថាយកកូនខ្ញុំទៅធ្វើការម៉េចអត់ឲ្យមកអីចឹង? មេកងមេក្រុមគេថាអ្ហឺយាយអើយកុំសង្ឃឹមពេក យាយឯងនិងខ្ញុំមុននិងក្រោយទេ ។ គេថាអស់សង្ឃឹមហើយមានតែងាប់ហើយ ។ ដល់មែនទែនទៅខ្ញុំបន់ឲ្យតែងាប់តាមកូនតាមចៅទៅជាស្អីក៏ទៅៗ ខ្ញុំអត់មានស្ដាយជីវិតអីត្រង់ណាបន្តិចទេ» ។

រំលងបានមួយឆ្នាំ កូនប្រុសទី៦ឈ្មោះ យ៉ា អាយុ១៨ឆ្នាំ ដែលធ្វើការនៅក្នុងកងចល័តយុវជនត្រូវខ្មែរក្រហមយកទៅសម្លាប់ទៀត ។ មុននេះមួយថ្ងៃ យាយស៊ីន បានជួប យ៉ា លុះដល់ស្អែកឡើងស្រាប់តែបាត់ យ៉ា ពីកន្លែងធ្វើការ ។ បើតាមសម្ដីរបស់ក្មួយប្រុសម្នាក់ដែលធ្វើការក្នុងកងជាមួយគ្នាបានឲ្យដឹងថា យ៉ា ត្រូវខ្មែរក្រហមនាំខ្លួនទៅនៅវេលាម៉ោង១០យប់ ។ នៅតាមផ្លូវ យ៉ា ខំស្រែកហៅម្ដាយៈ «ម៉ែអើយជួយកូនផង! គេយកកូនទៅហើយ» ។

ដើមខែមករា ឆ្នាំ១៩៧៩ ពេលដែលសភាពការណ៍ច្របូកច្របល់ខ្លាំង បូរ៉ា បានរត់មករកម្ដាយនៅកន្លែងត្បាញក្រមា ។ យាយស៊ីន នាំកូនចៅដែលសេសសល់ពីស្លាប់រត់ឡើងលើភ្នំ ប៉ុន្តែមិនទៅឆ្ងាយប៉ុន្មានទេ ។ ជារៀងរាល់ថ្ងៃ បូរ៉ា បានលបលួច



យាយស៊ីន និងកូនចៅរបស់គាត់

ត្រឡប់មកភូមិពីរនាក់បងថ្ងៃដើម្បីកិនស្រូវយកអង្ករទៅតាមបង្ការក្រែងខ្វះស្បៀង ។ នៅថ្ងៃទី៣ ពេលដែលបូរ៉ានិងប្រជាជនប្រមាណម្ភៃនាក់ទៀតកំពុងតែកិនស្រូវ កងទ័ពវៀតណាមក៏ចូលមកដល់ភូមិទួល ហើយបានឃាត់ប្រជាជនមិនឲ្យត្រឡប់ទៅលើភ្នំវិញ ។ ទាំងពីរភាគីមិនយល់គ្នាទៅវិញទៅមក ព្រោះកងទ័ពវៀតណាមមិនចេះភាសាខ្មែរ ។ លុះដល់វេលាយប់ មានក្រុមគ្រួសារមួយវិលត្រឡប់មកភូមិវិញ ហើយប្រពន្ធរបស់មេគ្រួសារនោះចេះភាសាវៀតណាម ។ កងទ័ពវៀតណាមបានប្រាប់ប្រជាជនថាកុំតក់អី ព្រោះកងទ័ពវៀតណាមមិនសម្លាប់ប្រជាជនទេ ហើយឲ្យទាំងអស់គ្នាទៅយកសាច់ញាតិដែលនៅលើភ្នំចុះមកវិញ ។ បូរ៉ាក៏ឡើងទៅលើភ្នំនាំម្ដាយនិងក្មួយចុះមកវិញ ។ ក្រុមគ្រួសាររបស់យាយស៊ឹន រស់នៅខេត្តកំពតបានបីខែ ចាប់បានគោក្របីមួយចំនួនទើបធ្វើដំណើរមកភូមិត្រពាំងឈូកខេត្តតាកែវ ដែលជាភូមិកំណើត ។ នៅតាមផ្លូវ យាយស៊ឹន បានជួបកូនប្រុសច្បងពីរនាក់ដែលកំពុងតែតាមរកម្ដាយនិងប្អូនដែរ ។ ទាំងអស់គ្នាមកដល់ភូមិកំណើតវិញនៅចុងឆ្នាំ១៩៧៩ ។ សមាជិកគ្រួសារបានជួបជុំគ្នាឡើងវិញ ប៉ុន្តែបាត់កូនស្រីទី៥ ដែលគ្មានដំណឹងរហូតដល់បច្ចុប្បន្ន ។

រហូតមកដល់ពេលនេះ បូរ៉ា បានរៀបការនិងមានកូន ៥នាក់ហើយ ប៉ុន្តែគាត់នៅតែនឹកដល់ក្មួយទាំងពីរនាក់មិនភ្លេច ។ បូរ៉ា ពោលថា «រាល់ថ្ងៃខ្ញុំនៅតែនឹកបងប្អូនណាស់ ជាពិសេសខ្ញុំនឹកក្មួយជាងគេ ។ គេ(ខ្មែរក្រហម)យកក្មួយទៅខ្ញុំអាណិតក្មួយណាស់ ។ ខ្ញុំចង់ឆ្កួត ។ ប្រាប់តាមត្រង់ ខ្ញុំមានកូនហើយក៏នៅតែនឹកក្មួយដែរ ស្រលាញ់កូនមិនស្មើនឹងស្រលាញ់ក្មួយទេ ខ្ញុំស្រលាញ់ក្មួយខ្ញុំណាស់» ។ ចំណែក យាយស៊ឹន រំឭកអំពីអារម្មណ៍របស់គាត់កាលពីរបបខ្មែរក្រហមថា «ម៉ែៗចង់សន្លប់បីដង ។ ដល់នឹកពេកទៅវារលេះរលួយដូចអត់មានវិញ្ញាណអស់មានស្មារតីអីបន្តិចសោះ ។ ដួសបាយមួយស្លាបព្រាលើកមកទើបនឹងដល់មាត់ដាក់ចុះទៅវិញ ដួសមកទៀតដាក់បានតែត្រឹមហ្នឹងអត់ចូលមាត់ទេ នឹកឃើញតែចៅ ។ នឹកកូននឹកចៅណាស់គ្មានថ្ងៃភ្លេចទេ បើថារលត់តែម្ដងទើបភ្លេច បើមិនទាន់រលត់ទេមិនភ្លេចទេ ។ កូនចៅកំពុងតែស្រលាញ់ពេញចិត្ត ។»

យាយស៊ឹន និង បូរ៉ា មិនព្រមទទួលយកសំណងជំងឺចិត្តណាមួយ ហើយក៏មិនចង់សងសឹកចំពោះអតីតកម្មាភិបាលខ្មែរក្រហមដែរ ប៉ុន្តែនេះមិនមានន័យថាគាត់បណ្ដោយឲ្យខ្មែរក្រហមរួចខ្លួននោះទេ ។ គាត់ចង់ឲ្យអតីតខ្មែរក្រហមទាំងនោះត្រូវតុលាការកាត់ទោសដើម្បីឲ្យសមនឹងអំពើដែលអ្នកទាំងនោះបានប្រព្រឹត្ត ។ បូរ៉ា និយាយថា «អ្វីក៏មិនស្មើនឹងជីវិតបងប្អូនដែរ ។ មិនអាចមានអ្វីមកលុបលាងការឈឺចាប់បានទេ ព្រោះអីមិនអាចយកអ្វីមកទិញទឹកចិត្តបាន ។ ទោះជាយ៉ាងណាក៏នៅតែនឹកឃើញ នៅតែអាឡោះអាល័យ ។ នឹកឃើញពេលណានៅតែស្ដាយ នៅតែស្រណោះ ។ បងប្អូនស្រីមានតែបីនាក់ឥឡូវនៅតែម្នាក់ឯង ។ ក្នុងចិត្តខ្ញុំមិនស្ងប់ទេ នៅតែនឹកឃើញអីចឹង ប៉ុន្តែខ្ញុំមិនចង់សងសឹក ព្រោះយើងកុំសងគំនុំឈាមនាំតែមានគំនុំតទៅមុខទៀត ។ យើងសងសឹកគេ គេសងសឹកយើង នៅតែមានកម្មពៀរទៅរហូត ។ ទោះជាសងសឹកក៏មិនបានអ្វីមកវិញដែរ ។ បើថាឲ្យអ្នកហ្នឹងឡើងតុលាការកាត់ទោសតាមច្បាប់ហ្នឹងខ្ញុំព្រម ប៉ុន្តែបើថាឲ្យខ្ញុំសងសឹក ដោយផ្ទាល់ដៃ យកអ្នកហ្នឹងមកឲ្យខ្ញុំសម្លាប់ធ្វើទារុណកម្ម ខ្ញុំធ្វើមិនបានទេ» ។

បច្ចុប្បន្ននេះ យាយស៊ឹន មិនសូវនឹករឭកកូនចៅខ្លាំងដូចពីមុនទៀតទេ ។ ធម៌ព្រះពុទ្ធបានជួយរម្ងាប់ចិត្តរបស់គាត់ឲ្យស្ងប់ ហើយពេលវេលាជួយឲ្យគាត់បំភ្លេចសោកនាដកម្មដែលបានកើតមកលើក្រុមគ្រួសាររបស់គាត់ ។ គាត់និយាយថា «រាល់ថ្ងៃខ្ញុំនឹកដែរ តែនឹកតិច ។ ឥឡូវលែងនឹកនាហើយ នឹកតែរៀនធម៌អាថ៌ ។ អត់មានអ្វីមកសងជីវិតកូនចៅបានទេ ។ ធ្វើម៉េចយើងវាហួសទៅហើយ ។ ខ្ញុំអត់សងសឹកទេ បាប ។ ទុកឲ្យគេ(អតីតខ្មែរក្រហម)ទទួលទៅយើងរួចខ្លួន ។ គេ(អតីតខ្មែរក្រហម)រស់នៅហ្នឹងមិនមែនថាមិនបាបទេ ។ ពេលណាដែលដល់កំណត់គេយកហើយរស់ក៏ដោយស្លាប់ក៏ដោយ ។ បើយកឡើងតុលាការអាហ្នឹងសងសឹកហើយ តែអត់បាបទេ ព្រោះអ្នកហ្នឹងអត់ទាន់ស្លាប់» ។

សព្វថ្ងៃ យាយស៊ឹន នៅសល់កូនបីនាក់ ។ គាត់រស់នៅភូមិត្រពាំងឈូកជាមួយ បូរ៉ា ដែលជាកូនពៅ ហើយចំណាយពេលវេលាស្ទើរតែទាំងអស់របស់គាត់ទៅវត្តរៀនធម៌និងភាវនា ដែលគាត់ជឿថាកុសលនៃទង្វើនោះនឹងជួយគាត់មិនឲ្យជួបទុក្ខវេទនានៅជាតិក្រោយទៀត ។ **សាន់ ភល្យាណ**

# តុលាការអន្តរជាតិលាតត្រដាងអំពីការកាត់ទោសដំបូងចំនួនបីនៅក្នុង "តុលាការពិសេសសម្រាប់ការរំលោភសិទ្ធិមនុស្សនៅទីម័រខាងកើត"

## *សេចក្តីសង្ខេប*

*ការកាត់សេចក្តី នៅក្នុងតុលាការពិសេសសម្រាប់ការរំលោភសិទ្ធិមនុស្សនៅទីម័រខាងកើតត្រូវបានរិះគន់យ៉ាងខ្លាំង ។ "កាត់សេចក្តីក្លែងក្លាយ" និង "កាត់សេចក្តីឲ្យតែបានៗ" គឺជាពាក្យដែលតែងតែប្រើប្រាស់ដើម្បីរិះគន់ ប៉ុន្តែមកទល់បច្ចុប្បន្នពុំទាន់មានការវាយតម្លៃឲ្យបានក្បោះក្បាយ ឬពន្យល់ឲ្យបានច្បាស់ ឬចងក្រងជាឯកសារ នូវដំណើរការកាត់ក្តីនៅឡើយទេ ។ អត្ថបទនេះជាការវាយតម្លៃទៅលើការកាត់សេចក្តីដំបូងចំនួនបីនៅក្នុងតុលាការ គឺការកាត់សេចក្តីទៅលើលោក អាប៊ីលីអូ ស័ររ៉េ អតីតអភិបាលទីម័រខាងកើត, ធីមប៊ុល ស៊ីឡែន អតីតមេប៉ូលិសទីម័រខាងកើត និងជនជាប់ចោទចំនួន៥រូបទៀតមកពីអង្គភាពយោធាប៉ូលិស និងរដ្ឋបាលស៊ីវិលដែលត្រូវបានចោទប្រកាន់ថា មានការទទួលខុសត្រូវចំពោះការសម្លាប់រង្គាលក្នុងវិហារមួយមានឈ្មោះសួយ ។ នៅឆ្នាំ២០០០ សហគមន៍អន្តរជាតិបានផ្តល់ឱកាសឲ្យប្រទេសឥណ្ឌូនេស៊ីកសាងកេរ្តិ៍ឈ្មោះឡើងវិញតាមរយៈការនាំឡើងតុលាការនូវជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះការបំផ្លិចបំផ្លាញទីម័រខាងកើតនៅក្នុងដំណើរការច្បាប់មួយដែលបំពេញតាមបទដ្ឋានអន្តរជាតិ ។ ប៉ុន្តែអត្ថបទនេះបានបង្ហាញថារឿងក្តីរបស់ អាប៊ីលីអូ ស័ររ៉េ, ធីមប៊ុល ស៊ីឡែន និងរឿងក្តីសម្លាប់រង្គាលក្នុងវិហារសួយ មិនត្រូវបានធ្វើឡើងតាមរបៀបមួយដែលស្របទៅតាមគោលដៅនៃការកាត់ទោសបុគ្គលទាំងឡាយដែលទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្សនៅកោះទីម័រខាងកើតទេ ។*

*បន្ទាប់ពីមានសម្ពាធដ៏ធ្ងន់ធ្ងរពីអន្តរជាតិ និងបន្ទាប់ពីមានការគំរាមបង្កើតតុលាការអន្តរជាតិមួយដើម្បីពិនិត្យទៅលើទង្វើរបស់ប្រទេសឥណ្ឌូនេស៊ីនៅទីម័រខាងកើត តុលាការពិសេសសម្រាប់ការរំលោភសិទ្ធិមនុស្សនៅទីម័រខាងកើតត្រូវបានបង្កើតឡើងនៅឯតុលាការថ្នាក់ខណ្ឌនាទីក្រុងហ្សាកាតានិងចាប់ផ្តើមដំណើរការនៅខែកុម្ភៈ ឆ្នាំ២០០២ ។ នេះគឺជាដំណើរការគ្មានពីរសម្រាប់ប្រទេសឥណ្ឌូនេស៊ីដែលគួរតែកែប្រែទាំងស្រុងនូវប្រព័ន្ធយុត្តិធម៌និងធម្មាធិបតេយ្យតាមរយៈការដាក់ឲ្យមានការទទួលខុសត្រូវលើឧក្រិដ្ឋកម្មដោយបុគ្គលដែលបានប្រព្រឹត្តនៅក្នុងប្រទេសឥណ្ឌូនេស៊ី ។ ប្រទេសឥណ្ឌូនេស៊ីធ្លាប់មានវិបត្តិដ៏ធំជាមួយនឹងភាពរួចទោសដែលចាស់ឫសគល់ពេញប្រទេស ។ នេះជាលើកទីមួយហើយដែលយោធា ប៉ូលិស និងជនស៊ីវិល ត្រូវបានកាត់ទោសជាសាធារណៈនៅចំពោះមុខចៅក្រមស៊ីវិលពីបទរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ។ ជនជាប់ចោទចំនួន១៨រូបត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងត្រូវកាត់សេចក្តីចំនួន១២លើក ។*

*ជនជាប់ចោទចំនួន៦រូបត្រូវបានរកឃើញថាមានពិរុទ្ធ ប៉ុន្តែអ្នកទាំង៦រូបនោះនៅតែមានសេរីភាពក្នុងអំឡុងពេលរង់ចាំការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការដាក់ទណ្ឌកម្ម ។ ទោះការដាក់ទណ្ឌកម្មជាអប្បបរមាចែងនៅក្នុងច្បាប់ពាក់ព័ន្ធ(ច្បាប់២៦/២០០០)ស្តីអំពីតុលាការសិទ្ធិមនុស្ស គឺរយៈពេល១០ឆ្នាំក្តី សាលក្រមដែលបានដាក់ចេញមានដូចតទៅ÷ សូចារ៉ូ អតីតមេបញ្ជាការយោធានៅឌីលីត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារចំនួន៥ឆ្នាំនិងត្រូវពិន័យជាប្រាក់ចំនួន៧ពាន់រូពី, ហាល់ម៉ាន់ ហ្គាល់តុម អតីតមេប៉ូលិសនៅឌីលីជាប់ពន្ធនាគារចំនួន៣ឆ្នាំ, ណូអឺរ មូអ៊ីស អតីតមេបញ្ជាការយោធាកោះទីម័រខាងកើតជាប់ពន្ធនាគារចំនួន៥ឆ្នាំ, អាដាំ ដាម៉ិរី អតីតមេបញ្ជាការយោធាតំបន់ជាប់ពន្ធនាគាររយៈពេល៣ឆ្នាំ, អាប៊ីលីអូ ស័ររ៉េ អតីតអភិបាលកោះទីម័រខាងកើត ជាប់ពន្ធនាគាររយៈពេល៣ឆ្នាំ និង យូរីកូ ហ្គុតតេរ៉េ អតីតមេដឹកនាំកងជីវពល*

ជាប់ពន្ធនាគាររយៈពេល១០ឆ្នាំ ។

ការវាយតម្លៃទៅលើការកាត់សេចក្តីដំបូងចំនួន៣មានបំណងពន្យល់អំពីដំណើរការរបស់តុលាការ ។ សហគមន៍អន្តរជាតិបានផ្តល់ឲ្យប្រទេសឥណ្ឌូនេស៊ីនូវឱកាសមួយដើម្បីនាំជនឥណ្ឌូនេស៊ីទាំងឡាយណាដែលទទួលខុសត្រូវក្នុងការបំផ្លិចបំផ្លាញទៅលើកោះទីម័រខាងកើតឡើងតុលាការមួយដែលបំពេញតាមបទដ្ឋានអន្តរជាតិ ។ អង្គការសង្កេតការណ៍សិទ្ធិមនុស្សបានប្រកាសថាតុលាការនេះជាតុលាការ«ឆបោក» ហើយបានស្នើឲ្យអង្គការសហប្រជាជាតិត្រួតពិនិត្យបរាជ័យរបស់តុលាការពិសេសនេះក្នុងការកាត់ទោសជនទាំងឡាយណាដែលមានការទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើហិង្សានៅទីម័រខាងកើត និងដើម្បីឲ្យតុលាការនេះកាត់សេចក្តីឲ្យបានត្រឹមត្រូវឡើងវិញ ។ អង្គការលើកលែងទោសអន្តរជាតិរិះគន់តុលាការនេះថា «មិនស្មោះត្រង់ មិនយុត្តិធម៌... ដល់ពេលដែលអង្គការសហប្រជាជាតិស្វែងរកជម្រើសថ្មីដើម្បីធានាឲ្យបានថា យុត្តិធម៌ត្រូវបានផ្តល់ជូនដោយដំណើរការកាត់ទោសដែលមានប្រសិទ្ធភាពនិងគួរឲ្យទុកចិត្តបាន» ។ ទោះបីជាបានដកចេញរឿងយុត្តិធម៌នៅទីម័រខាងកើតពីរបៀបវារៈ (ដោយមានការគាំទ្ររដ្ឋាភិបាលទីម័រ ឡិសស្ទី) ក៏គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិបញ្ជាក់ពី «ភាពអស់សង្ឃឹម» របស់ខ្លួនទាក់ទងទៅនឹងសកម្មភាពរបស់តុលាការ ។ សហរដ្ឋអាមេរិកក៏មិនសប្បាយចិត្តៈ «ប្រសិនបើពិនិត្យទៅលើរាល់រឿងក្តីទាំងអស់នៃតុលាការពិសេសនេះ ខ្ញុំគិតថាជាដំណើរការដ៏គួរឲ្យអស់សង្ឃឹមមួយទាក់ទងទៅនឹងការស្វែងរកយុត្តិធម៌ចំពោះអំពើឃោរឃៅនៅទីម័រខាងកើតប៉ុន្មានឆ្នាំមុន» ។ សហគមន៍អឺរ៉ុបបានលើកឡើងថា «តុលាការបានបរាជ័យក្នុងការផ្តល់យុត្តិធម៌ និងមិនបានរកឲ្យឃើញតាមផ្លូវច្បាប់នូវបទឧក្រិដ្ឋ» ។

អត្ថបទនេះត្រូវបានរៀបចំឡើងតាមរយៈការវិភាគដ៏ពិស្តារទៅលើរឿងក្តីរបស់ អាប៊ីលីអូ ស័ររ៉េ, ធីមប៊ុល ស៊ីឡែន និងជន៥រូបទៀតដែលជាប់ចោទពីបទសម្លាប់រង្គាលនៅក្នុងវិហារស្វួយ ។ ខ្ញុំ(អ្នកនិពន្ធ) បានតាមដានការកាត់ក្តីទាំងអស់នេះនៅឆ្នាំ២០០២ ។ ទោះបីជាយ៉ាងណា មុនពេលចាប់ផ្តើមវិភាគយើងចាំបាច់ត្រូវយល់អំពីប្រវត្តិនៃការបង្កើតតុលាការពិសេសនៅទីម័រខាងកើតនិងរឿងក្តីទាំងឡាយដែលតុលាការនេះបានទទួលយក ។

## ១) ប្រវត្តិនៃស្ថានការណ៍នៅទីម័រខាងកើត

នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៧៥ កងកម្លាំងប្រដាប់អាវុធរបស់សាធារណរដ្ឋឥណ្ឌូនេស៊ីបានឈ្លានពានទឹកដីទីម័រខាងកើត ហើយនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៧៦ ពាក់កណ្តាលខាងកើតនៃកោះទីម័រត្រូវបានប្រកាសថាជាខេត្តទី២៧របស់ប្រទេសឥណ្ឌូនេស៊ី ។ សហគមន៍អន្តរជាតិមួយភាគធំមិនដែលទទួលស្គាល់ភាពស្របច្បាប់នៃការបញ្ចូលទឹកដី និងវត្តមានរបស់ទាហានឥណ្ឌូនេស៊ីនៅលើកោះនេះទេ ។ ការត្រួតត្រាកោះទីម័រខាងកើតអស់រយៈពេល២៤ឆ្នាំរបស់ប្រទេសឥណ្ឌូនេស៊ីមានលក្ខណៈឃោរឃៅ ហើយប្រទេសឥណ្ឌូនេស៊ីត្រូវបានចោទប្រកាន់ជាញឹកញយពីការរៀបចំផែនការដាក់បញ្ជានិងប្រព្រឹត្តមិនត្រឹមតែបទឧក្រិដ្ឋសង្គ្រាម និងបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិប៉ុណ្ណោះទេ គឺថែមទាំងបទឧក្រិដ្ឋប្រល័យពូជសាសន៍ទៀតផង ។

ប្រទេសឥណ្ឌូនេស៊ីកាន់កាប់ទីម័រខាងកើតរហូតដល់ថ្ងៃទី២៥ ខែតុលាឆ្នាំ១៩៩៩ ជាពេលដែលកងកម្លាំងប្រដាប់អាវុធឥណ្ឌូនេស៊ីដកខ្លួនចេញក្រោយពីមានការធ្វើប្រជាមតិមួយដែលដឹកនាំដោយអង្គការសហប្រជាជាតិនៅថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៩ ។ នៅក្នុងការធ្វើប្រជាមតិនោះ ប្រជាជនទីម័រខាងកើត៧៨,៥ភាគរយបានគាំទ្រឲ្យមានឯករាជ្យភាពពីប្រទេសឥណ្ឌូនេស៊ី ។ មិនយូរប៉ុន្មានអំពើហិង្សាក៏កើតមានឡើង ។ ប៉ុន្មានម៉ោងក្រោយពីប្រកាសពីលទ្ធផល អំពើហិង្សាបានរីកដុះដាលយ៉ាងឆាប់រហ័សនៅទូទាំងទីម័រខាងកើត ក្នុងនោះមានមនុស្សឃាត ការចាប់ពង្រត់ ការរំលោភផ្លូវភេទ ការបំផ្លិចបំផ្លាញទ្រព្យសាធារណៈ ការលួចទ្រព្យសម្បត្តិ និងការដុតបំផ្លាញឧបករណ៍គ្រឿងបរិក្ខារយោធារដ្ឋនិងស៊ីវិល ។ ជនស៊ីវិលចំនួនប្រហែល២៥ម៉ឺននាក់ ត្រូវបានបង្ខំឲ្យចាកចេញពីផ្ទះសម្បែងទៅទីម័រខាងលិច ។ នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៩៩ កងកម្លាំងអន្តរជាតិហៅថា អ៊ីនធើហ្វេត ត្រូវបង្កើតឡើងដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិក្រោមសេចក្តីសម្រេចលេខ១២៦៤ (១៩៩៩) និងដឹកនាំដោយប្រទេសអូស្ត្រាលី ។ កងកម្លាំងអន្តរជាតិក៏បានសម្រួលឲ្យមានសណ្តាប់ធ្នាប់ឡើងវិញនៅទីម័រ

ខាងកើត ។ បច្ចុប្បន្នកោះទីម័រខាងកើតជារដ្ឋអធិបតេយ្យនិងឯករាជ្យមួយមានឈ្មោះថា "ទីម័រឡិសស្ទី" ។

អ្នកជំនាញការអង្គការសហប្រជាជាតិបានស៊ើបអង្កេតទៅលើស្ថានការណ៍នោះ ។ "គណៈកម្មការស៊ើបអង្កេតអន្តរជាតិ" និង"តំណាងពិសេស"ចំនួនបីរូបបានរាយការណ៍ថា បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិត្រូវបានប្រព្រឹត្តឡើង ដែលក្នុងនោះកងយោធានិងប៉ូលិសឥណ្ឌូនេស៊ីមានតួនាទីសំខាន់ ហើយកងជីវពលទីម័រខាងកើតជាអ្នកធ្វើសកម្មភាពដោយផ្ទាល់ ។ តាមការពិតអំពើហិង្សាត្រូវបានរកឃើញថាជាផ្នែកមួយនៃគោលនយោបាយជាប្រព័ន្ធរបស់សមាជិកនៃកងយោធាឥណ្ឌូនេស៊ី ហៅកាត់ថា ធីអិនអាយ និងរដ្ឋបាលស៊ីវិលដែលមានបំណងទប់ស្កាត់ប្រជាជនទីម័រខាងកើតមិនឲ្យចូលរួមនៅក្នុងការបោះឆ្នោតប្រជាមតិដោយសេរី និងក្រោយមកទៀតចំពោះការដាក់ទណ្ឌកម្មទៅលើអ្នកដែលបានបោះឆ្នោតគាំទ្រឯករាជ្យភាព ។ អង្គការស៊ើបអង្កេតអន្តរជាតិទាំងពីរក្រុមបានស្នើឲ្យមានការបង្កើតតុលាការអន្តរជាតិមួយដើម្បីកាត់ទោសជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះអំពើឃោរឃៅនៅទីម័រខាងកើតនៅឆ្នាំ១៩៩៩ ។ ផ្ទុយទៅវិញ សហគមន៍អន្តរជាតិបានដាក់ការជឿជាក់ទៅលើប្រទេសឥណ្ឌូនេស៊ីដែលបានសន្យាថានឹងកាត់ទោសទាហានប៉ូលិស និងជនស៊ីវិលទាំងឡាយណាដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មតាមរយៈតុលាការជាតិមួយ ។

## ២) គណៈកម្មការខេភីភីហាំ

ឆ្លើយតបទៅនឹងកំហឹងរបស់សហគមន៍អន្តរជាតិអំពីបញ្ហានៅទីម័រខាងកើត នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៩"គណៈកម្មការសិទ្ធិមនុស្សជាតិរបស់ប្រទេសឥណ្ឌូនេស៊ី" (កំណាស់ហាំ) បានបង្កើតគណៈកម្មការមួយគឺ ខេភីភីហាំ ដើម្បីស៊ើបអង្កេតទៅលើការរំលោភសិទ្ធិមនុស្សនៅទីម័រខាងកើត ។ ការងាររបស់ ខេភីភីហាំ គឺត្រូវស៊ើបអង្កេតទៅលើការរំលោភសិទ្ធិមនុស្សនៅទីម័រខាងកើតនៅឆ្នាំ១៩៩៩ ពិសេសការចូលរួមរបស់អង្គភាពខ្លះនៃប្រទេសឥណ្ឌូនេស៊ីនៅក្នុងការរំលោភបំពានបែបនោះ ។

ដោយធ្វើឲ្យអ្នករិះគន់ភ្ញាក់ផ្អើល ខេភីភីហាំ បានចេញនូវរបាយការណ៍ដ៏រឹងមាំមួយនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០០០ ។ របាយការណ៍នោះបញ្ជាក់អំពីវត្តមាននៃទំនាក់ទំនងដ៏ជិតស្និទ្ធរវាងអ៊ិនធីអាយ អង្គភាពប៉ូលិស រដ្ឋបាលស៊ីវិល និងកងជីវពលទីម័រខាងកើត ហើយបានលើកឡើងថា អំពើហិង្សាដែលបានកើតឡើងនៅទីម័រខាងកើតនៅឆ្នាំ១៩៩៩គឺជាលទ្ធផលនៃប្រតិបត្តិការជាខ្សែសង្វាក់មិនមែនបង្កឡើងដោយសង្គ្រាមស៊ីវិលនោះទេ ។ ការស៊ើបអង្កេតទៅលើអំពើហិង្សារបស់ ខេភីភីហាំ ដែលផ្តោតទៅលើការសម្លាប់រង្គាលជាច្រើនករណីបានរកឃើញភ័ស្តុតាងនៃការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ និងបន្ទាប់ពីបានវាយតម្លៃទៅលើភ័ស្តុតាងទាក់ទងនឹងការរៀបចំផែនការនិងការប្រព្រឹត្តបទឧក្រិដ្ឋជាខ្សែសង្វាក់ ខេភីភីហាំ បានបកស្រាយថា បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្តឡើងនៅទីម័រខាងកើត ។ បទឧក្រិដ្ឋនេះរួមមានការសម្លាប់ជាខ្សែសង្វាក់ក្នុងទ្រង់ទ្រាយធំនូវក្រុមមនុស្ស ការបំផ្លិចបំផ្លាញធំធេង ការដាក់ឲ្យធ្វើជាទាសករ ការបញ្ជូននិងបណ្តេញចេញពីលំនៅឋាន និងអំពើអមនុស្សធម៌ផ្សេងទៀតដែលបានធ្វើឡើងទៅលើជនស៊ីវិល ។

របាយការណ៍របស់ខេភីភីហាំមានភាពច្បាស់លាស់ ។ សមាជិករបស់ ធីអ៊ិនអាយ នគរបាល និងក្រុមកងជីវពលដែលត្រូវបានបង្កើតនិងបំពាក់បំប៉ន ជាអ្នកទទួលខុសត្រូវចំពោះអំពើហិង្សា ។ ខេភីភីហាំ កត់សម្គាល់ថា តួនាទីមន្ត្រីជាន់ខ្ពស់នៃធីអ៊ិនអាយ នៅក្នុងការបង្កើតក្រុមកងជីវពលប្រដាប់អាវុធ និងការទទួលខុសត្រូវផ្ទាល់របស់អតីតមេបញ្ជាការនៃកងកម្លាំងប្រដាប់អាវុធឥណ្ឌូនេស៊ី គឺឧត្តមសេនីយ៍ វីរ៉ាន់តូ ចំពោះបរាជ័យក្នុងការផ្តល់សន្តិសុខនៅទីម័រខាងកើតទោះបីជាប្រទេសឥណ្ឌូនេស៊ីបានប្រកាសជាអន្តរជាតិថាខ្ញុំការពារក៏ដោយ ។ អ្នកដែលត្រូវចោទប្រកាន់ថាបានទទួលខុសត្រូវ គឺជាអតីតអភិបាលទីម័រខាងកើតឈ្មោះ អាប៊ីលីអូ ស័ររ៉េ, អតីតមេបញ្ជាការកងទ័ពទីម័រខាងកើត, ឧត្តមសេនីយ៍ទទួលបន្ទុកកងពលតូច តូណូ សួរ៉ាត់ ម៉ាន់, អតីតមេបញ្ជាការយោធាតំបន់ឧត្តមសេនីយ៍ទោ អាដាំ ដាមីរី និងអតីតទីប្រឹក្សាសន្តិសុខ "ក្រុមការងារឥណ្ឌូនេស៊ី ដើម្បីអនុវត្តការប្រឹក្សាយោបល់នៅទីម័រខាងកើត" ឧត្តមសេនីយ៍ទោ ហ្សាក់គី ម៉ាការីម ។ សរុបទាំងអស់បុគ្គលចំនួន៣៣រូបត្រូវបានចោទប្រកាន់ ។

### ៣) ការិយាល័យអគ្គមេធាវី

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០០ អគ្គមេធាវីបានតែងតាំងក្រុមការងារមួយដែលមានសមាជិក៨៣រូបដើម្បីស៊ើបអង្កេតទៅលើអំពើឃោរឃៅនៅទីម័រខាងកើត ។ ការតែងតាំងនេះត្រូវបានរិះគន់ដោយសារសមាជិកនៃក្រុមការងារមួយចំនួនមានប្រភពមកពីកងប៉ូលិសនិងធីអិនអាយ ។ ក្រុមការងារនេះបានដឹកនាំដោយ អេចអិមអេ រ៉ាម៉ាន់ ដែលបច្ចុប្បន្នជាអគ្គមេធាវី ។ ការស៊ើបអង្កេតបានចាប់ផ្តើមឡើងតាមរយៈអនុក្រុមទៅលើរឿងក្តីមានអាទិភាពចំនួន៥ករណី ។ រឿងក្តីទាំងនោះគឺៈ

◆ ការសម្លាប់រង្គាលនៅវិហារ ចាវ ប្រីគតូ នៅថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩

◆ ការវាយប្រហារទៅលើគេហដ្ឋានមេដឹកនាំគាំទ្រឯករាជ្យឈ្មោះ ម៉ានូអែល ការ៉ាស់ស្កាឡូ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៩

◆ការវាយប្រហារទៅលើគេហដ្ឋានរបស់អាចារ្យ បែលឡូ នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៩៩

◆ការសម្លាប់រង្គាលនៅព្រះវិហារ អេវ ម៉ារិយ៉ាសួយ នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៩៩ និង

◆ឃាតកម្មទៅលើអ្នកសារព័ត៌មានហុល្លង់ សាន់ដឺរ ថូអិន នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៩

នៅខែ កញ្ញា ឆ្នាំ២០០០អ្នកស៊ើបអង្កេតមកពីការិយាល័យអគ្គមេធាវីបានទៅធ្វើទស្សនកិច្ចនៅទីម័រខាងកើតអស់រយៈពេល ៣សប្តាហ៍ ក្រោយពីមានអនុស្សរណៈនៃការយល់ដឹងទៅលើសហប្រតិបត្តិការផ្នែកច្បាប់ តុលាការ និងកិច្ចការសិទ្ធិមនុស្សដែលបានយល់ព្រមជាមួយនឹង«រដ្ឋបាលបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិ» ។ ដោយមានកិច្ចសហការរបស់អង្គការសហប្រជាជាតិ ក្រុមអ្នកស៊ើបអង្កេតអាចចូលជួបជាមួយជនរងគ្រោះនិងសាក្សីជាច្រើនដែលបានដឹងឮអំពីរឿងក្តីទាំងប្រាំនិងអាចនាំអ្នកស៊ើបអង្កេតទៅពិនិត្យកន្លែងកើតហេតុ ។

នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០០ បុគ្គលចំនួន១៩រូបត្រូវបានកំណត់ថាជាជនសង្ស័យ ។ ក្នុងចំណោមនោះមាន ដាមីរី, ស័ររ៉េ, សួរ៉ាត់ម៉ាន់ និង ធីមប៊ុល ស៊ីឡែន។ វីរ៉ាន់តូ មិនត្រូវបានរាប់បញ្ចូលទេ ។ ហ្សាក់គី ម៉ាការីម ក៏មិនបានរាប់បញ្ចូលដែរ ។ នៅខែតុលា ឆ្នាំ២០០០ បុគ្គលចំនួនបីរូបទៀតត្រូវបានចោទប្រកាន់ ក្នុងនោះមាន យូរីកកូ ហ្គុតតេរ៉េ ម្នាក់ដែរ ។

ការចោទប្រកាន់ត្រូវបានរៀបចំឡើងនិងតម្កល់ទុករហូតដល់ចៅក្រមនៃតុលាការពិសេសទីម័រខាងកើតត្រូវបានតែងតាំងហើយចាប់ផ្តើមដំណើរការនៅខែកុម្ភៈ ឆ្នាំ២០០២ ។

### ៤) តុលាការពិសេសសម្រាប់ការរំលោភសិទ្ធិមនុស្សនៅទីម័រខាងកើត

ប្រទេសឥណ្ឌូនេស៊ីមិនដែលបង្ហាញអំពីចេតនាចង់បង្កើតដំណើរការទទួលខុសត្រូវផ្នែកច្បាប់ពិតប្រាកដមួយសម្រាប់ការបំផ្លិចបំផ្លាញទីម័រខាងកើតនិងការសម្លាប់មនុស្សជាច្រើននៅឆ្នាំ១៩៩៩ទេ ។ ការត្រួតពិនិត្យទៅលើទង្វើរបស់ប្រទេសនេះសម្រាប់រយៈពេល២៨ឆ្នាំមុនកាន់តែមិនអាចធ្វើបានទៀត ។ សម័យកំណែទម្រង់ក្រោមការដឹកនាំរបស់ ស៊ូហាតូ បានធ្វើឲ្យចុះខ្សោយ ប៉ុន្តែមិនបានផ្តួលរំលំកងកម្លាំងទាំងឡាយដែលជាប់ពាក់ព័ន្ធជាមួយនឹងរដ្ឋាភិបាល«របៀបថ្មី»ទេ ។ កងទ័ពនិងស្ថាប័នពាក់ព័ន្ធរក្សាបាននូវឥទ្ធិពលនយោបាយនិងសង្គមខ្ពស់ ប៉ុន្តែសម្ពាធអន្តរជាតិនៅតែមានទំហំធំធេង ។ ការគំរាមបង្កើតតុលាការអន្តរជាតិទាំងស្រុងគឺជាឧបករណ៍មានប្រសិទ្ធភាពបំផុតដែលប្រើប្រាស់ដោយក្រុមទាមទារយុត្តិធម៌ឲ្យប្រជាជន ទីម័រខាងកើត ។ កត្តាសំខាន់គាំទ្រដល់ការបង្កើតយន្តការទទួលខុសត្រូវមួយ គឺការព្យួរទុកនូវជំនួយយោធាពីសហរដ្ឋអាមេរិករង់ចាំការចេញសេចក្តីសម្រេចទាក់ទងទៅនឹងការរំលោភសិទ្ធិមនុស្សនៅខែកញ្ញាឆ្នាំ ១៩៩៩ ។

នៅក្រោមច្បាប់ប្រទេសឥណ្ឌូនេស៊ី (ច្បាប់២៦/២០០០) ស្តីអំពីតុលាការសិទ្ធិមនុស្សប្រកាសជាធរមាននៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០០ ការរំលោភសិទ្ធិមនុស្សដែលបានប្រព្រឹត្តឡើងមុនពេលច្បាប់នេះមានប្រសិទ្ធភាពអាចកាត់ទោសបានតែនៅក្នុងតុលាការសិទ្ធិមនុស្សពិសេសបង្កើតឡើងដោយក្រឹត្យប្រធានាធិបតីបន្ទាប់ពីមានសំណើពីសភាឥណ្ឌូនេស៊ី ។ ទោះជាមានដែនសមត្ថកិច្ចត្រឹមអ្វីដែលបានកើតឡើងពីខែកញ្ញា ឆ្នាំ១៩៩៩ក៏ដោយ ក៏រឿងក្តីនៅទីម័រខាងកើតទាមទារឲ្យមានតុលាការ

ពិសេសដែរ ។ នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០០១ មុនការប្រជុំប្រចាំឆ្នាំរបស់គណៈកម្មការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ នៅទីក្រុងហ្សឺណែវ សភាប្រទេសឥណ្ឌូនេស៊ីបានស្នើទៅប្រធានាធិបតីថា តុលាការសិទ្ធិមនុស្សពិសេសមួយគួរតែបង្កើតឡើង ដើម្បីកាត់សេចក្តីទៅលើបទឧក្រិដ្ឋទាំងឡាយដែលបានកើតឡើង នៅទីម័រខាងកើតនៅឆ្នាំ១៩៩៩ និងដើម្បីដោះស្រាយការសម្លាប់រង្គាលទៅលើជនស៊ីវិល ដែលបានកើតឡើងនៅតំបន់កំពង់ផែតាន់ជុង ព្រីយ៉ុក នៅទីក្រុងហ្សាកាតាកាលពីឆ្នាំ១៩៨៤ ។ អ្នកនាំពាក្យបានទទួលស្គាល់ជាសាធារណៈថាបានធ្វើដូចនេះដើម្បីប្រឆាំងនឹងការចង់បានរបស់អន្តរជាតិ និងដើម្បីចៀសវាងការជ្រៀតជ្រែកពីអន្តរជាតិចំពោះការកាត់ទោសរឿងក្តីនៅទីម័រខាងកើត ។ គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានប្រជុំនៅទីក្រុងហ្សឺណែវនៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០០១ ហើយបានដាក់សម្ពាធទៅលើប្រទេសឥណ្ឌូនេស៊ី ។ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០១ ប្រធានគណៈកម្មការសិទ្ធិមនុស្សបានក្រើនរំឭកថា ប្រសិនបើប្រទេសឥណ្ឌូនេស៊ីមិនចាត់វិធានការឲ្យបានច្បាស់លាស់ដើម្បីកាត់ទោសមេដឹកនាំយោធានគរបាលនិងកងជីវពលដែលទទួលខុសត្រូវអំពើឃោរឃៅនៅទីម័រខាងកើតទេ អង្គការសហប្រជាជាតិអាចបង្កើតតុលាការអន្តរជាតិពិសេសមួយដើម្បីកាត់ទោស ។

ឆ្លើយតបទៅនឹងការដាក់សម្ពាធនេះ នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០១ ប្រធានាធិបតី វ៉ាហ៊ីត បានដាក់ចេញនូវក្រឹត្យច្បាប់មួយដើម្បីបង្កើតតុលាការសិទ្ធិមនុស្សពិសេស ។ សកម្មភាពនេះត្រូវបានស្វាគមន៍ពីដំបូង ប៉ុន្តែតាមការពិនិត្យឲ្យបានច្បាស់លាស់បង្ហាញថា តុលាការនេះត្រូវបានផ្តល់យុត្តាធិការកាត់ទោសតែរឿងក្តីដែលបានកើតឡើងក្រោយពីអនុស្សរណៈចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៩៩ប៉ុណ្ណោះ ។ នេះជាពេលមួយដែលអំពើប្រល័យពូជសាសន៍មួយភាគធំត្រូវបានធ្វើឡើងដោយកងជីវពលប្រដាប់អាវុធនិងហ្វឹកហាត់ដោយរដ្ឋាភិបាលឥណ្ឌូនេស៊ីមិនមែនអង្គភាពធីអ៊ិនអាយខ្លួនឯងទេ ។ ក្នុងចំណោមជនទាំងឡាយដែលគណៈកម្មការ ខេភីភីហាំ កត់សម្គាល់ថាជាជនសង្ស័យមាន ១២រូបមិនត្រូវបានរាប់បញ្ចូលទៅក្នុងរឿងក្តីសម្លាប់រង្គាលនៅវិហារ លីគ្វីកា នៅថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩, ការវាយប្រហារទៅលើគេហដ្ឋានមេដឹកនាំឯករាជ្យឈ្មោះ ម៉ារ្ញូអែល ការ៉ាស់ស្កាឡូនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៩,និងការវាយប្រហារធំៗទៅលើជនស៊ីវិលជាច្រើនករណីផ្សេងទៀតដែលបានកើតឡើងនៅរវាងខែមេសានិងខែកញ្ញា ។

ការិយាល័យអគ្គមេធាវីបានបោះបង់ចោលជាបន្ទាន់នូវករណីចំនួន៦ក្នុងចំណោម១៨ករណីដែលការិយាល័យនេះកំពុងស៊ើបអង្កេត ។ ក្នុងចំណោមរឿងក្តីដែលផាត់ចោលមានករណីឃាតកម្មទៅលើអ្នកសារពត៌មានរបស់ក្រុមហ៊ុនសារពត៌មានហូឡង់ឈ្មោះ សេនដឺរ ទ័ន ដោយយល់ថារឿងក្តីនេះមិនមានភស្តុតាងគ្រប់គ្រាន់ ។ នេះគឺជារឿងក្តីមួយដែលគណៈកម្មការ ខេភីភីហាំ រកឃើញថាមានជាប់ព័ន្ធនឹងសមាជិកនៃកងវរសេនាតូចលេខ៧៤៥របស់ធីអ៊ិនអាយ ។ សេចក្តីថ្លែងការណ៍មួយដែលធ្វើដោយអ្នកនាំពាក្យរបស់ការិយាល័យអគ្គមេធាវីបានចង្អុលបង្ហាញអំពីវិធីសាស្ត្រស៊ើបអង្កេតគួរឲ្យចាប់អារម្មណ៍មួយៈ «យើងកំពុងតែរង់ចាំភស្តុតាងនិងចម្លើយរបស់សាក្សី ។ ប្រសិនបើគ្មានកត្តាទាំងពីរនេះ តើឲ្យយើងទៅស៊ើបអង្កេតយ៉ាងម៉េច?» រឿងក្តីប្រឆាំងមេដឹកនាំកងជីវពលចំនួន៤រូបក៏ត្រូវបានលុបចោលដោយមូលហេតុថាអ្នកស៊ើបអង្កេតមិនអាចរកជនសង្ស័យឃើញ ។ អ៊ូលីវៀ ម៉ូរុក មេដឹកនាំដ៏ឃោរឃៅមួយរូបនៃកងជីវពលឡាក់សួរ ដែលបានវាយប្រហារទៅលើព្រះវិហារស្វាយនៅក្នុងខែកញ្ញា ឆ្នាំ១៩៩៩ ត្រូវលួចធ្វើឃាតប៉ុន្មានថ្ងៃក្រោយពីរបាយ-ការណ៍ខេភីភីហាំបញ្ជាក់ថា គាត់ជាជនសង្ស័យ ។ រឿងក្តីដែលបានបោះបង់ចោលមួយទៀតគឺ រឿងក្តីជនរួមជាតិរបស់ ម៉ូរុក នៅឡាក់សួរ មានឈ្មោះថា អ៊ីហ្គីដ្យូ ម៉ានិក ដែលល្បីឈ្មោះខាងចាប់ពង្រត់ រំលោភផ្លូវភេទ និងចាប់ធ្វើជាទាសករភេទ ។ គួរឲ្យចម្លែកណាស់ នៅពេលដែលការិយាល័យអគ្គមេធាវីប្រកាសថា មិនអាចរក ម៉ានិក ឃើញ ទាហានធីអ៊ិនអាយនៅទីម័រខាងកើតបែរជាអាចនាំ ម៉ានិក ទៅជួបជាមួយនឹងអ្នកយកពត៌មានបរទេសដើម្បីសម្ភាសនៅខែមេសា ឆ្នាំ២០០១ទៅវិញ ។

សកម្មភាពជាផ្លូវការទីមួយនៃប្រធានាធិបតីថ្មីរបស់ប្រទេសឥណ្ឌូនេស៊ី មេហ្គាវ៉ាទី ស៊ូកាណូពុទ្រី គឺការដាក់ចេញនូវ

ក្រឹត្យមួយដែលពង្រីកដែនអាជ្ញាយុកាលនៃតុលាការពិសេសសម្រាប់ការរំលោភសិទ្ធិមនុស្សនៅទីម័រខាងកើត ។ ក្រឹត្យថ្មីនេះបានកំណត់យ៉ាងច្បាស់លាស់នូវយុត្តាធិការតុលាការពិសេសឲ្យនៅត្រឹមរឿងក្តីរំលោភសិទ្ធិមនុស្សនៅទីម័រខាងកើតដែលបានកើតឡើងនៅខែមេសា ឆ្នាំ១៩៩៩ ។ ដូចក្រឹត្យមុនៗដែរ ក្រឹត្យចេញដោយប្រធានាធិបតី មេហ្គាវ៉ាទី ត្រូវបានស្វាគមន៍ថាជាដំណោះស្រាយថ្មី ប៉ុន្តែការវាយតម្លៃច្បាស់លាស់បញ្ជាក់ថាក្រឹត្យនេះក៏មិនគ្រប់គ្រាន់ដែរ ។ ក្រឹត្យនេះមិនបានធ្វើឲ្យមានយុត្តាធិការវវាង ខែមេសាទៅខែកញ្ញា ឆ្នាំ១៩៩៩ទេ គឺត្រឹមតែខែមេសា ឆ្នាំ១៩៩៩ប៉ុណ្ណោះ ។ យុត្តាធិការរបស់តុលាការពិសេសត្រូវបានកំណត់ឲ្យគ្របដណ្តប់ត្រឹមតែរឿងហេតុទាំងឡាយដែលបានកើតឡើងនៅ ឌីលី សួយ និង លីគ្វីកា ។ យុត្តាធិការនេះមិនបានរាប់បញ្ចូលការរំលោភសិទ្ធិមនុស្សធំៗនៅក្នុងតំបន់ពិសេសតំបន់ អូគូស៊ី ម៉ាលៀនណា និង សាមឡើយ ។ ហេតុនេះ ការងាររបស់ការិយាល័យអគ្គមេធាវីមានកម្រិតត្រឹមតែរឿងក្តី៤ ប៉ុណ្ណោះគឺ ការសម្លាប់រង្គាលនៅវិហារចាវប្រឹតតូ នៅថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩, ការវាយប្រហារទៅលើគេហដ្ឋានអាចារ្យ កាឡុស បែលឡូ នៅឌីលី នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៩៩, ការវាយប្រហារទៅលើគេហដ្ឋានមេដឹកនាំគាំទ្រឯករាជ្យឈ្មោះ ម៉ានូអែល ការ៉ាស់ស្កាឡូ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៩, និងការសម្លាប់រង្គាលនៅវិហារសួយ នាថ្ងៃទី៦ ខែកញ្ញា ឆ្នាំ ១៩៩៩ ។

ពីខែសីហាដល់ខែធ្នូ ឆ្នាំ២០០១ ហេតុផលមិនរឹងមាំជាច្រើនត្រូវបានប្រើប្រាស់សម្រាប់ការពន្យារពេលក្នុងការបង្កើតតុលាការ ។ កាលប្រវត្តិជាបន្តបន្ទាប់នឹងបង្ហាញអំពីកិច្ចខំប្រឹងទប់ស្កាត់ការបង្កើតឲ្យមានតុលាការពិសេសនេះ ។ ដំណើរការជ្រើសរើសមានភាពសម្ងាត់ ហើយព័ត៌មានគួរឲ្យភ័ន្តច្រឡំជាច្រើនត្រូវបានដាក់ចេញដោយជនដែលជាប់ពាក់ព័ន្ធនៅក្នុងដំណើរការជ្រើសរើស ។ សង្គមស៊ីវិលបានទទួលការអនុញ្ញាតឲ្យបញ្ចេញយោបល់ចំពោះបុគ្គលដែលត្រូវបានពិចារណាថាជាចៅក្រមទេ ។ នៅខែមិថុនា ឆ្នាំ២០០១ ប្រធានផ្នែកយុត្តិធម៌របស់ប្រទេសឥណ្ឌូនេស៊ី បាហ្គៀរ ម៉ាណាន់ បានអះអាងថា មានបញ្ហាជ្រើសរើសចៅក្រមអាជីព៣០រូបទៀត ដែល“មានចំណេះដឹងជ្រៅជ្រះផ្នែកច្បាប់ជាតិនិងអន្តរជាតិ” មានន័យថា ការកាត់ទោសនឹងត្រូវពន្យាររហូតដល់រយៈពេល៤ខែទៀត(ខែកញ្ញា) ។ ម៉ាណាន់ បានពោលថា ដំណើរការកាត់ទោសនឹងត្រូវពន្យារពេលបន្ថែមទៀតបន្ទាប់ពីមានការជ្រើសរើសចៅក្រម ពីព្រោះចៅក្រមដែលបានជ្រើសរើសរួច ចាំបាច់ត្រូវទទួលការហ្វឹកហ្វឺនបន្ថែមពិសេសអំពីផ្នែកច្បាប់ ។ កង្វះថវិកាក្នុងការជ្រើសរើសនិងការបង្កើតតុលាការកាន់តែធ្វើឲ្យរាំងស្ទះថែមទៀត ។ ក្រោយមកមានការពន្យារពេលនៅក្នុងការស្វែងរកចៅក្រមដែលមានបទពិសោធន៍ក្នុងការកាត់ក្តីសិទ្ធិមនុស្ស ។ នៅខែកក្កដា ឆ្នាំ២០០១ ចៅក្រមចំនួន៣៥រូបត្រូវបានជ្រើសរើស ។ នៅខែសីហា ឆ្នាំ២០០១ កត្តាពន្យារពេលបានក្លាយទៅជាការស្វែងរកប្រធានចៅក្រមទៅវិញ ។ បន្ទាប់មក ការជ្រើសរើសចៅក្រមមិនមែនអាជីពបានធ្វើឲ្យអ្វីៗគាំងលែងដំណើរការ ។ នៅថ្ងៃទី៣ ខែតុលា ឆ្នាំ២០០១ រដ្ឋមន្ត្រីយុត្តិធម៌បានប្រកាសថា សភានឹងជ្រើសរើសចៅក្រមសម្រាប់តុលាការពិសេសនៅខែវិច្ឆិកា ឆ្នាំ២០០១ ហេតុនេះតុលាការពិសេសនឹងអាចចាប់ដំណើរការនៅខែធ្នូ ឆ្នាំ២០០១បាន ។ នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០១ សម្តីរបស់ប្រធានយុត្តិធម៌បានបង្ហាញថា នៅក្នុងរយៈពេល១០ថ្ងៃ ក្រុមដែលទទួលខុសត្រូវចំពោះការបង្កើតតុលាការពិសេសនឹងជ្រើសរើសរួចរាល់នូវចៅក្រមទាំងអស់ ហើយបញ្ជីឈ្មោះនឹងត្រូវផ្ញើជូនប្រធានាធិបតីដើម្បីចុះហត្ថលេខា ។ ក្នុងពេលជាមួយគ្នានោះ ចៅក្រមដែលទទួលខុសត្រូវផ្នែកជ្រើសរើសឈ្មោះ បិនហ្សាមីន ម៉ាំងគូឌីឡាហ្គា បានថ្លែងថា “នៅខែវិច្ឆិកា ក្រុមការងារនឹងប្រកាសឈ្មោះចៅក្រមចំនួន៦០រូប ទាំងចៅក្រមអាជីពនិងមិនមែនអាជីព ។ ចៅក្រមទាំងនេះនឹងឆ្លងកាត់ការហ្វឹកហាត់ផ្នែកតុលាការសិទ្ធិមនុស្សនៅថ្ងៃទី៦ ខែវិច្ឆិកា” ។

ផ្ទុយទៅវិញ ទាំងតុលាការទាំងចៅក្រមដែលស្ថាប័នយុត្តិធម៌បានសន្យាថានឹងបង្កើតនិងជ្រើសរើស មិនទាន់ចេញជារូបរាងនៅឡើយទេ ។ នៅខែធ្នូ ឆ្នាំ២០០១ ចៅក្រមមួយចំនួនត្រូវបានជ្រើសរើស ប៉ុន្តែត្រូវរង់ចាំការគាំទ្រពីប្រធានាធិបតីជាមុនសិន ។ រដ្ឋមន្ត្រីយុត្តិធម៌និងសិទ្ធិមនុស្សបានសន្យាថា ចៅក្រមថ្មីនឹងចាប់

ផ្ដើមធ្វើការងារក្រោយពីបានចូលរួមវគ្គសិក្សាចំនួន៦ថ្ងៃអំពីសិទ្ធិមនុស្ស ។ ចៅក្រមទាំងនេះនឹងត្រូវបញ្ជូនឲ្យធ្វើការងារនៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០១ ។ ផ្ទុយទៅវិញ ខែធ្នូជាខែដែលប្រទេសឥណ្ឌូនេស៊ីបានសន្យាចំពោះគណៈកម្មការប្រឆាំងនឹងការធ្វើទារុណកម្មថាតុលាការពិសេសនឹងត្រូវបង្កើតឡើង ។ ចៅក្រម ម៉ាំងគូឌីឡាហ្កា និងតុលាការកំពូល បានថ្លែងថា បញ្ជីឈ្មោះចៅក្រមត្រូវបានប្រគល់ឲ្យប្រធានាធិបតីរួចហើយ ប៉ុន្តែខុទ្ទកាល័យប្រធានាធិបតីបានបដិសេធ ។ ហេតុនេះ ការចាប់អារម្មណ៍បានវិលទៅរកប្រធានាធិបតី ។ សហគមន៍អន្តរជាតិត្រូវតែចងចាំការប្រកាសនៅរាល់ករណីដែលតុលាការមិនអាចត្រូវបានបង្កើតឡើង ពីព្រោះគ្មាននរណាពីងទុកថាមានថ្ងៃសម្រាកនៅក្នុងខែធ្នូទេ ។ ឆ្នាំនេះបានកន្លងទៅដោយគ្មានក្រឹត្យចេញពីប្រធានាធិបតីអំពីការតែងតាំងចៅក្រម និងគ្មានតុលាការសិទ្ធិមនុស្សអចិន្ត្រៃយ៍ ឬតុលាការពិសេសសម្រាប់ការរំលោភសិទ្ធិមនុស្សនៅទីម័រខាងកើត និងកំពង់ផែ ថាន់ជុង ព្រីយ៉ុក ទេ ។

នៅទីបំផុត ចៅក្រមទាំងអស់បានចូលកាន់មុខតំណែងនៅខែមករា ឆ្នាំ២០០២ ក្នុងនោះមានចៅក្រមអាជីពនិងសាស្ត្រា-ចារ្យផ្នែកច្បាប់មកពីមហាវិទ្យាល័យជាតិនានា ។ មានកង្វល់មួយចំនួនដែលគ្មាននរណាម្នាក់អើពើអំពីការជ្រើសរើសចៅក្រមជាពិសេសចៅក្រមមកពីមហាវិទ្យាល័យដែលពីមុនមកធ្លាប់បានផ្ដល់ប្រឹក្សាឲ្យកងយោធា និងចៅក្រមមួយរូបទៀតដែលធ្លាប់បានធ្វើជាចៅក្រមនៅទីម័រខាងកើតក្រោមការគ្រប់គ្រងរបស់ប្រទេសឥណ្ឌូនេស៊ី ។

នៅខែកុម្ភៈ ឆ្នាំ២០០២ ការចោទប្រកាន់ទីមួយត្រូវបានធ្វើឡើងនៅតុលាការពិសេស ។ ការកាត់ទោសបានចាប់ផ្ដើមនៅខែមីនា ។

## ៥) ការកាត់ទោសដំបូងចំនួនបីនៅក្នុងតុលាការពិសេស

### ក) អាប៊ីលីអូ ស័ររ៉េ

អាប៊ីលីអូ ស័ររ៉េ គឺជាអភិបាលចុងក្រោយរបស់ទីម័រខាងកើតមុនពេលដែលកោះនេះលែងជាខេត្តទី២៧របស់ប្រទេសឥណ្ឌូនេស៊ី ។ ស័ររ៉េ ត្រូវបានចោទប្រកាន់នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០២ ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ គឺអំពើឃាតកម្ម (មាត្រា៩) និងការវាយប្រហារ(មាត្រា៩) ។ ស័ររ៉េ ត្រូវបានចោទប្រកាន់យ៉ាងជាក់លាក់ពីការទទួលខុសត្រូវក្នុងការដាក់បញ្ជាទៅលើជនស៊ីវិលសម្រាប់ការបរាជ័យនិងសកម្មភាពកូនចៅរបស់គាត់ ពិសេសតំណាងទាំងពីរគឺ ឡេអូណិតតូ ម៉ាទីន នៅស្រុកលីគ្វីកា និង ហឺម៉ាន់ សេឌីយ៉ូណូ នៅស្រុកកូវ៉ាលីម៉ា ។ ជាងនេះទៅទៀត ស័ររ៉េ ក៏ត្រូវចោទប្រកាន់ថាទទួលខុសត្រូវក្នុងការដាក់បញ្ជាទៅលើមេបញ្ជាការរងនៃកងកម្លាំងគាំទ្រការធ្វើសមាហរណកម្ម (ភីភីអាយ) យូរីកូ ហ្គុតេគេ ក៏ដូចជាកងសន្តិសុខស្ម័គ្រចិត្ត ទាក់ទងទៅនឹងបទឧក្រិដ្ឋធំចំនួន៥គឺការសម្លាប់រង្គាលនៅវិហារលីគ្វីកា ការសម្លាប់រង្គាលនៅគេហដ្ឋានរបស់ ម៉ានូអែល កាវ៉ាស្កាឡាវ នៅឌីលី, ការវាយប្រហារទៅលើឌីយ៉ូស៊ីស នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ១៩៩៩, ការវាយប្រហារទៅលើគេហដ្ឋានរបស់អាចារ្យបេឡូ នៅឌីលី និងការសម្លាប់រង្គាលនៅវិហារស្វៃយ ។ ការចោទប្រកាន់ត្រូវបានធ្វើឡើងដោយផ្អែកទៅលើទ្រឹស្តីនៃការទទួលខុសត្រូវចំពោះការដាក់បញ្ជាលើជនស៊ីវិលនៅក្រោមមាត្រា៤២(២) នៃច្បាប់២៦/២០០០ ។ ការចោទប្រកាន់នេះគឺៈ

*មេដឹកនាំកងនគរបាលនិងជនស៊ីវិលត្រូវទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្សក្នុងទ្រង់ទ្រាយធំធ្វើឡើងដោយអ្នកនៅក្រោមបង្គាប់របស់មេដឹកនាំទាំងនេះ ដែលកើតចេញមកពីបរាជ័យរបស់មេដឹកនាំក្នុងការគ្រប់គ្រងមិនបានត្រឹមត្រូវនិងមិនមានប្រសិទ្ធភាពទៅលើអ្នកនៅក្រោមបង្គាប់ដែលមានដូចតទៅៈ*

*មេដឹកនាំខាងលើដឹងឮ ឬមិនអើពើចំពោះពត៌មានដែលបញ្ជាក់យ៉ាងច្បាស់ថាអ្នកនៅក្រោមបង្គាប់កំពុងតែប្រព្រឹត្តឬទើបតែប្រព្រឹត្តការរំលោភសិទ្ធិមនុស្សក្នុងទ្រង់ទ្រាយធំ ។*

*មេដឹកនាំខាងលើមិនបានចាត់វិធានការតាមវិធីសាស្ត្រសមរម្យទៅតាមអំណាចដែលខ្លួនមាន ដូចជាទប់ស្កាត់ឬបញ្ឈប់សកម្មភាពបែបនោះ ឬប្រគល់ខ្លួនជនដៃដល់ទៅសួរនាំស៊ើបអង្កេតនិងកាត់ទោសតាមច្បាប់ ។*

នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០២ តុលាការកាត់ទោសអតីតអភិបាល ស័ររ៉េ ពីបទទាំងពីរខាងលើ ហើយដាក់ទណ្ឌកម្មឲ្យជាប់ពន្ធនាគារ៣ឆ្នាំ (ក្នុងខណៈដែលការដាក់ទណ្ឌកម្មទាបបំផុតគឺ ១០ឆ្នាំ) ។

### ៥) ធីមប៊ុល ស៊ីឡែន

មកដល់ថ្ងៃ៥ ខែឧសភា ឆ្នាំ១៩៩៩ ធីមប៊ុល ស៊ីឡែន ជាមេបញ្ជាការនគរបាលនៅទីម័រខាងកើត ។ ក្រោយពីនោះ ស៊ីឡែន ទទួលបន្ទុកផ្នែកប្រតិបត្តិការសន្តិសុខនៅមុនពេលដាក់ចេញនូវអនុស្សរណៈ និងធ្វើជាមេបញ្ជាការប្រតិបត្តិការ ។ ស៊ីឡែន ត្រូវបានចោទប្រកាន់នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០២ ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិចំនួនពីរ អំពើឃាតកម្ម តាមមាត្រាទី៩(១) នៃច្បាប់២៦/២០០០ និងការវាយប្រហារ(តាមមាត្រាទី៩) ។ ស៊ីឡែន ត្រូវបានចោទប្រកាន់ពីការទទួលខុសត្រូវចំពោះការដាក់បញ្ជាលើជនស៊ីវិលនៅក្រោមមាត្រាទី៤២(២) ។

ធីមប៊ុល ស៊ីឡែន ត្រូវបានចោទប្រកាន់ថាជាអ្នកទទួលខុសត្រូវចំពោះសកម្មភាពរបស់អ្នកនៅក្រោមបង្គាប់ (មានមេប៉ូលិសនៅឌីលី លីគីកា និង សួយ) ទាក់ទងទៅនឹងការវាយប្រហារទៅលើវិហារលីគីកា នៅថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩, ការវាយប្រហារទៅលើគេហដ្ឋានរបស់ម៉ានូអែល កាវ៉ាស្កាឡូ នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៩៩, ការវាយប្រហារទៅលើ ឌីយូស៊ី នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ១៩៩៩, ការវាយប្រហារទៅលើគេហដ្ឋានរបស់អាចារ្យ បេឡូ នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៩៩, ការវាយប្រហារទៅលើវិហារសួយ នៅថ្ងៃទី៦ខែកញ្ញា ឆ្នាំ១៩៩៩ និងការវាយប្រហារទៅលើការិយាល័យរបស់អង្គការសហប្រជាជាតិនៅលីគីកា នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៩៩ (ការវាយប្រហារនេះត្រូវបានរាប់បញ្ចូលនៅក្នុងចំណុចទីពីរនៃបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ប៉ុន្តែគ្មានភស្តុតាងគ្រប់គ្រាន់) ។

នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០២តុលាការបានប្រកាសថា ធីមប៊ុល ស៊ីឡែន មិនមានពិរុទ្ធភាពសម្រាប់រាល់ការចោទប្រកាន់ទាំងអស់ ។

### ក) ជនជាប់ចោទទាំងប្រាំរូបនៅក្នុងករណីសម្លាប់រង្គាលនៅវិហារសួយ

ជនជាប់ចោទនៅក្នុងករណីសម្លាប់រង្គាលនៅវិហារសួយគឺ វរសេនីយ៍ឯក ហឺម៉ាន់ ស៊ីឌីណូ, វរសេនីយ៍ឯក លីលៀក គូស្សាឌីយ៉ាន់តូ, អនុសេនីយ៍ឯក អាចម៉ាត់ ស៊ីយ៉ាមុសឌីន, អនុសេនីយ៍ទោ ស៊ូហ៊្គីតូ និងវរសេនីយ៍ឯក ហ្គាតូត ស៊ូប៊ីយ៉ាកតូរ៉ូ ។

ជនជាប់ចោទទាំងអស់ត្រូវបានចោទប្រកាន់នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០២ ពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ។ ការចោទប្រកាន់ត្រូវបានធ្វើឡើងដោយផ្អែកទៅលើការរួមផ្សំគ្នានៃផ្នែកផ្សេងៗក្នុងការទទួលខុសត្រូវ ដូចជា ការទទួលខុសត្រូវជាបុគ្គលនៅក្រោមមាត្រាទី៤១ ប្រព្រឹត្តិកម្ម (ដោយប្រយោល) ការទទួលខុសត្រូវចំពោះការដឹកនាំផ្នែកស៊ីវិល និងការទទួលខុសត្រូវចំពោះការដឹកនាំផ្នែកយោធា(មាត្រាទី៤២) ។ ការទទួលខុសត្រូវចំពោះការដឹកនាំផ្នែកយោធានៅក្រោមមាត្រាទី៤២ (១) នៃច្បាប់២៦/២០០០ដែលចែងថាៈ

មេបញ្ជាការយោធា ឬជនដែលមាននាទីជាមេបញ្ជាការនឹងត្រូវដាក់ឲ្យទទួលខុសត្រូវចំពោះរាល់ទង្វើឧក្រិដ្ឋកម្មនៅក្រោមយុត្តាធិការតុលាការសិទ្ធិមនុស្សដែលបទឧក្រិដ្ឋនេះធ្វើឡើងដោយកូនទាហាននៅក្រោមការដឹកនាំរបស់មេបញ្ជាការនោះ និងរាល់អំពើឧក្រិដ្ឋផ្សេងទៀតដែលជាលទ្ធផលនៃការដឹកនាំមិនត្រឹមត្រូវរបស់មេបញ្ជាការមានដូចតទៅៈ

- មេបញ្ជាការយោធាមួយរូប ឬជនដែលបានរៀបរាប់ខាងលើ ទទួលស្គាល់ ឬឋិតនៅក្រោមកាលៈទេសៈដាក់ស្តែងគួរតែទទួលស្គាល់ ទាហានទាំងនេះកំពុងប្រព្រឹត្តឬទើបតែបានប្រព្រឹត្តអំពើរំលោភសិទ្ធិមនុស្សក្នុងទ្រង់ទ្រាយធំ ។
- មេបញ្ជាការយោធាមួយរូប ឬជនដែលបានរៀបរាប់ខាងលើ មិនបានចាត់វិធានការឲ្យបានត្រឹមត្រូវទៅតាមអំណាចដែលខ្លួនមានដើម្បីការពារនិងបញ្ឈប់អំពើបែបនោះ ឬប្រគល់ខ្លួនជនដៃដល់ទៅឲ្យស្ថាប័នផ្សេងសួរចម្លើយ ស៊ើបអង្កេត និងកាត់ទោស ។

នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០២ តុលាការបានសម្រេចឲ្យជនទាំងប្រាំរូបរួចផុតពីការចោទប្រកាន់ទាំងអស់ ។

### ៦) ការចោទប្រកាន់

ការចោទប្រកាន់និងការលើកឡើងអំពីរឿងក្តីទាំងអស់បានទទួលឥទ្ធិពលពីការសរុបសេចក្តីរបស់អ្នកស៊ើបអង្កេតមកពីការិយាល័យអគ្គមេធាវីដែលថា បញ្ហានៅទីម័រខាងកើតបានបង្កឡើងដោយប្រជាជនក្នុងតំបន់ប្រយុទ្ធគ្នាទៅវិញទៅមកដែលថា អង្គការសហប្រជាជាតិបានបោកប្រាស់នៅក្នុងការធ្វើប្រជាមតិ

ហេតុនេះអំពើហិង្សាដែលបានផ្ទុះឡើងនៅខែកញ្ញាបណ្តាលមកអំពីកំហឹងដែលផ្ទុះចំពោះការបោកប្រាស់នោះព្រមជាមួយគ្នា ។ អ្នកស៊ើបអង្កេតបានសរុបសេចក្តីថា “មូលហេតុនៃឧបទ្ទវហេតុមុននិងក្រោយពេលធ្វើប្រជាមតិថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៩៩ គឺបណ្តាលមកពីជម្រើសសម្រាប់ឯករាជ្យភាពត្រូវបានផ្តល់ឲ្យ ហើយគ្មានការពិភាក្សាជាមួយអភិបាលខេត្តបានច្បាស់លាស់មុនពេលសម្រេចចិត្ត ហេតុនេះមិនអាចចាត់វិធានការបាន ។ ការិយាល័យអគ្គមេធាវីបានចោទប្រកាន់អភិបាលខេត្តពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ។ អនុស្សរណៈរបស់ខេភីភីហាំមិនមានសញ្ញាបង្ហាញពីឯកសារថា ការស៊ើបអង្កេតទៅលើការជម្លៀសប្រជាជនទីម័រខាងកើតចំនួន២៥ម៉ឺននាក់ ឬយុទ្ធនាការ“ដីក្តៅ” ត្រូវបានធ្វើឡើងទេ ។ គួរកត់សម្គាល់ថា ដោយសារដែនកំណត់នៅក្នុងច្បាប់២៦/២០០០ យុទ្ធនាការដីក្តៅនៅទីម័រខាងកើតមិនអាចយកទៅចោទប្រកាន់ថាជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិឬអំពើប្រល័យពូជសាសន៍បានទេ ថែមទាំងមិនអាចរាប់បញ្ចូលថាជាការគាបសង្កត់ទៀតផង ដោយសារច្បាប់២៦/២០០០ ប្រើប្រាស់ពាក្យ“វាយប្រហារ” ដើម្បីរៀបរាប់អ្វីដែលលក្ខន្តិកៈទីក្រុងរ៉ូមរាប់ថាជា “ការគាបសង្កត់” ។ ហេតុនេះមិនមានការចោទប្រកាន់ទាក់ទងទៅនឹងការរំលោភសិទ្ធិមនុស្សធំៗពីរនៅខែកញ្ញា ឆ្នាំ១៩៩៩ឡើយ ។

ប្រហែលជាមិនរាប់បញ្ចូលជនជាប់ចោទ ស៊ូហ៊ឺតូ នៅក្នុងករណីសម្លាប់រង្គាលនៅវិហារស្វួយទេ ។ ជនជាប់ចោទនៅក្នុងករណីខាងលើគឺជាមន្ត្រីមានឋានន្តរស័ក្តិកណ្តាលនៃក្រុមដែលខេភីភីហាំរៀបរាប់ថាបានធ្វើប្រត្តិបត្តិការដោយផ្ទាល់ នៅក្នុងការិយាធិបតេយ្យស៊ីវិល រួមមានអភិបាលស្តីទី អភិបាលខេត្ត មន្ត្រីប៉ូលិស និងយោធាក្នុងតំបន់ ។ ការិយាល័យអគ្គរដ្ឋអាជ្ញាអាចកសាងសំណុំរឿងប្រឆាំងនឹងជនដៃដល់ដោយផ្ទាល់ រួចប្រើប្រាស់ភ័ស្តុតាងដើម្បីកាត់ទោសមេដឹកនាំធំៗ ប៉ុន្តែការិយាល័យនេះបែរជាប្តឹងទល់នឹងក្រុមដែលមានឋានៈកណ្តាលជាមុនទៅវិញ ។ ដោយធ្វើដូច្នេះ និងតាមទម្រង់នៃការធ្វើសេចក្តីព្រាងដែលការិយាល័យនេះបានជ្រើសរើសសម្រាប់ការចោទប្រកាន់ ការិយាល័យនេះបានបង្កើតដោយខ្លួនឯងនូវបន្ទុកភ័ស្តុតាងជាច្រើនបែបគឺ ជនជាប់ចោទជាអ្នកដាក់បង្គាប់ឲ្យជនដែលប្រព្រឹត្តបទឧក្រិដ្ឋដោយផ្ទាល់ដៃ, ជនជាប់ចោទបានប្រព្រឹត្តបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ, ហើយជនជាប់ចោទជាអ្នកទទួលខុសត្រូវចំពោះបរាជ័យក្នុងការដាក់បញ្ជាឲ្យបានត្រឹមត្រូវទៅលើអ្នកក្រោមបង្គាប់ ។ ចំណុចសំខាន់គឺថា បរាជ័យនៅក្នុងថ្នាក់កណ្តាលនឹងមានផលជាអវិជ្ជមានចំពោះរឿងក្តីនៃមេដឹកនាំធំៗ ពីព្រោះវាកាត់ផ្តាច់ខ្សែរយៈរវាងជនដៃដល់ផ្ទាល់និងអ្នកធ្វើគោលនយោបាយ ។

ទោះជាការចោទប្រកាន់ផ្តោតសំខាន់ទៅលើបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិក្តី ក៏រាល់ការចោទប្រកាន់ទាំងអស់បានបង្ហាញពីស្ថានការណ៍ នៅខែមេសានិងកញ្ញា ឆ្នាំ១៩៩៩ដែលប្រជាជនទីម័រខាងកើតបានចូលរួមនៅក្នុងសកម្មភាពជម្លោះនិងកុបកម្មដោយមានការចូលរួមពីក្រុមទាហានមិនស្មោះត្រង់ គឺជាបណ្តុំនៃឧបទ្ទវហេតុធម្មតានិងភាពគ្មានទំនាក់ទំនងគ្នា ។ ការចោទប្រកាន់នេះបានបង្ហាញពីស្ថានភាពសង្គ្រាមស៊ីវិលមួយរវាងប្រជាជនទីម័រខាងកើតដោយមានឥណ្ឌូនេស៊ីជាភាគីកណ្តាលជួយបញ្ចប់ជម្លោះនិងការពារជនស៊ីវិល ។ ជាក់ស្តែងដូចនៅក្នុងករណីសម្លាប់រង្គាលនៅវិហារស្វួយ ដីកាចោទប្រកាន់បានចែងថា ក្រោយពីមានការធ្វើប្រជាមតិនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៩៩ “ស្ថានការណ៍ដ៏ក្តៅគគុកនិងជម្លោះបានកើតឡើងរវាងក្រុមដែលចាត់ទុកខ្លួនឯងថាជាអ្នកគាំទ្រសមាហរណកម្មនិងក្រុមចង់បំបែករដ្ឋ ដែលបណ្តាលឲ្យរដ្ឋាភិបាលប្រកាសអាសន្ននៅទីម័រខាងកើត” ។ ការរៀបរាប់ដូចគ្នាត្រូវបានសរសេរនៅក្នុងដីកាចោទប្រកាន់លើអាប៊ីលីអូ ស័ររ៉េ ដែលរៀបរាប់អំពី “ភាពជាសត្រូវ ជម្លោះ និងការមិនចុះសម្រុងគ្នារវាងក្រុមគាំទ្រសមាហរណកម្មនិងក្រុមគាំទ្រឯករាជ្យភាព” ។ ការចង្អុលបង្ហាញតែមួយគត់អំពី “ការបំពាក់បំប៉ន”ក្រុមកងជីវពលនៅក្នុងដីកាចោទប្រកាន់លើរឿងក្តីវិហារស្វួយ គឺមេឃុំស្តីទីនិងមេទាហានប្រចាំឃុំស្វួយដែលបានផ្តល់ថវិកានិងហ្វឹកហាត់ក្រុមកងជីវពល ប៉ុន្តែមិនមានការចោទប្រកាន់អំពីរឿងនេះទេ ។ ការលើកឡើងបែបនេះផ្ទុយទាំងស្រុងទៅនឹងការរកឃើញរបស់ខេភីភីហាំ និងរបាយការណ៍របស់អង្គការសហប្រជាជាតិទាំងពីរដែលថា បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិបាន

រាលដាលនិងត្រូវបានធ្វើឡើងជាខ្សែសង្វាក់លេចចេញផែនការដ៏ប្រុងប្រយ័ត្នរបស់បុគ្គលដែលមានឋានៈផ្សេងៗគ្នា ។ ខេភីភីហាំ បានបដិសេធទាំងស្រុងនូវហេតុផលសង្គ្រាមស៊ីវិល ។ ទាក់ទងទៅនឹងខបទ្ទុវហេតុនៅខែកញ្ញាឆ្នាំ១៩៩៩ ខេភីភីហាំ បានរកឃើញថាសមាជិករបស់ ធីអ៊ិនអាយ ប៉ូលិសនិងកងជីវពល គឺជាក្រុមសំខាន់ដែលទទួលខុសត្រូវចំពោះយុទ្ធនាការនេះ ដែលទាក់ទងទៅនឹងការបង្កើតលក្ខខណ្ឌទាំងឡាយនិងជម្រើសនៃសកម្មភាពដែលបានប្រព្រឹត្តព្រមទាំងការកំណត់ពេលវេលានិងរៀបចំផែនការជម្លៀសប្រជាជន ។ ខេភីភីហាំ បានរកឃើញថា យុទ្ធនាការនេះត្រូវបានធ្វើឡើងដើម្បីពន្យល់ដល់សហគមន៍អន្តរជាតិថា លទ្ធផលនៃការធ្វើប្រជាមតិបានបណ្តាលឲ្យអស្ថិរភាពដូចដែលបានបង្ហាញដោយ“ការពិត” ដែលប្រជាជនទីម័រខាងកើតបានភៀសខ្លួនទៅទីម័រខាងលិចមិនចង់រស់នៅក្នុងទីម័រខាងកើតដែលមានឯករាជ្យ ។ ហេតុផលនេះមិនត្រូវបានលើកឡើងនៅក្នុងដីកាចោទប្រកាន់ដែលបានវិភាគនៅទីនេះឬរឿងក្តីផ្សេងទៀតទេ ។ ខេភីភីហាំ បានលាតត្រដាងទម្រង់នៃការឃុបឃិតគ្នាដ៏ធំនិងផែនការរួមពាក់ព័ន្ធទៅនឹងស្ថាប័នរដ្ឋនិងអាជ្ញាធរថ្នាក់ខ្ពស់នៅទីម័រខាងកើតនិងទីក្រុងហ្សាកាតា ដែលត្រូវបានបញ្ជូនចុះក្រោមតាមលំដាប់ថ្នាក់សម្រាប់អនុវត្តនៅតាមមូលដ្ឋាន ។ ក៏ប៉ុន្តែ ការិយាល័យអគ្គមេធាវីបានត្រៀមខ្លួនត្រឹមតែដើម្បីចោទប្រកាន់ថាអាជ្ញាធរស៊ីវិលថ្នាក់ខ្ពស់នៅទីម័រខាងកើតបានកោះហៅមន្ត្រីទាំងអស់និងប្រាប់ឲ្យរៀបចំខ្លួនសម្រាប់ការធ្វើប្រជាមតិប៉ុណ្ណោះ ក្រោយពីនោះមន្ត្រីទាំងអស់ត្រូវត្រឡប់ទៅកាន់ស្រុករបស់ខ្លួនដើម្បីរួចបង្កើតក្រុមសន្តិសុខស្ម័គ្រចិត្តក្នុងតំបន់ ។ ដោយមូលហេតុនេះនៅក្នុងឃុំសួយមានការប្រជុំនៅឯគេហដ្ឋានរបស់អភិបាលស្តីទីនៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៩៩ នៅពេលដែលមេដឹកនាំកងជីវពលបានជួបជាមួយជនជាប់ចោទចំនួន៣រូបក្នុងនោះមានអភិបាលស្តីទីឃុំសួយ មេបញ្ជាការប៉ូលិសប្រចាំឃុំសួយ និងមេទាហានប្រចាំឃុំ ។ ក្រោយពីនោះមក ក្រុមកងជីវពលបានបន្តដំណើរទៅវិហារអេវម៉ារីយ៉ាដើម្បីអនុវត្តការវាយប្រហារ ។ ទោះជាយ៉ាងនេះក៏ដោយមិនមានការចោទប្រកាន់ជាក់លាក់ផ្អែកទៅលើគោលបំណងតែមួយឬការឃុបឃិតគ្នា(ច្បាប់២៦/២០០០អនុញ្ញាតឲ្យមានការចោទប្រកាន់ផ្អែកទៅលើ “ការរៀបចំផែនការសម្ងាត់”) ដែលជាបទឧក្រិដ្ឋតាមរយៈការខកខានមិនប្រតិបត្តិតាមរយៈទ្រឹស្តីនៃការទទួលខុសត្រូវក្នុងការដឹកនាំ ។

ជាងនេះទៅទៀត ក្នុងចំណោមរឿងក្តីទាំងបី ជនជាប់ចោទដែល ខេភីភីហាំ រកឃើញថាជាជនដៃដល់ផ្ទាល់(ដូចជាអភិបាលស្តីទី ហើម៉ាន និងស៊ុគីតូ) មិនត្រូវបានចោទប្រកាន់ទៅតាមនោះទេ ។ ចំណែកជនដែលមានតួនាទីផ្ទាល់(ដូចជា ស៊ុយ៉ាម ស៊ុឌីន) ក៏មិនត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តដោយផ្ទាល់ដែរ ប៉ុន្តែបែរជាត្រូវចោទប្រកាន់អំពីទម្រង់តិចតួចនៃការទទួលខុសត្រូវរបស់បុគ្គលក្នុងការប៉ុនប៉ង រៀបចំគម្រោងឬការជួយឧបត្ថម្ភគាំទ្រការប្រព្រឹត្តបទឧក្រិដ្ឋកម្មនៅក្នុងដែនយុត្តាធិការទៅវិញ ។

ដីកាចោទប្រកាន់មិនបានឆ្លុះបញ្ចាំងអំពីទំហំនៃការរកឃើញរបស់ ខេភីភីហាំ អំពីទំនាក់ទំនងរវាងធីអ៊ិនអាយប៉ូលិសការិយាធិបតេយ្យរបស់រដ្ឋាភិបាលនិងក្រុមកងជីវពល ថែមទាំងមិនបានឆ្លុះបញ្ចាំងការរកឃើញថា អំពើហិង្សាដែលបានកើតឡើងនៅទីម័រខាងកើតមិនបានបង្កឡើងដោយសង្គ្រាមស៊ីវិលទេ ប៉ុន្តែជាលទ្ធផលនៃយុទ្ធនាការអំពើហិង្សាដែលរៀបចំឡើងជាខ្សែរយៈ ។ ទំនាក់ទំនងបែបនោះបង្កជាភ័ស្តុតាងសំខាន់ដែលបញ្ជាក់អំពីវត្តមាននៃគោលនយោបាយរបស់រដ្ឋមួយ ។ គោលនយោបាយរដ្ឋគឺជាកត្តាចម្បងនៃបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងត្រូវបានចាត់ទុកជាចំណុចពិសេសនៃបទឧក្រិដ្ឋអន្តរជាតិនេះ ។ ដើម្បីកាត់ទោសបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិនៅទីម័រខាងកើតឲ្យបានជោគជ័យ ច្បាប់អន្តរជាតិទាមទារឲ្យមានភ័ស្តុតាងច្បាស់លាស់ថាការវាយប្រហារទៅលើប្រជាជនស៊ីវិលគឺជាផ្នែកមួយនៃគោលនយោបាយរបស់រដ្ឋាភិបាលឥណ្ឌូនេស៊ីនិងគាំទ្រដោយរដ្ឋាភិបាលនេះ ឬយ៉ាងហោចណាស់រដ្ឋាភិបាលនេះ អត់ទ្រាំនឹងគោលនយោបាយនេះ ។ ដើម្បីឲ្យក្លាយជាខ្សែសង្វាក់ ការវាយប្រហារត្រូវតែបង្ហាញឲ្យឃើញថា “បានរៀបចំឡើងយ៉ាងត្រឹមត្រូវនិងធ្វើទៅតាមបែបបទមួយច្បាស់លាស់ផ្អែកទៅលើគោលនយោបាយរួមមួយ និងមានធនធានឯកជនឬរដ្ឋចូលរួមជាមួយ” ។ គោលនយោបាយនេះមិនត្រូវការឲ្យរៀបចំឡើងច្បាស់លាស់ទេ ឬក៏ត្រូវមានលក្ខណៈស្មើនឹងគោលនយោបាយពិតប្រាកដរបស់រដ្ឋមួយ ។

គោលនយោបាយនេះត្រូវធ្វើឲ្យទៅជាផ្លូវការនិងអាចទាញការសន្និដ្ឋានចេញពីអ្វីដែលបានកើតឡើង ។ ប្រសិនបើសកម្មភាពទាំងអស់បានកើតឡើងក្នុងលក្ខណៈរាលដាលនោះ គោលនយោបាយមួយអាចត្រូវបានបង្កើតឡើង ហើយទោះជាផ្លូវការឬមិនផ្លូវការក្តី ។ ខេភីភីហាំ បានរកឃើញភ័ស្តុតាងបែបនោះ និងបានប្រគល់ទៅឲ្យការិយាល័យអគ្គមេធាវី ប៉ុន្តែការិយាល័យនេះបានសម្រេចមិនប្រើប្រាស់ភ័ស្តុតាងនោះ ។ ហេតុនេះការកាត់ទោសត្រូវបានដាក់កម្រិតដោយដីកាចោទប្រកាន់ដែលមិនបានពន្យល់អំពីអ្វីឲ្យលើសពីបទឧក្រិដ្ឋសាមញ្ញនៅទីម័រខាងកើត និងមិនបានបង្ហាញពីគោលនយោបាយរបស់រដ្ឋ ។ អ្វីដែលប្រព្រឹត្តនៅក្នុងករណីទាំងអស់នេះគឺការមិនអើពើចំពោះបទឧក្រិដ្ឋការខកខានមិនប្រព្រឹត្តតាមច្បាប់ដូចជាការមិនបានចាត់វិធានការឬគ្រប់គ្រងអ្នកនៅក្រោមបង្គាប់ ។ នេះមិនមែនមានន័យថា គ្មានកំហុសអំពីការបង្កើតកងជីវពលទេ ។ ហឺម៉ាន់ សេឌីនណូ អភិបាលស្តីទីនៃស្រុកខូវ៉ាលីម៉ា បានបង្កើតកងកម្លាំងគាំទ្រការធ្វើសមាហរណកម្មនិងប្រមូលផ្តុំក្រុមអ្នកគាំទ្រការធ្វើសមាហរណកម្មនៅក្នុងពិធីសម្ពោធជាផ្លូវការមួយនៅស្រុកសួយ និងផ្តល់ប្រាក់ឈ្នួលដល់ក្រុមនេះដើម្បីឲ្យក្លាយជាផ្នែកមួយនៃកងកម្លាំងនៅសួយ ។ ទោះជាទើបតែបានទទួលមុខតំណែងប្រហែលមួយសប្តាហ៍នៅពេលដែលការវាយប្រហារទៅលើវិហារបានកើតឡើងក៏ដោយ ក៏មេបញ្ជាការរបស់ធីអិនអាយនៅសួយមានកំហុសពីបទផ្តល់ការហ្វឹកហាត់ឲ្យកងជីវពលជាមួយនឹងជនជាប់ចោទស៊ូគីតូ ។ ទោះជាបែបនេះក៏ដោយ ក៏បុគ្គលទាំងអស់មិនត្រូវបានតុលាការចោទប្រកាន់ពីអំពើទាំងអស់នេះដែរ ។

ដោយសារដីកាចោទប្រកាន់ត្រូវរៀបចំឡើងជាពិសេសគ្មានរឿងក្តីណាមួយបានផ្តល់ហេតុផលសម្រាប់ត្រួតពិនិត្យប្រតិបត្តិការផ្លូវការនិងមិនផ្លូវការផ្សេងៗនៅទីម័រខាងកើត ។ ការចាប់អារម្មណ៍ទាំងអស់ត្រូវបានប្រមូលទៅលើភាពមិនទាក់ទងគ្នានិងចំណុចពិស្តារតូចៗនៃខបទូវហេតុ ហើយគ្មានទំនាក់ទំនងអ្វីដែលអាចបង្កើតជារូបភាពធំបានឡើយ ។ ជាយូរមកហើយអង្គការក្រៅរដ្ឋាភិបាលបានចោទថាអំពើហិង្សានៅដើមខែមេសានៅក្នុងស្រុកលីគ្វីកាដែលនាំទៅរកការសម្លាប់រង្គាលនៅក្នុងវិហារគឺជាផ្នែកមួយនៃប្រតិបត្តិការយោធាដ៏ធំរបស់ធីអិនអាយដែលមានគោលបំណងលុបបំបាត់ចោលកម្លាំងបះបោរនៅទីម័រខាងកើតនិងអ្នកគាំទ្រក្រុមនេះ ។ គ្មានការស៊ើបអង្កេតករណីនោះទេ ឯរូបភាពដែលបានលេចឡើងគឺថា ប្រជាជនទីម័រខាងកើតបានប្រយុទ្ធគ្នាទៅវិញទៅមក ។ មនុស្សម្នាក់អាចគិតថា គោលបំណងសំខាន់របស់អ្នកស៊ើបអង្កេតទៅលើ ធីមប៊ុល ស៊ីឡែន គឺអំពីមូលហេតុដែលប៉ូលិសទីម័រខាងកើតខំប្រឹងជម្លៀសប្រជាជនរាប់សែននាក់ទៅទីម័រខាងលិចក្នុងទម្រង់មួយដែលមានរៀបចំផែនការច្បាស់លាស់ដោយមិនដោះស្រាយទៅនឹងបញ្ហាច្បាប់និងសណ្តាប់ធ្នាប់ដែលលេចចេញពីចលាចលដែលរំពឹងថានឹងកើតឡើងក្រោយពីធ្វើប្រជាមតិឡើយ ។ នេះមិនមែនជាការប្តឹងប្រឆាំងនឹងធីមប៊ុល ស៊ីឡែន ទេ ទោះបីជាផែនការរបស់ប៉ូលិសត្រូវបានបញ្ចូលទៅក្នុងឯកសារកាត់ទោសដែលផ្ញើទៅតុលាការរួចហើយក្តី ។ ទោះជាយ៉ាងណាក៏ដោយ គ្មាននរណាម្នាក់បានកត់សម្គាល់អំពីការពិតដ៏ចម្លែកដែលថា ទំព័រខាងមុខនៃផែនការនេះ តាមការពិតមានចំណងជើងថា «ការត្រួតត្រាសណ្តាប់ធ្នាប់និងសន្តិសុខសាធារណៈការជម្លៀសជនបរទេសនិងប្រជាជនឥណ្ឌូនេស៊ីក្រោយពីមានការធ្វើប្រជាមតិប្រជាជនទីម័រខាងកើត» ។ ផែនការទីពីរបង្កើតឡើងនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៩ (ផែនការដ៏ពិស្តាររបស់ប៉ូលិសសម្រាប់ការចាកចេញរបស់ប្រជាជនទៅទីម័រខាងលិច) បានទទួលការចាប់អារម្មណ៍តិចតួច ។ ឯប្រតិបត្តិការរបស់ធីអិនអាយ មិនត្រូវបានរៀបរាប់នៅក្នុងដីកាចោទប្រកាន់ទេ ។

នៅក្នុងពាក្យប្រតិបត្តិការធីអិនអាយស្តាប់ទៅហាក់ដូចជាចម្លែកនៅត្រង់ថាពាក្យ «កាប៊ុត» មានន័យថា «ដកចេញឬដកថយ» ហើយក៏ដូចជាផែនការប្រតិបត្តិការទីមួយដែរ ។ ពាក្យបញ្ជាដំបូងត្រូវបានយកមកអនុវត្ត នៅពេលដែលប្រទេសឥណ្ឌូនេស៊ីមានបំណងផ្តោតការយកចិត្តទុកដាក់ទៅលើការធានាឲ្យប្រាកដថាសភាពការណ៍ច្បាប់និងសណ្តាប់ធ្នាប់មានលក្ខណៈអំណោយផលដល់ការធ្វើប្រជាមតិប្រកបដោយជោគជ័យជាជាងផ្តោតការយកចិត្តទុកដាក់ទៅលើហេតុការណ៍ដ៏ធ្ងន់ធ្ងរបំផុតក្នុងការជម្លៀសប្រជាជនភ្លាមៗ ។ ផែនការកាប៊ុតទីពីរគឺជាផែនការជម្លៀសប្រជាជនទាំងស្រុង ដែលត្រូវបានដាក់ចេញដោយខ្សែសង្វាក់

បញ្ហានៃប្រតិបត្តិការសន្តិសុខ ។ បញ្ហានេះចេញមកពីប៉ូលិសទៅឲ្យអន្តភាពយោធានៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ១៩៩៩ ។ វាហាក់ដូចជាមានការប៉ុនប៉ងដោយចេតនាដើម្បីគេចចេញមិនព្រមទប់ស្កាត់ផែនការនេះ ។ ផែនការ ហាណឹង ឡារូសើ និងកាប៉ិត មានជាប់ទាក់ទិននឹងគោលនយោបាយទ្រង់ទ្រាយធំនិងការទទួលខុសត្រូវរបស់បុគ្គលចំពោះឧក្រិដ្ឋកម្មរបស់ចារី ដែលការកាត់ទោសលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅទីម័រខាងកើតធ្វើឡើងសំដៅលាតត្រដាងគោលនយោបាយដែលមានលក្ខណៈទ្រង់ទ្រាយធំ ។ វាមិនខុសទេដែលថាការចោទប្រកាន់នេះមិនបានពិនិត្យពិច័យទៅលើផែនការប្រតិបត្តិការដែលគ្មានការពាក់ព័ន្ធ ហើយសំណួរដូចជាតើហេតុអ្វីបានជាកងកម្លាំងសន្តិសុខមិនបានចាប់អារម្មណ៍ទៅលើការស្តារច្បាប់និងសណ្តាប់ធ្នាប់ជាអត្តិភាព បែរជាធ្វើការជម្លៀសប្រជាជនទៅវិញនោះ មិនត្រូវបានចោទសួរឡើយ ។

ការចោទប្រកាន់ពីបទសម្លាប់រង្គាលនៅព្រះវិហារសួយ បានបង្ហាញយ៉ាងច្បាស់ ។ ដូចការចោទប្រកាន់ដទៃទៀតដែរ វាដូចរូបភាពនៃប្រជាជនទីម័រខាងកើតពីការប្រយុទ្ធគ្នាឯង ។ ការចោទប្រកាន់នេះគឺថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្តនៅព្រះវិហារសួយ ក៏ប៉ុន្តែត្រូវបានរាប់បញ្ចូលតែឧបទ្ទវហេតុតែមួយគត់គឺ ការវាយប្រហារកាលពីថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៩៩ ។ គ្មានការចោទប្រកាន់ណាមួយត្រូវបានធ្វើឡើងទាក់ទងទៅនឹងឧបទ្ទវហេតុផ្សេងៗនៅព្រះវិហារសួយ ដែលមានទម្រង់ជាភាគតូចមួយនៃការវាយប្រហារតាមបែបប្រព័ន្ធនិងរាលដាលប្រឆាំងជនស៊ីវិលនេះមិនទាន់គិតដល់ការជាប់ទាក់ទិនដល់ការវាយប្រហារបែបនេះទៅនឹងអ្វីដែលបានកើតឡើងនៅទីម័រខាងកើតទាំងមូល ។ រដ្ឋអាជ្ញាបានជ្រើសរើសអដ្ឋិធាតុជនរងគ្រោះចំនួន២៧ដែលបានរក្សាទុកយ៉ាងល្អ ហើយអដ្ឋិធាតុទាំងអស់នោះត្រូវបានរកឃើញដោយខេភីភីហាំនៅទីម័រខាងលិច ។ ក្រុមអ្នកស៊ើបអង្កេតបានត្រួតពិនិត្យបូជនីយដ្ឋានមួយនៅខាងក្រៅវិហារសួយកាលពីខែកក្កដាឆ្នាំ២០០០ ហើយបានរកឃើញថាមានថ្មមុខផ្នូរមានយ៉ាងហោចណាស់ចំនួន១០០ ដែលសមាជិកក្រុមគ្រួសារបានបញ្ចុះដើម្បីជាការរំឭកដល់អ្នកដែលបានស្លាប់នៅក្នុងការសម្លាប់រង្គាលនេះ ។ អគ្គរដ្ឋអាជ្ញានៅទីម័រខាងកើតត្រូវបានចោទប្រកាន់ទាក់ទងទៅនឹងការសម្លាប់រង្គាលចំនួន១០០ករណី ។ ការិយាល័យអគ្គមេធាវីខកខានមិនបានធ្វើការចោទប្រកាន់ទាក់ទងជាមួយនឹងអ្នកដែលទទួលរងរបួសជាច្រើននៅក្នុងការវាយប្រហារជនបទ ។

ខេភីភីហាំបានរៀបរាប់នៅក្នុងរបាយការណ៍របស់ខ្លួនស្តីអំពីសភាពការណ៍ក្រោយឆាកនៃអំពើហិង្សាដែលចេះតែកើនខ្លាំងឡើងៗនៅក្នុងស្រុកកូវ៉ាលីម៉ា ហើយជាពិសេសបានចុចឈ្មោះស៊ូគីតូ ថាជាមនុស្សម្នាក់ដែលបានចូលរួមនៅក្នុងការប្រព្រឹត្តបទឧក្រិដ្ឋកម្ម មុនពេលឧបទ្ទវហេតុនៅព្រះវិហារសួយកើតឡើង ។ មេបញ្ជាការយោធាឃុំសួយ និងទាហានស័ក្តិពីរ ស៊ូគីតូ បានចូលរួមនៅក្នុងការដុតបំផ្លាញនិងការលួចប្លន់ ។ ខេភីភីហាំ បានរកឃើញថា ស៊ូគីតូ និងអភិបាលស្តីទី បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការសម្លាប់រង្គាលនៅព្រះវិហារសួយ ។ គណៈកម្មការបានសន្និដ្ឋានថា "ការវាយប្រហារ (តាមរយៈឡាក់សូរ, ហើម៉ាន, ធីអិនអាយ និងក្រុមប៉ូលិស) មានការដឹកនាំបញ្ជាផ្ទាល់ពីប៊ូប៉ាទីអភិបាលស្តីទីនៅកូវ៉ាលីម៉ា, ហើម៉ាន សេឌីណូ មេបញ្ជាការយោធាឃុំសួយ, និងទាហានសក្តិពីរ ស៊ូគីតូ ។ ទោះជាយ៉ាងណាក៏ដោយ ការិយាល័យអគ្គមេធាវីយល់ថា ការចោទប្រកាន់បែបនោះមិនស័ក្តិសមទេ ហើយទាំង ស៊ូគីតូ និងអភិបាលស្តីទី មិនត្រូវបានចោទប្រកាន់ពីបទចូលរួមដោយផ្ទាល់ឡើយ ។ តាមពិតជនសង្ស័យ ស៊ូគីតូ គឺជាមន្ត្រីម្នាក់ស្ថិតនៅក្នុងចំណោមមន្ត្រីឥណ្ឌូនេស៊ីជាច្រើនទៀតដែលប្រធាន *UNAMET*មានបំណងដកតំណែង ដោយសារគាត់មានជាប់ពាក់ព័ន្ធជាមួយពួកកងជីវពលនិងអំពើហិង្សានៅក្នុងស្រុក ។ (ការពិតបែបនោះមិនត្រូវបានលើកយកមកសំអាងដើម្បីជាចំណែកមួយនៃរឿងក្តីប្រឆាំងស៊ូគីតូឡើយ) ។ អ្វីដែលតុលាការបានធ្វើនោះ គឺចោទប្រកាន់ ហើម៉ានជាអភិបាលស្តីទីថា គាត់មានវត្តមាននៅក្នុងព្រះវិហារ ឈរមើលនិងមិនបានចាត់វិធានការណាមួយទប់ស្កាត់ឬជួយជនស៊ីវិលដែលភ័យរន្ធត់និងរបួសឡើយ ។ តាមការពិតអភិបាលស្តីទី ហើម៉ានបានចាកចេញពីព្រះវិហារនៅពេលដែលការកាប់សម្លាប់កើតឡើង ។ ស៊ូគីតូ មិនត្រូវបានចោទប្រកាន់អំពីបទចូលរួមក្នុងការ

សម្លាប់នេះទេ ប៉ុន្តែត្រូវបានចោទប្រកាន់ពីបទនាំយកសាកសពចេញពីព្រះវិហារដោយមិនបានសហការឲ្យបានត្រឹមត្រូវជាមួយអាជ្ញាធរនិងពីបទមិនបានធ្វើកិច្ចការឲ្យបានគ្រប់គ្រាន់ដើម្បីរារាំងការវាយប្រហារនេះ ។

គួរកត់សម្គាល់ថា មន្ត្រីការិយាល័យអគ្គមេធាវីបានចោទប្រកាន់បន្ថែមចំពោះគ្រប់ជនសង្ស័យទាំងអស់ ដោយការសម្លាប់មនុស្សថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយផ្អែកលើមូលដ្ឋាននៃការចូលរួមដោយប្រយោលអនុលោមតាមមាត្រា៤១ ក៏មិនទាន់ច្បាស់លាស់នៅឡើយដែរ ។ ការចោទបែបនេះអាចត្រូវយកមកអនុវត្ត ឧទាហរណ៍ បើការសម្រេចចិត្តផ្នែកគោលនយោបាយចោទប្រកាន់ ស៊ូគីតូ ពីបទប្រព្រឹត្តផ្ទាល់ក៏ដោយ ក៏យ៉ាងហោចណាស់ ការនាំយកសាកសពចំនួន២៧ចេញពីកន្លែងប្រព្រឹត្តបទឧក្រិដ្ឋកម្មគួរតែត្រូវបានពិចារណាពីបទប៉ុនប៉ងបង្វែងដាននិងបំផ្លាញភស្តុតាង និងជួយសម្រួលដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ។ ការពិតទៅ ស៊ូគីតូ គ្រាន់តែត្រូវចោទពីបទទទួលខុសត្រូវខាងផ្នែកបញ្ជាមិនមែនពីបទជួយឧបត្ថម្ភគាំទ្រអំពើឧក្រិដ្ឋកម្មទេ ។ ហាក់ដូចជាមិនមានការចោទប្រកាន់បន្ថែមជាក់លាក់ទេ។ យោងតាមមាត្រាទី៤១ការចោទប្រកាន់ជាទូទៅគឺ ស៊ូគីតូ ខកខានមិនបានត្រៀមឬចាត់វិធានការទប់ស្កាត់ណាមួយដើម្បីដោះស្រាយសភាពការណ៍ឡើយ ។

នៅក្នុងការលុបចោលរឿងក្តីដ៏គួរឲ្យកត់សម្គាល់មួយទៀត អ្នកដើរតួនាទីជាគន្លឹះម្នាក់នៅវិហារសួយគឺមេបញ្ជាការយោធាឃុំសួយ វរសេនីយ៍ឯកកងទ័ពថ្មើរជើង១៦៣៥ អាក់ម៉ាត់ មាសាគុស មិនត្រូវបានចោទប្រកាន់ទេ ។ មាសាគុស បានទទួលបន្ទុកប្រតិបត្តិការយោធានៅឃុំសួយរហូតដល់មុនការធ្វើប្រជាមតិត្រូវបានរៀបចំឡើង ។ តាមពិត ប្រធាន*UNAMET*បានទាមទារឲ្យដក មាសាគុស ចេញពីតំណែងដោយសារថា មាសាគុស មានតួនាទីនៅក្នុងការគាំទ្រហ៊ីកហ៊ីន និងបំពាក់អាវុធឲ្យពួកកងជីវពលនៅសួយ ។ ជាលទ្ធផល មាសាគុស ត្រូវបានដកឲ្យទៅឈរជើងនៅទីក្រុងឌីលីការលោតគ្រដាងកាន់តែច្រើនឡើងថែមទៀតនោះ គឺគ្មានសមាជិកកងជីវពលណាម្នាក់ដែលចូលរួមនៅក្នុងការវាយប្រហារលើព្រះវិហារសួយត្រូវបាននាំយកទៅជំនុំជម្រះនៅចំពោះមុខតុលាការពិសេសទេ ។

គ្មានការចោទប្រកាន់ណាមួយក្នុងចំណោមការចោទប្រកាន់ទាំងបីខាងលើត្រូវភ្ជាប់ទៅនឹងឧបទ្ទវហេតុនៅទីក្រុងឌីលី, លីគីកា និងសួយឡើយ ហើយក៏គ្មានការចោទប្រកាន់ណាមួយត្រូវបានពិចារណាលើសភាពការណ៍ដែលបង្ហាញឲ្យឃើញពីការចោទប្រកាន់ជនសង្ស័យឬពីការអះអាងលើការវាយប្រហារចេតនាដោយមានផែនការទុកជាមុន រាលដាល និងតាមបែបប្រព័ន្ធទៅលើជនស៊ីវិលដែរ ។ ការចោទប្រកាន់តែមួយគត់ដែលនាំឡើងតុលាការនៅក្នុងរឿងក្តីនេះគឺពីបទសម្លាប់មនុស្សនិងការវាយប្រហារដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ គ្មានការចោទប្រកាន់ណាមួយចំពោះជនសង្ស័យពីបទទទួលខុសត្រូវចំពោះការជម្លៀសប្រជាជនចេញឬឧក្រិដ្ឋកម្មដ៏វិភេទដូចការរំលោភសេពសន្ថវៈជាដើម ។ ការកំណត់លើកាលបរិច្ឆេទនិងដែនដីដែលត្រូវបានដាក់ចេញដោយក្រឹត្យរបស់ មេហ្គាវ៉ាទី បានធ្វើការពន្យល់ហេតុផលដែលនាំឲ្យការចោទប្រកាន់មិនបានលើកអំពីហេតុការណ៍កើតឡើងនៅចន្លោះខែមេសានិងខែកញ្ញា ឆ្នាំ១៩៩៩ទេ ។ ទោះជាយ៉ាងណាក៏ដោយ ក្រឹត្យនោះមិនបានហាមឃាត់មិនឲ្យប្រើប្រាស់ឧបទ្ទវហេតុដែលកើតឡើងចន្លោះពេលនោះធ្វើជាភស្តុតាងនៃការវាយប្រហារដែលរាលដាលឬមានបែបជាប្រព័ន្ធឡើយ ហើយក៏មិនបានហាមមិនឲ្យប្រើប្រាស់ឧបទ្ទវហេតុហួសពីប្រាំករណី ដែលត្រូវបានប្រើជាប្រចាំសម្រាប់ទីក្រុងឌីលី, លីគីកា និងសួយ ។ ឧទាហរណ៍ នៅក្នុងរឿងក្តីជីមប៊ុលស៊ីឡែន ដែលជាអតីតមេប៉ូលិសនៅទីម័រខាងកើតអាចប្រើប្រាស់ក្នុងការរៀបចំកម្រោងសាជាថ្មីសម្រាប់ការចុះឈ្មោះបោះឆ្នោតដោយឈរលើហេតុផលសន្តិសុខ ដើម្បីធ្វើជាភស្តុតាងថាតើគាត់បរាជ័យក្នុងការកិច្ចរបស់គាត់យ៉ាងដូចម្តេច នៅក្នុងពេលនោះ ព្រមទាំងអាចប្រើឧបទ្ទវហេតុទាំងនោះភ្ជាប់ទៅនឹងខែមេសានិងកញ្ញាដើម្បីយកមកអះអាងលើការវាយប្រហារតាមបែបប្រព័ន្ធដែលរាលដាលប្រឆាំងជនស៊ីវិល ។ ស្រដៀងគ្នានេះដែរ ឧបទ្ទវហេតុផ្សេងៗទៀតនៅទីក្រុងឌីលី ក្រៅពីការវាយប្រហារលើទីតាំងនិងលំនៅដ្ឋានរបស់អាចារ្យបេឡូអាចត្រូវបានលើកឡើង ។

**(នៅមានត)** **ស៊ូហ្សាណា លីនតុន**





# ទារុណកម្មនៅមន្ទីរស-២១

## វិចិត្រករ វ៉ាន់ ណាត
## អតីតអ្នកទោសនៅមន្ទីរស-២១







# យោបល់ទៅលើសៀវភៅ "ការផ្សះផ្សានៅកម្ពុជា"

នៅក្នុងឆ្នាំ២០០២ មជ្ឈមណ្ឌលឯកសារកម្ពុជាបាន ធ្វើការស្ទាបស្ទង់មតិអ្នកអានទស្សនាវដ្ដី "ស្វែងរកការពិត" ដែលចេញផ្សាយជារៀងរាល់ខែ ដើម្បីប្រមូលទស្សនៈនានាស្ដី អំពីបញ្ហាយុត្តិធម៌ ការទទួលខុសត្រូវ និងការផ្សះផ្សានៅកម្ពុជា ទាក់ទងទៅនឹងអំពើរំលោភបំពានដែលប្រព្រឹត្តនៅក្រោមរបបខ្មែរក្រហមនៃកម្ពុជាប្រជាធិបតេយ្យនាទសវត្សរ៍ឆ្នាំ១៩៧០ ។ ស៊ូហ្សាណា លីនតុន បានយកលទ្ធផលនៃការស្ទាបស្ទង់មតិនេះ ទៅពិនិត្យមើលសាឡើងវិញ និងចាប់អារម្មណ៍ទៅលើភារកិច្ចលំបាកៗជាច្រើន ដែលប្រជាជនកម្ពុជាកំពុងប្រឈមមុខក្នុងខណៈដែលខ្លួនកំពុងស្វះស្វែងរកការជានាគ្នាឡើងវិញជាមួយនឹងភាពភ័យរន្ធត់ផ្ទាល់ខ្លួននិងជាសមូហភាពរបស់របបប្រល័យពូជសាសន៍កន្លងទៅ ។

ខ្ញុំជាមនុស្សម្នាក់ដែលមានប្រវត្តិធ្លាប់សិក្សាខាងសន្តិភាព និងការផ្សះផ្សាជាតិ និងជាបុគ្គលគ្មានបទពិសោធន៍អំពីបញ្ហាកម្ពុជា ប៉ុន្តែមានការចាប់អារម្មណ៍មកលើប្រទេសនេះ ។ ខ្ញុំមានចំណាប់អារម្មណ៍ទៅលើការសិក្សាជាន់ខ្ពស់គ្រប់ជ្រុងជ្រោយរបស់ លីនតុន ដែលបានផ្ដល់នូវសក្ខីកម្មបញ្ជាក់អំពីប្រភពជាច្រើនដែលគាត់យកមកប្រើប្រាស់ក្នុងការស្វះស្វែងរកឲ្យឃើញពីបទពិសោធន៍របស់ប្រជាជនកម្ពុជាក្នុងវិស័យទូលំទូលាយជាមុននូវការសិក្សាស្ដីពីយុត្តិធម៌អន្តរកាល ។ ខណៈដែលចម្លើយចំពោះការស្ទាបស្ទង់មតិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាអាចបម្រើជាគម្រូយសម្រាប់ការឆ្លុះបញ្ចាំង លីនតុន បានធ្វើសេចក្ដីវិភាគមួយចំនួនស្ដីអំពីថាតើរបបកាន់អំណាចបន្ទាប់ខុសៗគ្នាបានព្យាយាមដោះស្រាយយ៉ាងដូចម្ដេចខ្លះចំពោះកេរដំណែលនៃការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ ការបែកបាក់ និងការប៉ះទង្គិចផ្លូវចិត្តរួមដើម្បីជាប្រយោជន៍នៃសន្តិសហវិជ្ជមាននិងការផ្សះផ្សា ។

ក្នុងករណីជាច្រើន ដំណើរការផ្លូវច្បាប់និងប្រហាក់ប្រហែលផ្លូវច្បាប់ព្រមទាំងនីតិវិធីរបស់ស្ថាប័នផ្សេងៗទៀតពាក់ព័ន្ធទៅនឹងកម្មវិធីយុត្តិធម៌អន្តរកាលតែងតែត្រូវបានបង្កើតឡើងភ្លាមៗបន្ទាប់ពីរបបចាស់ដួលរលំទៅ ។ មានភាពខុសប្លែកគ្នាសម្រាប់ករណីប្រទេសកម្ពុជា ដែលការសិក្សាបែបនេះគួរតែបោះពុម្ពផ្សាយកាលពី២៥ឆ្នាំមុនបន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិតេយ្យ ។ ប្រការនេះបានឆ្លុះបញ្ចាំងឲ្យឃើញអំពីកង្វះខាតការរីកចម្រើនជាដុំកំភួនក្នុងការនាំយកជនដៃដល់នៃអំពើរំលោភបំពានឡើងតុលាការ ព្រមទាំងផ្ដល់សំណងដ៏ស័ក្ដិសមដល់ជនរងគ្រោះ ។

ការសិក្សាបានបង្ហាញថា កិច្ចខិតខំប្រឹងប្រែងដោយផ្ទាល់ពីសំណាក់រដ្ឋមួយចំនួនធំក្នុងការដោះស្រាយទៅនឹងកេរដំណែលនៃអំពើរំលោភបំពានពីអតីតកាល មានបីប្រភេទខុសគ្នាៗ÷ ការលើកលែងទោសនិងការកាត់ទោស និងគណៈកម្មការស្វែងរកការពិត ។ ដើម្បីឈានដល់កម្រិតមួយដ៏មានសារសំខាន់នោះ វិធីដោះស្រាយដែលប្រកាន់យកត្រូវតែឆ្លុះបញ្ចាំងអំពីផលប្រយោជន៍និងតុល្យភាពនៃអំណាចរបស់ភាគីរដ្ឋនិងមិនមែនរដ្ឋដែលពាក់ព័ន្ធនៅក្នុងអំឡុងពេលនៃដំណើរការអន្តរកាល ។ ជាធម្មតាការលើកលែងទោសត្រូវបានយកមកអនុវត្តដោយរបបកាន់អំណាចទាំងឡាយណាដែលឡើងកាន់អំណាចតាមរយៈដំណើរការចរចារវាងវរជនឆ្នើមៗដែលប្រកួតប្រជែងគ្នានៅក្នុងសភាពការណ៍មួយដែលអ្នកតំណាងខាងរបបចាស់អាចធ្វើការតស៊ូមតិប្រកបដោយជំនឿចិត្តជាមួយក្រុមនយោបាយថ្មី ប្រសិនបើមានការគំរាមកំហែងខាងទណ្ឌកម្មផ្លូវច្បាប់និងទណ្ឌកម្មដទៃទៀត ។ ផ្ទុយទៅវិញ ការកាត់ទោសអ្នកដែលត្រូវចាត់ទុកថាទទួលខុសត្រូវចំពោះការរំលោភបំពានពីអតីតកាល ជាទូទៅត្រូវបានយកមកអនុវត្តនៅពេលដែលរបបថ្មីជឿជាក់លើអំណាចនិងសមត្ថភាពរបស់ខ្លួនក្នុងការរកយុត្តិធម៌ ដោយមិនធ្វើឲ្យស្ថិរភាពនយោបាយនិងសង្គមមានគ្រោះថ្នាក់ឡើយ និងត្រូវបានជំរុញដោយមានការទាមទារជាសាធារណៈដ៏ច្រើនលើសលប់ឲ្យមានទណ្ឌកម្មបែប

នេះ ។ ជាធម្មតា លក្ខខណ្ឌនៃការដាក់ទោសទណ្ឌបែបនេះអាចធ្វើទៅបាននៅពេលដែលរបបថ្មីនោះបានឡើងកាន់អំណាចដោយសារតែមានជ័យជម្នះខាងប្រជាជនយ៉ាងលើសលប់ទៅលើអ្នកទាំងឡាយណាដែលជាមុខសញ្ញាសំខាន់សម្រាប់ការកាត់ទោស ។

ផ្ទុយទៅវិញ ការកាត់ទោសធ្វើឡើងសំដៅដាក់ទោសជនដៃដល់នៃអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជាជនខ្លួនឯង ។ ការព្រួយបារម្ភចម្បងដើម្បីដោះស្រាយការឈឺចាប់ពីអតីតកាល តាមគណៈកម្មការស្វែងរកការពិត គឺទាក់ទងផ្ទាល់ជាមួយជនរងគ្រោះ ។ គោលបំណងនេះ គឺត្រូវរកឲ្យឃើញអត្តសញ្ញាណជនដៃដល់ ទទួលស្គាល់ជនដៃដល់និងកំហុសដែលជននោះបានប្រព្រឹត្តមកលើជនរងគ្រោះ និងឈានទៅដល់ការសងជំងឺចិត្តសមស្រប ។ គំរូដែលទទួលស្គាល់ច្រើនបំផុតចំពោះវិធីដោះស្រាយនេះរួមមានការធ្វើអន្តរកាលឆ្ពោះទៅរកការគ្រប់គ្រងតាមបែបលទ្ធិប្រជាធិបតេយ្យ ក្រោយរបបយោធានៅប្រទេសអាហ្សង់ទីននិងប្រទេសឈីលី ព្រមទាំងការបង្កើតរបបក្រោយរបបអាប៉ាថេតនៅប្រទេសអាហ្វ្រិកខាងត្បូង ។ ជាទូទៅវាហាក់ដូចជាថា វិធីដោះស្រាយតាមរយៈគណៈកម្មការស្វែងរកការពិតបានទទួលការគាំទ្រពីសំណាក់របបដែលខ្វះសុឆន្ទៈឬខ្វះមធ្យោបាយ ដើម្បីចោទប្រកាន់ជនដៃដល់ប្រព្រឹត្តឧក្រិដ្ឋកម្មនយោបាយ ដោយសារប្រភពពាក់ព័ន្ធត្រូវគ្រប់គ្រងដោយអ្នកដែលនឹងអាចក្លាយទៅជាមុខសញ្ញាចម្បងរបស់គណៈកម្មការនេះ ។ វិធីដោះស្រាយរបស់គណៈកម្មការនេះក៏ទទួលបានការគាំទ្រពីសំណាក់របបដែលគោលនយោបាយ "លើកលែងទោសនិងបំភ្លេចចោល" មិនអាចធ្វើទៅបានដោយសារតែដម្រៅនៃការប្រេះឆានិងកម្រិតនៃភាពល្វីងជូរចត់នៅក្នុងសង្គម ។ ស្ថានភាពបែបនេះទំនងជាកើតមានច្រើននៅពេលរបបចាស់មួយត្រូវបានបណ្តេញចេញតាមរយៈការចរចាផ្ទេរអំណាចដែលធ្វើឲ្យមានកំហឹងនិងការមិនពេញចិត្តពីសាធារណជនដ៏ច្រើនលើសលប់ ដែលធ្វើឲ្យខូចដល់សមត្ថភាពរបស់រដ្ឋចាស់ក្នុងការដាក់ចេញនូវឆន្ទៈរបស់ខ្លួន ។

ទោះបីជាដំណោះស្រាយណាមួយត្រូវបានយកមកអនុវត្តក៏ដោយ ក៏គ្គីគន្លងចម្បងរបស់របបថ្មីគឺលើកកម្ពស់សណ្តាប់ធ្នាប់សង្គមដើម្បីធានាឲ្យមានសន្តិសុខនិងភាពស្របច្បាប់ ។ ដូច្នេះក្នុងករណីប្រទេសកម្ពុជាខ្វះការរីកចម្រើនជាដុំកំភួនខាងកម្មវិធីដ៏ស្អិតល្មួតនៃយុត្តិធម៌អន្តរកាលនិងការផ្សះផ្សាគឺដោយសារតែការប៉ះពាល់ទៅលើប្រយោជន៍វរជននយោបាយ ។ គោលនយោបាយសំខាន់នោះគឺសំដៅបញ្ចប់នូវការគំរាមកំហែងអំពើហិង្សាតាមវិធីនានាពីសំណាក់ខ្មែរក្រហមដោយមានការដាក់បញ្ចូលឥស្សរជនជាន់ខ្ពស់ទៅកាន់មុខតំណែងសំខាន់ៗរបស់របបថ្មី ។ តាមសម្តី លីនតុន "ការផ្សះផ្សានៅកម្ពុជាត្រូវបានវរជនទាំងនោះយកមកប្រើធ្វើជាផ្លាកដ៏សមគួរមួយសម្រាប់ការបែងចែកអំណាចដែលជាដំណោះស្រាយចំពោះការតស៊ូខាងនយោបាយ" ។

ការបញ្ចប់អំពើហិង្សាគឺជាធាតុដ៏សំខាន់នៃដែនការផ្សះផ្សាជាតិ ។ ជាអកុសលណាស់ដែលអត្ថិភាពនេះធ្វើឲ្យជនរងគ្រោះនៃអំពើរំលោភបំពានមានកំហឹងចំពោះអ្វីដែលខ្លួនចាត់ទុកថាជាការរួចទោសរបស់បណ្តាអ្នកទទួលខុសត្រូវចំពោះការឈឺចាប់នោះ និងធ្វើឲ្យជនរងគ្រោះមានកំហឹងចំពោះភាពគ្មានសំណងឲ្យបានសមស្រប ។ ភ័ស្តុតាងនៅប្រទេសអាហ្វ្រិកខាងត្បូងហាក់ដូចជាបង្ហាញឲ្យឃើញថា ជនរងគ្រោះជាច្រើនបានឆ្លងកាត់ដំណើរការស្វែងរកការពិតនិងការផ្សះផ្សាស្ទើរតែចាត់ទុកដំណើរការនេះថាជាការសម្តែងនៅលើឆាកសាធារណៈមួយដែលឆ្ងាយពីជីវិតនិងបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ ។ ទាំងនេះគឺជាការកិច្ចដ៏លំបាកដែលប្រជាជនកម្ពុជាបន្តប្រឈមមុខថាតើត្រូវបង្កើតកម្មវិធីយុត្តិធម៌អន្តរកាលដ៏ស្អិតល្មួតមួយដែលនឹងជំរុញឲ្យមានការផ្សះផ្សាមិនត្រឹមតែនៅថ្នាក់ជាតិសម្រាប់វរជននយោបាយប៉ុណ្ណោះទេ ក៏ប៉ុន្តែនៅថ្នាក់មូលដ្ឋានតាមភូមិ ឃុំ និងគ្រួសារ ជាទីកន្លែងដែលប្រជាជនជួបប្រទះការឈឺចាប់ដោយផ្ទាល់ក្នុងសម័យខ្មែរក្រហមនិងប្រកបដោយការឈឺចាប់ដែរ ។

ដោយផ្អែកលើការអង្កេតទៅលើអ្នកឆ្លើយសំណួរស្ទាបស្ទង់មតិ ការសិក្សារបស់ លីនតុន គឺជាការរកឲ្យឃើញអំពីថាតើដំណើរការនេះអាចនឹងវិវត្តទៅជាយ៉ាងម៉េច ។ លីនតុន បានលើកមកនិយាយនូវនិយមន័យតាមន័យត្រង់ថា÷

*ការផ្សះផ្សាទាក់ទិនទៅនឹងការរៀនពីរបៀបរួមរស់និង*

ធ្វើការជាមួយអ្នកដែលយើងមិនចូលចិត្ត ឬអ្នកដែលមិនចូលចិត្តយើង និងទាក់ទិនទៅនឹងការរួមរស់ជាមួយបទពិសោធន៍អវិជ្ជមានផ្ទាល់ខ្លួន ទោះជាអ្នកនោះជាជនរងគ្រោះឬក៏ជនដៃដល់ក៏ដោយ ។ ការផ្សះផ្សាជាដំណើរការមួយធ្វើឡើងគ្រាន់តែដើម្បីជួយប្រជាជននិងសង្គមជាតិទាំងមូលដើម្បីឲ្យអ្វីៗមានសភាពរស់រវើកឡើងវិញ ដូច្នេះមនុស្សទាំងអស់នឹងអាចមានជីវភាពដូចធម្មតា ។

លីនតុន បានបន្តក្នុងភាពប្រាកដនិយមថា គ្មានទិសថស័ក្តិសិទ្ធិណាមួយអាចនាំមកនូវមូលដ្ឋាននៃការជឿទុកចិត្តគ្នាជាអប្បបរមាដែលចាំបាច់សម្រាប់ប្រជាជនកម្ពុជាក្នុងការសហការគ្នាដើម្បីជាប្រយោជន៍នៃអនាគតរួមឡើយ ។ ដូចបានពិពណ៌នាត្រួសៗដោយអ្នកឆ្លើយសំណួរនិងការបកស្រាយរបស់អ្នកនិពន្ធទស្សនៈពិតប្រាកដនៃអនាគតរួមគឺចង់បានសង្គមស្មើភាពគ្នានិងប្រជាធិតេយ្យរួចចាកផុតពីអំពើពុករលួយនិងអំពើហិង្សា ។ សង្គមបែបនេះហើយដែលសន្តិភាពនិងយុត្តិធម៌ត្រូវបានបង្កើតឡើង និងការពារដោយវិធាននៃច្បាប់ ។

ការសង្កេតដ៏សំខាន់មួយដែល លីនតុន បានទាញចេញពីការស្ទាបស្ទង់មតិគឺថា ដើម្បីបង្កើតយុទ្ធសាស្ត្រយុត្តិធម៌អន្តរកាលពេញលេញមួយដែលនឹងសាបព្រោះគ្រាប់ពូជនៃភាពសុខដុមរម្យនាទាពេលអនាគត មេដឹកនាំកម្ពុជាត្រូវតែចូលរួមការពិភាក្សាជាចំហជាមួយប្រជាជនគ្រប់ស្រទាប់វណ្ណៈក្នុងការបង្កើតឲ្យមានវិធីដោះស្រាយរួមដែលនឹងទៅបានវែងឆ្ងាយជាងការកាត់ទោសឲ្យតែបានៗទៅលើមេដឹកនាំវ័យចំណាស់មួយចំនួនតូច ។ លីនតុន បានរកឃើញកម្មវត្ថុសំខាន់បួនដែលជួយដល់ដំណើរការបែបនេះ "...ស្វែងរកយុត្តិធម៌ ផ្តល់ជូនជនរងគ្រោះនូវសិទ្ធិដឹងពីការពិត សំណងដល់ជនរងគ្រោះក្នុងរបៀបមួយដែលទទួលស្គាល់តម្លៃនិងសេចក្តីថ្លៃថ្នូរជាមនុស្ស និងការដកចេញពីការិយាល័យសាធារណៈនូវអ្នកទាំងឡាយណាដែលជាប់ពាក់ព័ន្ធជាមួយរបបជិះជាន់ ។ ដំណើរការនេះគួរតែធ្វើឡើងសំដៅទប់ស្កាត់មិនឲ្យអំពើរំលោភបំពានបែបនេះកើតឡើងជាថ្មីទៀត ហើយបើសិនជាអាចជួសជុលការខូចខាតដែលអ្នកទាំងនោះបានធ្វើឡើង" ។ តើមនុស្សម្នាក់អាចស្វែងរកយុត្តិធម៌នៅក្នុងសង្គមក្រោយរបបប្រល័យពូជសាសន៍បានយ៉ាងដូចម្តេច? ចំពោះប្រជាជនភាគច្រើននៅប្រទេសលោកខាងលិច យុត្តិធម៌អាចយល់បានតាមរយៈការសងជំងឺចិត្ត ឬការកែកំហុស និងតាមរយៈការដាក់ឲ្យអ្នកទាំងនោះទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ។ ប៉ុន្តែការពិតប្រកបដោយការឈឺចាប់នៅក្នុងសង្គមមួយដូចជាសង្គមកម្ពុជានេះគឺថា បែបផែននៃសំណងពេញលេញនឹងមិនអាចកើតមានទេ ។ អ្វីដែលបានបាត់បង់ទៅហើយមិនអាចត្រឡប់មកវិញដែរ ។ ជាងនេះទៅទៀត គ្មានមធ្យោបាយណាមួយដែលរឿងរ៉ាវទាំងនេះអាចត្រូវបានដោះស្រាយជាមួយអ្នកដែលពាក់ព័ន្ធទៅនឹងអំពើទារុណកម្មនិងការសម្លាប់ប្រជាជនកម្ពុជាច្រើនហួសប្រមាណនោះឡើយ ។ ការជំនុំជម្រះទោសនិងការចោទប្រកាន់ក្នុងចំនួនច្រើនអាចនឹងបំផ្លាញរចនាសម្ព័ន្ធសង្គម បើទោះជាការដំណើរការបែបនេះអាចធ្វើទៅបានក៏ដោយ ។ បន្ថែមពីនោះទៀត ការសិក្សាបានបង្ហាញថា ក្នុងករណីជាច្រើន វាគ្មានភាពខុសប្លែកគ្នាដាច់ស្រេចរវាងជនដៃដល់នៃអំពើឃោរឃៅនិងជនរងគ្រោះឡើយ ។ អ្នកធ្វើទារុណកម្មនិងអ្នកសម្លាប់ភាគច្រើនត្រូវបានបំបែកចេញពីក្រុមគ្រួសារទទួលការបំពាក់បំប៉នអំពីភាពឃោរឃៅនិងត្រូវបង្ខំឲ្យជឿលើអំណាចរបស់របបនោះទាំងស្រុង មិនតែប៉ុណ្ណោះគឺត្រូវប្រឈមមុខនឹងការសម្លាប់ទៀតផងប្រសិនបើអ្នកទាំងនោះបដិសេធមិនព្រមអនុវត្តតាមបញ្ជា ។ ការស្ទាបស្ទង់មតិបានលាតត្រដាងឲ្យឃើញថាប្រជាជនកម្ពុជាខ្លួនឯងមានលទ្ធភាពបែងចែកដាច់ពីគ្នារវាងសមាជិកធម្មតានិងអ្នកដែលមានពិរុទ្ធភាពខ្លាំងបំផុតដែលជានិច្ចកាលជាជនដៃដល់នៃអំពើឃោរឃៅ ។ លទ្ធផលភាគច្រើនអ្នកឆ្លើយសំណួរចាត់ទុក "ការស្វែងរកយុត្តិធម៌" ថាមានការពាក់ព័ន្ធទៅនឹងការចោទប្រកាន់មេដឹកនាំខ្មែរក្រហមដែលនៅរស់រានមានជីវិតដោយចង់ឲ្យមានការចូលរួមពីសំណាក់អន្តរជាតិ ។ ប្រការនេះដោយសារតែកង្វះការជឿទុកចិត្តគ្នានិងកង្វះសមត្ថភាពរបស់ចៅក្រមកម្ពុជា ។

ទោះបីជាយ៉ាងណាក៏ដោយ លីនតុន បានបកស្រាយថាការផ្តោតអារម្មណ៍ទៅលើការដាក់បុគ្គលជាន់ខ្ពស់ឲ្យទទួលខុសត្រូវនៅក្នុងតុលាការមានសារសំខាន់ជាងការសងសឹក ។ លីនតុន

បានផ្តោតទៅលើ«និមិត្តរូបយុត្តិធម៌»នៃការកាត់ទោសបែបនេះ ដោយពិនិត្យសង្កេតក្នុងចំណោមអ្នកឆ្លើយសំណួរ៖

មនុស្សភាគច្រើនបានបញ្ចេញយោបល់ថា ការជំនុំជម្រះជាមេរៀនផ្នែកសីលធម៌ដែលអ្នកឆ្លើយសំណួរភ្ជាប់ពីសារសំខាន់នៃការជំនុំជម្រះដើម្បីសម្រេចបាននូវការផ្លាស់ប្តូរការប្រព្រឹត្តរបស់មនុស្សជំនាន់ក្រោយ ។ ការជំនុំជម្រះត្រូវបានមើលឃើញថាមានសក្តានុពលដើម្បីបំបែកវដ្តនៃអំពើហិង្សានិងវប្បធម៌នៃភាពរួចទោស ។ នេះគឺជាការប្រើប្រាស់ដំណើការតុលាការធ្វើជាការអប់រំដែលមានន័យថាជាការទប់ស្កាត់អ្វីដែលកើតឡើងនិងមានសភាពទន្ទត់ខ្លាំងពេក ។ ហេតុនេះ ដំណើរការតុលាការនេះនឹងប្រើជាការព្រមានចំពោះការគោរពទ្រឹស្តីទាំងងងឹតងងល់គ្រោះថ្នាក់នៃមេដឹកនាំផ្តាច់ការនិងការដាក់ទោសទៅលើបុគ្គលសម្រាប់តួនាទីនៅក្នុងអំពើឃោរឃៅនោះ ។

លីនតុន ដែលមានប្រវត្តិជាអ្នកឯកទេសខាងច្បាប់អន្តរជាតិនិងច្បាប់សិទ្ធិមនុស្ស បានគូសបញ្ជាក់ថា តួនាទីជានិមិត្តរូបនិងការអប់រំដ៏សំខាន់មួយនៃការជំនុំជម្រះខ្មែរក្រហមគឺស្ថិតនៅក្នុងច្បាប់អន្តរជាតិនិងច្បាប់សិទ្ធិមនុស្សដែលបង្ហាញពីភាពចាំបាច់នៃនិតិវិធីយុត្តិធម៌និងនីតិរដ្ឋនៅក្នុងប្រទេសកម្ពុជា ។ អ្នកឆ្លើយសំណួរបានគូសបញ្ជាក់ម្តងហើយម្តងទៀតថា ខ្លួនបានព្យាយាមស្វែងរកនូវការបញ្ចប់ភាពរួចទោសនិងភាពគ្មានច្បាប់ទម្លាប់ដែលចេះតែបន្តនៅក្នុងសង្គមកម្ពុជា ។ អ្វីដែលអ្នកឆ្លើយសំណួរស្វែងរកនោះគឺសង្គមមួយដែលគ្រប់គ្រងដោយនីតិរដ្ឋនិងមានតុលាការជាវេទិកាដ៏ស័ក្តិសមបំផុតដើម្បីចាត់ការជាមួយជនសង្ស័យព្រមទាំងសង្គមមួយដែលបដិសេធចោលនូវគំនិតសងសឹកផ្ទាល់ខ្លួន ។

ឱវាទរបស់ព្រះពុទ្ធបានចែងថា «ពៀររំងាប់ដោយការមិនចងពៀរ» ក៏បានបង្ហាញផ្លូវឲ្យឃើញអំពីវិធីដោះស្រាយរបស់ប្រជាជនកម្ពុជា ចំណែកឯ លីនតុន បានសង្កត់ធ្ងន់ពីសារសំខាន់នៅក្នុងសៀវភៅរបស់គាត់នូវវប្បធម៌ពុទ្ធសាសនានៅកម្ពុជាក្នុងការបង្កើតដំណើរការផ្សះផ្សា ។ គោលការណ៍ជាមូលដ្ឋានមួយរបស់ព្រះពុទ្ធបានចែងថា «បុគ្គលម្នាក់ៗតែងតែប្រឈមមុខទៅនឹងអំពើទាំងពួងដែលខ្លួនបានសាង» ប៉ុន្តែគោលការណ៍នោះក៏ផ្តល់ឱវាទឲ្យមានមេត្តាធម៌ដែរ ដែលជាដំបូន្មានជួយអ្នកដែលបានប្រព្រឹត្តខុសឲ្យបោះបង់ផ្លូវចាស់ចោលនិងរំដោះខ្លួនចេញពីអំពើឆ្គួតលេលាដែលញ៉ាំងចិត្តមកពីលោភៈនិងទោសៈ ។ សង្ឃកម្ពុជាជាន់ខ្ពស់មួយអង្គដែលបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានសម្ភាសន៍កាលពីឆ្នាំ២០០២ បានមានពុទ្ធដីកាថា «ការសងសឹកនឹងមិនបញ្ចប់ទេបើមនុស្សដោះស្រាយជម្លោះដោយតណ្ហា លោភៈ ទោសៈ និងអំពើឆ្គួតលេលា...» ។ រឿងសំខាន់បំផុតនោះគឺការពិតនិងការទទួលខុសត្រូវដើម្បីធ្វើជាគំរូសម្រាប់អ្នកដទៃកុំឲ្យប្រព្រឹត្តរឿងរ៉ាវបែបនេះទៀត ។ វាច្បាស់ណាស់ថា សម្រាប់អ្នកកាន់ព្រះពុទ្ធសាសនានៅក្នុងប្រទេសកម្ពុជា វិធីដ៏ប្រសើរបំផុតដើម្បីលាតត្រដាងការពិតនិងបង្កើតការទទួលខុសត្រូវគឺតាមរយៈការជំនុំជម្រះដ៏ត្រឹមត្រូវមួយ ។ អ្នកឆ្លើយសំណួរម្នាក់បានសរសេរឃ្លាមួយថា «នៅក្នុងច្បាប់រដ្ឋ អ្នកដែលប្រព្រឹត្តបទឧក្រិដ្ឋត្រូវមានទោស ។ នៅក្នុងច្បាប់ព្រះពុទ្ធសាសនា អ្នកដែលប្រព្រឹត្តអំពើអាក្រក់ត្រូវទទួលផលអាក្រក់ ។ យើងត្រូវបញ្ចប់ពៀរដោយការមិនចងពៀរ ។ យុត្តិធម៌និងការដាក់ទោសដ៏ត្រឹមត្រូវ ចាំបាច់ត្រូវតែមានប្រសិនបើយើងចង់រស់នៅក្នុងសន្តិភាពនិងវិបុលភាព ។»

លទ្ធផលគួរឲ្យភ្ញាក់ផ្អើលនៃការស្ទាបស្ទង់គឺមានការគាំទ្រតិចតួចក្នុងចំណោមអ្នកឆ្លើយសំណួរចំពោះគណៈកម្មការស្វែងរកការពិតនៅកម្ពុជា ។ ហេតុផលជាយថាហេតុតែមួយគត់គឺបណ្តាលមកពីកង្វះការយល់ដឹងពីដំណើរស្ថាប័នបែបនេះ ពីព្រោះប្រជាជនកម្ពុជាមានការគាំទ្រច្រើនជាងចំពោះគណៈកម្មការស៊ើបអង្កេតច្បាស់លាស់ដែលនឹងជួយឲ្យប្រជាជនយល់អំពីថាតើប្រជាជនត្រូវបានប្រែក្លាយទៅជាអ្នកធ្វើទារុណកម្មនិងអ្នកសម្លាប់មនុស្សយ៉ាងដូចម្តេចនិងដោយសារមូលហេតុអ្វី ។ អ្នកឆ្លើយសំណួរបានបញ្ជាក់ច្បាស់ថា វាជាការចាំបាច់ណាស់សម្រាប់ប្រជាជនកម្ពុជាទាំងអស់ដែលត្រូវបង្កើនការយល់ដឹងអំពីឫសគល់នៃ«ឧក្រិដ្ឋកម្មប្រល័យជាតិសាសន៍ឯង» ដូច្នេះប្រជាជនកម្ពុជាអាចចាប់ផ្តើមពន្យល់ប្រាប់នូវអ្វីជាច្រើនទៀតដែលនៅសេសសល់ហើយមិន

ទាន់បានរៀបរាប់ ។ លីនតុន បានសន្និដ្ឋានថា “ប្រជាជនកម្ពុជាគ្រប់រូប ទោះជាមានជំនឿសាសនានិងចក្ខុវិស័យនយោបាយអ្វីក៏ដោយ ត្រូវតែរួមចំណែកក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើតកំណត់ហេតុអតីតកាលផ្ទាល់ខ្លួនដែលជាប្រយោជន៍ដល់ការផ្សះផ្សាអ្វីដែលបានកើតមានឡើង ។

ចំណុចសំខាន់ទីបីនៃកម្មវិធីយុត្តិធម៌អន្តរកាលពេញលេញដែល លីនតុន បានព្យាយាមបកស្រាយមានទំនាក់ទំនងទៅនឹងសំណងដល់ជនរងគ្រោះនៃអំពើព្រៃផ្សៃពីអតីតកាល ។ ត្រង់ចំណុចនេះ លីនតុន បានគូសបញ្ជាក់បន្ថែមពីសារសំខាន់នៃកម្មវិធីសុខភាពផ្លូវចិត្តនិងស្តារលទ្ធភាពពលកម្មដ៏ទូលំទូលាយ នៅតាមថ្នាក់មូលដ្ឋាន ។ លីនតុន បានចាត់ទុកកម្មវិធីទាំងនេះថាជាធាតុសំខាន់របស់គណៈកម្មការស៊ើបអង្កេតទ្រង់ទ្រាយធំដែលគាត់បានផ្តល់អនុសាសន៍ ។ ជាការពិតណាស់ មានភស្តុតាងនៅក្នុងប្រទេសអាហ្វ្រិកខាងត្បូងនិងកន្លែងផ្សេងៗទៀតដែលបទពិសោធន៍របស់សាក្សីជាច្រើននៅក្នុងគណៈកម្មការស្វែងរកការពិតបានធ្វើឲ្យប៉ះពាល់ផ្លូវចិត្តសាក្សីយ៉ាងខ្លាំង ហើយគ្មានការព្យាបាលទេ ។ សាក្សីទាំងនោះនឹងត្រូវតុលាការកោះហៅឲ្យមកនិយាយរំពុកឡើងវិញពីការប៉ះទង្គិចផ្លូវចិត្តពីអតីតកាលដោយគ្មានសេវាកម្មគាំទ្រឲ្យបានសមរម្យ ។ ជនរងគ្រោះនៃរបបខ្មែរក្រហមបានលាតសន្ធឹងហួសពីអ្នកដែលបាត់បង់សាច់ញាតិនិងអ្នករស់រានមានជីវិតនៃអំពើទារុណកម្ម ។ មនុស្សពេញមួយជំនាន់បានទទួលរងនូវការបាត់បង់ដោយផ្ទាល់និងទទួលរងអំពើហិង្សាក្នុងទម្រង់មួយឬច្រើនក្នុងអំឡុងប៉ុន្មានឆ្នាំនោះ ហើយមនុស្សមួយជំនាន់បន្ទាប់ពីទទួលផលប៉ះពាល់ដល់មរតកនៃវប្បធម៌ហិង្សានិងការរួចទោស ការបែកបាក់ និងភាពក្រីក្រ ។ ក្នុងបរិបទនេះ មូលដ្ឋានសំខាន់បំផុតដើម្បីកសាងការផ្សះផ្សាជាតិត្រូវតែមានកិច្ចខិតខំប្រឹងប្រែងប្រកបដោយនិរន្តរភាពក្នុងន័យធ្វើឲ្យយុត្តិធម៌សង្គមបានប្រសើរឡើង ។ អ្នកឆ្លើយសំណួរម្នាក់បានបញ្ចេញមតិថា÷

ការផ្សះផ្សាជាតិជាផ្លូវមួយឆ្ពោះទៅរកស្ថិរភាពនិងសន្តិភាពដើម្បីកសាងសង្គមមួយដែលត្រូវបំផ្លិចបំផ្លាញដោយសារសង្គ្រាម ហើយការផ្សះផ្សាជាតិត្រូវតែឈរលើយុត្តិធម៌សង្គម ។ យុត្តិធម៌សង្គមអាចកើតមានលុះត្រាតែយើងលើកកម្ពស់វប្បធម៌គោរពសិទ្ធិមនុស្ស យល់គោលការណ៍សីលធម៌សង្គម និងអនុវត្តកាតព្វកិច្ចផ្លូវច្បាប់....ការផ្សះផ្សាជាតិផ្អែកទៅលើតម្លាភាព ស្មើភាពគ្នានិងយុត្តិធម៌ ។

កម្មវត្ថុនាំមុខទីបួននៃកម្មវិធីយុត្តិធម៌អន្តរកាលពេញលេញមួយសម្រាប់ប្រទេសកម្ពុជាដែលរកឃើញដោយ លីនតុន គឺការដកចេញពីការិយាល័យសាធារណៈនូវអ្នកទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងរបបជិះជាន់ ។ ទោះបីជាយ៉ាងណាក៏ដោយ លីនតុន បានបង្ខំចិត្តទទួលយកទាំងស្ទាក់ស្ទើរថា មានអតីតកម្មាភិបាលខ្មែរក្រហមជាច្រើនកំពុងកាន់មុខតំណែងក្នុងរចនាសម្ព័ន្ធរដ្ឋកម្ពុជាដែលការបណ្តេញចេញមិនអាចធ្វើទៅបាន ។ ទោះជាយ៉ាងណាក៏ដោយ លីនតុន បានប្រកាន់ខ្ជាប់នូវសេចក្តីសង្ឃឹមថា ទម្រង់ទទួលខុសត្រូវផ្សេងៗទៀតអាចយកមកអនុវត្តចំពោះអតីតជនដៃដល់ត្រូវលើកទឹកចិត្តឲ្យកែប្រែអត្តចរិតចំពោះកំហុសពីអតីតកាល ។

តើនរណាជាភ្នាក់ងារគន្លឹះក្នុងការអនុវត្តកម្មវិធីយុត្តិធម៌អន្តរកាលដ៏យូរអង្វែងបែបនេះបាន? លីនតុន រកឃើញថាមានបីប្រភេទ ។ រដ្ឋាភិបាលកម្ពុជាគួរតែធ្វើកិច្ចការច្រើនជាងការត្រួតពិនិត្យមើលការជំនុំជម្រះឧក្រិដ្ឋកម្មនិងការបង្កើតឡើងនូវស្ថាប័នដទៃទៀតដែលអំណោយផលដល់បរិយាកាសនយោបាយចំហនិងកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់យុត្តិធម៌សង្គម ។ តួនាទីសំខាន់របស់អង្គការមិនមែនរដ្ឋាភិបាលនិងចលនាសង្គមស៊ីវិលគឺត្រូវលើកទឹកចិត្ត ដាក់សម្ពាធ និងជួយឧបត្ថម្ភរដ្ឋក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ជាពិសេសតាមរយៈជួយអ្នករស់រានមានជីវិតនិងក្រុមគ្រួសារឲ្យបង្ហាញនិងសម្តែងការទាមទារទៅរដ្ឋាភិបាល ។ លីនតុន បានស្នើថា ទីភ្នាក់ងារសង្គមស៊ីវិលមានសម្បទានិងការទទួលខុសត្រូវពិសេសចំពោះការងារនៅថ្នាក់មូលដ្ឋានដែលបង្កើតឲ្យមានដំណើរការទទួលខុសត្រូវដោយផ្ទាល់ទៅលើការផ្សះផ្សានិងការស្តាបនាសង្គម ។ ភ្នាក់ងារគន្លឹះទីបីគឺប្រជាជនកម្ពុជាខ្លួនឯង ។ ជាថ្មីម្តងទៀត អ្នកឆ្លើយសំណួរជាច្រើនបានគូសបញ្ជាក់ពីសារសំខាន់នៃការផ្លាស់ប្តូរអាកប្បកិរិយានិងបុគ្គលិកលក្ខណៈផ្ទាល់ខ្លួនថាជាសមាសភាពចំបាច់មួយក្នុងដំណើរការនៃ

ការផ្សះផ្សាជាតិដោយទទួលស្គាល់តម្រូវការរបស់ប្រជាជនក្នុងការរួមរស់ជាមួយមនុស្សកំណាចពីអតីតកាល និងរៀនរស់នៅជាមួយគ្នាឆ្ពោះទៅកាន់អនាគតរួមមួយ ។ ទាក់ទងដល់ចំណុចនេះ លីនតុន បានភ្ជាប់បញ្ហានៃការលើកលែងទោសនៅក្នុងចំណុចផ្សេងៗនៅក្នុងសៀវភៅថាជាដំណើរការនៃការផ្សះផ្សា ។ លីនតុនក៏ដូចជាអ្នកនិពន្ធផ្សេងៗទៀតបានសន្និដ្ឋានថា គ្មាននរណាម្នាក់មានសិទ្ធិរំពឹងឬតម្រូវឲ្យអ្នករស់រានមានជីវិតបង្ហាញពីការលើកលែងទោសដល់ព្រះរាជអាជ្ញារបស់ខ្លួនឡើយ ។ ការផ្សះផ្សាក្នុងរូបភាពសហគ្គិភាព(ការរួមរស់ជាមួយគ្នា) អាចធ្វើឡើងដោយគ្មានការលើកលែងទោស ។

ដូចជាសៀវភៅផ្សេងទៀតដែរ សៀវភៅ"ការផ្សះផ្សានៅកម្ពុជា"មានគុណវិបត្តិមួយចំនួន ។ សៀវភៅនេះបាននិយាយច្រំដែលនិងបានទទួលផលប្រយោជន៍ច្រើនពីទឹកដៃកំណែ ។ ពេលខ្លះខ្ញុំមានអារម្មណ៍ថា អ្នកនិពន្ធមិនអាចសម្រេចឲ្យបានច្បាស់ថាតើគាត់កំពុងធ្វើរបាយការណ៍ស្រាវជ្រាវឬសរសេរសៀវភៅសម្រាប់អ្នកអានទូទៅ ។ អ្នកខ្លះអាចចោទសួរអំពីភាពសមរម្យក្នុងការចំណាយពេលមួយផ្នែកធំរបស់សៀវភៅទៅលើទស្សនៈនៃការស្ទាបស្ទង់មតិ ដោយផ្ដល់ពត៌មានលម្អិតអំពីទិន្នន័យដែលប្រមូលបាននិងយកមកប្រើប្រាស់ ហើយបន្ទាប់មកពិនិត្យលើចម្លើយដែលបង្ហាញតាមស្ថិតិចំណុចទសភាគពីរខ្ទង់ ក្រាហ្វិក និងតារាង ។ ស្ថិតិទាំងអស់នេះអាចមានប្រយោជន៍សម្រាប់អ្នកវិទ្យាសាស្ត្រសង្គមអាជីពនិងអ្នកធ្វើប្រជាមតិសាធារណៈ ប៉ុន្តែខ្ញុំមិនបដិសេធថា យ៉ាងហោចណាស់ចំណែកនេះបង្ហាញពីការរកឃើញនេះថា “មានលក្ខណៈវិទ្យាសាស្ត្រ” ដោយមាន “ការពិតដែលមិនអាចប្រកែកបាន” ដើម្បីគាំទ្រដល់ការអង្កេត និងសេចក្ដីសន្និដ្ឋានរបស់អ្នកនិពន្ធ ។ ខ្ញុំមិនអាចបដិសេធអារម្មណ៍ថា លីនតុន មានជំនឿយ៉ាងខ្លាំងទៅលើឥទ្ធិពលផ្សះផ្សារបស់នីតិរដ្ឋដែលឆ្លុះបញ្ចាំងអំពីប្រវត្តិផ្លូវច្បាប់របស់គាត់ទេ ។ ជាងនេះទៅទៀតក្នុងខណៈដែលខ្ញុំមិនមែនជាអ្នកឯកទេសខាងប្រវត្តិសាស្ត្រកម្ពុជាបច្ចុប្បន្ន ខ្ញុំមានអារម្មណ៍ថា លីនតុន បានប្រានចោលការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរមកលើសន្តិភាពជាតិនិងសន្តិសុខដែលរដ្ឋាភិបាលបានប្រឈមមុខកាលពីមួយទសវត្សរ៍កន្លងទៅ ។ ខ្ញុំយល់ថា លីនតុន មានភាពឆ្គងគ្នាបន្តិចដែលអះអាងអំពីតម្រូវការចាំបាច់ក្នុងការដកមន្ត្រីនានាដែលធ្លាប់ជាផ្នែកមួយនៃរបបនាសម័ន្ទដឹកនាំខ្មែរក្រហម ប៉ុន្តែបែរជាទទួលស្គាល់ថា ប្រតិបត្តិការបោសសម្អាតបែបនេះមិនអាចធ្វើទៅរួច ។ ខ្ញុំក៏មានការមិនពេញចិត្តដែរ ដែល លីនតុន មិនបានពិចារណាចំពោះសំណើថ្មីៗជាច្រើនដើម្បីបង្កើតឲ្យមានការទទួលខុសត្រូវដែលបានលើកឡើងដោយបញ្ញាជននានា ដូចជា ក្រេក អេចឆេសាន់ ជាដើម ។

សូមទុកករណីលើកលែងនេះមួយឡែកសិន ។ ភាពហ្មត់ចត់និងកម្រិតនៃភាពស្មោះត្រង់មានចំពោះស្នាដៃនេះនឹងក្លាយជាឯកសារពិគ្រោះដ៏សំខាន់សម្រាប់អ្នកដែលទទួលខុសត្រូវក្នុងការដឹកនាំផ្លូវឆ្ពោះទៅកាន់ការផ្សះផ្សាជាតិនៅកម្ពុជា ។ ការស្ទាបស្ទង់មតិនេះគឺជាការព្យាយាមដ៏មានសារសំខាន់ក្នុងការភ្ជាប់ប្រជាជនកម្ពុជាជាមួយនឹងបញ្ហាទាក់ទងនឹងការផ្សះផ្សានៅក្នុងប្រទេស ។ ដូចនេះ ការពិតស្ថិតនៅលើចំណុចសំខាន់នៃការស្រាវជ្រាវដើម្បីជាសញ្ញាបង្ហាញពីលំដាប់នៃទស្សនៈនិងបញ្ហាដែលប្រជាជនកម្ពុជាជឿថាត្រូវតែដោះស្រាយក្នុងពេលដែលប្រទេសកំពុងវិវត្តតាមមាគ៌ានៃការផ្សះផ្សា ។ ដូច្នេះសៀវភៅនេះគឺជាសៀវភៅដ៏មានតម្លៃនិងគួរឲ្យចាប់អារម្មណ៍ ។ ប្រហែលជាមិនអាចទៅរួចទេដែលថា ឥឡូវនេះសៀវភៅនេះនឹងចូលទៅក្នុងចម្ការមីននយោបាយនៃការពិភាក្សាថ្នាក់ជាតិនិងអន្តរជាតិស្តីអំពីថាតើត្រូវដោះស្រាយយ៉ាងដូចម្ដេចជាមួយនឹងអតីតកាលដ៏គួរឲ្យឈឺចាប់របស់កម្ពុជា ។ កិច្ចការពិតប្រាកដនោះគឺថាតើត្រូវនាំយកបញ្ហានិងការពិភាក្សាទាំងនេះត្រឡប់ទៅឲ្យប្រជាជនយ៉ាងដូចម្ដេចដើម្បីបន្តនិងបង្កើនឲ្យមានការចូលរួមនិងការពិភាក្សាដែលបាននាំមកនូវការស្រាវជ្រាវនេះតាំងពីដំបូងមក ។ ធ្វើដូច្នេះទោះបីជាមានសណ្ឋានណាមួយនៃកម្មវិធីយុត្តិធម៌អន្តរកាលពេញលេញកើតជារូបរាងឡើងក៏ដោយ ក៏ប្រជាជនកម្ពុជាខ្លួនឯងនឹងយល់ឃើញពីភាពម្ចាស់ការក្នុងកម្រិតមួយចាំបាច់សម្រាប់ទស្សនៈអនាគតរួមមួយក្លាយទៅជាការពិតដែរ ។

**អេនឌ្រូ វីជបឺ**

អ្នកទោសនៅមន្ទីរស-២១



# ឱកាសដ៏កម្រដើម្បីកាត់ទោសស្លាបនិកនៃអំពើឃោរឃៅ

នៅទីបំផុតយុត្តិធម៌ប្រហែលជាអាចត្រូវផ្តល់ឲ្យប្រជាជនកម្ពុជាចំនួន១,៧លាននាក់ដែលបានស្លាប់បាត់បង់ជីវិតនៅក្រោមរបបផ្តាច់ការខ្មែរក្រហមកាលពីជាងពីរទសវត្សរ៍មុន ។ នៅទីបញ្ចប់ រដ្ឋសភាជាតិកម្ពុជាអាណត្តិទី៣ត្រូវបានបង្កើតឡើងក្រោយពីរដ្ឋាភិបាលចម្រុះបានលេចចេញជារូបរាងបន្ទាប់ពីជាប់គាំងអស់រយៈពេលជាច្រើនខែ ហើយត្រូវបានរំពឹងថានឹងផ្តល់សច្ចាប័នដល់កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិនៅពេលខាងមុខឆាប់ៗនេះ ។ ការផ្តល់សច្ចាប័ននេះនឹងធ្វើឲ្យរដ្ឋាភិបាលអាចបង្កើតតុលាការជាតិពិសេសមួយដើម្បីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមដែលនៅរស់សព្វថ្ងៃ ។ នៅក្នុងការស្ទាបស្ទង់មតិថ្មីៗ និងនៅពេលដែលការបង្កើតតុលាការត្រូវបានដឹងឮប្រជាជនកម្ពុជាមួយភាគធំបានគាំទ្រយ៉ាងមុតមាំចំពោះ “អង្គជំនុំជម្រះវិសាមញ្ញ”នេះ ។

តុលាការចម្រុះនេះមិនមានលក្ខណៈដូចគ្នានឹងតុលាការផ្សេងទេ ទោះបីមានរូបភាពជាតុលាការជាតិ ឬតុលាការអន្តរជាតិក្តី ។ កម្ពុជាបានអនុម័តច្បាប់មួយនៅឆ្នាំ២០០១ដើម្បីបង្កើតតុលាការនេះ ប៉ុន្តែកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិធានាថាអ្នកជំនាញការអន្តរជាតិនិងបទដ្ឋាននីតិវិធីអន្តរជាតិនឹងត្រូវបញ្ចូលទៅក្នុងការស៊ើបអង្កេតនិងការកាត់ក្តីរបស់តុលាការ ។ មានតែបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងនៅសម័យប៉ុលពតចាប់ពីឆ្នាំ១៩៧៥ដល់១៩៧៩ទេដែលនឹងត្រូវយកមកកាត់សេចក្តីនិងមានតែមេដឹកនាំដែលមានការទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋដ៏ធំធេងមកលើប្រជាជនកម្ពុជាទេដែលត្រូវស៊ើបអង្កេត ។ ដោយហេតុថាមានការខ្វះខាតផ្នែកធនធាន និងការកន្លងផុតទៅនៃពេលវេលា គឺមានតែអតីតមេដឹកនាំមួយចំនួនតូចប៉ុណ្ណោះដែលនឹងត្រូវនាំឡើងតុលាការ ។

អង្គជំនុំជម្រះវិសាមញ្ញគឺជាលទ្ធផលនៃការសម្របសម្រួលគ្នារវាងនយោបាយកម្ពុជាដ៏ស្មុគស្មាញគួរឲ្យឈឺក្បាល និងសេចក្តីប្រាថ្នាដ៏ទទូចរបស់សហគមន៍អន្តរជាតិ ។ សម្រាប់បុគ្គលណាដែលទាមទារនូវយុត្តិធម៌ពេញលេញឥតខ្ចោះ តុលាការប្រភេទនេះមិនគួរឲ្យពេញចិត្តទេ ប៉ុន្តែវាជាការអាម៉ាស់ប្រសិនបើយើងបណ្តោយឲ្យឱកាសកន្លងផុតទៅដោយមិនបាននាំមេដឹកនាំខ្មែរក្រហមដែលនៅរស់មកកាត់ទោសនោះ ។

ចាប់តាំងពេលដែលសភាសហរដ្ឋអាមេរិកផ្តល់ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងចងក្រងឯកសារនៃអំពើឃោរឃៅរយៈពេល១០ឆ្នាំក្នុងការបង្កើតតុលាការគឺជាដំណាក់កាលដ៏សែនរំដើបរំជួល ។ ម្តងហើយម្តងទៀត ការបង្កើតតុលាការត្រូវបានពន្យារពេលដោយសារតែភាពមិនទៀងទាត់នៃនយោបាយក្នុងស្រុកនិងអន្តរជាតិ ។ អ្នកខ្លះបានសួរថា ហេតុអ្វីបានជាការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើប្រទេសកម្ពុជានៅក្នុងអាណត្តិរដ្ឋាភិបាល និកសុន មិនត្រូវបានរាប់បញ្ចូលក្នុងយុត្តាធិការតុលាការនេះផង ។ មនុស្សជាច្រើនមានការភ្ញាក់ផ្អើលនៅពេលឃើញថា មេដឹកនាំខ្មែរក្រហមដែលប្រទេសជាច្រើន(រួមទាំងសហរដ្ឋអាមេរិកផង) ធ្លាប់បានទទួលស្គាល់ថាជាផ្នែកមួយនៃរដ្ឋាភិបាលស្របច្បាប់របស់កម្ពុជាក្រោយពីការឈ្លានពានរបស់វៀតណាមនៅឆ្នាំ១៩៧៩ បានត្រូវកាត់ទោសជាឧក្រិដ្ឋជនសង្គ្រាមដោយអតីតសម្ព័ន្ធមិត្តអន្តរជាតិរបស់ខ្លួនទៅវិញ ។

ចៅក្រមភាគច្រើននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនឹងជាជនជាតិកម្ពុជា ប៉ុន្តែការសម្រេចចុងក្រោយទាមទារសំឡេងគាំទ្រភាគច្រើនលើសលប់ដោយមានការគាំទ្រពីចៅក្រមអន្តរជាតិយ៉ាងហោចមួយរូបដែរ ។ អង្គជំនុំជម្រះវិសាមញ្ញនឹងមានសហព្រះរាជអាជ្ញាចំនួនពីររូប (មួយរូបជាជនជាតិកម្ពុជានិងមួយរូបទៀតជាជនបរទេស) និងសហចៅក្រមស៊ើបអង្កេតចំនួនពីររូប (កម្ពុជាមួយរូបនិងបរទេសមួយរូប) ។ វិវាទរវាងអ្នកច្បាប់ទាំងពីរនឹងត្រូវដោះស្រាយតាមការបោះឆ្នោតយកសំឡេងភាគច្រើនលើសលប់នៃចៅក្រម ប៉ុន្តែនីតិវិធីត្រូវបានធ្វើឡើងដើម្បីជំរុញ

ឲ្យមានការស៊ើបអង្កេតនិងកាត់ទោសឲ្យមានលក្ខណៈម៉ឺងម៉ាត់ ។

ទោះបីជាអង្គការសហប្រជាជាតិមានកាតព្វកិច្ចផ្តត់ផ្គង់អ្នកច្បាប់អន្តរជាតិនូវថវិកានិងបច្ចេកទេសផ្នែករដ្ឋបាលក៏ដោយ ក៏អង្គការសហប្រជាជាតិនឹងមិនមានអំណាចផ្នែកច្បាប់ជាផ្លូវការច្បាស់លាស់ទៅលើតុលាការដែរ ។ ក៏ប៉ុន្តែ ការងាររបស់ចៅក្រមព្រះរាជអាជ្ញា និងបុគ្គលិកដែលតែងតាំងដោយអង្គការសហប្រជាជាតិ ព្រមទាំងសិទ្ធិរបស់អង្គការសហប្រជាជាតិក្នុងការដកខ្លួនចេញពីតុលាការប្រសិនបើតុលាការនេះទទួលឥទ្ធិពលផ្នែកនយោបាយ គួរតែធានាឲ្យបាននូវវិន័យនិងភាពត្រឹមត្រូវ ។ ដូចគ្នាដែរ រដ្ឋាភិបាលកម្ពុជាត្រូវប្រឆាំងនឹងការប៉ុនប៉ងច្រើនយោបាយគាបសង្កត់ក្នុងការជ្រើសរើសចៅក្រមជាតិ ឬជ្រៀតជ្រែកនៅក្នុងការសម្រេចចិត្តរបស់តុលាការ ។

បញ្ហាធំគឺត្រូវធ្វើយ៉ាងដូចម្តេចដើម្បីផ្តល់ថវិកាដល់ការស៊ើបអង្កេតជាច្រើនឆ្នាំទៅមុខទៀត ។ គម្រោងចំណាយសម្រាប់រយៈពេល៣ឆ្នាំដែលរៀបចំដោយអង្គការសហប្រជាជាតិ (ប្រហែល៦០លានដុល្លារ) មានកម្រិតខ្ពស់ជាងអ្វីដែលប្រទេសផ្តល់ជំនួយ ជប៉ុន បារាំង អូស្ត្រាលី និងសហរដ្ឋអាមេរិក ចង់ផ្តល់ឲ្យ ។ កម្ពុជាត្រូវរួមចំណែកនៅក្នុងការចំណាយ ប៉ុន្តែតម្រូវការសង្គមបានស្រូបយកថវិកាជាតិអស់ច្រើនណាស់ទៅហើយ ។ ក្នុងពេលជាមួយគ្នានេះ រដ្ឋាភិបាលប្រធានាធិបតី ប៊ូស បានចំណាយថវិកាអស់រាប់លានដុល្លារដើម្បីបង្កើតតុលាការពិសេសមួយនៅប្រទេសអ៊ីរ៉ាក់ដើម្បីកាត់ទោស សាដាម ហ៊ូសេន ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ។ នេះជាតុលាការមួយដែលល្អតែនៅលើក្រដាស ប៉ុន្តែធានាបានតិចតួចនូវតម្លាភាពនិងការចូលរួមត្រួតពិនិត្យពីអន្តរជាតិដែលតម្រូវឲ្យមាននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។

បទឧក្រិដ្ឋនៅក្នុងប្រទេសកម្ពុជាមានលក្ខណៈធ្ងន់ធ្ងរណាស់ ។ សឹងតែរាល់គ្រួសារកម្ពុជាបានបាត់បង់សមាជិកម្នាក់ឬច្រើននាក់ដោយសារតែការកាប់សម្លាប់ដែលមិនធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រ ដូច្នេះការទាមទារភ័ស្តុតាងមានលក្ខណៈធំធេងណាស់ ហើយយុត្តិធម៌នឹងមិនទទួលបានដោយចំណាយអស់ថវិកាតិចតួចនោះទេ ក៏ប៉ុន្តែ ការចំណាយទៅលើផ្នែកផ្សេងទៀតសម្រាប់តុលាការ ដូចជាចលនទ្រព្យដែលមិនធ្វើឲ្យដំណើរការទាំងមូលធ្លាក់ក្រោមបទដ្ឋានអន្តរជាតិ គួរតែកាត់បន្ថយ ។

រដ្ឋាភិបាលនានាដែលផ្តល់ជំនួយមិនត្រូវពន្យារពេលតទៅទៀតទេ ។ ប្រសិនបើពន្យារពេលទៀត ស្ថាបនិកនៃអំពើប្រល័យពូជសាសន៍កម្ពុជាដែលចាស់ជរាណាស់ទៅហើយនឹងមិនត្រូវបាននាំឡើងតុលាការជារៀងរហូត ។

**ដេវីដ ស៊ីហ្វ័រ**



ទារុណកម្មនៅមន្ទីរស-២១

# អ្នកទោសអង្គការ

ភូមិទួលត្បែងជាភូមិតូចមួយ នៅតាមមាត់ព្រែកកាំពីក្នុងឃុំចន្ទ្រង់ ស្រុកក្រចេះ មានចម្ងាយ៥០គីឡូម៉ែត្រពីទីរួមខេត្តក្រចេះ ។ ភូមិនេះមានជាជនជាតិខ្មែរសុទ្ធមកពីឃុំថ្មក្រែចំនួនប្រាំពីរគ្រួសារ ។ នៅចម្ងាយពីភូមិនេះប្រហែល១គីឡូម៉ែត្រ មានភូមិមួយទៀតឈ្មោះថា ភូមិកំពង់ក្តី ដែលមានតែជនជាតិព្នងរស់នៅ ។ ភូមិទាំងពីរនេះពុំមានរដ្ឋអំណាចណាមកគ្រប់គ្រងទេ ហើយមុខរបរប្រចាំជីវិតគឺធ្វើស្រែចម្ការនិងប្រមាញ់ ។

នៅរដូវចម្រូតនាខែធ្នូ ឆ្នាំ១៩៧៣ ពេលដែលខ្ញុំកំពុងជញ្ជូនកណ្តាប់ស្រូវគរជាពំនូក សំឡេងមាន់ព្រៃផ្អើលរត់ប្រសេចប្រសាច ខ្ញុំងើបមុខឡើងឃើញមនុស្ស៣នាក់ស្លៀកពាក់ខ្មៅបង់កក្រមា ពាក់ស្បែកជើងកង់ឡាន ប្រដាប់ដោយអាវុធគ្រប់ដៃ ។ បុរសម្នាក់សម្បុរខ្មៅមាឌធំដំបង បបូរមាត់និងចិញ្ចើមក្រាស់ បានដើរចូលមកជិតខ្ញុំ ហើយសួរថាៈ

-មិត្តមានឃើញខ្មែរសមកទីនេះដែរទេ?

ខ្ញុំឆ្លើយថាៈ ខ្ញុំពុំដែលស្គាល់ខ្មែរសទេ ហើយក៏ពុំដែលឃើញមានទ័ពណាមកទីនេះដែរ ។

-មិត្តស្គាល់ផ្លូវទៅមូលដ្ឋានអង្គការនៅកាម៉ាល់ទេ សូមមិត្តជួយនាំផ្លូវខ្ញុំទៅបន្តិច ។

ខ្ញុំផ្អាកការងាររបស់ខ្ញុំ ហើយដើរនាំមុខមិត្តយើងតាមដងផ្លូវឆ្ពោះទៅភូមិកាម៉ាល់ ។ ចេញផុតពីភូមិចម្ងាយ៨០០ម៉ែត្រ ស្រាប់តែមានមនុស្ស១០នាក់ងើបពីគុម្ពោតព្រៃភ្ជង់ខ្ញុំគ្រប់ទិស ពេលនោះខ្ញុំភ័យតក់ស្លុតក្រៃលែង ។ បុរសម្នាក់សួរខ្ញុំថាៈ

-អ្នកឯងជាក្រុមខ្មែរសមែនទេ?

ខ្ញុំឆ្លើយៈ ពុំមែនទេ! ខ្ញុំពុំស្គាល់អ្នកណាទាំងអស់ ។

-គេរាយការណ៍មកថាឯងជានិរសារខ្មែរស ។

បុរសទាំងនេះយកខ្សែអង្រឹងមកចងត្រង់កន្ទាក់កែងដៃខ្ញុំយ៉ាងតឹង ហើយបណ្តើរខ្ញុំទៅឃុំចន្ទ្រង់ទាំងយប់ពពឹមពពើម ។ ព្រឹកឡើង សន្តិសុខឃុំចន្ទ្រង់សួរចម្លើយខ្ញុំ ។ សំណួរនិងចម្លើយគ្មានខុសប្លែកពីមុនទេ ។ ខ្ញុំនៅតែឆ្លើយថាមិនស្គាល់ ។ សន្តិសុខម្នាក់បានទះកំផ្លៀងខ្ញុំបីដៃ ។ យប់ចុងខែ១២ ឆ្នាំ១៩៧៣ ខ្ញុំត្រូវបានបញ្ជូនមកឃុំឃាំងក្នុងបន្ទប់មួយ នៅក្នុងអគារកម្ពស់ពីរជាន់នៃវិទ្យាល័យព្រះមហាក្សត្រិយានីកុសុមៈក្នុងទីរួមខេត្តក្រចេះ ។ ក្នុងបន្ទប់នេះមានខ្នោះឈើបួនជួរ នៅតាមបណ្តោយជញ្ជាំង ។ ជើងរបស់ខ្ញុំម្ខាងត្រូវសន្តិសុខកៀប ហើយវាយស្នៀតនៅចុងខ្នោះ ។ អ្នកទោសដែលជាប់ខ្នោះអាចដេក អង្គុយឈរ ជើងម្ខាងផ្អៀង និងធ្វើចលនាបានគ្រប់ឥរិយាបថ គ្រាន់តែពុំអាចដើរបាន ។ ខ្ញុំឃើញអ្នកទោសទាំងអស់មានតែខោអាវមួយកំប្លេជាប់ខ្លួនប៉ុណ្ណោះ ។ រាល់ព្រឹក កងសន្តិសុខតែងចាក់សោបន្ទប់និងវាយស្នៀតចេញដើម្បីឲ្យអ្នកទោស៤នាក់យកកាដុងសម្រាប់បន្ទោរបង់និងកាកសំណល់ផ្សេងៗទៅចាក់ចោល ។ ខ្ញុំស្ម័គ្រចិត្តយកកាដុងចេញទៅក្រៅរាល់ព្រឹកក្នុងគោលបំណងចង់ឃើញទិដ្ឋភាពខាងក្រៅ និងបានធ្វើចលនាដើម្បីចៀសវាងភាពស្ពឹកស្រពន់ ។ ខ្ញុំពុំដឹងថាក្នុងអគារពីរជាន់នេះមានអ្នកទោសប៉ុន្មាននាក់ទេ ប៉ុន្តែក្នុងបន្ទប់ខ្ញុំមានអ្នកទោសដេកជាប់ខ្នោះចំនួន២០នាក់ អ្នកទោសចំណាស់បំផុតអាយុ៦០ឆ្នាំ រីឯអ្នកមានអាយុតិចបំផុតគឺខ្ញុំអាយុ២៣ឆ្នាំ ។

ភាពរីករាយរបស់យើងទាំងអស់គ្នា គឺនៅពេលព្រះអាទិត្យរះ ហើយការភ័យខ្លាចសេចក្តីស្លាប់នឹងកើតមានឡើងនៅរាល់ពេលហូបបបរមួយកូនចាននិងពេលព្រះអាទិត្យអស្តង្គត ។ ចាប់ពីម៉ោង៧យប់ទៅ ខ្ញុំតែងឮសន្តិសុខវាយខ្នោះដូងដាំងជាមួយនឹងសម្រែកដង្ហោយហៅឲ្យជួយរបស់អ្នកទោស ជួនកាលឮនៅក្នុងបន្ទប់ ជួនកាលឮនៅក្រៅអគារ ។ អ្នកទោសទាំងអស់ដេកយកដៃគងថ្ងាសយ៉ាងស្ងៀមស្ងាត់ ។ ខ្ញុំចំណាំមុខអ្នកទោសនៅក្នុងបន្ទប់ខ្ញុំស្ទើរពុំបាន ព្រោះត្រូវសន្តិសុខប្តូរចេញជាញឹកញាប់ ។ រយៈពេលពីរខែមកហើយដែលខ្ញុំទទួលទានអាហារពីរពេលក្នុងមួយថ្ងៃពេលព្រឹកម៉ោង១១:០០ បាយស្រូបមួយចានចង្កឹះពេល

ល្វាចបបរមួយចានចង្កឹះហូបជាមួយអំបិល ។ រាងកាយរបស់ខ្ញុំចុះស្គមស្លេកស្លាំង ក្អែលរុំកាយក្រាស់ឃ្មឹក សក់រីងក្រញាសវែងលុបត្រចៀក ហើយក្លាយជាសំបុកចៃដ៏ច្រើនសន្ធឹក ។

ព្រឹកមួយវេលាម៉ោង៨ៈ០០ កងសន្តិសុខបានដោះជើងខ្ញុំចេញពីខ្នោះហើយបណ្តើរទៅបន្ទប់សួរចម្លើយ ។ ក្នុងបន្ទប់នោះខ្ញុំឃើញតុមួយគ្មានឯកសារអ្វីទេ ឃើញតែមេសន្តិសុខម្នាក់មាឌធំខ្មៅនៅក្បែរនោះ ។ មុខគាត់ពុំសូវជាកាចប៉ុន្មានទេ ។ សន្តិសុខដទៃទៀតហៅគាត់ថា បងគុំ ឬមិត្តគុំ ។ គាត់អង្គុយលើកៅអីចំពីមុខខ្ញុំ ។ ខាងស្តាំដៃខ្ញុំមានព្យួរឃ្នាបគ្នោត២ប្រភេទ រំពាត់ខ្សែកាប៥បែបខុសៗគ្នា ដែលខាងចុងមានរុំសំណាប៉ុនៗមេដៃផង និងសន្តិសុខម្នាក់ឈរយាម ។ ខាងឆ្វេងដៃខ្ញុំមានសន្តិសុខម្នាក់កាន់កាំភ្លើងឈរក្បែរតុមួយដែលមានក្រណាត់កៅស៊ូច្រើនសណ្ឋាន រំពាត់ខ្សែតី កូនកាំបិតស្នៀត១ កូនពូថៅ១ កូនញញួរ១ ដង្កាប់១ ខ្សែភ្លើងធុនកណ្តាល១ ដើងស្នាចបាចទឹកស្រែ១ ខ្សែទីឡុងពណ៌ខ្មៅនិងចម្រៀកធាងត្នោតមួយបាច់ដាក់នៅក្បែរពាងទឹកមួយ ។ មិត្តគុំ សួរខ្ញុំថាៈ

-ឯងដឹងទេហេតុអ្វីបានជាគេចាប់ឯងមកទីនេះ?

-ខ្ញុំពុំបានដឹងថាខ្ញុំមានកំហុសអ្វីទេ ។

-អង្គការមិនដែលចាប់អ្នកគ្មានកំហុសមកទីនេះទេ ។

ខ្ញុំនៅតែមិនដឹងពីកំហុសរបស់ខ្ញុំពិតមែន ព្រោះខ្ញុំពុំបានធ្វើអ្វីទាល់តែសោះ ។ ពេលនោះកងសន្តិសុខទាំងពីរស្ទុះមកបម្រុងវាយខ្ញុំនឹងខ្សែតី ស្នូកកាំភ្លើង ប៉ុន្តែ សមមិត្តគុំ គោះតុដូង អ្នកទាំងពីរក៏ថយទៅវិញទាំងទឹកមុខខឹងក្រេវក្រោធ ។ បងគុំ ក៏យករបាយការណ៍ដែលផ្ញើពីភូមិមកប្រាប់ថា ខ្ញុំមានបងប្អូនសាច់ញាតិជាមេខ្មែរស បន្ទាប់មក មិត្តគុំ ណែនាំខ្ញុំថាៈ

-មិត្តឯងនៅក្មេងខំកសាងខ្លួនឡើង ។

គាត់ឈប់សួរខ្ញុំ ។ កងសន្តិសុខក៏បណ្តើរខ្ញុំមកកន្លែងវិញ ។ ខ្ញុំពុំមានតក់ស្លុតឬភ័យខ្លាចអ្វីឡើយ ព្រោះបើស្លាប់នៅពេលនោះប្រសើរជាងរស់នៅទាំងស្រេកឃ្លាន ។ រយៈពេល៣ខែហើយដែលខ្ញុំដេកលើឥដ្ឋផ្ទាល់ រាងកាយសល់តែស្បែកដណ្តប់ឆ្អឹង សក់ក្បាលរីង ក្រចកដៃក្រចកជើងវែងដូចខ្មោច ។ ពេលនេះនៅក្នុងបន្ទប់ខ្ញុំនៅសល់តែអ្នកទោស១១នាក់ប៉ុណ្ណោះ ប៉ុន្តែអ្នកទាំងអស់នោះនៅរឹងមាំជាងខ្ញុំ ព្រោះទើបតែមកក្រោយ ។ ខ្ញុំឈប់យកកាដុងដាក់កាកសំណល់ចេញទៅក្រៅជាងកន្លះខែហើយ ព្រោះខ្ញុំដើរមិនរួច ។ ខ្ញុំបានត្រឹមតែប្រឹងក្រោកអង្គុយប៉ុណ្ណោះ ។ អ្នកទោសក្នុងនោះនិយាយថាកន្លះខែទៀតខ្ញុំនឹងស្លាប់មិនខាន ។ អារម្មណ៍ខ្ញុំពេលនោះគ្មាននឹកឃើញអ្វីក្រៅពីការស្រមើស្រមៃកាលនៅសាលារៀន មិត្តភក្តិស្រីប្រុស លោកគ្រូអ្នកគ្រូឡើយ ។ ឪពុកម្តាយនិងប្អូនពៅរបស់ខ្ញុំបានស្លាប់អស់ហើយ ។ ខ្ញុំនៅសល់តែបងប្រុសបីនាក់ ដែលពីរនាក់រស់នៅភ្នំពេញ ។

ធាតុអាកាសក្តៅហប់ក្នុងបន្ទប់ថ្មបិទជិត ខ្ញុំដេកលែងខ្លួនទទេ ។ ស្បែករបស់ខ្ញុំមានលេចចេញពងៗពេញខ្លួន ខ្ញុំយកក្រចកកេះពងបែកចេញសុទ្ធតែទឹក ។ ខ្ញុំគិតថាពុំមែនជារោគទេ គឺញើសចេញមកបំប៉ោងស្រទាប់ស្បែកក្អែលតែប៉ុណ្ណោះ ។ ស្អែកឡើងម៉ោង៨ព្រឹកថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៧៨ អ្នកទោស១០នាក់ដែលនៅក្នុងបន្ទប់ជាមួយខ្ញុំបានចេញទៅអស់ហើយ សល់តែខ្ញុំម្នាក់គត់ ។ ខ្ញុំត្រូវឈ្លបដោះចេញពីខ្នោះ ឈូសខ្ញុំនឹងស្បែកជើងកង់ឡាន ហើយប្រាប់ថា ចេញទៅអង្គការឲ្យឯងចេញកសាងខ្លួនហើយ ខ្ញុំខំប្រឹងក្រោកឡើងយ៉ាងត្រដាបត្រដួស ។ ពេលនោះខ្ញុំឃើញ មិត្តគុំ ឈរនៅមាត់ទ្វារ ហើយបញ្ជាថា "គ្រាហ៍វាចេញមក វាដើរមិនរួចទេ" ។

កងសន្តិសុខគ្រាហ៍ខ្ញុំមកអង្គុយកាំជណ្តើរថ្មនៅមុខបន្ទប់ ខ្ញុំដូចជាព្រិលភ្នែកហើយវិលមុខ ។ សន្តិសុខម្នាក់បានយកកាំបិតកោរមកកោរសក់ខ្ញុំ ដុំសក់ដ៏រីងកន្ទ្រើងបានធ្លាក់ដល់ឥដ្ឋ ហ្វូងចៃរត់ចេញប្រសាចលើការ៉ូ សន្តិសុខជាន់ឈ្លីនឹងស្បែកជើងបែកឈាមក្រហមឆ្អៅ ។ សន្តិសុខពីរនាក់បានយកខ្ញុំមកដាក់នៅលើផ្ទាំងថ្មប្រឡាយទឹកនៅក្រោមស្ពានស ហើយបានឲ្យក្រមាជិនមួយមកខ្ញុំ ។ ខ្ញុំដោះខោអាវដែលមានក្អែលក្រាស់ទម្លាក់ទៅក្នុងទឹកក្បែរនោះ ហ្វូងត្រីចង្វាជាច្រើនបានមកចោមរោមចឹកសម្លៀកបំពាក់របស់ខ្ញុំ ។ កងសន្តិសុខបានដងទឹកស្រោចរាងកាយខ្ញុំនិងយកកាំបិតស្នៀតកោសក្អែលខ្មៅៗចេញពីខ្លួនខ្ញុំនិងដុះសាប៊ូឲ្យខ្ញុំយ៉ាងស្អាត ។ ខ្ញុំលើកខោអាវមកបោកគក់ ក៏ប៉ុន្តែវារហែកធ្លុះធ្លាយសុសសាច់អស់ទៅហើយ ព្រោះត្រីចឹកស៊ី ។ មកដល់កន្លែងវិញកងសន្តិសុខបានឲ្យខោអាវថ្មីមួយកំប្លេដែលធំជាងខ្លួនខ្ញុំ ។ ថ្ងៃនេះខ្ញុំអត់ធ្មើពលកម្ម

ទេ ខ្ញុំអង្គុយស្ងៀមនៅមុខអគារថ្មុ ។ ខ្ញុំសម្លឹងទៅទីធ្លាសាលា ឃើញអ្នកទោសច្រើនស្លៀកពាក់ចម្រុះពណ៌ខុសពីកងសន្តិសុខដែលស្លៀកពាក់ខ្មៅ ពាក់មួកកន្ត្រឹប និងប្រដាប់ដោយអាវុធគ្រប់ដៃ ។ អ្នកទោសខ្លះឈូសឈើ កាប់ចាំង ខ្លះកិនស្រូវ បុកអង្ករ ខ្លះទៀតគាស់គល់ឈើ ដាំចេក ដាំដូង រីឯអ្នកទោសនារីៗដាំបាយនិងស្ល ។ ក្លិនសម្លម្ជូរគ្រឿងសាច់គោ ដែលជារបបរបស់សន្តិសុខជះមកប៉ះច្រមុះខ្ញុំ ធ្វើឲ្យការស្រេកឃ្លានរុកទន្ទ្រានអារម្មណ៍ខ្ញុំកាន់តែខ្លាំងឡើង ។ ខ្ញុំក្រឡេកទៅម្ខាងឃើញសំបកចេកណាំវ៉ានៅលើដី ខ្ញុំក៏រើសយកមកហូបដើម្បីសម្រន់ការស្រេកឃ្លាន សំបកចេកទុំមានរសជាតិផ្អែមដូចសាច់ចេកទុំដែរ ។ ពេលយប់គេដាក់ខ្នោះខ្ញុំ ពេលថ្ងៃទើបបញ្ចេញឲ្យធ្វើការ ។ ខ្ញុំអង្គុយផាត់អង្ករនៅក្នុងត្បាល់ក្តៀង ផាត់បណ្តើរលួចអង្ករស៊ីបណ្តើរ ។ សន្តិសុខឃើញក៏ពោលពាក្យប្រមាថរកបាញ់ខ្ញុំ ប៉ុន្តែខ្ញុំពុំខ្វល់ឡើយ ធ្វើយ៉ាងណាឲ្យតែពេញក្រពះ ។

ពីរសប្តាហ៍កន្លងផុត អ្នកទោសប្រមាណពាក់កណ្តាលក្នុងនោះមានខ្ញុំដែរ ត្រូវអង្គការបញ្ជូនមកនៅជំរំមួយនៅភូមិអណ្តែងដូង ឃុំក្រគរ ចម្ងាយប្រហែល២គីឡូម៉ែត្រពីសាលារៀន ។ ជំរំនោះមានទំហំ៧០ម៉ែត្របួនជ្រុងមានមន្ទីរធំល្មមចំនួនប្រាំមួយសង់ក្នុងព្រៃចេកនិងក្រោមដើមឈើធំៗ ។ មន្ទីរមួយខ្នងធំជាងគេបន្តិច ប្រក់ដែកធុងកៅស៊ូ ក្រាលក្តារតែគ្មានជញ្ជាំងទេមានកម្ពស់ត្រឹមទ្រូងមនុស្សចាស់មានខ្នោះឈើហូតដែកពីរស្ទួសម្រាប់ដាក់អ្នកទោស ។ មន្ទីរបីទៀតសម្រាប់កងសន្តិសុខស្នាក់នៅ ។ មន្ទីរមួយសម្រាប់ផ្ទះបាយ និងរោងមួយធ្វើផ្ទាល់ដីសម្រាប់ឲ្យអ្នកទោសហូបបាយ ។ នៅក្បែរមាត់ព្រែកមានរោងមួយធំជារោងសិប្បកម្មដែក ធ្វើខ្នោះ នង្គ័ល រនាស់ និងឧបករណ៍កសិកម្មគ្រប់ប្រភេទ ។ ថ្ងៃដំបូងអង្គការបានឲ្យខ្ញុំដើរប្រមូលស្លឹកចេក ព្រោះខ្ញុំធ្វើការធ្ងន់មិនទាន់បាន ប៉ុន្តែកងឈ្លបដើរតាមខ្ញុំរហូតព្រោះខ្លាចខ្ញុំលួចរត់ ។ ក្រោយពីហូបបាយថ្ងៃត្រង់រួច ខ្ញុំឃើញមេសន្តិសុខឈ្មោះ មិត្តអ៊ាវ ដើរមកជិតអ្នកទោស ហើយនិយាយថា “អ្នកទាំងអស់គ្នាខំកសាងខ្លួន ស្មោះត្រង់នឹងអង្គការ កុំលួចរត់ឲ្យសោះ អ្នកណាកសាងខ្លួនបាន អង្គការឲ្យទៅជួបជុំគ្រួសារម៉ែឪវិញ អង្គការមិនទុកធ្វើអីទេ” ។ តាមពាក្យសម្តីនិងទឹកមុខ មិត្តអាវដូចជាមិនកាចទេ ប៉ុន្តែគ្រប់គ្នាដឹងច្បាស់ថា គាត់បានសម្លាប់មនុស្សអស់រាប់រយនាក់ហើយ ។ នេះជាយប់ទីពីរហើយដែលខ្ញុំសម្រាកនៅក្នុងជំរំថ្មី យើងនាំគ្នាបំពក់ភ្លើងខសពីក្រោយមន្ទីរការពារមូសខាំដូចជាសត្វគោរអ៊ីចឹង ។ ប្រហែលម៉ោង៩យប់មានភ្លើងពិលភ្លឺផ្លែងឆ្នាត់ ខ្ញុំឮបទបញ្ជាពីខាងក្រោយមកថា “កុំក្រោកកុំដកជើងចេញពីខ្នោះប្រយ័ត្នស្លាប់” ឈ្លបក៏ដកដែកខ្នោះចេញពីជើងរបស់ខ្ញុំ រួចបញ្ចូលអ៊ីម្នាក់ទើបមកថ្មី បន្ទាប់មកទើបរុញដែកចាក់សោរវិញ ។ ខ្ញុំដេកពុំលក់ទេ អ៊ីខ្សឹបសួរខ្ញុំថា “ក្មួយមកយូរហើយ?” ខ្ញុំឆ្លើយថា “បាទ!ជិត៨ខែហើយ” ។ រំពេចនោះមានសំឡេងស្រែកគំហកថា “អាណាខ្សឹបគ្នា ចង់ងាប់ឬ” ។ ខ្ញុំភ័យខ្លាំងណាស់ក៏សម្ងំដេកលក់ទៅ ប៉ុន្តែអ៊ីមិនទាន់សម្រាន្តលក់ទេ ។ ខ្ញុំដឹងខ្លួនដោយស្នូរគ្រាប់កាំភ្លើងលាន់ឮរំពង ភ្លើងពិលនិងពន្លឺគ្រាប់រត់ឆ្វាត់ផ្លែងពីលើក្បាលខ្ញុំ ។ ខ្ញុំពុំហ៊ានក្រោកអង្គុយទេ ។ ខ្ញុំបានដឹងពេលវេលាដោយសារមាន់រងាវ ។ មួយស្របក់ក្រោយមកភាពរំជើបរំជួលក៏ស្ងាត់បាត់ទៅវិញ ។ កងឈ្លបបានមកត្រួតពិនិត្យមើលខ្នោះជើងអ្នកទោសជាច្រើនសា ។ លុះព្រឹកឡើងទើបខ្ញុំដឹងថា យប់មិញនេះ នៅពេលហូតខ្នោះដាក់ជើងអ៊ីដែលមកថ្មីមានអ្នកទោសម្នាក់នៅខាងចុងខ្នោះបានលួចដកជើងចេញ ហើយលួចរត់នៅពេលជិតភ្លឺ ។ យើងទាំងអស់គ្នាពុំបានដឹងថា គាត់រត់រួចឬអត់ទេ ព្រោះមិនឃើញអង្គការបញ្ជូនមកដាក់កន្លែងវិញ ។ យប់ឡើងប្រហែលម៉ោង៨ ឈ្លបបានមកយកអ៊ីចេញទៅ ហើយជិតភ្លឺទើបបញ្ជូនគាត់មកកន្លែងវិញ ។ ខ្ញុំឃើញគាត់មានសភាពទ្រុឌទ្រោមខុសពីពេលដែលគាត់ចេញទៅ ។ គាត់ដេកថ្ងូរតិចៗ ។ ព្រឹកឡើងអង្គការឲ្យអ៊ីធ្វើកណ្តៀវឲ្យបានតាមផែនការ ។ អ៊ីបានសុំខ្ញុំឲ្យជួយរវៃស្នូបឲ្យគាត់ ។ ទាំងពីរនាក់ធ្វើការបណ្តើរប្រាប់ពីលំនាំទោសគ្នាទៅវិញទៅមកបណ្តើរ ។ អ៊ីឈ្មោះ ឈៀង ជាគ្រូខ្មែរបូរាណដ៏ល្បីល្បាញម្នាក់នៅភូមិថ្នល់ ឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ ។ ស្បែករបស់អ៊ីស្វិតណាស់ ព្រោះគាត់ធ្លាប់ប្រយុទ្ធឈ្នះសត្វជ្រូកព្រៃនិងសត្វខ្លាធំទៀតផង ។ អ៊ីឈៀង លួចប្រាប់ខ្ញុំថា យប់មិញឈ្លបយកអ៊ីទៅសាលាព្យួរជើងឡើងលើ វាយគាត់នឹងមែកសង្កែដែលលួសបន្លាចេញត្រឹមពាក់ៗកណ្តាលប្រហែលជា៨០ដំបង ប៉ុន្តែសាច់គាត់អត់មាន

បែកឈាមទេ ។ នៅយប់បន្ទាប់ ឈ្លបបានមកយក អ៊ីឈៀង ទៅម្តងទៀត ។ ព្រឹកឡើងអ៊ីប្រាប់ខ្ញុំថា "យប់មិញសន្តិសុខវាយគាត់នឹងរំពាត់ខ្សែកាបដែលមានរុំសំណនៅចុងជាច្រើនរំពាត់" ។ អ៊ី បាន បើកអាវឲ្យខ្ញុំមើលគ្មានឃើញឈាមបន្តិចសោះ ។

ខ្ញុំសួរគាត់ថា "អ៊ីធ្វើអ្វីបានជាមានទោសដល់ថ្នាក់នេះ?"

គាត់ឆ្លើយថា "គេបង្ខំឲ្យខ្ញុំសារភាពថាជាមេខ្មែរសេរីកនាំការប្រឆាំងនឹងបដិវត្ត ។ ក្មួយអើយ! អ៊ីរក្សាសុខណាស់ ពុំដែលមានសកម្មភាពអ្វីប្រឆាំងនឹងគេទេ ហើយក៏ពុំដែលឈ្លោះទាស់ទែងនឹងអ្នកណាដែរ ។ តាមអ៊ីស្មានមានតែរឿងមួយទេដែលអ៊ីធ្វើដោយពុំដឹងខ្លួន ព្រោះយល់ថាវាធម្មតាតាំងពីមុនមក ។ កាលពីមួយខែមុន អ្នកស្រុកបានឲ្យអ៊ីចារគាថានិងកន្សែងយន្តការពារខ្លួន ព្រោះស្រុកទេសកើតវឹកវរ ។ អ៊ីធ្វើឲ្យតាមទម្លាប់ដែលអ្នកស្រុកធ្លាប់ឲ្យធ្វើ ប៉ុន្តែមិនដឹងថាអ្នកនោះយកទៅធ្វើជាទាហានណាឬចលនាណាទេ ។

-ចុះអ៊ីប្រាប់គេថាម៉េច?

អ៊ីឆ្លើយថា "អត់មានធ្វើអ្វីខុសទេ គេថាខ្ញុំមិនសារភាព ព្រោះអង្គការដឹងអស់ទៅហើយ" ។

អ៊ីឈៀង ត្រូវសន្តិសុខធ្វើទោសតែពីរយប់ប៉ុណ្ណោះ បន្ទាប់ពីនោះទុកគាត់ដូចអ្នកទោសដទៃទៀតដែរ ។ ព្រឹកមួយពេលក្រោកពីដំណេកសន្តិសុខពីរនាក់បាននាំក្រុមខ្ញុំ៨នាក់ដើរកាត់ព្រៃចារនិងវាលស្មៅសក់សេះ ។ អ្នកទោសទាំង៨នាក់គ្មានពាក់ស្បែកជើងទេ ខោអាវពាក់កណ្តាលខ្លួនត្រូវទឹកជោកដោយសន្សើម ។ បាតជើងរបស់ខ្ញុំមុតបន្លាស្បូវឡើងសុស ។ ឈ្លបបានគៀនយើងឲ្យធ្វើដំណើរឲ្យលឿន ។ ប្រហែលជាម៉ោង១១:៣០ យើងបានទៅដល់វាលមួយធំដែលមានទួលមួយខ្ពស់មានដុះឈើគ្រប់ប្រភេទ ។ ទួលនោះឈ្មោះ "ដុំបឹងក្លូ" ។ ខ្ញុំបានឃើញអ្នកទោសមួយចំនួនធ្វើការនៅទីនោះ ។ អ្នកទោសនៅទីនោះបានប្រាប់យើងថា អ្នកដែលមកនៅទីនេះគឺជាអ្នកទោសស្រាល ។ មុននេះ៤-៥ ថ្ងៃ អង្គការបានដោះលែងអ្នកទោសពីរនាក់ឲ្យត្រឡប់ទៅផ្ទះជួបជុំគ្រួសារវិញ ។ ការងារអ្នកទោសនៅទីនេះគឺធ្វើស្រែប្រាំង ដាំបន្លែ ដាំអំពៅ ចិញ្ចឹមជ្រូក និងឡើងត្នោតផលិតស្ករ ។ មានតែអ្នកឡើងត្នោតនិងអ្នកក្ដួររាស់ទេ ដែលទៅធ្វើការឆ្ងាយៗ រីឯអ្នកដាំត្រសក់ ស្ពៃ អំពៅ និងអ្នកចិញ្ចឹមជ្រូក ធ្វើការនៅក្នុងដំរី ។ ចំណែកខ្ញុំធ្វើជាចុងភៅ ។ ពេលយប់យើងទាំងអស់គ្នាសម្រាកធម្មតាពុំមានដាប់ខ្នោះទេ ។ នៅកណ្តាលមន្ទីរយើងក្រាលដែកហើយបំពក់ភ្លើងបំភ្លឺជំនួសចង្កៀង រីឯផ្សែងជំនួសមុង ។ យើងអាចពិគ្រោះគ្នាឬរយោបល់គ្នា ដោយគ្មានសំឡេងគំរាមទៀតឡើយ ។ អ៊ីៗខ្លះសម្តែងការបារម្ភពីប្រពន្ធកូននៅផ្ទះមិនដឹងសុខទុក្ខយ៉ាងណា ។ ពួខ្លះព្រួយពីជំងឺរបស់គាត់ខ្លាចពុំជា ព្រោះនៅទីនោះគ្មានពេទ្យព្យាបាល ឬថ្នាំសង្កូវ ។ ខ្លះទៀតដេកស្ងៀមគ្មាននិយាយមួយម៉ាត់ ។ ចំពោះរូបខ្ញុំពុំសូវខ្វល់ឡើយ ព្រោះខ្ញុំជាក្មេងកំព្រាស្រាប់ទៅហើយ ។ រាល់ព្រឹកខ្ញុំទៅបើករបបអង្ករពីសន្តិសុខដើម្បីយកមកដាំបាយលាយជាមួយពោតក្រហម ឬដំឡូងចេក ឈូសហាលឲ្យក្រៀមសម្រាប់ឲ្យអ្នកទោសដូចគ្នា ពេលល្ងាចខ្ញុំដាំបបរស ចំណែកត្រីសាច់ ជួនកាលមានផ្អក សាច់ត្រី ពេលខ្លះខ្ញុំដាក់សន្ទូចនៅបឹងបានត្រីរស់ ។ អ្នកទោសដែលទៅធ្វើការនៅស្រែឆ្ងាយៗ ពេលត្រឡប់មកវិញមានផ្ញើក្តាម ខ្យង កំពឹស កូនត្រី ជួលកាលមានត្រីធំៗខ្លះដែរ ។ ពូសែម ដែលមានរាងកាយស្គមស្គាំងជាងគេ បានសំណូមពរអង្គការឲ្យឈប់ដាំបាយលាយពោតឬចេក ប៉ុន្តែប្រធានគុកមិនយកចិត្តទុកដាក់នឹងសំណើនេះទេ ។ ប៉ុន្មានថ្ងៃក្រោយមក ពូសែម ក៏ស្លាប់ទៅ ។ ចំណែក តាតឹង គឺជាអ្នកឡើងត្នោត ។ ថ្ងៃមួយគាត់មិនទៅឡើងត្នោតទេ ដោយសារគាត់កប់ច្បាក់មិនអាចងាកខ្លួនរួច ។ គាត់អង្គុយត្រង់ភ្លើងសម្បើតែលេបទឹកមាត់ក៏មិនបានផង ។ តាត្រូវឈ្លបរីយក្មេងម្នាក់សួរគាត់ដោយសម្តីគំរោះគំរើយថា "ម៉េចហ្អែងឡើងកើតឬមិនកើត បើមិនគ្រប់ដៃនការអង្គការហ្អែងមុខជាស្លាប់មិនខានទេ" ។ តាតឹង អង្វរថា "ខ្ញុំឡើងពុំកើតទេ ខ្ញុំកប់ច្បាក់ហើយ ងាកខ្លួនមិនរួចផង" ។ តាតឹង អង្គុយថ្ងូរទាំងយប់ទាំងថ្ងៃគ្មាននរណាអាចជួយគាត់បានឡើយ ។ ៣ថ្ងៃក្រោយមក តាតឹង បានអនិច្ចកម្មទាំងអង្គុយ ។

៣ខែក្រោយមក អង្គការបានបំបែកក្រុមអ្នកទោសទាំងអស់ចេញពីដំរី ។ ខ្ញុំត្រូវបញ្ជូនទៅភូមិដំរី១ ដើម្បីរានព្រៃយកដីធ្វើស្រែវស្សានិងដាំសណ្តែកបាយ ។ ពេលយប់យើងគរខ្សាច់គ្រាក់ដុតធ្វើជាពន្លឺនិងបង្ការកុំឲ្យមូសនិងរបោមខាំ ។ រាល់ថ្ងៃ

សន្តិសុខ៣នាក់បណ្តើរអ្នកទោសចំនួន១១នាក់ទៅកាប់គាស់គល់ឈើ លើកភ្លឺ ភ្ជួររាស់ ដកស្ទូង ចំណែកខ្ញុំនៅដាំបាយដដែល ។ នៅខែតុលា ឆ្នាំ១៩៧៨ អង្គការបានបញ្ជូនខ្ញុំមកនៅជំរំមួយទៀតឈ្មោះរនាមដាច់ ក្នុងឃុំក្រគរ ចម្ងាយប្រហែល១០គីឡូម៉ែត្រពីទីរួមខេត្តក្រចេះ ។ ជំរំនេះនៅមិនឆ្ងាយពីភូមិស្រុកប៉ុន្មានទេ ។ ការងាររបស់អ្នកទោសនៅទីនោះគឺរានស្រែថ្មី លើកភ្លឺ និងដកស្ទូង ។ នៅជំរំថ្មីនេះ អ្នកទោសសរុបទាំងអស់មាន១៦នាក់ ខ្ញុំស្គាល់តែ៨នាក់ទេ ក្រៅពីនោះខ្ញុំពុំស្គាល់ឡើយ ។ ខ្ញុំសម្គាល់ឃើញថារាល់ពេលប្តូរកន្លែងម្តងៗ អង្គការតែងប្តូរអ្នកទោសរហូត ។ ខ្ញុំរស់នៅក្នុងជំរំបាន១ខែ យប់មួយ ពូម៉ុស ដែលមានមាឌធំជិបង្គខ្ពស់ស្រឡះ ឆ្អឹងធំៗ សក់រួញ សម្បុរខ្មៅ មានប្រជ្រុយប៉ុនមេដៃដុះរោមនៅក្រោមភ្នែកខាងឆ្វេង ជាខ្មែរកម្ពុជាក្រោម និងធ្លាប់ធ្វើជាកម្មករកំពង់ផែកាលពីសង្គមចាស់បានដាស់អ្នកទោសទាំងអស់ឲ្យក្រោកឡើងហូបបាយជាមួយត្រីរ៉ស់ដុតទាំងអស់គ្នាហូបយ៉ាងស្ងាត់ស្ងៀមរហូតឆ្អែតព្រោះ ពូម៉ុស បានហាមមិនឲ្យសួរនិងនិយាយអ្វីទាំងអស់ ។

ស្អែកឡើង ពូម៉ុស បាននិយាយប្រាប់ក្នុងពេលយើងកំពុងធ្វើការថា យប់ម្សិលគាត់នឹកប្រពន្ធកូន គាត់ដេកពុំលក់ចេះតែប្រែខ្លួនទៅមកៗ ហើយប៉ះបន្ទះក្តារមួយអត់វាយដែកគោលគាត់ក៏ទាញក្តារនោះឡើង ហើយមានប្រឡោះល្មមអាចចុះទៅក្រោមបាន ។ គាត់ក៏សាកល្បងចុះតែម្នាក់ឯងនៅពេលអ្នកទោសដេកលក់អស់ ។ គាត់បានទៅលួចអង្ករពីឃ្លាំង១កូនបាវយកទៅលាក់ទុកក្នុងព្រៃ ។ យប់ទី២ទើបគាត់ហៅគ្នា២នាក់បន្ថែមទៅដាំនិងទៅលួចលើកទ្រូរបស់អ្នកស្រុកនៅទំនប់ទ្រនូលឆ្នាំងយកបានត្រីរ៉ស់យ៉ាងច្រើនមកដុតចែកយើងទាំងអស់គ្នាហូបនៅក្នុងយប់នោះ ។ ក្រោយពេលសម្រាកពីការងារ ពូម៉ុស បានខ្សឹបប្រាប់អ្នកទោសទាំងអស់គ្នាថា «យប់នេះអស់អង្ករដាំបាយហើយពួកឯងទាំងអស់គ្នាចុះរកស៊ីខ្លួនឯងទៅ ហ៊ានក៏ហ៊ាន បើមិនហ៊ានក៏ហី អញឈប់បម្រើពួកឯងទៀតហើយ ។ ក៏ប៉ុន្តែចាំម៉ោង១១យប់ចាំចុះ ម៉ោង៣ត្រូវឡើងមន្ទីរវិញឲ្យទាន់ពេល ។» គ្រប់គ្នាចុះអស់រាល់យប់ នៅសល់តែខ្ញុំនិងចិក គុយ ហាក់ ប៉ុណ្ណោះ ។ ទីបំផុតខ្ញុំសម្រេចចិត្តទៅលួចជាមួយនឹងគេដែរ ។ មួយរយៈនេះយើងហូបចេកទុំរហូត អ្នកទោសទាំងអស់មានសាច់ឈាមមាំមួនធ្វើការមិនចេះហត់ទេ ។ កងសន្តិសុខនឹកចម្លែកក្នុងចិត្តក៏និយាយថា «ពួកឯងឲ្យតាមអញហូបមានរបបកំណត់ពេលវេលាត្រឹមត្រូវធ្វើពលកម្ម និងមានរាងកាយមាំមួនដូចពេលនេះអីចឹងនេះមកពីអង្គការយើង» ។ ទាំងអស់គ្នាមានអារម្មណ៍មិនស្រួលហើយ ពូម៉ុស បានពិគ្រោះថា «ទោសយើងគ្មានអ្វីក្រៅពីសេចក្តីស្លាប់ទេ ប៉ុន្តែទាំងអស់គ្នាកុំរត់ឲ្យសោះ បើរត់ក៏រត់មិនរួចដែរ យើងនឹងស្លាប់ទាំងអស់គ្នានៅទីនេះ» ។ យើងទាំងអស់គ្នាពុំបានបញ្ឈប់ការចុះលួចដំណាំរបស់ប្រជាជនទេ ទោះបីដឹងថាសន្តិសុខសង្ស័យក៏ដោយ ។ នៅយប់មួយប្រហែលជាម៉ោង២កន្លះ ពេលត្រឡប់មកពីរកអាហារវិញ ខ្ញុំឃើញអ្នកទោសខ្លះអង្គុយក្រោមមន្ទីរខ្លះសម្រូតចុះពីសសរមកវិញ ។ ពូម៉ុស ខ្សឹបថា អង្គុយក្រោមនេះឲ្យស្ងៀមកុំទៅណាគេវាយក្តារជិតវិញ ហើយយើងពុំអាចឡើងវិញបានទេ ។ ពន្លឺព្រះអាទិត្យព្រាងៗអ្នកទោសខ្លះដេកលក់ទាំងត្របោមក្បាលជង្គង់ ខ្លះអង្គុយស្ងៀម ។ សន្តិសុខ១៥នាក់ភ្ជង់កាំភ្លើងដាក់យើងពីគ្រប់ទិស ។ យើងតម្រង់ជួរនៅមុខមន្ទីរអប់រំ ។ «ហេតុអ្វីបានពួកឯងធ្វើដូចនេះ?» យើងឆ្លើយព្រមគ្នាថា «គឺខ្ញុំឃ្លានណាស់» ។ បន្ទាប់ពីនោះសន្តិសុខបានចាក់សោឲ្យអ្នកទោសទាំងអស់នៅក្នុងមន្ទីរចំនួនពីរថ្ងៃ មានតែ ពូម៉ុស ម្នាក់គត់ដែលបានទទួលការអនុញ្ញាតឲ្យចុះមកដាំស្ល ។ ម៉ោងប្រហែល៨ព្រឹកថ្ងៃទីបី យើងត្រូវបានអនុញ្ញាតឲ្យចុះមកដី ។ ខ្ញុំឃើញ មិត្តគុំ មិត្តជ័យ មិត្តអ៊ាវ និងសន្តិសុខ១៥នាក់ នៅជុំវិញមានចាននំចិនប្រហែល៦ចានដាក់លើតុមួយនិងទឹកក្រូចប្រហែល៣០ដប ។ ទាំងអស់គ្នាខ្សឹបថា ថ្ងៃបញ្ចប់ជីវិតយើងមកដល់ហើយ ។ មិត្តអ៊ាវ ដើរខិតជិតមកអ្នកទោស ហើយនិយាយដោយទឹកមុខញញឹមថា «អង្គការសូមអរគុណអ្នកទាំងអស់គ្នាដែលមានគោលជំហរស្មោះត្រង់ មិនរត់ចោលអង្គការ ទោះបីជួបការលំបាកយ៉ាងណា ក៏ដោយ រីឯការលួចគឺគ្រាន់តែបំបាត់ការស្រេកឃ្លានរបស់អ្នកទាំងអស់គ្នាប៉ុណ្ណោះ អង្គការយើងស្រឡាញ់អ្នកស្មោះត្រង់អង្គការនឹងឲ្យបងប្អូនទៅជួបម៉ែឪប្រពន្ធកូននិងរស់នៅជាមួយប្រជាជនវិញនៅពេលឆាប់ៗនេះ» ។ ស្នូរទះដៃលាន់ប្រាវ ខ្លះរំភើបហួសប្រមាណទៅជាយំ ។

ក្រោយពីយើងបង្ហើយការងារដែលនៅសេសសល់នៅក្នុងជំរំ សន្តិសុខបាននាំផ្លូវយើងធ្វើដំណើរដោយថ្មើរជើងពេញមួយថ្ងៃទើបទៅដល់ភូមិមួយផ្សេងទៀត ។ នៅពេលនោះខ្ញុំឃើញក្រុមគ្រួសាររបស់អ្នកទោសទាំងអស់រង់ចាំនៅទីនោះជាស្រេច ។ ទាំងអស់គ្នារីករាយណាស់ក្រោយពីបានជួបជុំប្រពន្ធកូន ចំណែកខ្ញុំនិងយុវជនចំនួន១៣នាក់ អង្គការបញ្ជូនមកនៅមន្ទីរមួយឋិតនៅក្នុងភូមិប្រប់ ក្នុងឃុំចង្រ្កង់ ជាភូមិចាស់មួយរបស់ជនជាតិព្នង ។ នៅទីនោះមានអាហារគួរសមសម្រាប់ហូប ។ យើងបំពេញការងារប្រចាំថ្ងៃតាមរបបផែនការរបស់អង្គការ ។ ពេលព្រឹកយើងឃើញក្រុមកុមារអាយុតិចជាង៣ឆ្នាំនៅជាមួយយាយចាស់ៗ កុមារអាយុពី៥ឆ្នាំឡើងទៅរៀននិងប្រមូលជីអាចម៍គោ ។ ពេលយប់មានផែនការលើទំនប់ដល់ម៉ោង៩ ។ បន្ទាប់ពីសម្រាកការងារមានប្រជុំចែកថ្នាំការពារជំងឺគ្រុនចាញ់ និងទទួលផែនការថ្មីសម្រាប់ថ្ងៃស្អែក ។

រដូវប្រាំង ខែមេសា ឆ្នាំ១៩៧៦ អង្គការតម្រូវឲ្យយុវជនទាំងអស់រៀបគ្រួសារ ប៉ុន្តែអង្គការមិនអនុញ្ញាតឲ្យយើងជ្រើសរើសតាមចិត្តទេ គឺសមមិត្ត ឡេ និង ជ័យ ជាអ្នកផ្សំផ្គុំឲ្យ ។ ថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៦ ជាថ្ងៃរៀបអាពាហ៍ពិពាហ៍គូស្រករ ១២គូ ។ ប្រជាជននៅតាមការដ្ឋានបានមកជួបជុំគ្នានៅក្នុងផ្ទះបាយរួម ។ កូនកម្លោះនិងកូនក្រមុំស្លៀកពាក់ខោអាវខ្មៅបង់កក្រមា ។ អង្គការអានប្រវត្តិរូបម្នាក់ៗម្តងមួយគូនិងឲ្យគូស្វាមីភរិយាថ្មីប្តេជ្ញាចិត្តស្មោះត្រង់ដើរតាមអង្គការនិងស្រឡាញ់គ្នាដល់ស្លាប់ ។ ពិធីនេះបានចប់ក្នុងពេល១ព្រឹក ។ទាំងអស់គ្នាមានរបបបាយនិងបង្អែមស្វាយទុំម្នាក់មួយ ។ តាំងពីថ្ងៃនោះមកខ្ញុំនិងប្រពន្ធបានទៅរស់នៅជាមួយ អ៊ំឈៀង ។ គាត់ស្រឡាញ់រាប់អានខ្ញុំទាំងពីរដូចជាកូនគាត់ដែរ ។

មួយឆ្នាំក្រោយមក មិត្តឡេ និង មិត្តជ័យ ត្រូវថ្នាក់លើទម្លាក់បុណ្យស័ក្តិមកនៅជាប្រជាជនសាមញ្ញវិញ ហើយយកសមមិត្ត ជុន និង យុត គ្រប់គ្រងជំនួស ។ មិត្តថ្មីនេះបានរៀបចំភូមិថ្មីនៅកន្លែងផ្សេងដែលនៅមិនឆ្ងាយពីភូមិចាស់ប៉ុន្មាន ។ ក្នុងមួយគ្រួសារអង្គការចែកដីមួយឡូត៍ទទឹង២៥ម៉ែត្រនិងបណ្តោយវែងប៉ុនណាក៏បានតាមលទ្ធភាពយើងរានបាន ។ ជីវភាពរស់នៅរបស់ប្រជាជននៅការដ្ឋានមានសភាពសុខស្រួលណាស់ ព្រោះនៅលើដីភូមិមានដាំដំណាំច្រើនមុខហូបតាមចំណង់ចំណូលចិត្ត ។ ដីភូមិខ្ញុំមាន ពោត ចេក ននោង ត្រឡាច ត្រាវ សាគូ និងមួយភាគគឺដំឡូងរកា ។

ចាប់ពីខែ១០ដល់ខែ១២ឆ្នាំ១៩៧៨ មានសភាពការណ៍វឹកវរ មិត្តជុន និង មិត្តយុត បានត្រូវថ្នាក់លើដកចេញពីការដ្ឋានប្រប់ ។ ក្នុងអំឡុងពេលនោះ អង្គការបានចុះធ្វើប្រវត្តិរូបញឹកញាប់ណាស់ ។ សភាពការណ៍កាន់តែតឹងតែងឡើងស្ទើរគ្រាប់ផ្លោងព្រុកាន់តែជិត នៅចុងខែ១២ ឆ្នាំ១៩៧៨ អង្គការបានឲ្យយើងរៀបចំអីវ៉ាន់ដើម្បីភៀសខ្លួន ។ យើងធ្វើដំណើរចេញពីភូមិដោយថ្មើរជើងទាំងយប់ទាំងថ្ងៃ ។ ខ្មែរក្រហមដឹកស្បៀងអាហារឆ្ពោះទៅស្រុកសំបូរឆ្លងទៅភ្នំជីខេត្តកំពង់ធំ ។ ចំណែកប្រជាជនបានធ្វើដំណើរទៅមុខទៀត ហើយរស់នៅជាមួយអ្នកស្រុកនៅទីនោះ ។ នៅពេលជាមួយគ្នានោះ យើងឃើញរថក្រោះ២គ្រឿងបំពងសំឡេងតាមផ្លូវថា សូមបងប្អូនវិលត្រឡប់ទៅស្រុកកំណើតវិញ ព្រោះរណសិរ្សយើងរំដោះប្រទេសបានហើយ ។ ព្រឹងណឹងនេះ ខ្ញុំបីនាក់ប្រពន្ធនិងកូនបានស្រូតវិលត្រឡប់ទៅស្រុកខាងប្រពន្ធដោយសុវត្ថិភាព ។

**សំ ប៊ិន**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
*Email: dccam@online.com.kh*
*Home page: www.dccam.org*

# សេចក្តីប្រកាសរកបងប្អូន


យិន ហ៊ន

ខ្ញុំបាទឈ្មោះ យិន ហ៊ន ភេទប្រុស អាយុ៣៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិស្រែលាវ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត ។ ឪពុកឈ្មោះ ប្រូក យិន ម្តាយឈ្មោះ សន ស្រុកកំណើតនៅភូមិត្រពាំងថ្ម ឃុំល្បើក ស្រុកឈូក ខេត្តកំពត ។ ខ្ញុំបាទមានបងប្អូនប្រាំបីនាក់÷

១) ឈ្មោះ ធី ភេទប្រុស (បាត់ខ្លួន) ២) ឈ្មោះ ហ៊ាន ភេទប្រុស(បាត់ខ្លួន) ៣) ឈ្មោះ វ៉ាន ភេទស្រី ៤) ឈ្មោះ ណន ភេទស្រី ៥) គឺរូបខ្ញុំបាទឈ្មោះ ហ៊ន ៦) ឈ្មោះ ហួន ភេទប្រុស ៧) ឈ្មោះ ហ៊ឹម ភេទប្រុស និង៨) ឈ្មោះ ណាន់ ភេទស្រី ។

ខ្ញុំបាទសូមសួរបងប្រុសឈ្មោះ ធី និង ឈ្មោះ ហ៊ាន ដែលបានបែកគ្នាក្នុងជំនាន់ ប៉ុល ពត ។ ប្រសិនបើបងទាំងពីរបានឮ ឬញាតិមិត្តណាបានស្គាល់ឈ្មោះទាំងពីរនេះ សូមមេត្តាផ្តល់ដំណឹងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ឬតាមទូរស័ព្ទលេខ (៨៥៥) ០២៣ ២១១ ៨៧៥ ។

សូមអរគុណ ។

# សេចក្តីប្រកាសរកបងប្អូន


សម គា

ខ្ញុំបាទឈ្មោះ សម គា អាយុ៣៩ឆ្នាំ រស់នៅក្នុងភូមិស្បូវអណ្តែត ឃុំដំបូកខ្ពស់ ស្រុកអង្គរជ័យ ខេត្តកំពត ។ ឪពុកខ្ញុំឈ្មោះ ដាន ស្លាប់កាលពីរឆ្នាំមុន ចំណែកម្តាយឈ្មោះលួន ស្លាប់រយៈពេល៧ឆ្នាំមកហើយ ។ កាលមុនឆ្នាំ១៩៧៥ ខ្ញុំបាទមានបងប្អូនបង្កើតចំនួន៦នាក់ ប្រុសប្រាំ ស្រីមួយ ដែលមានឈ្មោះដូចខាងក្រោមនេះ÷

១) ភួន ហៅ ផល ភេទប្រុស, ២) ម៉ៅ ហៅ ដា ភេទប្រុស, ៣) ឡាត ហៅរ៉េត ភេទស្រី, ៤) គារ (ការ) ភេទប្រុស, ៥) ចាន់ ភេទប្រុស, ៦) ភឿន ភេទប្រុស ។

ខ្ញុំសូមសួររកបងស្រីឈ្មោះ ឡាត ហៅ រ៉េត ដែលបានបាត់ខ្លួនតាំងពីពេលចេញទៅធ្វើបដិវត្តន៍នៅមន្ទីរពេទ្យ៦មករា នៅថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៧៨ ។ ប្រហែលជាបីបួនឆ្នាំមុនខ្ញុំធ្លាប់បានទទួលដំណឹងតាមសំបុត្រនិងរូបថតមួយចំនួនតាមរយៈអ្នកភូមិម្នាក់ ។ គាត់បានប្រាប់ខ្ញុំឲ្យទៅទាក់ទងមនុស្សម្នាក់ទៀតនៅភ្នំពេញដើម្បីទទួលដំណឹងបន្ថែមទៀតពីបងដែលរស់នៅប្រទេសក្រៅ ប៉ុន្តែនៅពេលខ្ញុំទៅដល់ភ្នំពេញខ្ញុំមិនបានជួបមនុស្សនោះទេ ហើយក៏មិនបានទទួលដំណឹងអ្វីទៀតដែរ ។ ចាប់តាំងពីនោះមក ខ្ញុំលែងរវីរវល់ទាក់ទងស្វែងរកដំណឹងអ្វីទៀត ម្យ៉ាងដោយខ្ញុំរវល់ជាប់ធ្វើស្រែចម្ការ ម្យ៉ាងមិនដឹងថាត្រូវពឹងពាក់នរណា ។

នៅក្នុងសំបុត្រមានដាក់អាសយដ្ឋាន លេខទូរស័ព្ទ និងឈ្មោះប្តីរបស់គាត់ ហើយនៅក្នុងរូបថត ខ្ញុំក៏បានឃើញរូបបងស្រីប្តីរបស់គាត់ ព្រមទាំងកូនគាត់ ។ ខាងក្រោមនេះជាអាសយដ្ឋានដែលខ្ញុំបានឃើញនៅក្នុងសំបុត្រ÷

Mr Say Born: *G-Rue VLADIMIR KOMAROV*, ៦៩២០០ *VENISSIEUX-FRANCE*

ផ្ទះលេខ ៤៣២២៨ ទូរស័ព្ទ (០៨) ៣៥១៧៣៥៧, ៦១៤២៧៤៨៧៨៥

បើបងស្រីពិតជានៅរស់ហើយបានឃើញដំណឹងនេះ ឬអស់លោកណាដែលស្គាល់ឈ្មោះនិងអាសយដ្ឋានដូចខាងលើ សូមមេត្តាផ្តល់ដំណឹងមកខ្ញុំបាទនៅក្នុងភូមិស្បូវអណ្តែត ឃុំដំបូកខ្ពស់ ស្រុកអង្គរជ័យ ខេត្តតាកែវ ឬតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទលេខ(៨៥៥) ២៣ ២១១ ៨៧៥ ទូរសារលេខ (៨៥៥) ២៣ ២១០ ៣៥៨ ឬ *Email: dccam@online.com.kh.* ដោយអនុគ្រោះ ។ សូមអរគុណ ។



ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ ក្នុងមួយច្បាប់តម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@online.com.kh. Thank you.

**A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 57, September 2004.**
**Funded by Germany, Norway, Sweden, the Netherlands, and USA.**